ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ការពិតដែលមិនអាចប្រកែកបាន

◆ ពីរទសវត្សរ៍នៃគណៈកម្មការស្វែងរកការពិតរបស់របស់កម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១៤ ខែមិថុនា ឆ្នាំ២០០៩

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*លេខ១១៨ ខែមិថុនា ឆ្នាំ២០០៩*

## មាតិកា


◆ការពិតដែលមិនអាចប្រកែកបាន ...............................................១

**ផ្នែកឯកសារ**

◆ចម្លើយរបស់ ឌុច ទាក់ទងនឹងមន្ទីរ ស-២១ .......................................៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆កម្ពុជាប្រជាធិបតេយ្យ ៖ ក្រសួងការបរទេស ...................................៩

◆យុត្តិធម៌មូលដ្ឋាន ...........................................................១៥

◆ឈរនៅកណ្ដាល ...........................................................១៨

◆៣០ឆ្នាំមុន ឌុច បានដកក្រចកជើងរបស់គាត់ ...............................២១

◆ការប្រព្រឹត្តទៅលើអ្នកទោស .................................................២៦

**ផ្នែកច្បាប់**

◆ក្រោយពីសក្ខីកម្មដ៏ឈឺចាប់របស់ក្មេងរស់រានមានជីវិត.....................២៩

◆ពីរទសវត្សរ៍នៃគណៈកម្មការស្វែងរកការពិតរបស់កម្ពុជា .............៣៣

◆ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍...................................................៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ភាពក្លៀសក្លាយនៃគោលនយោបាយ ភាពខ្មៅងងឹតនៃសង្គ្រាម ..............៣៧

◆នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) .........៣៩

◆សោកនាដកម្មនៅតែបន្តមាន...................................................៤៥

◆របួសកម្ពុជាដែលមិនទាន់ព្យាបាល ...............................................៤៧

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ពិភពលោកនៅសែនឆ្ងាយ ......................................................៥៤




សិស្សានុសិស្សអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ»



នង ចាន់ផល និងប្អូនប្រុស នង ចាន់ឌី
(រូបថតឆ្នាំ១៩៧៩)


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** ញាណ សុជាតិ, លី សុខឃាង, ឆាល ដេកសុន, អឹម.អ ប្រ៉ាង, កែវ ដាស៊ីល, អង់ដ្រេ អូលីវី និងហៀថឺ មូរ៉េវ, ឡូរ៉ា ម៉ាកដូណល, អ៊ីដី ម៉ូរ៉ាស្ស៊ីម៉ា, ណរម៉ែន ដេនគេឡ្វីច, សែន វិចិត្រ, ហេង ខុន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារ៉ែម **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ការពិតដែលមិនអាចប្រែកែបាន

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ការមិនទទួលស្គាល់ចំពោះហេតុការណ៍ប្រវត្តិសាស្ត្រមួយបានកើតឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឌុច បានបដិសេធថា នង ចាន់ផល មិនមែនជាអ្នកទោសមន្ទីរស-២១ទេ ហើយបន្តទៀតថា តាមគោលនយោបាយរបស់អង្គការ រាល់កុមារដែលបានមកដល់មន្ទីរស-២១ទាំងអស់ត្រូវបានសម្លាប់ ហើយជាមួយគ្នានោះដែរ ឌុច ក៏មិនទទួលស្គាល់ថា នង ចាន់ផល គឺជាកុមារដែលបានរួចរស់ជីវិតពីទីនោះដែរ ។ ពេលនេះ នង ចាន់ផល គឺជាសាក្សីម្នាក់ដែលកំពុងធ្វើសក្ខីកម្មនៅចំពោះមុខអង្គសវនាការនិងជនរងគ្រោះនៃរបបខ្មែរក្រហមរាប់លាននាក់ទាំងក្នុងនិងក្រៅប្រទេស ហើយការមិនទទួលស្គាល់របស់ ឌុច នេះ ធ្វើឲ្យ នង ចាន់ផល និងសាធារណជនទូទៅមានការងឿងឆ្ងល់ថាតើ នង ចាន់ផល ពិតជាអ្នកទោសនៅមន្ទីរស-២១ មែនដែរឬទេ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា នង ចាន់ផល កុមារដែលរស់រានមានជីវិតនៅគុកទួលស្លែងពិតជាអ្នកទោសដែលបានរួចរស់ជីវិតពីគុកទួលស្លែងពិតមែន តាមរយៈការសួរនាំ នង ចាន់ផល ជាច្រើនលើកច្រើនសា និងតាមរយៈខ្សែភាពយន្តឯកសាររបស់កងទ័ពវៀតណាម ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជឿជាក់ថា នង ចាន់ផល គឺជាអតីតអ្នកទោសស-២១យ៉ាងពិតប្រាកដមែននោះបានមានយោបល់ចំពោះការបដិសេធរបស់ ឌុច ថា ឌុច នៅតែមិនបានលះបង់ចោលនូវចរិតឃោរឃៅមកលើជនរងគ្រោះដដែល ។

ឌុច បានអះអាងនូវការបដិសេធរបស់ខ្លួនដោយសង្កត់ធ្ងន់ថា នង ចាន់ផល មិនមានភ័ស្តុតាងណាមួយបញ្ជាក់ថាជាអតីតអ្នកទោសនៅមន្ទីរស-២១ ឬគុកទួលស្លែងទេ ហើយក៏មិនមានភ័ស្តុតាងណាមួយអះអាងថាម្តាយរបស់ នង ចាន់ផល បានមកដល់មន្ទីរស-២១ ដែរ ។

*(តទៅទំព័រទី១៨)*



នង ចាន់ផល និងប្អូនប្រុស នង ចាន់ឌី

# ចម្លើយរបស់ ឌុច ទាក់ទងនឹងមន្ទីរ ស-២១

ឌុច កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពោធិ៍ឈើ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។ នៅឆ្នាំ១៩៥៧ ឌុច បានប្រលងវិញ្ញាបនប័ត្របឋមសិក្សានៅខេត្តកំពង់ធំ ។ ក្រោយមក ឌុច បានប្រលងជាប់ផ្នែកគណិតវិទ្យានៅសាលាគរុកោសល្យក្រុងភ្នំពេញ ដោយគាត់ស្នាក់នៅវត្តខណ្ឌលោម ។ នៅឆ្នាំ១៩៦៤ ឌុច បានសម្រេចចិត្តចូលរួមជាមួយជាមួយចលនាអង្គការសម្ព័ន្ធយុវជនកម្ពុជា រហូតដល់ឆ្នាំ១៩៦៨ ឌុច ត្រូវបានចាប់ខ្លួនដោយប៉ូលិសរបស់សម្តេច សីហនុ ដោយចោទប្រកាន់ថា «ប្រឆាំងនឹងសេចក្តីសុខសាន្តក្នុងព្រះនគរ និងចូលដៃ-ជើងជាមួយបរទេស» ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៦៩ ឌុច ត្រូវបានបញ្ចូលជាបក្សជនពេញសិទ្ធិ ដោយមាន ស សៀន ជាអ្នកទទួលស្គាល់ ។ បន្ទាប់ពីដោះលែងចេញពីគុកនាចុងខែសីហា ឆ្នាំ១៩៧០ ឌុច ត្រូវបានបក្សអនុញ្ញាតឲ្យទៅស្រុកស្អាងដើម្បីបង្រៀនពីសីលធម៌ និងនយោបាយដល់កម្មាភិបាលនៅក្នុងអង្គភាពមួយ ។ នៅខែឧសភា ឆ្នាំ១៩៧១ ឌុច បានប្តូរទៅភូមិភាគនិរតី រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧១ វន វើត បានចាត់តាំងឲ្យ ឌុច ធ្វើជាប្រធានមន្ទីរ ម-១៣ដែលមានទីតាំងក្នុងឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ នៅទីនោះ វន វើត ណែនាំ ឌុច ពីវិធីធ្វើទារុណកម្មមួយចំនួន ហើយក្រោយមកគាត់បានសួរចម្លើយនិងបង្កើតវិធីធ្វើទារុណកម្មសួរចម្លើយអ្នកទោសដោយខ្លួនឯង ។ បើយោងតាមសម្តីរបស់ ឌុច នៅចន្លោះពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ អ្នកទោសប្រមាណ ២០០-៣០០នាក់ត្រូវបានសម្លាប់ ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៥ ឌុច ត្រូវបាន សុន សេន ហៅមកធ្វើការនៅភ្នំពេញវិញ ។

### ការចូលរួមជាចលនាបដិវត្តន៍

នៅឆ្នាំ១៩៦២ ឌុច ស្នាក់នៅនិងរៀនសូត្រក្នុងកុដិលេខ៣ វត្តខណ្ឌលោម ក្រុងភ្នំពេញ ដែលមានលោកគ្រូ ប្រាជ្ញ ប៉ុល ជាមេកុដិ និងជាមន្ត្រីសង្ឃជាន់ខ្ពស់ ដែលគាត់គោរពនិងស្រឡាញ់ជាងគេ ។ ក្រោយមក ដោយសារលោកគ្រូ ប្រាជ្ញ ប៉ុល ដឹងថា ឌុច បានចូលរួមចលនាបដិវត្តន៍ គាត់ក៏បានផ្តល់ឱវាទឲ្យ ឌុច ។ បន្ទាប់ពីប្រាប់ការពិតរួចមក លោកក៏អនុគ្រោះនិងបានឲ្យឱ្វាទខ្លះថា «ឯងចូលនេះវាត្រូវហើយ អញស្មានតែឯងចូលដៃចូលជើងជាមួយពួកអាចារ្យ នាង ខាងខ្មែរសេរី ព្រោះខ្មែរសេរីមិនបានទេ គេយកសាច់ឯងទៅរងកាណុងជំនួសគេមិនខាន» ។ ជាញឹកញាប់ ឌុច តែងតែទៅសាកសួរសុខទុក្ខម្តាយរបស់គាត់នៅស្រុកស្ទោង ប៉ុន្តែក្រោយមក ឌុច មិនដែលបានទៅលេងផ្ទះដូចមុនទៀតទេ ព្រោះខ្លាចរដ្ឋាភិបាលចាប់ខ្លួនដោយសារតែគាត់ជាអ្នកបដិវត្តន៍ ។

នៅពេលសិក្សានៅសាលាគរុកោសល្យក្រុងភ្នំពេញ ឌុច ចាប់អារម្មណ៍ជាមួយសាស្ត្រាចារ្យ សុន សេន និង កែ គឹមហួត ដែលតែងតែលើកឡើងពីរឿងនយោបាយ ។ រហូតដល់ឆ្នាំ១៩៦៤ ទើប ឌុច សម្រេចចិត្តចូលរួមជាមួយ «អង្គការមហាជនរបស់បក្ស ឬ អង្គការបង្គោល ឬ អង្គការសម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា» ។ ដោយសារតែស្មោះស្ម័គ្រចំពោះបដិវត្តន៍ ឌុច សុខចិត្តយកប្រាក់បៀវត្សរ៍ជាគ្រូបង្រៀននៅស្គន់ ខេត្តកំពង់ចាម ចំនួន៥.៥០០ រៀលជូនទៅបដិវត្តន៍ ដោយទុកតែ១.៥០០រៀលសម្រាប់ការរស់នៅផ្ទាល់ខ្លួនប៉ុណ្ណោះ ។

នៅវិស្សមកាលឆ្នាំ១៩៦៧ ដោយសារចង់ដឹងពីជីវិតកម្មករពិបាកយ៉ាងណានោះ ឌុច ដោះឯកសណ្ឋានគ្រូបង្រៀនចេញមកធ្វើជាគូលីសំណង់រយៈពេល២០ថ្ងៃ ដោយក្នុងមួយថ្ងៃទទួលបានប្រាក់២០រៀល ។ នៅអំឡុងខែ៦-៧ ឆ្នាំ១៩៦៧ ឌុច បានចូលរៀនសូត្រវគ្គសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជានៅផ្ទះផ្លូវលេខ១៦៣ ខាងលិចឆៀងខាងត្បូងផ្សារទួលទំពូងដែល ឌុច បានជួលដោយមានលោកគ្រូ ឆាយ គឹមហ៊ ជាអ្នកដឹកនាំបង្រៀនរួមមានឯកសារស្តីពីមាគ៌ាជាយុទ្ធសាស្ត្រនៃការតស៊ូបដិវត្តន៍នៅកម្ពុជា គោលនយោបាយនៃយុទ្ធវិធីប្រមូលកម្លាំងរណសិរ្សធំទូលាយសម្រាប់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៦០ មោទនភាពត្រូវនិងខុស និងសតិអារម្មណ៍អង្គការវិន័យ ។ បន្ទាប់មក ឌុច មើលកុនមកពីស្រុក

ចិនអំពីការតាមដានចារកម្ម ដែលមានមិត្តភក្តិស្រីរបស់គាត់ឈ្មោះ ឡៅ គាវ ជាអ្នកបកប្រែ ។

## ការផ្លាស់ប្តូរឈ្មោះ

នៅពេលនោះ ឆាយ គីមហ៊ា បានប្រាប់ ឌុច ឲ្យជ្រើសរើសឈ្មោះមួយសម្រាប់ប្រើក្នុងបដិវត្តន៍ ។ បន្ទាប់មក គាត់ក៏បានជ្រើសយកឈ្មោះ ឌុច មកប្រើ ព្រោះឈ្មោះ កាំង ហ្កេកអ៊ាវ ជាឈ្មោះចិនមិនអាចប្រើក្នុងការធ្វើបដិវត្តន៍នៅខ្មែរបានទេ ។ ឌុច បានលើកឡើងថា កាលពីនៅកុមារ ខ្មោចជីតាខាងម្តាយរបស់គាត់បានសរសើរជាងចម្លាក់ម្នាក់ឈ្មោះ ឌុច ដែលសាងសង់ព្រះបដិមាពុទ្ធអង្គធំមួយនៅវត្តពោធិ៍រើយ ស្រុកស្ទោង ខេត្តកំពង់ធំ ។ ម្យ៉ាងទៀត ពេល ឌុច រៀននៅថ្នាក់កុមារដ្ឋាន មានអត្ថបទដែលសរសេរនៅទំព័រខាងមុខសៀវភៅថា «គ្រូឲ្យ ឌុច អានសៀវភៅ និងឲ្យគូររូប ឌុច បានងើបឡើងឈរត្រង់ខ្លួន ក្បាលមិនងឹកងោក អានមួយៗ ច្បាស់ៗ» ។ ដូច្នេះ ឌុច បានចងចាំ និងយកឈ្មោះនេះមកប្រើរហូតមក ។

នៅខែតុលា ឆ្នាំ១៩៦៧ ក្រោយពី វន វ៉េត បានហៅ ឌុច ឲ្យចេញទៅធ្វើការជាមួយគាត់លើកដំបូង ឌុច បានទៅជម្រាបលាឪពុកម្តាយរបស់គាត់ ។ នៅពេលនោះ ឪពុករបស់គាត់បានឲ្យខ្សែគាថាមួយខ្សែទៅគាត់ដើម្បីទុកការពារខ្លួន ។ បន្ទាប់មក ឌុច បានទៅលាមិត្តភក្តិរបស់គាត់ទៀត ដែលខណៈនោះមានមិត្តម្នាក់បានដោះនាឡិកាដៃម៉ាកទីតូនីរបស់គេមកឲ្យគាត់ ។ ក្រោយមក ឌុច បានទៅលោកគ្រូមេកុងដិឈ្មោះ ប្រាជ្ញ ប៉ុល ប៉ុន្តែដោយសារលោកជាប់រវល់និមន្តចេញទៅទេសនា គាត់បានត្រឹមតែផ្តាំផ្ញើពាក្យសម្តីតាមរយៈមិត្តភក្តិប៉ុណ្ណោះ ។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦៧ ឌុច ទៅចូលរួមពិធីបុណ្យបញ្ចូលជាបក្សជនត្រៀមនៅចម្ការលើ ដោយមាន កែ ពក ទទួលស្គាល់ ។ ឌុច ឈរមុខទង់បក្សលើកដៃគោរព ហើយសច្ចាថា «ស្មោះត្រង់ និងបម្រើបក្ស វណ្ណៈប្រជាជនអស់មួយជីវិត ដោយមិនខ្លាចធ្វើពលិកម្ម» ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៨ ក្រោយពីមានផ្ទុះសង្គ្រាមរវាងខ្មែរក្រហមនិងរដ្ឋាភិបាល បក្សកុម្មុយនីស្តកម្ពុជាបានចាត់តាំង ញឹម រស់ ឲ្យធ្វើកុបកម្មដណ្តើមអាវុធនៅបាយដំរាំ ដោយយកភ្នំវាយចាបធ្វើជាមូលដ្ឋានបផ្អែក ។ ចំណែកភូមិភាគនិរតី ម៉ា ម៉ង់ ជាលេខាយកភ្នំឱរ៉ាល់ធ្វើជាមូលដ្ឋានបផ្អែក តាម៉ុកយកភ្នំវល្លិធ្វើជាមូលដ្ឋានបផ្អែក ចំណែក កែ ពក ហើយនិង កុយ ធួន យកព្រៃឡង់ធ្វើជាមូលដ្ឋានបផ្អែក ។ ដោយឡែក ប៉ុល ពត វាយបានដីរំដោះនៅភូមិភាគឦសាន ហើយបានបែងចែកកម្លាំងទ័ពជាពីរ គឺកម្លាំងការពារសម្ងាត់ និងកម្លាំងសម្រាប់ធ្វើសង្គ្រាមឈ្លប ។ នៅឆ្នាំ១៩៧០ សុន សេន ឡើងធ្វើជាលេខាភូមិភាគឦសាន ក្រោយមកគាត់បានប្តូរមកធ្វើជាសហប្រធានភូមិភាគឧត្តរ ជាមួយនឹង កុយ ធួន ។ រហូតដល់ចុងឆ្នាំ១៩៧៣ សុន សេន ទទួលភារកិច្ចជាលេខាភូមិភាគពិសេសដែលគ្រប់គ្រងតំបន់១៥ និងកម្លាំងសម្ងាត់នៅភ្នំពេញ ។ ចំណែក ប៉ុល ពត, នួន ជា, ខៀវ សំផន បានទៅបោះទីតាំងសម្ងាត់នៅភូមិប្រកស្បាច់ ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលពីមុន ឃុំពាម ស្ថិតនៅភូមិភាគនិរតី ប៉ុន្តែបានប្រគល់មកឲ្យភូមិពិសេសគ្រប់គ្រងចាប់ពីឆ្នាំ (១៩៧១) ។

## ក្នុងមន្ទីរឃុំឃាំង

នៅថ្ងៃទី៥ មករា ឆ្នាំ១៩៦៨ ឌុច ត្រូវបានចាប់ខ្លួនដោយប៉ូលិសរបស់ព្រះបាទនរោត្តម សីហនុ ឈ្មោះ ស្រី គឹមសឿន ជាអ្នកស្រុកស្ទោង និងជាសិស្សរួមសាលាជាមួយគាត់ ។ ឌុច ត្រូវ បានរដ្ឋាភិបាលចោទប្រកាន់ថា «ប្រឆាំងនឹងសេចក្តីសុខសាន្តក្នុងព្រះនគរ និងចូលដៃដើងជាមួយបរទេស» ។ បន្ទាប់មក ប៉ូលិសបានឃុំឃាំង ឌុច នៅទួលគោក រួចបញ្ជូនបន្តទៅឃុំឃាំងនៅគុកប៉េអ៊ឹមស្រះចក និងគុកធំភ្នំពេញ ដែលនៅទីនោះប្រធានបន្ទប់ដែលជាអ្នកទោសដូចគ្នាបានហាមឃាត់មិនឲ្យ ឌុច និយាយជាមួយអ្នកទោសផ្សេងទៀតទេ ប៉ុន្តែរបបអាហារគាត់ទទួលបានគ្រប់គ្រាន់ដោយសារចាងហ្វាងគុកលួចយកមកឲ្យ ។ នៅខែ៥ ឆ្នាំ១៩៦៨ ប៉ូលិសបានបញ្ជូន ឌុច ទៅឃុំឃាំងនៅព្រៃសដែលជាគុករបស់ទាហាន ដោយមានធ្វើទារុណកម្មទាត់ធាក់ផង ប្រសិនបើនរណាម្នាក់ធ្វើខុស ។ នៅដើមខែ៧ ឌុច ត្រូវបានបញ្ជូនត្រឡប់មកឃុំឃាំងនៅក្នុងគុកធំវិញ ដោយមិនមានការធ្វើទារុណកម្មលើអ្នកទោសទេ ។ ប៉ុន្តែ នៅទីនោះរបបអាហារសម្រាប់អ្នកទោសមិនគ្រប់គ្រាន់ទេ ដូច្នេះឆ្មាំគុកបានផ្តល់លុយឲ្យ ឌុច ចំនួន

មួយរៀលក្នុងមួយថ្ងៃ ដើម្បីយកទៅទិញស្ករសនិងអំបិលមកហូបបន្ថែម ។

នៅអំឡុងពេលជាប់ឃុំឃាំង ឌុច មិនដែលឃើញមានមេធាវីមកសាកសួរពីមូលហេតុនៃទោសកំហុសរបស់គាត់ឡើយ ។ រហូតមកដល់ខែមិថុនា ឆ្នាំ១៩៦៩ ទើបតុលាការកោះហៅ ឌុច មកកាត់ទោស ដោយមានមេធាវីលោកតា មួង ឡៅខាំ ជាអ្នកការពារក្តីឲ្យគាត់ ។ ដំណើរការសវនាការប្រព្រឹត្តទៅរយៈពេលពេញមួយព្រឹក ហើយនៅចុងបញ្ចប់តុលាការបានចេញសាលដីកាសម្រេចឲ្យ ឌុច ជាប់ឃុំរយៈពេល២០ឆ្នាំ និងត្រូវធ្វើការជាទម្ងន់ ។ ពេលជាប់ឃុំ ឌុច បានជួបជាមួយសាខាបក្សកុម្មុយនីស្តកម្ពុជាឈ្មោះ ទេព សៀន ក្រោយមកប្តូរឈ្មោះទៅជា ស សៀន ជាសមាជិកអចិន្ត្រៃយ៍ (សភាប្រជាជន) ដែលត្រូវរដ្ឋាភិបាលចាប់ខ្លួនឃុំនៅទីនោះដែរ ។ បន្ទាប់មក នៅថ្ងៃទី២០ កក្កដា ឆ្នាំ១៩៦៩ ស សៀន ក៏បានបញ្ចូល ឌុច ជាបក្ខជនពេញសិទ្ធិនៃបក្សកុម្មុយនីស្តកម្ពុជា ។

ក្រោយពីបានឮដំណឹងថា ឌុច ជាប់ឃុំឃាំង ម្តាយរបស់គាត់បានទៅពីងប្អូនជីទួតមួយដែលត្រូវជាក្មួយប្រសាររបស់ លន់ នល់ ដើម្បីសុំឲ្យបានរួចខ្លួន ។ រដ្ឋាភិបាលសន្យាថានឹងដោះលែងប្រសិនបើ ឌុច ព្រមចុះហត្ថលេខាលើញត្តិសុំទោស ។ ប៉ុន្តែ ឌុច បានគិតថា រដ្ឋាភិបាលនឹងចាញ់បដិវត្តន៍ ដូច្នេះគាត់មិនបានចុះហត្ថលេខាឡើយ ។ ឌុច លើកហេតុផលប្រាប់ម្តាយរបស់គាត់ថា «ខ្ញុំកំពុងគោងមែកឈើខ្មែរក្រហម ប្រសិនបើខ្ញុំបោះមែកឈើនេះចោល ទៅគោងមែកឈើ លន់ នល់ សួរថាគាត់ទុកចិត្តខ្ញុំទេ? លន់ នល់ មិនទុកចិត្តខ្ញុំ ខ្មែរក្រហមក៏មិនទុកចិត្តខ្ញុំ ខ្ញុំងាប់ទទេ ។ ម្ល៉ោះហើយកូនសុំនៅទីនេះចុះ» ។ ឌុច បានបន្តថា កង់ទ័ពនៅពេញព្រៃប្រាំឆ្នាំទៀតគេមកដោះខ្ញុំ ។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារ លន់ នល់ ក៏មានធ្វើពិធីដោះលែង ឌុច និងអ្នកទោសនយោបាយផ្សេងទៀតរួមមាន ខ្មែរសេរី យួនយៀកកុង និងយួនធីវគី យៀកមិញ នៅមុខរដ្ឋសភា ដើម្បីបញ្ជាក់ប្រាប់សកលលោកថា របបថ្មីនេះមិនចេះតែដើរចោទគេថាជាខ្មែរខៀវ-ក្រហម ហើយចាប់ដាក់គុកនោះទេ ។ ឌុច បានមកស្នាក់នៅផ្ទះក្នុងខេត្តកំពង់ធំបានរយៈពេល ៣សប្តាហ៍ ។ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧០ គាត់ក៏ត្រឡប់មកស្នាក់នៅកុដិលេខ៣ វត្តខណ្ឌលោម ក្នុងក្រុងភ្នំពេញវិញ ដើម្បីប្រមូលកម្លាំងរង់ចាំទទួលភារកិច្ចបដិវត្តន៍ ។

## ភារកិច្ចថ្មី

នៅចុងខែសីហា ឆ្នាំ១៩៧០ ឌុច ត្រូវបានអនុញ្ញាតឲ្យទៅតំបន់រំដោះស្រុកស្អាង និងកោះធំ តំបន់២៥ ដើម្បីបង្រៀននយោបាយ និងសីលធម៌នៅអង្គភាពមួយ ។ នៅខែធ្នូ ឆ្នាំ១៩៧០ មន្ទីរនគរបាលមួយត្រូវបានបង្កើតឡើង ដែលមានមិត្ត ម៉ឹង


ឌុច

សំណាង ហៅ គេង ប្រធានយោធាតំបន់គ្រប់គ្រង ។ នៅទីនោះមិត្ត ម៉េង ផន ហៅ សុខ បានប្រាប់ ឌុច ពីវិធីធ្វើទារុណកម្មដោយវាយនឹងរំពាត់ ។ ក្រោយមក ទំនាស់រវាងអ្នកបដិវត្តន៍និងចក្រពត្តិ លន់ នល់ បានកើតឡើង ហើយ សុខ ប៊ុតចំរើន (ឈ្មោះដើម ស៊ីសុវត្ថិប៊ុតមុន្នី) អនុលេខាគណៈកម្មាធិការតំបន់២៥ បានចាប់បក្ខជនម្នាក់ឈ្មោះ ហ៊ួន គៀត និងចាប់៣នាក់ផ្សេងទៀត ដាក់ឃុំឃាំងក្នុងផ្ទះនៅសៃវ៉ា ដោយគ្មានការអនុញ្ញាតពីមជ្ឈិម ។ ស្របពេលនោះ បក្សពលករវៀតណាមក្នុងខេត្តអានយ៉ាងបានចូលមកចាត់តាំងរដ្ឋអំណាចនៅកម្ពុជា និងបាញ់សម្លាប់ខ្មែរដើរទាពន្ធដារម្នាក់ឈ្មោះ ពិន ឯម នៅលើទន្លេបាសាក់ម្តុំ ឃុំព្រែកស្តី ។

ចំណែក រដ្ឋាភិបាលបានទម្លាក់គ្រាប់បែកណាប៉ាល់ និងផ្លោងគ្រាប់ ១០៥មីលីម៉ែត្រចូលទៅក្នុងដីរំដោះដែលធ្វើឲ្យសភាពការណ៍កាន់តែច្របូកច្របល់ ។

នៅខែឧសភា ឆ្នាំ១៩៧១ ឌុច ឆ្លៀតធ្វើការទាក់ទងជាមួយប្រធានសេនាធិការតំបន់ដើម្បីផ្លាស់មកនៅភូមិភាគនិរតី ។ នៅទីនោះ ឌុច បានជួបជាមួយមិត្តចាស់ម្នាក់ឈ្មោះ តាំង ខែក អតីតគ្រូបង្រៀននៅវិទ្យាល័យចំរើនវិជ្ជាទទួលភារកិច្ចប្រធានមន្ទីរនគរបាលត្រពាំងជោរ តំបន់៣២ ដែលគាត់ជាអ្នកប្រកាន់ជំហរ



វណ្ណៈខ្ពស់ ហើយតែងតែជូនយោបល់ទៅថ្នាក់លើចំពោះមនុស្សណាដែលសង្ស័យ ។ នៅថ្ងៃ២០ កក្កដា ១៩៧១ វន វើត បានប្រាប់ ឆាយ គឹមហ៊ី មកទទួលយក ឌុច ទៅជួប ប៉ុន្តែបានអាក់ខានទៅវិញ ដោយសារ វន វើន ទទួលកម្លាំងសម្ងាត់មកពីភ្នំពេញ ។ នៅថ្ងៃបន្ទាប់ វន វើត បានផ្តាំ ឌុច ឲ្យធ្វើការជាមួយមិត្ត ឆាយ គឹមហ៊ី និងបានចាត់តាំង ឌុច ឲ្យធ្វើជាប្រធានមន្ទីរម-១៣ ស្ថិតនៅក្រោមការបញ្ជាផ្ទាល់របស់គាត់ តាម៉ុក និង ជូ ជេត ។

ប៉ុន្តែ ឌុច បានបដិសេធដោយលើកឡើងថា «ខ្ញុំមិនចេះសួរចម្លើយទេ» ។ ព្រោះដូច្នេះ ឆាយ គឹមហ៊ី តបវិញថា «មិត្តមានមតិត្រូវហើយ អ្នកដែលទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រគឺសមាជិក មជ្ឈិមរួមមាន អ៊ុង ជឿន (តាម៉ុក), ជូ ជេត (ស៊ី), ហួត ហេង (ប៉ាល់) និង វន វើត ។ ដូច្នេះ មិត្តកុំភ័យខ្វំតែធ្វើការងារទៅ ហើយកុំទាមទារចាប់នរណាឲ្យសោះ សូម្បីសេចក្តីរាយការណ៍របស់មិត្តក៏កុំឲ្យមានលម្អៀងដែរ» ។ ឆាយ គឹមហ៊ី បន្តថា «ជាតិប្រជាជនត្រូវការកុលបុត្ររបស់ខ្លួនដើម្បីការពារតំបន់រំដោះ និងអាយុជីវិតជាតិប្រជាជន ។ ការបង្រៀននគរបាលគ្មាននរណាបង្រៀនយើងទេ ព្រោះវាប៉ះពាល់ដល់ប្រទេសជាតិគេ ។ យើងរំដោះជាតិ មិនមែនរំដោះយកដីអត់មនុស្សនោះទេ យើងរំដោះយកមនុស្សជាសំខាន់ មានមនុស្សគឺមានអ្វីៗទាំងអស់» ។ ប៉ុន្តែ ឌុច នៅតែបដិសេធដដែល ដោយលើកឡើងការភ័យខ្លាចថា «ខ្ញុំមិនហ៊ានសម្លាប់មនុស្សទេ» ។ ពេលនោះ ឆាយ គឹមហ៊ី បញ្ជាក់ម្តងទៀតថា «យើងជាបញ្ញាជនមានការតឹងតែង យើងត្រូវរៀនសូត្រពីកសិករ ទុកឲ្យកសិករធ្វើ យើងគ្រាន់តែប្រាប់គេទៅ» ។ ចំណែក ជូ ជេត ប្រាប់ថា «យើងកម្ទេចតែសក្តិភូមិ និងនាយទុនប៉ុណ្ណោះទេ» ។ បន្ទាប់ពីការចាត់តាំង ឌុច បានទទួលភារកិច្ចពីរគឺ «កន្លះខែត្រូវទៅចូលរួមប្រជុំជីវភាពផង និងចូលរួមប្រជុំស្ម័យទិតៀនជាមួយលេខាមន្ទីរផ្សេងៗទៀត» ។

## ការបង្កើតមន្ទីរម-១៣

មន្ទីរម-១៣ ជាមន្ទីរដែល វន វើត បានដាក់ឈ្មោះឲ្យ ដោយសារមន្ទីរនេះមានបក្សជនតែម្នាក់ ហើយនៅឆ្ងាយពីគេ ទើបមន្ទីរម-១៣នេះមានលក្ខណៈប្លែកពីមន្ទីរពិសេសនានាដែលមានលេខបីខ្ទង់ ដូចជាមន្ទីរភូមិភាគ៣០៥ មន្ទីរឃោសនាការ ៣០៦ គ្រប់គ្រងដោយអតីតវិស្វករ ជី គឹមអាន មន្ទីរសេដ្ឋកិច្ច ៣០៧ គ្រប់គ្រងដោយអតីតវិស្វករ សៀង ប៉ៅសែ និងមន្ទីរនិរសារ ៣០៩ ។ មន្ទីរម-១៣ មានទីតាំងនៅភូមិថ្មគប់ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលជាគោលការណ៍មន្ទីរនគរបាល នេះចាំតែទទួលសួរចម្លើយអ្នកទោស រួចកម្ទេចចោលប៉ុណ្ណោះ ។ ប៉ុន្តែ ដោយសារមន្ទីរនេះបានដោះលែងអ្នកទោសមួយចំនួន ហើយ ឌុច ចង់ឲ្យអ្នកដែលត្រូវបានដោះលែងនៅដាច់ឆ្ងាយពីអ្នកត្រូវកម្ទេច ទើបគាត់សុំអនុញ្ញាតពី វន វើត បង្កើតមន្ទីរម-១៣«ខ» ដែលមានទីតាំងនៅភូមិស្តុកស្រាត ឃុំស្តុកគោល ស្រុកអង្គស្នួល តំបន់១៥ សម្រាប់អប់រំអ្នកទោសដែលមាន

កំហុសស្រាល ហើយដោះលែងឲ្យទៅភូមិវិញ ក្រោមការគ្រប់គ្រង ដោយមិត្ត ស៊ុំ ហៅ ហូ គីមអេង ជាអនុប្រធានរបស់ ឌុច ។

## ការជ្រើសរើសបុគ្គលិក

ឌុច បានយកបុគ្គលិកពីភ្នំពេញប្រហែលជាង១០នាក់ រួមមានក្មេង ចាស់ និងស្នើយកក្មេងៗនៅក្នុងមូលដ្ឋានមកធ្វើជាបុគ្គលិកក្នុងមន្ទីរម-១៣ ដែលសរុបប្រមាណ១៧-២០នាក់ ។ ឌុច បានយកទ្រឹស្តីតាមរឿងចិនដែលមានចំណងជើងថា «ចង្កៀងក្រហម» មានន័យថា «កូនអ្នកក្រឆាប់ដឹងក្តី ដាក់ពូជអីដុះពូជហ្នឹង» មកអប់រំក្មេងៗឲ្យធ្វើការងារ ព្រោះ ឌុច គិតថា វណ្ណៈភាពរបស់គាត់ បក្សពុំសូវពេញចិត្តទេ ដូច្នេះហើយគាត់បានយកក្មេងៗដើម្បីឲ្យគេយិតយោងគាត់ ។ បន្ទាប់មក ឌុច បានជ្រើសរើសក្មេងអាយុ១២ឆ្នាំ ចំនួនពីរនាក់ គឺ មិត្ត សើ កូនរបស់មិត្តមុំ និង មិត្ត ឆេន កូនរបស់កម្មាភិបាលនៅមន្ទីរម-១៣ មកធ្វើជានិរសារផ្ទាល់ខ្លួន ។

## វិធីសួរចម្លើយ

វ៉ន វ៉េត បានណែនាំឲ្យយកស្បោងប្លាស្ទិកប្រកពីលើក្បាលដើម្បីឲ្យថប់ដង្ហើម និងវិធីពិនិត្យមើលជីពចរ ប្រសិនបើលោតខ្លាំងអ្នកនោះនឹងធ្វើខុស ។ ប៉ុន្តែ ឌុច បានបដិសេធ ដោយសារពុំចេះពីវិធីមើលជីពចរ ម្យ៉ាងទៀតនៅតំបន់រំដោះពុំមានស្បោងប្លាស្ទិកផង ។ ដូច្នេះ ឌុច បានបង្កើតវិធីសួរចម្លើយតាមរបៀបបីបែប ទី១) សួរស្ងួត គឺបបួលអ្នកទោសនិយាយពីនេះពីនោះ និង ណែនាំបញ្ចុះបញ្ចូលឲ្យឆ្លើយសារភាព ។ ទី២) សម្លុតដោយយកដំបងប្ញញ្ញូរទៅកំញើញ និង ទី៣) និយាយតែពីរឬបីម៉ាត់ វាយតែម្តង ។ ពេលសួររកកាំភ្លើង ប៉ុន្តែអ្នកទោសមិនព្រមឆ្លើយសារភាព ឌុច ក៏បានទៅពិគ្រោះយោបល់ជាមួយ ជូ ជេត (ស៊ី) អនុលេខាភូមិភាគនិរតីដើម្បីឲ្យគាត់ផ្តល់យោបល់ ។ ពេលនោះ ជូ ជេត បានណែនាំ ឌុច ឲ្យបោះបង្គោលចំនួន៤ ដោយយកខ្សែអង្រឹងមកចងដៃអ្នកទោសទៅក្រោយភ្ជាប់នឹងបង្គោល ហើយយកអ្នកទោសម្នាក់ទៀតមកដាក់នៅចំកណ្តាល រួចឲ្យកងការពារបាញ់ឲ្យចំក្បាលអ្នកទោសដើម្បីគំរាមអ្នកទោសផ្សេងទៀត ។ ក្រោយមក ឌុច និង ប៉ុន ក៏បានធ្វើទារុណកម្មមួយបែបទៀតចំពោះអ្នកទោសស្រីម្នាក់ ដោយឲ្យអ្នកទោសនោះមុជទឹកស៊ីង ហើយងើបឡើងហាលខ្យល់ត្រជាក់ ប៉ុន្តែវិធីនេះក្រោយមក ឌុច មិនបានយកមកអនុវត្តទេ ព្រោះមិនបានលទ្ធផល ។

ឌុច បានសួរចម្លើយអ្នកទោសឈ្មោះ កៅ ហ៊ាង ឬ កៅ ប៊ុនហៀង តាមវិធីត្រជាក់ នៅលើផ្ទះមួយខ្នងជាប់ផ្លូវស្ថិតក្នុងភូមិថ្នគប់ ឃុំអមលាំង ស្រុកថ្ពង ។ ដោយសារតែ ហៀង នៅតែឆ្លើយដដែលៗថា មកទិញជ្រូក ទិញមាន់ ទើបកម្មាភិបាលមកពីហាណូយពីរនាក់ដែលមានកាំភ្លើងខ្លីចូលមកវាយ ហ៊ាង តែម្តងដោយគ្មានការចាត់តាំង ។ ពេលឃើញអ្នកទោសឆ្លើយថាជាគិញ ឌុច ខឹងយ៉ាងខ្លាំង ក៏ស្ទុះទៅវាយថែមទៀត ។ ហៀង បានលើកដៃសំពះដើម្បីកុំឲ្យវាយតទៅទៀត ប៉ុន្តែជាគោលការណ៍ អ្នកទោសដែលសួរចម្លើយហើយត្រូវតែកម្ទេច ដើម្បីការពារទីកដី រំដោះប្រជាជនកុំឲ្យខ្មាំងដណ្តើមបាន ការពារការទម្លាក់គ្រាប់បែក និងការពារពីការវាយលុករបស់ខ្មាំង ។

នៅពេលនោះ ដោយចង់បានបទពិសោធន៍ ឌុច បានចំណាយរយៈពេល២ខែ ដើម្បីសួរចម្លើយអ្នកទោសម្នាក់ឈ្មោះ ង៉ែត សំប៊ុន ហៅ រំពេ អ្នកសរសេរកំណាព្យឲ្យកាសែត ដែលបានចូលមកបង្កប់ខ្លួនក្នុងដីរំដោះ ។ ចំណែកអ្នកទោសផ្សេងទៀត គាត់បានណែនាំឲ្យកងការពារសួរចម្លើយ ។

ឌុច ក៏បានសួរចម្លើយផ្ទាល់ខ្លួនចំពោះអ្នកទោសណាដែលគាត់ចង់ដោះលែងដូចជា ហម អ៊ីន និងឈ្មោះ គៀន មេក្រុមសិល្បៈដែលបានដើរឃោសនាថា ខ្មែរក្រហមបំបាត់ពុទ្ធសាសនា ។ បន្ទាប់ពីសួរប្រវត្តិរូបចប់ ឌុច បានរាយការណ៍ទៅមជ្ឈិមដើម្បីសុំដោះលែង ហម អ៊ីន ដោយសារគាត់ធ្លាប់រាប់អានជាមួយឪពុករបស់ ហម អ៊ីន ។

ក្រោយមក មានការចាប់ខ្លួនអ្នកទោសស្ត្រីម្នាក់រស់នៅភូមិកុមារមាស ឃុំអមលាំង បញ្ជូនមកមន្ទីរម-១៣ ដោយចោទថា លួចក្រវិលទំហំ៥ហ៊ុន ។ ប៉ុន្តែ ឌុច មិនបានឃុំឃាំងទេ ព្រោះអ្នកទោសនោះមានជីវភាពធូរធារ ហើយគាត់បានស្នើសុំការអនុញ្ញាតពី ឆាយ គីមហ៊ា និង តាម៉ុក ដើម្បីដោះលែង ។

នៅយប់មួយ ឌុច បានចាប់មិត្ត ម៉ែន ផល គូនាទីអនុរបស់មិត្ត ស៊ុំ តាមបញ្ជារបស់ សុន សេន ដោយចោទប្រកាន់ពីរឿងស្រីញីនិងបង្កហេតុនៅក្នុងអង្គភាព ។ នៅពេលនោះ ឌុច ចង់

បង្រៀនមិត្ត មាស ពីវិធីសួរចម្លើយ គាត់ក៏ទៅដេកក្នុងអង្រឹងជាមួយមិត្ត ប៉ុន ដោយទុកមិត្ត មាស ឲ្យសួរមិត្ត ផល ។ មាស បានហៅមិត្តផល ថា «អ៊្ហែង ប៉ុន្តែដោយសារមិត្តមាស ក្មេងជាង មិត្ត ផល ក៏ខឹងហើយបួងដៃដាល់មិត្តមាសពីក្រោម» ។ ឃើញដូច្នេះមិត្ត ប៉ុន ក្រោកពីអង្រឹងយកចន្ទុះរុញទៅលើមុខមិត្ត ផល ចំនួនពីរទៅបីដងរហូតរបកសាច់មុខ ។

សុន សេន បានបញ្ជាឲ្យចាប់ប្រជាជននៅភូមិពោធិ តំបន់ ១៥ ជាប់តំបន់ខ្នាំង សរុបទាំងអស់២០-៣០នាក់ ដោយចោទថា គិញ សក្តិភូមិ នាយទុន និងទទួលឥទ្ធិពីខ្មាំង ។ សុន សេន បានបញ្ជូនអ្នកទោសទាំងអស់មកឲ្យ ឌុច ដោយជ្រើសរើសទុកតែ ៥-៦នាក់ប៉ុណ្ណោះ ឲ្យមន្ទីរម-១៣ សួរចម្លើយ ចំណែកអ្នកទោសដែលនៅសល់ត្រូវបញ្ជូនឲ្យទៅរស់នៅខេត្តបាត់ដំបង ។

**ទីតាំងមន្ទីរម-១៣ «ក»**

មន្ទីរម-១៣ បានផ្លាស់ប្តូរទីតាំងជាច្រើនកន្លែង គឺដំបូងនៅភូមិថ្មគប់ ឃុំអមលាំង ប៉ុន្តែដោយសារគ្មានពន្លឺព្រះអាទិត្យ ខ្វះអាហារ ខ្វះថ្នាំសង្កូវ និង មានសំណើម បណ្តាលឲ្យអ្នកទោសស្លាប់ ទើប ឌុច បានប្តូរមកបោះទីតាំងនៅភូមិទួលស្វាយមាស ឬតាលាវ (ជាប់ជើងភ្នំពីស) ឃុំអមលាំង ស្រុកថ្ពងវិញ ។ នៅទីនោះ ឌុច បានបញ្ជាឲ្យអ្នកទោសទាំងអស់ធ្វើស្រែនិងមានកងការពារម្នាក់យាមលើដំបូក ។ ពេលនោះ ឆ្លៀតពេលកងការពារដក់បារី អ្នកទោសឈ្មោះ រឿង ចូលមកសុំថ្នាំជក់និងឆក់បានកាំភ្លើងអាកាដេញបាញ់មិត្ត ប៉ុន, មាស, ម៉ៅ ឲ្យរបួស ហើយអ្នកទោសប្រមាណ ៣០នាក់រត់ចេញពីមន្ទីរឃុំឃាំង ។ រហូតដល់ម៉ោង៥ល្ងាច ឌុច ទទួលបានដំណឹងនេះ គាត់ឲ្យប្រធានឃុំអមលាំងយកម៉ូតូជូនទៅមន្ទីរភូមិភាគសុំជួប វន វ៉េត ដើម្បីរាយការណ៍ ។ ឌុច បានសុំឲ្យ វន វ៉េត ដាក់ទោសគាត់ ប៉ុន្តែ វន វ៉េត មិនបានចាប់កំហុសនេះ ទេ ។

នៅខែ៣-៤ ឆ្នាំ១៩៧៣ ឌុច បានផ្ទេរមន្ទីរម-១៣ ទៅភូមិព្រែក ឃុំថ្មគប់ ស្រុកថ្ពង ។ អ្នកទោសដែលយកមកពីភូមិទួលស្វាយមាស ឃុំអមលាំង ឌុច ទុកសម្រាប់ធ្វើស្រែ និង បង្កបង្កើនផលសម្រាប់ផ្គត់ផ្គង់អង្គភាព ។ តាម៉ុក បានបញ្ជាឲ្យចាប់ ពត ហៅប្រាជ្ញ សុន អនុលេខាវរសេនាតូច ដោយចោទថាបាញ់មិត្ត យ៉ាន ជាលេខា និងបានប្រាប់ ឌុច ឲ្យវាយមិត្ត ពត ប្រសិនបើមិនព្រមឆ្លើយសារភាព ។ ដោយដឹងថា យ៉ាន បាញ់ខ្លួនឯង ឌុច ក៏រាយការណ៍ទៅ វន វ៉េត រួចរាយការណ៍បន្តទៅមជ្ឈិម ។ ពេលឮដំណឹងនេះ តាម៉ុក បានលើកឡើងថា «អញមួយជាតិ អញឈប់ប្រើឌុច» ហើយមជ្ឈិមក៏លើកឡើងទៀតថា «កុំបច្ចេកទេសពេកត្រូវប្រើនយោបាយផង» ដែលមានន័យ «កុំឈរលើបច្ចេកទេសវិភាគខ្លាំង ត្រូវឈរលើនយោបាយ» ។

រយៈពេលពីរខែក្រោយមក តាម៉ុក បានឲ្យ ឌុច ទៅនៅត្រពាំងច្រាប ឃុំត្រពាំងច្រាប ស្រុកថ្ពង ។ នៅទីនេះ អ្នកទោសស្រីត្រូវដាំត្រប់ ចំណែកអ្នកទោសប្រុសៗលើកទំនប់ ដែលមានកងការពារក្មេងៗកាន់កាំភ្លើងយាមអ្នកទោសចំនួន៣ៗនាក់ដែលត្រូវចងខ្សែអង្រឹងភ្ជាប់នឹងក ។ អ្នកទោសម្នាក់ឈ្មោះ ប៊ុត បានពង្រត់ប្រពន្ធអ្នកភូមិទៅនៅខត្តុង្គ និងបានជួប សារី សយ និង ហង់ យីវ ជាទាហានសក្តិបួនកន្ទុះរបស់ លន់ នល់ ។ មួយរយៈក្រោយមក ប៊ុត បានត្រឡប់មកភូមិវិញ ពេលនោះ ដូ ដេត បានបញ្ជាឲ្យចាប់ខ្លួន ប៊ុត ប្រគល់មកឲ្យមន្ទីរម-១៣ ។ ឌុច និង ប៉ុន បានវាយសួរចម្លើយ បន្ទាប់មក ប៊ុត ក៏បានសារភាពថាបានយកកាំភ្លើងមកលាក់ទុកនៅក្នុងតំបន់រំដោះដើម្បីធ្វើការបះបោរ ។ ក្រោយពីឮដំណឹងនេះ តាម៉ុក បានបញ្ជាឲ្យមានការស៊ើបរកកាំភ្លើងជាបន្ទាន់ ហើយប្រសិនបើរកឃើញគាត់នឹងយកមកបំពាក់ឲ្យមួយវរសេនាតូច ។ បន្ទាប់ពីទទួលបានបញ្ជា ឌុច និងដូ ដេត បានពិភាក្សាគ្នា ហើយសម្រេចចាប់ខ្លួនអ្នកមូលដ្ឋាននៅអមលាំងប្រហែលជិត៥០នាក់ យកមកសួរចម្លើយ ។

នៅឆ្នាំ១៩៧៣ អ្នកទោសម្នាក់ឈ្មោះ យឺ ត្រូវបានចាប់មកសួរចម្លើយដើម្បីតាមដានរកកាំភ្លើង ។ ប៉ុន្តែ ដោយសារគាត់បញ្ចេញអត្តចរិតប្រឆេងប្រឆាង ឌុច ក៏បានរាយការណ៍ទៅ ដូ ដេត ក្នុងបំណងយកទៅកម្ទេចជាសម្ងាត់ ។ ពេលនោះ ដូ ដេត ក៏បានបញ្ជាឲ្យ ឌុច ប្រើកងការពារម្នាក់បាញ់ឲ្យចំក្បាល ដើម្បីឲ្យធ្លាយខួរខ្ទាតទៅលើអ្នកទោសផ្សេងទៀត ។

ដោយសារខ្លាចអ្នកទោសរត់រួច និងការពារពីការទម្លាក់គ្រាប់បែកបេ៥២ ឌុច បានបញ្ជាឲ្យអ្នកទោសកាប់ឬស្សី (ជាឫស្សីមួយបែប) យកមកត្រាំទឹក រួចត្បាញធ្វើជាប្រដេស ដើម្បីធ្វើជារបងព័ទ្ធជុំវិញមន្ទីរឃុំឃាំងនិងឲ្យជីករណ្តៅចំនួន៣ដែលមានជម្រៅ

២ម៉ែត្រ ទទឹង២ម៉ែត្រ បណ្តោយ៣ម៉ែត្រ ហើយប្រក់ដំបូលពីលើនិងរណ្តៅមួយទៀតសម្រាប់កប់សាកសព ។ អ្នកទោសត្រូវដាក់ខ្នោះជើងជាមួយរនុកដែកវែងនៅក្នុងរណ្តៅដែលមានចំនួនពី៥-១០នាក់ ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យទៅមុជទឹករាល់ថ្ងៃដោយមានមិត្ត មាស ជាអ្នកជូនទៅ ប៉ុន្តែត្រូវចងខ្សែអង្រឹងភ្ជាប់នឹង-ក ។ អ្នកទោសដែលបញ្ជូនចូលមកមន្ទីរម-១៣ ត្រូវកត់ឈ្មោះលើក្រដាសដែល ឌុច សុំពីការិយាល័យ២០១ កន្លែងបោះពុម្ពកាសែត ។

នៅទីនោះ ឌុច បានចាប់សួរចម្លើយ ឬចាប់ឃុំអ្នកទោសនៅទីនោះដោយមិនឲ្យចេញ ប្រសិនបើសង្កេតឃើញថាអ្នកទោសមានបំណងប្រុងរត់គេចចេញពីមន្ទីរម-១៣ ។ ប៉ុន្តែ ប្រសិនបើកងទ័ព ឬមូលដ្ឋានចាប់បានវិញ អ្នកទោសនោះត្រូវកម្ទេចចោលនៅនឹងកន្លែងតែម្តង ហើយ ឌុច ត្រូវរាយការណ៍ទៅថ្នាក់លើភ្លាមៗ ។

នៅពេល តាម៉ុក បានចាប់ សង្ហា ហឿន អ្នកច្រៀងអាយ៉ៃមកឲ្យ ឌុច ដើម្បីណែនាំ ប៉ុន្តែមិនឲ្យវាយសួរចម្លើយទេ ពេលនោះ ឌុច បានឃុំឃាំងរហូតដល់ស្លាប់ដោយសារលក្ខខណ្ឌជីវភាព ។ ចំណែកអ្នកទោសបរទេសម្នាក់ឈ្មោះ ប៊ីហ្សូ អ្នកស្រាវជ្រាវនិងអ្នកបកប្រែភាសាបារាំង ពីនាក់គឺ មិត្ត ឡាយ និងមិត្ត ស៊ុន ក៏ត្រូវបាន តាម៉ុក ចាប់ខ្លួនបញ្ជូនមកមន្ទីរម-១៣ដែរ ដោយចោទប្រកាន់ថាសេអ៊ីអា ។ ប៉ុន្តែ ឌុច មិនបានសួរចម្លើយទេ បន្ទាប់មកគាត់ក៏រាយការណ៍ ទៅ វន វ៉េត ហើយក្រោយមក វន វ៉េត ក៏បញ្ជាឲ្យដោះលែងឈ្មោះ ប៊ីហ្សូ ចំណែកមិត្ត ឡាយ និង មិត្ត ស៊ុន ត្រូវនៅជាប់ឃុំឃាំងដដែល ។

ចាប់ពីខែ៩-១០ ឆ្នាំ១៩៧៤ នៅមន្ទីរម-១៣ របបអាហារសម្រាប់អ្នកទោសមានតែកន្ទក់ ដំឡូងជ្វា ដំឡូងមី និងក្តួចប៉ុណ្ណោះ ហើយថែមទាំងគ្មានមានថ្នាំសង្កូវសម្រាប់ព្យាបាលទៀតផង បណ្តាលឲ្យទោសខ្លះស្លាប់ដោយសារជំងឺ និងបាក់កម្លាំង ។

**ការកម្ទេច**

នៅមន្ទីរម-១៣ នៅពេលយកចម្លើយពីទោសបានចំនួន២-៣នាក់ ឌុច ត្រូវរាយការណ៍ជូនទៅថ្នាក់លើម្តង ។ ប្រសិនបើចម្លើយបានគ្រប់គ្រាន់ហើយ អ្នកទោសត្រូវយកទៅកម្ទេច ដែលមានមិត្ត មាស អាយុ១៦ឆ្នាំ ជាកូនកសិករនៅភូមិស្នួល ឃុំអមលាំង ទទួលខុសត្រូវ និងដឹកនាំចលនាកម្ទេច ព្រមទាំងមានមិត្ត ទិត្យ និង មិត្ត ណាន ។ ការសម្លាប់អ្នកទោសនៅមន្ទីរម-១៣ ត្រូវរក្សាជាការសម្ងាត់ និងមិនត្រូវឲ្យមនុស្សនៅក្រៅអង្គភាពរបស់ខ្លួនបានឃើញទេ ។ រណ្តៅកប់សាកសពអ្នកទោសនៅមន្ទីរម-១៣មានចម្ងាយ១០០ម៉ែត្រពីមន្ទីរ ដែលអ្នកទោសប្រមាណពី ២០០-៣០០នាក់ ត្រូវបានកម្ទេចនៅទីនោះ ។

**ចុងបញ្ចប់នៅមន្ទីរម-១៣**

ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ សុន សេន មិនបានមកពិនិត្យមើលមន្ទីរម-១៣ទេ ដោយសារគាត់ដឹកនាំកងទ័ពវាយសម្រុកផ្តាច់ព្រ័ត្រចូលទីក្រុងភ្នំពេញ ។ ហើយអ្នកទោសដែលនៅសល់ទាំងប៉ុន្មានត្រូវ ឌុច សួរចម្លើយបញ្ចប់ ហើយដាក់ក្នុងឃុំដដែល ។ រហូតដល់ថ្ងៃទី៣០ ខែមេសា សុន សេន បានឲ្យនិរសារមកហៅ ឌុច ទៅធ្វើការជាមួយគាត់ ។ ពេលនោះ សុន សេន បានឲ្យ ឌុច រាយការណ៍ពីចំនួនអ្នកទោសនៅក្នុងមន្ទីរម-១៣«ក» ។ ក្រោយពីដឹងចំនួនពិតប្រាកដ សុន សេន បានរាប់ឈ្មោះ បន្ទាប់មកបែងចែកយកទៅកម្ទេច ហើយនៅសល់ប៉ុន្មានត្រូវបញ្ជូនទៅមន្ទីរម-៩៩ ឬមន្ទីរនគរបាលតំបន់៣២ ។ ឆ្លៀតពេលនោះ ឌុច បានស្នើសុំដោះលែង ហម អ៊ីន ជាស្ពាន ប៉ុន្តែ សុន សេន បដិសេធ រួចបញ្ជាឲ្យបញ្ជូនយកទៅដាក់នៅមន្ទីរនគរបាលតំបន់៣២ ។ ចំពោះបុគ្គលិកនៅម-១៣ក សុន សេន បាន ប្រាប់ ឌុច ឲ្យយកមកភ្នំពេញទាំងអស់ លើកលែងតែនៅមន្ទីរ ម-១៣ «ខ» គាត់ឲ្យយកតែមិត្ត ស៊ុំ អនុប្រធានរបស់របស់ ឌុច តែម្នាក់ប៉ុណ្ណោះ នៅសល់ប៉ុន្មានត្រូវប្រគល់ឲ្យខាងមូលដ្ឋានជាអ្នកចាត់ចែង ចំណែកអ្នកទោសនៅមន្ទីរម-១៣ «ខ» ទាំងអស់ត្រូវបានដោះលែងឲ្យទៅភូមិវិញ ។

សុន សេន បានប្រាប់ឲ្យ ឌុច ជ្រើសរើសយកម៉ូតូម៉ាកយ៉ាម៉ាហា-៨០មួយគ្រឿងសម្រាប់ធ្វើដំណើរ ប៉ុន្តែគាត់ត្រូវរង់ចាំសេចក្តីសម្រេចពីថ្នាក់លើរហូតដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៥ ទើប ឌុច ផ្លាស់មកធ្វើការនៅភ្នំពេញ ។

**សោម ប៊ុនថន**

# កម្ពុជាប្រជាធិបតេយ្យ
# ក្រសួងការបរទេស

ភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨

សូមគោរពជូនឯកឧត្តម

**១)** រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យសូមធ្វើការកោតសរសើរយ៉ាងស្មោះស្ម័គ្រដល់រដ្ឋាភិបាលរបស់ឯកឧត្តមក៏ដូចជារដ្ឋាភិបាលនៃប្រទេសមិនចូលបក្សសម្ព័ន្ធដទៃទៀតដែលបានផ្តល់ការពិចារណាលើសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៧ ទាក់ទងនឹងសកម្មភាពឈ្លានពាន និងវាតទីនិយមដែលប្រព្រឹត្តដោយ «សាធារណរដ្ឋសង្គមនិយមវៀតណាម» មកលើរបបកម្ពុជាប្រជាធិបតេយ្យ ។

**២)** ឥរិយាបថរបស់ប្រទេសមិនចូលបក្សសម្ព័ន្ធគឺជាការជំរុញទឹកចិត្តដល់ប្រជាជននិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលកំពុងជម្នះរាល់ឧបសគ្គទាំងអស់ដើម្បីក្តាប់ឲ្យបាននូវស្ថានភាពគ្រប់បែបយ៉ាងនៅក្នុងកិច្ចថែរក្សានិងការពារឯករាជ្យភាពអធិបតេយ្យភាពនិងបូរណភាពដែនដីប្រទេសនិងសិទ្ធិដើម្បីធ្វើការសម្រេចចិត្តលើជោគវាសនារបស់ខ្លួននិងជោគវាសនាប្រទេសដោយខ្លួនឯង ។ សារសំខាន់នៃការតស៊ូបច្ចុប្បន្នរបស់ប្រជាជននិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមិនមានភាពខុសប្លែកគ្នានឹងការតស៊ូស្វែងរកសេរីភាពជាតិកាលពីប្រាំឆ្នាំមុន (១៩៧០ - ១៩៧៥) ដើម្បីប្រឆាំងនឹងសង្រ្គាមឈ្លានពានដែលប្រព្រឹត្តដោយពួកចក្រពត្តិអាមេរិកនៅអំឡុងពេលដែលប្រជាជនកម្ពុជាយើងបានស្ម័គ្រចិត្តធ្វើការលះបង់ដ៏អស្ចារ្យដើម្បីឯករាជ្យភាពជាតិរបស់ខ្លួន និងសម្រាប់ជ័យជម្នះតាមគោលការណ៍អព្យាក្រឹត ។ ការតស៊ូក្នុងពេលបច្ចុប្បន្នរបស់កម្ពុជា ពិសេសដើម្បីធ្វើយ៉ាងណាឲ្យរបបកម្ពុជាប្រជាធិបតេយ្យរស់រានមានជីវិត អភិវឌ្ឍន៍ និងឈានទៅរកប្រទេសមានឯករាជ្យភាព សន្តិភាព និងមិនចូលបក្សសម្ព័ន្ធ ។ កាលពីអតីតកាល ក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធបានគាំទ្រយ៉ាងសកម្មចំពោះបុព្វហេតុដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជា ។ ឥឡូវប្រទេសទាំងនេះបានបន្តធ្វើការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើសកម្មភាពឈ្លានពានរបស់វៀតណាមមកលើរបបកម្ពុជាប្រជាធិបតេយ្យ ។ ឥរិយាបថទាំងអស់នេះបានបន្តជំរុញទឹកចិត្តដល់ប្រជាជនកម្ពុជា យើងដែលជានិច្ចជាកាលប្រកាន់ខ្ជាប់នូវជំនឿយ៉ាងមុតមាំលើគោលការណ៍អព្យាក្រឹតភាពនិងបានពង្រឹងជំនឿទុកចិត្តយ៉ាងរឹងមាំទៅលើបុព្វហេតុត្រឹមត្រូវនិងជ័យជម្នះរបស់ប្រជាជនកម្ពុជា ។

**៣)** ក្នុងការនាំយកបញ្ហាជម្លោះរវាងកម្ពុជានិងវៀតណាមជម្រាបជូនជាការស្វែងយល់ដល់ឯកឧត្តម កម្ពុជាយើងមានបំណងចង់ជម្រាបជូនបញ្ហាថ្មីមួយទៀតស្តីអំពីការក្តោបក្តាប់ពីមុនរបស់យើងដល់ប្រទេសសម្ព័ន្ធមិត្តនិងប្រទេសមិនចូលបក្សសម្ព័ន្ធ ។ ជាក់ស្តែង កម្ពុជាបានស្វែងយល់យ៉ាងច្បាស់ថា សកម្មភាពរបស់កម្ពុជាកំពុងតែជួបនូវបញ្ហាលំបាកជាច្រើន ដូចជាការជ្រៀតជ្រែកនិងការអន្តរាគមន៍ដែលបង្កឡើងដោយពួកចក្រពត្តិនិយម ជនវាតទីនិយម និងបនបរិវាររបស់ពួកវា ដែលធ្វើការប្រឆាំងនឹងចលនាបដិវត្តន៍របស់យើង ។ យើងសុំលើកឡើងពីជម្លោះរវាងកម្ពុជានិងវៀតណាម ដើម្បីឲ្យប្រទេសសម្ព័ន្ធមិត្តធ្វើការស្វែងយល់ពីការពិតឲ្យកាន់តែច្បាស់ ។ កម្ពុជាបានប្រព្រឹត្តនូវឥរិយាបថនេះឡើងដើម្បីដើរតួជាសមាជិកដ៏បូងក្នុងចលនាមិនចូលបក្សសម្ព័ន្ធ ហើយកម្ពុជាប្រជាធិបតេយ្យមិនដែលដកខ្លួនចេញពីចលនារបស់ខ្លួនដែលជាប្រទេសអព្យាក្រឹតនិងមិនដែលចូលរួមក្នុងក្រុមណាមួយឡើយ ។ ជាងនេះទៅទៀត ដោយសារជានិច្ចជាកាលកម្ពុជាតែងតែប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ខ្ពស់ចំពោះគោលនយោបាយអព្យាក្រឹត កម្ពុជាតែងតែធ្វើការបដិសេធក្នុងការប្រើប្រាស់ឈ្មោះ «ប្រទេសអព្យាក្រឹត» ដើម្បីទាញយកផលប្រយោជន៍របស់ខ្លួន ។ កម្ពុជាប្រជាធិបតេយ្យសុំឲ្យចំណងក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធធ្វើការលះបង់ពេលវេលា និងបង្រួបបង្រួមកម្លាំងរបស់ខ្លួនដើម្បីតស៊ូប្រឆាំងនឹងចក្រពត្តិនិយម ជនវាតទីនិយម និងបនបរិវាររបស់ពួកវា ។ ដូច្នេះ នៅក្នុងការលើកឡើងពីជម្លោះរវាងកម្ពុជានិងវៀតណាម យើងសូមធ្វើការចៀសវាងលើការជ្រុលជ្រួសទាំង

ឡាយណាដែលរំខានដល់ប្រទេសសម្ព័ន្ធមិត្ត ។ ប៉ុន្តែក្នុងនាមជាសមាជិករបស់ក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធ ខ្ញុំមានកាតព្វកិច្ចដើម្បីជម្រាបជូនរដ្ឋាភិបាលរបស់ឯកឧត្តមស្តីអំពីដំណើរការវិវត្តដ៏ពិតប្រាកដនៃបញ្ហានេះ ក៏ដូចជាទស្សនៈយល់ឃើញ និងតួនាទីរបស់យើងផងដែរ ។

**៤)** ដូចដែលបានសង្កត់ធ្ងន់ក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៧ វៀតណាមបានបង្កើតគោលការណ៍យុត្តិសាស្ត្រពីមុនរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំមកហើយដើម្បីបង្កើត «សហព័ន្ធឥណ្ឌូចិន» គឺមានប្រទេសមួយ បក្សមួយ និងប្រជាជនមួយ ។ វៀតណាមចង់បង្ខំឲ្យកម្ពុជាចូលរួមក្នុង «សហព័ន្ធឥណ្ឌូចិន» ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។ ដោយផ្អែកទៅលើយុត្តិសាស្ត្រនយោបាយនេះអស់ពេលជាច្រើនឆ្នាំ ជាពិសេសក្នុងឆ្នាំ១៩៧៥ វៀតណាមបានអនុវត្តសកម្មភាពគ្រប់បែបយ៉ាង ទាំងលាក់លៀម និង បើកចំហតាមមធ្យោបាយសន្តិភាពឬប្រើកម្លាំងដើម្បីបង្ខំឲ្យកម្ពុជាចូលជាសមាជិកក្នុង «សហព័ន្ធឥណ្ឌូចិន» ដើម្បីធ្វើឲ្យខ្លួនអាចធ្វើជាម្ចាស់ និងលេបយកទឹកដីកម្ពុជាក្នុងរយៈពេលដ៏ជាក់លាក់មួយ ។

ប៉ុន្តែវៀតណាមបានទទួលរងនូវបរាជ័យក្នុង ៈ

◆ ផែនការអប់រំពី «មិត្តភាពពិសេស» និង «សាមគ្គីភាពវិសាមញ្ញ» ជាមួយនឹងកម្ពុជា ។

◆ សកម្មភាពស៊ើបការណ៍សម្ងាត់ និង វិទ្ធង្សនា

◆ ការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ខ្លួនមកលើកម្ពុជា

◆ ការរំលោភដោយផ្នែកយោធា និង ការទន្ទ្រានលុកលុយលើទឹកដីកម្ពុជានៅតាមខ្សែបន្ទាត់ព្រំដែន ។

បន្ទាប់ពីទទួលបរាជ័យរាល់ផែនការទាំងអស់នេះ វៀតណាមបានចាប់ផ្តើមបង្កើតការប្រយុទ្ធលុកលុយ និងរំលោភឈ្លានពានដែលមានទ្រង់ទ្រាយធំរបស់ខ្លួន ដោយស្តែងចេញចរិតលក្ខណៈអនុវត្តសង្គ្រាមដែលមិនប្រកាសជាមុនដើម្បីប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងខែកញ្ញា តុលា វិច្ឆិកា និង ខែធ្នូ ឆ្នាំ១៩៧៧ ហើយនៅដើមខែមករា ឆ្នាំ១៩៧៨ ។

**៥)** នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ កងទ័ពបដិវត្តន៍កម្ពុជាបានបោសសម្អាតកងទ័ពឈ្លានពានវៀតណាមនិងបានកម្ចាត់កងទ័ពវៀតណាមទាំងអស់ចេញពីទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក កងទ័ពបដិវត្តន៍ទាំងនេះបានធ្វើឲ្យវៀតណាមទទួលរងនូវបរាជ័យថ្មីមួយទៀត ។ ប៉ុន្តែ វៀតណាមនៅតែមិនបោះបង់ចោលនូវគោលនយោបាយយុត្តិសាស្ត្ររបស់ខ្លួនក្នុងការបង្ខំឲ្យកម្ពុជាចូលជាសមាជិកក្នុង «សហព័ន្ធឥណ្ឌូចិន» ដែលស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាម ។ នេះគឺជាហេតុផលដែលបន្ទាប់ពីថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៨ ស្ថានភាពជម្លោះរវាងកម្ពុជានិងវៀតណាមនៅតែមានភាពតានតឹងនៅឡើយ ។ វៀតណាមបានអនុវត្តសកម្មភាពយោធារបស់ខ្លួនដែលមានរៀបរាប់ដូចខាងក្រោម ៈ

◆ កងទ័ពវៀតណាមបានបន្តបាញ់កាំភ្លើងយន្ត ផ្លោងគ្រាប់ចូលក្នុងទឹកដីកម្ពុជា បញ្ជូនភ្នាក់ងារស៊ើបការណ៍សម្ងាត់តាមដែនទឹកនិងដែនគោក ដើម្បីប្រមូលព័ត៌មានក្នុងទឹកដីកម្ពុជា ហើយកងទ័ពវៀតណាមបានបន្តធ្វើការវាយប្រហាររបស់ខ្លួន និងទន្ទ្រានចូលយ៉ាងជ្រៅក្នុងទឹកដីកម្ពុជាតាមខ្សែបន្ទាត់ព្រំដែនចាប់ពីដែនសមុទ្ររហូតដល់ «កន្ទុយនាគ» ដែលជាតំបន់ស្ថិតនៅជាប់ប្រទេសកម្ពុជា និងព្រំដែនប្រទេសឡាវ ។

◆ ទន្ទឹមនឹងនោះ «សាធារណរដ្ឋសង្គមនិយមវៀតណាម» បានរៀបចំកងកម្លាំងយោធារបស់ខ្លួនយ៉ាងសកម្ម និងបានបញ្ជូនទាហានកងពលធំជាច្រើនឲ្យចូលមកបោះជំរំនៅតាមបណ្តោយព្រំដែន និងជុំវិញប្រទេសកម្ពុជាគ្រប់ទិសដៅទាំងអស់ដើម្បីអនុវត្តការប្រយុទ្ធលុកលុយ រំលោភឈ្លានពានដែលមានទ្រង់ទ្រាយធំប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៨ នេះ ។

ក្រៅពីនេះ វៀតណាមកំពុងអនុវត្តសកម្មភាពផ្តួលរំលំរដ្ឋាភិបាលកម្ពុជាជាសម្ងាត់ និង បើកចំហ ដោយជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ក្នុងគោលបំណងបង្កើតឲ្យមានការមិនព្រមព្រៀង និងប្រឆាំងនឹងប្រជាជនកម្ពុជា ។ នេះជាផ្នែកមួយនៃផែនការរបស់វៀតណាម ធ្វើឡើងក្នុងគោលបំណងបង្កើតនូវរបបដែលជាអាយ៉ងមួយនៅក្នុងប្រទេសកម្ពុជាដើម្បីប្រើប្រាស់របបនេះធ្វើជាឧបករណ៍សម្រាប់សកម្មភាពរំលោភឈ្លានពានរបស់ខ្លួន ។ វៀតណាមបានបន្តអនុវត្តសកម្មភាពរបស់ខ្លួនយ៉ាងសកម្មលើឆាកអន្តរជាតិដើម្បីបង្ខូចកេរ្តិ៍ឈ្មោះរបស់កម្ពុជាប្រជា

ធិបតេយ្យ ។ សូម្បីតែមេដឹកនាំជាន់ខ្ពស់វៀតណាមដែលគួរតែសម្តែងនូវភាពចាស់ទុំលើផ្នែកនយោបាយក៏បានបង្ខូចកេរ្តិ៍ឈ្មោះរបស់កម្ពុជាដោយគ្មានភាពអៀនខ្មាសក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់ខ្លួនទៅបរទេស ។ កម្ពុជាប្រជាធិបតេយ្យគឺជារបបមួយដែលប្រជាជនកម្ពុជាបានជ្រើសរើសដោយខ្លួនឯង ។ តើវៀតណាមគួរតែមានសិទ្ធិក្នុងការអនុវត្តសកម្មភាពបែបនេះដែរឬទេ?

**៦)** ក្រោយពីបរាជ័យរបស់ខ្លួនកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ នៅពេលដែលគោលបំណង «សហព័ន្ធឥណ្ឌូចិន» របស់ខ្លួនបានទទួលបរាជ័យម្តងទៀត និងដើម្បីក្តោបក្តាប់នូវរាល់សកម្មភាពឈ្លានពានដដែល និងគម្រោងការរៀបចំទន្ទ្រានលុកលុយ និងឈ្លានពានទ្រង់ទ្រាយធំរបស់ខ្លួន និងមានបំណងធ្វើឲ្យកម្ពុជាឯកោពីឆាកអន្តរជាតិវៀតណាមបានអនុវត្តនូវដំណើរការឃោសនា និងសកម្មភាពការទូតជាច្រើនទាក់ទងនឹង «ការដោះស្រាយបញ្ហាព្រំដែនតាមរយៈកិច្ចចរចា» ។ នៅពេលដែលប្រទេសវៀតណាមកំពុងពង្រឹងសកម្មភាពឃោសនាលើដំណើរការកិច្ចចរចារបស់ខ្លួន ។ កងទ័ពវៀតណាមបានពង្រឹងកម្លាំងវាយប្រហារកាន់តែខ្លាំងក្លាមកលើប្រទេសកម្ពុជា ។

កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដែលជាថ្ងៃមុនពេលដែលប្រទេសវៀតណាមបានប្រកាសស្នើរកកិច្ចចរចាកាំភ្លើងធំធុនធ្ងន់ផលិតនៅសូវៀត និងអាមេរិកគ្រប់ប្រភេទរបស់វៀតណាមបានចាប់ផ្តើមបាញ់ចូលក្នុងទឹកដីកម្ពុជានៅក្នុងតំបន់កោះធំដែលស្ថិតនៅទន្លេបាសាក់ក្រោម ភាគខាងត្បូងទីក្រុងភ្នំពេញ ។ ហើយទ័ពថ្មើរជើងនៃកងវរសេនាធំទាំងបួនរបស់វៀតណាមរួមជាមួយអន្តរាគមន៍ពីរថក្រោះមួយចំនួនធំ យន្តហោះ និងទូកម្ពាគចក្រជាច្រើនគ្រឿងបានធ្វើការវាយលុកតាមតំបន់នេះ ។

កាលពីថ្ងៃទី៥ , ៦ , ៧ និង ៨ ខែកុម្ភៈ ប្រទេសវៀតណាមបានបន្តការវាយប្រហាររបស់ខ្លួននៅតាមតំបន់ទន្លេបាសាក់ក្រោម ហើយនៅទីកន្លែងជាច្រើនទៀតក្នុងខេត្តស្វាយរៀង ។

រាល់សកម្មភាពទាំងអស់នេះបានបង្ហាញថា ការស្នើសុំ «កិច្ចចរចា» ដែលវៀតណាមបាននឹងកំពុងអនុវត្តដំណើរការឃោសនាលើឆាកអន្តរជាតិ គឺមិនពិតប្រាកដទាល់តែសោះ ។ ការស្នើសុំសម្រាប់កិច្ចចរចារួមជាមួយនឹងសកម្មភាពយោធាលើសមរភូមិ និងសកម្មភាពនយោបាយនៃការផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យរបស់វៀតណាមទាំងអស់នេះបានបង្ហាញថាស្ថានភាពបច្ចុប្បន្នមិនមានភាពខុសប្លែកគ្នាពីស្ថានភាពដែលកើតមានឡើងមុនពេលការវាយប្រហារឈ្លានពានទ្រង់ទ្រាយធំរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យកាលពីចុងឆ្នាំ១៩៧៧នោះទេ ។ នៅពេលដែលវៀតណាមកំពុងតែបន្តសកម្មភាពរំលោភឈ្លានពានលើកម្ពុជា និងបញ្ជូនទាហានកងពលតូចរបស់ខ្លួនឲ្យត្រៀមខ្លួនរួចជាស្រេចនៅតាមទិសដៅជាច្រើនសម្រាប់ការវាយប្រហារជាទ្រង់ទ្រាយធំមកលើកម្ពុជា វៀតណាមបានធ្វើការស្នើសុំសម្រាប់កិច្ចចរចាជាមួយកម្ពុជា ។ តើវៀតណាមចង់ឲ្យកម្ពុជាចរចាពីអ្វី?

**៧)** កម្ពុជាប្រជាធិបតេយ្យមិនដែលធ្វើការបដិសេធលើគោលការណ៍ដោះស្រាយបញ្ហាជាមួយវៀតណាមដោយសន្តិវិធីនោះទេ ។ ដូចដែលបានសង្កត់ធ្ងន់នៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៧៧ ហើយដែលមាននៅក្នុងឯកសារផ្លូវការរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីឆ្នាំ១៩៧៥ កម្ពុជាបានជ្រើសយកនូវវិធីសាស្ត្រដ៏ជាក់លាក់ដើម្បីដោះស្រាយបញ្ហាជាមួយនឹងវៀតណាម ។

នៅខែមិថុនា ឆ្នាំ១៩៧៥ ដោយសារតែនៅពេលដែលវៀតណាមកំពុងធ្វើការឈ្លានពាននិងក្តោបក្តាប់បាននូវតំបន់កោះរបស់កម្ពុជាមានឈ្មោះថាកោះវៃ និងដែលកម្ពុជាបានជួបប្រទះនូវបញ្ហាដ៏លំបាកជាច្រើនបន្ទាប់ពីសង្គ្រាមផ្ទៃក្នុង មេដឹកនាំជាន់ខ្ពស់របស់កម្ពុជា រួមមានលេខាធិការ អនុលេខាធិការនៃគណៈកម្មការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការបរទេសបានដឹកនាំគណៈប្រតិភូមួយក្រុមទៅកាន់ទីក្រុងហាណូយ ដើម្បីធ្វើការចរចាដោះស្រាយបញ្ហាព្រំដែនជាមួយវៀតណាម ។

នៅខែឧសភា ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានអញ្ជើញគណៈប្រតិភូវៀតណាមមកចូលរួមកិច្ចចរចាដើម្បីដោះស្រាយបញ្ហាព្រំដែននៅទីក្រុងភ្នំពេញ ។

ស្របពេលជាមួយគ្នានោះផងដែរ ដោយមានបំណងដោះស្រាយបញ្ហាដោយសន្តិភាព កម្ពុជាប្រជាធិបតេយ្យបានព្យាយាមរក្សានូវទំនាក់ទំនងធម្មតាជាមួយនឹងវៀតណាមតាមរយៈគណៈកម្មការទំនាក់ទំនងថ្នាក់មជ្ឈិម ថ្នាក់តំបន់ និង ថ្នាក់ស្រុក ។

ប៉ុន្តែវៀតណាមនៅតែមិនអើពើនឹងបំណងល្អរបស់កម្ពុជាឡើយ បែរជាសម្តែងនូវអាកប្បកិរិយាដែលផ្ទុយពីសេចក្តីថ្លែងការណ៍របស់ខ្លួនធ្វើឡើងកាលពីឆ្នាំ១៩៦៦ និង ១៩៦៧ ដែលបានទទួលស្គាល់លើខ្សែបន្ទាត់ព្រំដែនបច្ចុប្បន្នរបស់កម្ពុជា និងដែលសន្យាថានឹងគោរពខ្លឹមសារនៃសេចក្តីថ្លែងការណ៍ទាំងនោះ ។ វៀតណាមបានពង្រឹងសកម្មភាពយោធារបស់ខ្លួនលើកម្ពុជានៅតាមខ្សែបន្ទាត់ព្រំដែន ។ វៀតណាមបានប្រើប្រាស់មិត្តភាពបើកចំហតាមរយៈគណៈកម្មការទំនាក់ទំនង ដើម្បីអនុវត្តនូវសកម្មភាពវិទ្ធង្សនា ស៊ើបការណ៍សម្ងាត់ និងផែនការសម្ងាត់ ការញុះញង់ឲ្យមានការបះបោរ និងការព្យាយាមធ្វើរដ្ឋប្រហារផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ខែមេសា ឆ្នាំ១៩៧៦ ខែកញ្ញា ឆ្នាំ១៩៧៧ និង ខែកញ្ញា ឆ្នាំ១៩៧៧ ។

ទោះបីជាស្ថិតនៅក្នុងស្ថានភាពតានតឹងយ៉ាងណាក៏ដោយ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ កម្ពុជាក៏នៅតែធ្វើការស្នើសុំថាភាគីទាំងពីរគួរតែ ៈ

- ចៀសវាងទំនាស់ដោយប្រើអាវុធនៅតាមបណ្តោយព្រំដែនគោក និងដែនទឹក ។
- បេ្តជ្ញាដាច់ខាតមិនអនុវត្តនូវសកម្មភាពស៊ើបការណ៍សម្ងាត់ ការរំលោភបូរណភាពទឹកដី ការបាញ់កាំភ្លើង គ្រាប់ផ្លោងឬក៏សកម្មភាពរំលោភលើផ្លូវអាកាស ការទម្លាក់គ្រាប់បែក ការធ្វើវិទ្ធង្សនា និងជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក ។
- ហាមមិនឲ្យមានការដាក់កងទ័ពនៅចម្ងាយតិចជាង៥០០ ទៅ១០០០ម៉ែត្រពីព្រំដែន បច្ចុប្បន្នដើម្បីចៀសវាងជម្លោះប្រដាប់អាវុធ ។
- ត្រូវតែអប់រំទាហាន និងប្រជាជនប្រុសស្រីនៃភាគីនីមួយៗ ឲ្យយល់ច្បាស់ពីគោលការណ៍ មិត្តភាព និង សាមគ្គីភាព ការគោរពគ្នាទៅវិញទៅមក ភាពស្មើគ្នា និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ការគោរពឯករាជ្យភាព អធិបតេយ្យភាព និង បូរណភាពទឹកដីគ្នាទៅវិញទៅមក ។

ការស្នើសុំរបស់កម្ពុជាទាំងអស់នេះត្រូវបានធ្វើឡើងក្នុងគោលបំណងបង្កើតនូវបរិយាកាសស្រុះស្រួលគ្នា និង ជឿទុកចិត្តគ្នាទៅវិញទៅមកដែលអំណោយផលដល់ការជួបប្រជុំនៅថ្ងៃខាងមុខ ។ ប៉ុន្តែ វៀតណាមនៅតែមិនធ្វើការឆ្លើយតបទៅនឹងសំណើទាំងនេះដដែល ។ ផ្ទុយទៅវិញ កាលពីដើមខែ កក្កដា ឆ្នាំ១៩៧៧ វៀតណាមបានបន្តពង្រឹងសកម្មភាពឈ្លានពានរបស់ខ្លួនមកលើកម្ពុជា ។ កម្ពុជាមិនដែលប្រកាសជាសាធារណៈពីសកម្មភាពឈ្លានពានរបស់វៀតណាមទេ ដោយសារតែកម្ពុជាចង់ដោះស្រាយបញ្ហាដែលកើតឡើងនេះដោយសន្តិវិធីនិងស្មោះត្រង់ ។ ប៉ុន្តែសម្រាប់ភាគីវៀតណាមវិញ វៀតណាមបានអនុវត្តសកម្មភាពការទូតដែលធ្វើឡើងដើម្បីបន្លំចកេរ្តិ៍ឈ្មោះ និងដាក់គម្លាតកម្ពុជាឲ្យនៅឆ្ងាយពីឆាកអន្តរជាតិ ។ ក្រោយពីទស្សនៈពិភពលោកបានយល់ច្បាស់ពីបញ្ហានេះ វៀតណាមបានចាប់ផ្តើមការវាយប្រហារទន្រ្ទាននិងឈ្លានពានទ្រង់ទ្រាយធំដែលស្តែងចេញនូវលក្ខណៈនៃសង្រ្គាមមិនប្រកាសជាមុនតាំងពីខែកញ្ញា ឆ្នាំ១៩៧៧ មកម្ល៉េះ ។

ទាក់ទងនឹងគោលដៅនៃការវាយប្រហារ ទន្រ្ទាន និង ឈ្លានពានទ្រង់ទ្រាយធំរបស់ខ្លួននៅចុងឆ្នាំ១៩៧៧ វៀតណាមបានអនុវត្តគម្រោងការមួយដែលធ្វើឡើងក្នុងគោលបំណងប្រមូលផ្តុំប្រជាជនកម្ពុជាឲ្យធ្វើរដ្ឋប្រហារនៅក្នុងឆ្នាំ១៩៧៨ ។ រដ្ឋប្រហារនេះរួមមានការវាយប្រហារពីខាងក្រៅអាចនឹងឲ្យវៀតណាមគ្រប់គ្រងកម្ពុជាបានភ្លាមតែម្តង ។ រហូតមកដល់បច្ចុប្បន្ន ទោះបីជាបានទទួលបរាជ័យពេលថ្មីនេះក៏ដោយ ក៏វៀតណាមនៅតែរឹងចចេសអនុវត្តនូវគម្រោងការរបស់ខ្លួនដដែល ។

ដូច្នេះហើយ កម្ពុជាប្រជាធិបតេយ្យបានអត់ធ្មត់ ហើយជាលទ្ធផលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី ដោយឈរលើស្មារតីមិត្តភាព និងសាមគ្គីភាព ។

**៨)** ឫសគល់នៃជម្លោះរវាងកម្ពុជានិងវៀតណាមគឺមិនមែនបញ្ហាព្រំដែនធម្មតានោះទេ ។ ប្រសិនបើវាជាបញ្ហាព្រំដែនធម្មតាចុះហេតុអ្វីបានជានៅចុងឆ្នាំ១៩៧៧នេះ កងទ័ពវៀតណាមបានទន្រ្ទាននិងឈ្លានពានចូលមកយ៉ាងជ្រៅក្នុងទឹកដីកម្ពុជារហូតដល់ទី

ប្រជុំជនក្នុងស្រុក ដែលទីតាំងនេះស្ថិតនៅចម្ងាយ៣០គីឡូម៉ែត្រពីបន្ទាត់ព្រំដែន? ប្រសិនបើវាជាបញ្ហាព្រំដែនធម្មតា ចុះហេតុអ្វីបានជាកងទ័ពវៀតណាមបានកម្ទេចចោលនូវអំណាចរដ្ឋរបស់ប្រជាជនកម្ពុជា ហើយបានបង្កើតក្រុមឈ្លានពាននៅគ្រប់ទីកន្លែងដែលពួកគេបានទៅដល់? ហើយហេតុអ្វីបានជាវៀតណាមអនុវត្តសកម្មភាពយ៉ាងច្រើនក្នុងបំណងផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យបច្ចុប្បន្ន? ព្រំដែនកម្ពុជា-វៀតណាម បច្ចុប្បន្នជាលទ្ធផលដ៏អាក្រក់នៃសកម្មភាពឈ្លានពាន វាតទីនិយមដែលប្រព្រឹត្តដោយចក្រពត្តិនិយម អាណានិគមនិយម សក្តិភូមិវៀតណាម និង បនប្រតិកិរិយា និង ជនជាតិបរទេសដទៃទៀត ។ ប៉ុន្តែ ជម្លោះព្រំដែននេះពិតជាបានកើតមានយ៉ាងប្រាកដមែន ។ តាមរយៈសកម្មភាពឈ្លានពាននិងវាតទីក្នុងអំឡុងពេលនោះ ប្រជាជនកម្ពុជាបានបាត់បង់នូវទឹកដីរាប់ពាន់គីឡូម៉ែត្រការ៉េ ដូចជាទឹកដីកម្ពុជាក្រោមនិងកោះជាច្រើន រួមទាំងតំបន់ទឹកមួយចំនួនផងដែរ ។ ប៉ុន្តែ ប្រជាជនកម្ពុជាមិនដឹកកកាយរឿងរ៉ាវចាស់ៗពីមុនទាំងអស់នោះទេ ។ ប្រជាជនកម្ពុជាចង់តែរស់នៅដោយសន្តិភាព កិត្តិយស និងសេចក្តីថ្លៃថ្នូរតាមរយៈការគ្រប់គ្រងលើបូរណភាពដែនគោក និងដែនទឹករបស់ខ្លួនដែលមានក្នុងព្រំដែនបច្ចុប្បន្នដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារប្រវត្តិសាស្ត្រ អត្ថបទ និង ផែនទីៗ នៅអំឡុងកិច្ចចរចាររវាងកម្ពុជានិងរណសិរ្សប្រជួបប្រជុំមជាតិរបស់វៀតណាមខាងត្បូងកាលពីខែសីហា និង កញ្ញា ឆ្នាំ១៩៦៦ ក្នុងសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់គណៈកម្មការមជ្ឈិមនៃរណសិរ្សប្រជួបប្រជុំមជាតិវៀតណាមខាងត្បូងចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៦៧ និងនៅក្នុងសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦៧ វៀតណាមបានប្រកាសយ៉ាងម៉ឺងម៉ាត់ថានឹងទទួលស្គាល់ ហើយសន្យាថានឹងគោរពព្រំដែនបច្ចុប្បន្នរបស់កម្ពុជា ។ ចុះហេតុអ្វីបានជាឥឡូវនេះវៀតណាមបដិសេធមិនគោរពតាមការសន្យារបស់ខ្លួន?

**៩)** ដូចដែលបានសង្កត់ធ្ងន់យ៉ាងច្បាស់លាស់ក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ បុសគល់ពិតប្រាកដនៃជម្លោះរវាងកម្ពុជា និងវៀតណាមកើតចេញពីមហិច្ឆតារបស់វៀតណាមដើម្បីលេបយកទឹកដីកម្ពុជានិងអនុវត្តគោលនយោបាយបង្ខំឲ្យកម្ពុជាចូលរួមក្នុង «សហព័ន្ធឥណ្ឌូចិន» ដែលស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាមដើម្បីឲ្យខ្លួនអាចធ្វើជាអ្នកគ្រប់គ្រងលើកម្ពុជាក្នុងរយៈពេលមួយដ៏ជាក់លាក់ ហើយនិងដើម្បីសម្រេចនូវមហិច្ឆតារបស់ខ្លួនក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ជម្លោះនេះអាចដោះស្រាយបានលុះត្រាតែបុសគល់នេះត្រូវបានកាត់ផ្តាច់ចោល ។ ប្រសិនបើវៀតណាមបោះបង់ចោលនូវមហិច្ឆតានិងគោលនយោបាយដ៏អាក្រក់របស់ខ្លួន វៀតណាមបញ្ឈប់សកម្មភាពឈ្លានពាន វាតទី និងលេបយកទឹកដីកម្ពុជា ហើយប្រសិនបើវៀតណាមគោរពសកម្មភាពឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យដោយពិតប្រាកដ និងគោរពសិទ្ធិប្រជាជនកម្ពុជា ដែលធ្វើការសម្រេចចិត្តដោយខ្លួនឯងពីជោគវាសនារបស់ខ្លួននិងជោគវាសនារបស់ប្រទេសខ្លួនដោយឯករាជ្យ និងអធិបតេយ្យភាព នោះជម្លោះនេះនឹងមិនអាចកើតមាននោះទេ ។ មិត្តភាពដ៏ពិតប្រាកដច្បាស់ជានឹងកើតមានឡើង ដើម្បីពង្រឹងនិងអភិវឌ្ឍ ។ នេះគឺជាគោលបំណងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ប្រទេសនិងប្រជាជនដ៏តូចនេះមិនដែលមានកងទ័ពនៅក្នុងប្រទេសដទៃឡើយ ប្រទេសនេះត្រូវការតែពេលវេលានិងសន្តិភាពសម្រាប់ការកសាងជាតិ និងអភិវឌ្ឍន៍ជីវភាពរស់នៅប្រជាជនរបស់ខ្លួនតែប៉ុណ្ណោះ ។ ប្រទេសនេះមិនមានហេតុផលផ្សេងដើម្បីបង្កចលាចលដល់នរណាម្នាក់ឡើយ ហើយគ្រាន់តែសុំរស់ដោយសន្តិភាព កិត្តិយសនិងសេចក្តីថ្លៃថ្នូរដោយឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីប៉ុណ្ណោះ ។

**១០)** បច្ចុប្បន្ន រាល់ពេលដែលគ្មានមុខសញ្ញាណាមួយដែលវៀតណាមអាចនឹងបង្កនូវបរិយាកាសល្អក់កករនៅតាមព្រំដែននោះកម្ពុជាយើងត្រូវតែប្រកាន់ខ្ជាប់នូវការឃ្លាំមើលជាប្រចាំ ។ ក្នុងការបំពេញតួនាទីរបស់ខ្លួនដើម្បីការពារប្រយោជន៍ដ៏សំខាន់និងដ៏ពិសិដ្ឋរបស់ខ្លួន កម្ពុជាប្រជាធិបតេយ្យក៏បានយល់យ៉ាងច្បាស់ពីទំនួលខុសត្រូវនិងកាតព្វកិច្ចរបស់ខ្លួនលើដំណើរការអព្យាក្រឹតភាពរបស់ពួកយើង ។ កម្ពុជាប្រជាធិបតេយ្យជឿជាក់ថា ការតស៊ូបច្ចុប្បន្នគឺជាការខបត្ថម្ភមួយដ៏សមរម្យដើម្បីពង្រឹងឯករាជ្យភាព

អធិបតេយ្យភាព និងសន្តិភាពក្នុងតំបន់អាស៊ីអាគ្នេយ៍ និងក្នុងពិភពលោកប្រឆាំងនឹងមហិច្ឆតារបស់ចក្រពត្តិនិយម វាតទីនិយម និងបនបរិវាររបស់វា ។ ការតស៊ូនេះបានដើរតួយ៉ាងសំខាន់នៅក្នុងការពង្រឹងគោលការណ៍មិនចូលបក្សសម្ព័ន្ធ ។

សូមឯកឧត្តមទទួលយកនូវការអះអាងដោយឈរលើការពិចារណាយ៉ាងហ្មត់ចត់របស់យើងខ្ញុំ ។ ហត្ថលេខាៈ អៀង សារី

ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស

**ឯកសារ D២៩០៥៣**

---

***(តមកពីទំព័រទី១)***

ឌុច បានបន្ថែមទៀតថា បើសិនជា នង ចាន់ផល និងម្តាយបានមកដល់មន្ទីរស-២១មែន អ្នកទាំងពីរពិតជាមិនមានឱកាសរស់រានមានជីវិតមកដល់សព្វថ្ងៃនេះទេ ។

រាល់អ្នកទោសដែលបានចូលដល់មន្ទីរស-២១ត្រូវបានបង្ខាប់ឲ្យថតរូបធ្វើប្រវត្តិរូបនិងសួរចម្លើយ ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជា ឌុច បាននិយាយថា បើសិនមិនបានឃើញប្រវត្តិរូបម្តាយ នង ចាន់ផល ទេ គាត់មិនអាចទទួលស្គាល់ថា នង ចាន់ផល ពិតជាអតីតអ្នកទោសនៅមន្ទីរស-២១ទេ ។ ជាអកុសល នៅពេលសវនាការនោះ ប្រវត្តិរូបម្តាយរបស់ នង ចាន់ផល មិនទាន់បានរកឃើញនៅឡើយទេ ។

ដើម្បីបង្ហាញព្រឹត្តិការណ៍ប្រវត្តិសាស្ត្រឲ្យឃើញកាន់តែច្បាស់ បុគ្គលិកពីររូប (ហ៊ិន សុធានី និង សុខ វណ្ណៈ) របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំរុករកប្រវត្តិរូបម្តាយរបស់ នង ចាន់ផល ហើយក៏បានឃើញប្រវត្តិនោះប្រាកដមែន រួចក៏បានដាក់ជូនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាភ្លាមៗដែរ ។

ក្រោយពីទទួលបានឯកសារនេះភ្លាម សហព្រះរាជអាជ្ញាបានប្រកាសពីដំណឹងល្អនេះភ្លាមៗដែរ ។ ប្រវត្តិរូបដែលបានរកឃើញថ្មីនេះបង្ហាញថា ម្តាយរបស់ នង ចាន់ផល ឈ្មោះ មុំ យ៉ូវ គឺជាអ្នកទោសចុងក្រោយគេបង្អស់ដែលបានមកដល់មន្ទីរស-២១ នេះនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ មុននឹងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពវៀតណាមបានមកដល់ទីក្រុងភ្នំពេញ ។ លោក ឆាំង យុ បានបន្តទៀតថា នង ចាន់ផល គឺជាកុមារដែលត្រូវបានរកឃើញដំបូងគេដោយកងទ័ពវៀតណាម ។

ស្របពេលដែល ឌុច មិនទទួលស្គាល់ នង ចាន់ផល ជាអតីតអ្នកទោសមន្ទីរស-២១ ហើយជាការមួយដែលមិនផ្តល់តម្លៃដល់សាក្សីរស់និងប្រវត្តិសាស្ត្រនោះ លោក ឆាំង យុ ក៏បានរិះគន់ដល់ក្រុមស៊ើបអង្កេតសាលាក្តីខ្មែរក្រហមដែលមិនបានធ្វើការស៊ើបអង្កេតឲ្យបានគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ។

លោក ឆាំង យុ បានបន្ថែមទៀតថា ឯកសារនេះពិបាកនឹងធ្វើឲ្យ ឌុច បដិសេធណាស់ ហើយ ឌុច ក៏បានទទួលស្គាល់ថាម្តាយរបស់ នង ចាន់ផល ហើយនិង នង ចាន់ផល ពិតជាអ្នកធ្លាប់ជាប់ឃុំឃាំងនៅមន្ទីរស-២១មែន ។



ទាហានវៀតណាម និង កុមារដែលរួចផុតជីវិតពីគុកទួលស្លែង

ក្រោយពីប្រវត្តិរូបម្តាយរបស់ ចាន់ផល ត្រូវបានដាក់បង្ហាញជូននៅចំពោះមុខជនជាប់ចោទ ឌុច និងអ្នករងគ្រោះដោយរបបខ្មែរក្រហម ឌុច ក៏បានបន្ទន់កាយវិការចំពោះភស្តុតាង ដែលទើបបានរកឃើញ ហើយធ្វើការសុំទោស នង ចាន់ផល នៅចំពោះមុខសហចៅក្រមជាតិនិងអន្តរជាតិ ព្រមទាំងប្រជាជនកម្ពុជារាប់លាននាក់រួចទទួលស្គាល់ប្រវត្តិរូបនេះថាបានធ្វើឡើងនៅមន្ទីរស-២១ ។

**ញាណ សុជាតិ**

# យុត្តិធម៌មូលដ្ឋាន

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងក្នុងគោលបំណងនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរមកធ្វើការកាត់ទោស ។ ដោយសារតែមើលឃើញពីសារសំខាន់នៃកិច្ចការរបស់តុលាការ ទើបធ្វើឲ្យតុលាការនេះត្រូវបានគេឃ្លាំមើលយ៉ាងជិតដល់ដើម្បីធានានូវដំណើរការយុត្តាធិការរបស់អង្គជំនុំជម្រះនេះអាចនាំមកនូវយុត្តិធម៌ដែលប្រជាជនខ្មែរ និងប្រជាជនទូទាំងសកលលោកអាចទទួលយកបាន ។

ដោយសារតែជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការការពារយុត្តិធម៌ ទើបក្នុងខែឧសភាឆ្នាំនេះ ប្រជាជន៦០នាក់ មកពីភូមិពាម ខេត្តកំពង់ឆ្នាំង បានលះបង់នូវពេលវេលាដ៏មមាញឹករបស់គេមកចូលរួមសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការមិនធ្វេសប្រហែសក្នុងការចូលរួមរបស់អ្នកភូមិនេះកើតចេញពីស្ថានភាពដ៏គួរឲ្យភ័យខ្លាច ដែលគាត់បានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមានការបង្ខំឲ្យធ្វើការហួសកម្លាំង ការហូបមិនគ្រប់គាន់ និងការសម្លាប់រង្គាល ។ ប្រជាជននៅក្នុងភូមិទាំងអស់ត្រូវបានគេធ្វើបាបនិងសម្លាប់ជាលក្ខណៈប្រព័ន្ធ ។ ដោយសារតែបទពិសោធន៍ដែលមិនអាចបំភ្លេចបានទាំងនេះហើយ ទើបធ្វើឲ្យអ្នកភូមិពាមមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការចូលរួមមើលដំណើរការសវនាការរបស់អតីតមេដឹកនាំខ្មែរក្រហម ។

អ្នកភូមិពាមភាគច្រើនមកចូលរួមសវនាការរបស់អង្គជំនុំជម្រះលើកទី១ ដោយមានការអញ្ជើញពីគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបង្កើតឡើងដើម្បីលើកទឹកចិត្តឲ្យមានចូលរួមអង្កេតក្នុងតុលាការ ដើម្បីជួយអ្នកឲ្យភូមិយល់ដឹងពីកិច្ចការពាយ៉ាង ៖ ស្វែងយល់ពីតុលាការ ពាំនាំនូវព័ត៌មានដែលទទួលបានទៅចែករំលែកជាមួយអ្នកជិតខាងក្នុងសហគមន៍របស់គេ និងដើម្បីឲ្យអ្នកភូមិមានឱកាសបញ្ចេញមតិទាក់ទងទៅនឹងសំណាងសមូហភាព ដែលប្រហែលជានឹងអាចផ្តល់ឲ្យប្រជាជនក្នុងលក្ខណៈជាផ្នែកមួយនៃកេរដំណែលរបស់សាលាក្តី ។

**ឧក្រិដ្ឋកម្មប្រឆាំងទៅនឹងអ្នកភូមិពាម**

របបខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យបានកាន់កាប់អំណាចនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ចលនានៃលទ្ធិម៉ៅជ្រុលនិយមបានប្រែក្លាយប្រទេសទាំងមូលឲ្យទៅជាសង្គមកសិកម្ម ។ អាក្រក់ជាងនេះទៅទៀត របបនេះបានអនុវត្តនូវគោលការណ៍សម្លាប់រង្គាលចំពោះអ្នករដ្ឋការចាស់នៃរបបមុនរួមមាន បញ្ញវន្ត គ្រូបង្រៀន និងជនទាំងឡាយណាដែលគេយល់ថាជាសត្រូវ ។ ចំនួនឧក្រិដ្ឋកម្មដែលកើតឡើងគឺខុសគ្នាពីកន្លែងមួយទៅកន្លែងមួយ ។

នៅក្នុងបទសម្ភាសន៍មួយជាមួយនឹងតំណាងអ្នកភូមិ៤រូប គាត់បាននិយាយរៀបរាប់ឡើងវិញពីការគាបសង្កត់ និងការសម្លាប់ជាប្រព័ន្ធចំពោះអ្នកភូមិពាម ។ ក្រោយពីសកម្មភាពឧទ្ទាមមិនបានសម្រេចនៅក្នុងឆ្នាំ១៩៧៦ អ្នកទាំងនោះត្រូវបានចោទប្រកាន់ និងចោទថាជាសត្រូវនៃរបបនេះ ។ ម៉ៅ ពៅ និង សួស សាលីម ជាប្រធានភូមិបាននិយាយថា នោះគឺជាចលនា «ខ្មែរស» ក្នុងគោលបំណងប្រឆាំងនឹងការសម្រេចចិត្តរបស់ខ្មែរក្រហមក្នុងការបិទផ្សារ សាលារៀន ហាមប្រាមការគោរពសាសនា និងការចាយវាយក្រដាសប្រាក់ ។ ជាពិសេស គឺប្រឆាំងទៅនឹងការរឹបអូសទ្រព្យសម្បត្តិឯកជនដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជារបស់រួម ។

ចលនានេះត្រូវបានចាត់វិធានការលុបបំបាត់ ជាពិសេសអ្នកដែលខ្មែរក្រហមចោទថាជាមេខ្លោងរួមមាន ហ៊ូ នឹម និង ហ៊ូ យន់ ត្រូវបានចាប់ខ្លួននិងសម្លាប់ចោល ។ ចំណែកឯអ្នកភូមិពាមវិញត្រូវរត់ភៀសខ្លួនចូលទៅក្នុងព្រៃដើម្បីចៀសវាងការចាប់ខ្លួន ។ សាលីម ជាអ្នករត់គេចខ្លួនម្នាក់ក្នុងចំណោមអ្នករត់គេចខ្លួនទាំងអស់បានរៀបរាប់ថា គាត់បានចំណាយពេលតែមួយថ្ងៃប៉ុណ្ណោះក្នុងការលាក់ខ្លួននៅក្នុងព្រៃដោយសារតែខ្វះស្បៀងអាហារ ។



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាពន្យល់អ្នកភូមិអំពីដំណើរការតុលាការខ្មែរក្រហម

ពេលដែលគាត់ត្រឡប់មកផ្ទះវិញគឺបានត្រឹមតែដឹងថាបងប្អូន ក្មួយប្រុសស្រី និងឪពុកម្ដាយរបស់គាត់ត្រូវបានសម្លាប់អស់ហើយ ។ បងប្អូនរបស់ ពៅ និងពូៗរបស់គាត់បានទទួលរងទុក្ខវេទនាដូចគ្នានឹងសមាជិកគ្រួសាររបស់ សាលីម ដែរ ។ ទាំង ពៅ និង សាលីម សុទ្ធតែបានប្រាប់ថា អ្នករត់គេចខ្លួនភាគច្រើនត្រូវបានខ្មែរក្រហមបាញ់សម្លាប់ ឬ ស្លាប់ដោយការអត់ឃ្លាន ។

ការរត់គេចខ្លួននិងការស្លាប់នៅក្នុងព្រៃមិនមានន័យថាខ្មែរក្រហមបានទុកជីវិតឲ្យសមាជិកក្រុមគ្រួសារនិងអ្នកភូមិពាមទាំងអស់នោះទេ ។ ពៅ បាននិយាយថា អ្នកភូមិត្រូវបានជម្លៀសឲ្យទៅនៅសហករណ៍ផ្សេង ហើយត្រូវបានគេធ្វើបាបនិងសម្លាប់ជាបន្តបន្ទាប់ ។

អ៊ំស្រី ប្រាក់ រ៉ាន អាយុ៥៨ឆ្នាំ បានក្លាយជាជនរងគ្រោះម្នាក់ក្នុងចលនានោះ ។ គាត់ត្រូវបានចោទប្រកាន់ថាជាអ្នកនាំយកស្បៀងអាហារទៅឲ្យអ្នករត់គេចខ្លួន ។ ស្ត្រីភាគច្រើននៅក្នុងភូមិត្រូវបានជាប់ឈ្មោះថាជាប្រពន្ធរបស់សមាជិកខ្មែរស ។ អ៊ំស្រី រ៉ាន បានរៀបរាប់វិធានការដែលដឹកនាំដោយខ្មែរក្រហមដើម្បីកម្ទេចក្រុមគ្រួសាររបស់គាត់ ។ អ៊ំស្រីត្រូវបានឃុំខ្លួនរហូតដល់ឆ្នាំ១៩៧៨ នៅក្នុងគុកខ្ទាប់ដែលជាមន្ទីរសន្តិសុខធំមួយសម្រាប់ដាក់អ្នកភូមិពាម ។ នៅពេលថ្ងៃ គាត់ត្រូវបានឆ្មាំគុកឲ្យធ្វើការធ្ងន់ៗ ហើយនៅពេលយប់ គាត់ត្រូវបានគេសួរចម្លើយ ធ្វើទារុណកម្មនិងចាក់សោឃុំក្នុងគុក ។

អ៊ំស្រី សោម ស៊ីម គឺជាស្ត្រីម្នាក់ទៀតដែលមានជោគវាសនាដូចគ្នានឹងអ៊ំស្រី រ៉ាន ដែរ ។ ប្ដីរបស់គាត់ត្រូវបានចាប់ខ្លួននៅពេលដែលគាត់កំពុងភ្ជួរស្រែ ។ បន្ទាប់មក គាត់ក៏ត្រូវបានខ្មែរក្រហមសម្លាប់ភ្លាម ។ អ៊ំស្រី ស៊ីម បាននិយាយថា ៖

«គេជម្លៀសខ្ញុំទៅនៅភូមិពាមខាងត្បូង ហើយឲ្យខ្ញុំធ្វើស្រែ ។ បន្ទាប់មកខ្ញុំនិងកូនក៏ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦ ដោយសារតែខ្មែរក្រហមចោទកូនខ្ញុំថាលួចដំឡូង ។ ខ្ញុំជាប់ឃុំក្នុងគុកខ្ទាប់អស់រយៈពេល ៥ខែ ។ កូនៗរបស់ខ្ញុំត្រូវបានយកទៅសម្លាប់ចោល ដោយសារតែពួកវាមិនចេះធ្វើការ ។ ខ្មែរក្រហមនិយាយថា ឲ្យវានៅរស់ធ្វើអីបង្ហិនតែបាយ» ។

យោងទៅតាមអ្នកតំណាងអ្នកភូមិខាងលើ មានប្រជាជនជាច្រើនត្រូវបានសម្លាប់ ហើយភូមិទាំងមូលដូចជាភូមិច្រកកូវត្រូវបានបោះបង់ចោល ។ វិធានការដ៏ធ្ងន់ធ្ងរមកលើអ្នកភូមិពាមនេះបានបន្សល់ស្លាកស្នាមដ៏គួរឲ្យឈឺចាប់ដែលមិនអាចបំភ្លេចបាន ។ នេះគឺជាប្រវត្តិសាស្ត្រមួយដែលបានលើកទឹកចិត្តអ្នកភូមិពាមឲ្យមកចូលរួមក្នុងដំណើរការសវនាការរបស់អង្គជំនុំជម្រះដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។

## ការកាត់ទោសមេដឹកនាំខ្មែរក្រហម

ក្នុងការឆ្លើយតបទៅនឹងសំណួរថាតើពីមុនមកគាត់បានទទួលព័ត៌មានទាក់ទងទៅនឹងការកាត់ទោសដែរឬទេ ភាគច្រើននៃអ្នកភូមិពាមទាំង៦០នាក់ដែលមកចូលរួមសុទ្ធតែឆ្លើយថា «ធ្លាប់បាន» ដឹងឮ ជាពិសេសតាមរយៈទូរទស្សន៍និងវិទ្យុ ។ យ៉ាងណាមិញ អ្នកភូមិនិយាយថា នេះគឺជាឱកាសដំបូងរបស់គាត់ទាំងអស់គ្នា ហើយដែលបានមកចូលរួមមើលសវនាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ។ ដោយសារតែឱកាសដ៏កម្រនេះទើបធ្វើឲ្យ សាលីម លើកឡើងថា៖ «សវនាការនេះមានសារសំខាន់ណាស់ ... ដោយសារតែខ្មែរក្រហមធ្វើទុក្ខបុកម្នេញប្រឆាំងនឹងប្រជាជនខ្មែរនិងជាពិសេសអ្នកភូមិរបស់ខ្ញុំ ។ គាត់ទទួលរងការឈឺចាប់ខ្លាំងជាងគេ ។ ចំណែកឯគ្រួសារខ្ញុំត្រូវបានសម្លាប់ទាំងអស់» ។

ការកាត់ទោសនេះត្រូវបានយល់ឃើញថាជាមធ្យោបាយមួយក្នុងការជួយសម្រួលការឈឺចាប់យ៉ាងខ្លាំងរបស់ប្រជាជន

រស់ជិត៣០ឆ្នាំមកនេះ ។ យ៉ាងណាមិញ អ្នកភូមិខ្លះបានយល់ឃើញថា ដំណើរការយុត្តាធិការមិនអាចជួយសម្រួលផ្នែកសតិអារម្មណ៍របស់គាត់បាននោះទេ ។ គាត់ទាំងអស់គ្នានៅតែចង់កំហឹងដ៏ឈឺចាប់ទៅលើមេដឹកនាំខ្មែរក្រហមនិងកម្មាភិបាលថ្នាក់ទាប ។ អ៊ឹ ស្រី វ៉ាន ដែលកូនរបស់គាត់ត្រូវបានខ្មែរក្រហមសម្លាប់ បាននិយាយថា គាត់នឹងសម្លាប់ជនជាប់ចោទប្រសិនបើគាត់អាចធ្វើទៅបាន ។ ចំណែកឯ អ៊ឹ ស្រី ស៊ីម យល់ឃើញថា ជនជាប់ចោទគួរតែត្រូវផ្តន្ទាទោសឲ្យស្លាប់ ទោះបីជាទង្វើនេះត្រូវបានហាមប្រាមក្នុងមាត្រា៣២នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ ។

នេះគឺជាប្រតិកម្មធម្មតារបស់មនុស្សនោះក្នុងការចង់សងសឹកចំពោះអ្វីដែលបានខូចខាត ជាពិសេសទៅលើការឈឺចាប់ទាំងប៉ុន្មាន ។ យ៉ាងណាមិញ ក្នុងករណីខ្លះទៀត អំពើហិង្សាផ្សេងៗអាចកាត់បន្ថយនិងទប់ស្កាត់បានក្នុងគោលបំណងបញ្ចៀសការសងសឹកទៅវិញទៅមក ។ ចំណែកឯ សាលីម ដែលសមាជិកគ្រួសាររបស់គាត់ត្រូវបានសម្លាប់ទាំងអស់នោះបានលើកឡើងផ្ទុយពីគំនិតរបស់អ៊ឹ ស្រី វ៉ាន និង ស៊ីម ទោះបីជាគាត់ទទួលស្គាល់ការឈឺចាប់របស់ខ្លួនក៏ដោយ ។ សាលីម សម្លឹងមើលទៅថ្ងៃក្រោយថា ការសងសឹកទៅវិញទៅមកនឹងត្រូវបានបញ្ឈប់ប្រសិនបើអ្នកដែលរួចរស់ជីវិតទាំងអស់បេះអត់ធ្មត់ ។ គាត់បានបន្ថែមទៀតថា តាមគំនិតរបស់គាត់យល់ឃើញថា ដោយសារតែហេតុផលនេះហើយទើបធ្វើឲ្យច្បាប់ក្លាយជាមធ្យោបាយមួយដ៏សមរម្យជាទីបំផុតក្នុងការជួយប្រជាជនទាំងឡាយ ។

កែ ទីន អាយុ៧៥ឆ្នាំ ជាអ្នកតំណាងមកពីសមាគមខ្មែរអ៊ីស្លាមបានមានប្រសាសន៍គាំទ្រសវនាការរបស់តុលាការថា យើងទាំងអស់គ្នាគួរតែធ្វើតាម «អ្វីដែលសហព្រះរាជអាជ្ញាចោទជនត្រូវចោទនិងអ្វីដែលជនត្រូវចោទបានសារភាព» ។ ទីន ជឿជាក់ថា «ការដែលមើលឃើញយុត្តិធម៌អាចទទួលយកបាន គឺអាចធ្វើឲ្យយើងទាំងអស់គ្នាមានអារម្មណ៍ធូរស្បើយ ។ ទាំងនេះគឺដូចជាមុខរបួសដែលត្រូវការថ្នាំជាចាំបាច់អ៊ីចឹង ទោះបីជាថ្នាំនោះមិនបានផ្តល់នូវការធូរស្បើយទាំងស្រុងក៏ដោយ» ។ អ៊ឹ ស្រី វ៉ាន ក៏បានទទួលស្គាល់ពីសារសំខាន់នៃសវនាការដែរ ប៉ុន្តែគាត់នៅតែបន្តថា គាត់នឹងមិនអាចធូរស្បើយបានឡើយរហូតដល់ថ្ងៃស្លាប់ ។

## ការចែករំលែកព័ត៌មាន

ទោះបីជាអ្នកដែលចូលរួមមានទស្សនៈផ្សេងគ្នាក៏ដោយ ក៏គេនៅតែផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើដំណើរការយុត្តាធិការរបស់អង្គជំនុំជម្រះ ។ ប្រជាជនខ្លះយល់ឃើញថា ដំណើរការនីតិវិធីផ្តល់នូវសារប្រយោជន៍ជាច្រើនរួមមាន ការផ្តល់នូវការយល់ដឹងយ៉ាងច្បាស់លាស់អំពីការសម្លាប់រង្គាលក្នុងរបបខ្មែរក្រហមទៅដល់ក្មេងជំនាន់ក្រោយ ជាពិសេស ពង្រឹងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ។ ទីន បានស្នើឡើងពីសំណងសមូហភាពសម្រាប់ជនរងគ្រោះ បន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការស្នើសុំរបស់គាត់ចំពោះស្រុកនីមួយៗគួរតែទទួលបានសាលាមួយខ្នងឬនិមិត្តរូបផ្សេងទៀត ដែលប្រហែលគ្នាដើម្បីផ្តល់ជាសំណងជូនជនរងគ្រោះ ដែលទទួលរងការឈឺចាប់កន្លងមក ។ គាត់ក៏ណែនាំថា សំណងសមូហភាពគឺដូចជាឱសថដែលនឹងអាចជួយព្យាបាលមុខរបួសចាស់ឲ្យជាសះស្បើយឡើងវិញ ។

បន្ថែមទៅនឹងការថ្លែងអំណរគុណដល់សមាជិកគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា តំណាងអ្នកភូមិជាច្រើនបាននិយាយថា គាត់នឹងពាំនាំព័ត៌មានដែលគាត់បានដឹងព្រយកទៅប្រាប់អ្នកជិតខាងរបស់គាត់ ។ លោកពូប្រធានភូមិឈ្មោះ ពៅ បានមានប្រសាសន៍ថា «មុនពេលដែលខ្ញុំធ្វើដំណើរមកទីនេះ មានប្រជាជនជាច្រើននិយាយប្រាប់ខ្ញុំថា ពួកគេរំពឹងទុកថានឹងអាចទទួលបានព័ត៌មានពីខ្ញុំទាក់ទងនឹងដំណើរការសវនាការ» ។ សាលីម បានបន្ថែមទៀតថា បន្ទាប់ពីការធ្វើទស្សនកិច្ចនេះរួចមកធ្វើឲ្យគាត់យល់ឃើញថាគាត់អាចពន្យល់អ្នកភូមិរបស់គាត់និងអ្នកដទៃទៀតអំពីដំណើរការនីតិវិធីប្រឆាំងទៅនឹងមេដឹកនាំខ្មែរក្រហម ។ អ្នកចូលរួមបានយល់ឃើញថា ការចែករំលែកព័ត៌មាននេះគឺជាមធ្យោបាយមួយក្នុងការទាក់ទាញការយកចិត្តទុកដាក់ខ្លាំងបំផុតទៅលើការកាត់ទោស ។ ក្នុងរបៀបនេះដែរ វាគឺជាមធ្យោបាយមួយក្នុងការរក្សាបាននូវយុត្តិធម៌ឲ្យដើរនៅលើទិសដៅមួយដ៏ត្រឹមត្រូវ និងក៏ជាវិធីល្អក្នុងការជួយប្រជាជនឲ្យទទួលបាននូវយុត្តិធម៌សម្រាប់ការឈឺចាប់ជាងពាទសវត្សរ៍មុនដែលគេធ្លាប់ជួបប្រទះ ។

**លី សុខឃាង**

# ឈរនៅកណ្តាល

សហព្រះរាជអាជ្ញាប្រើពេលសួរសំណួរដាក់លាក់ទៅកាន់ កាំង ហ្កេកអ៊ាវ (ឌុច) ដោយផ្តោតទៅលើការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ និងមន្ទីរម-១៣ ។ ខណៈពេលដែលសហព្រះរាជអាជ្ញាព្យាយាមស្វែងរកថា ឌុច មិនត្រឹមតែជាអ្នកអនុវត្តនោះទេ ប៉ុន្តែថែមទាំងជាអ្នកបង្កើតគោលនយោបាយមួយចំនួនទៀតផង ។ ឌុច បានបញ្ជាក់ពីតួនាទីរបស់គាត់ថាជាអ្នកនៅកណ្តាលដែលគ្រាន់តែទទួលបញ្ជា ហើយបញ្ជូនបន្តទៅឲ្យអ្នកក្រោមបង្គាប់ប៉ុណ្ណោះ ។

***«ត្រូវតែកម្ទេចខ្មាំងទាំងអស់»***

សហព្រះរាជអាជ្ញារង លោក គាន់ សេណារ៉ុង ចាប់ផ្តើមសវនាការដោយមានគោលបំណងបែងចែករយៈពេលផ្សេងគ្នា ដើម្បីពិភាក្សាពីការវិវត្តនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនដែលត្រូវចាត់ទុកថាអ្នកទោស ។ លោក សេណារ៉ុង ស្នើឲ្យមានការបែងចែកបក្សកុម្មុយនីស្តកម្ពុជាជាបួនរយៈកាលគឺមុនឆ្នាំ១៩៦៨ ពីឆ្នាំ១៩៦៨-១៩៧០ ពីឆ្នាំ១៩៧០-១៩៧៥ និង ពីឆ្នាំ១៩៧៥-១៩៧៩ ។ ប៉ុន្តែ ឌុច បដិសេធថាមិនមានពេលវេលាផ្សេងគ្នាសម្រាប់គាត់ទេ ។ ឌុច បាននិយាយរៀបរាប់ពីតួនាទីគ្រប់គ្រងរបស់គាត់នៅមន្ទីរម-១៣ និងមន្ទីរស-២១ ហើយបានរៀបរាប់បន្តិចបន្តួចទាក់ទងនឹងការប្រើអំណាចរបស់គាត់ក្នុងការសម្រេចចិត្តធ្វើអ្វីមួយ ។ តាមពិត



អ្នកភូមិឈរតម្រង់ជួរចូលមើលសវនាការកាត់ទោស ឌុច

តាមពាក្យសម្តីរបស់គាត់ យើងដឹងថាមានគោលនយោបាយស្នូលមួយដែលធ្វើឲ្យគាត់សកម្មនៅក្នុងសកម្មភាពរបស់គាត់ ។ «អ្នកដែលបានបញ្ជូនទៅមន្ទីរស-២១ ត្រូវបានចាត់ទុកជាខ្មាំងរួចទៅហើយ ហើយខ្មាំងទាំងអស់ត្រូវតែកម្ទេច» ។ បន្ទាប់មកនៅពេលដែលព្រះរាជអាជ្ញាព្យាយាមបំបែកអ្នកទោសជាក្រុមតាមហេតុផលចាប់ខ្លួន ឌុច នៅតែនិយាយថា គ្រប់ពេលដែលចាប់ខ្លួនគឺស្ថិតនៅក្រោមបញ្ជារបស់អ្នកគ្រប់គ្រង ។ នៅពេលដែលអ្នកទោសឃុំឃាំងនៅមន្ទីរ ស-២១ ជម្រើសតែមួយគត់របស់ ឌុច គឺចាត់ទុករាល់អ្នកទោសជាខ្មាំង ។ ទោះបីជាបានដឹងពីតួនាទីច្បាស់របស់ ឌុច ក៏ដោយ ក៏សហព្រះរាជអាជ្ញារងនៅតែចាប់ផ្តើមសំណួរដើម្បីស្វែងយល់ពីវិសាលភាពដែល ឌុច ប្រហែលជាបានបែងចែកអ្នកទោសផ្សេងៗគ្នា និងវិធីសាស្ត្រផ្សេងគ្នាដែលគេធ្វើទៅលើអ្នកទោស ។ សេណារ៉ុង សួរ ឌុច អំពីកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចាប់ខ្លួន បញ្ញវន្ត ខ្មាំងដែលជាអ្នករដ្ឋការ ស្ត្រី និងកូនក្មេង ប៉ុន្តែ ឌុច បានបដិសេធថា គាត់មិនបានគិតពីការបែងចែកទេ ប៉ុន្តែគាត់បានព្យាយាមដកខ្លួនមិនចូលរួមក្នុងការសម្រេចរបស់បក្សថាតើអ្នកណាត្រូវចាប់ខ្លួន និងសួរចម្លើយទេ ។



មានតែនៅពេលដែលសួរអំពីការសម្លាប់ក្មេងៗទេទើប ឌុច និយាយថាគាត់ក៏មានចម្ងល់អំពីការចាប់ខ្លួនក្មេងៗទាំងនោះ ។ ដោយបង្ហាញពីភាពស្មោះត្រង់ដែលមិនច្បាស់លាស់ ឌុច បាននិយាយថា គាត់បានសម្តែងពីក្តីព្រួយបារម្ភអំពីការចាប់ខ្លួននិងសម្លាប់ក្មេងៗទៅថ្នាក់លើរបស់គាត់ សុន សេន ដែរ ប៉ុន្តែ សុន សេន និយាយថាក្មេងៗនោះអាចនឹងសងសឹក ដូច្នេះយើងត្រូវតែ «កម្ទេច» ។ បន្ទាប់ពីទម្លាក់ការស្តីបន្ទោសចំពោះការធ្វើសេចក្តីសម្រេចទៅថ្នាក់លើរបស់គាត់ ឌុច ក៏បញ្ជាក់ថាមិនមានទំនាក់ទំនងជាមួយអ្នកយាមមន្ទីរស-២១ ដែលអនុវត្តការសួរចម្លើយនិងសម្លាប់ទេ ។ នៅពេលដែលគេសួរ ឌុច ថាមានដឹងពីក្មេងៗដែលត្រូវបានគេសម្លាប់ដោយបោកនឹងដើមឈើទេ គាត់បដិសេធថា មិនដឹងឬបដិសេធថាមិនមានការគ្រប់គ្រងដោយផ្ទាល់ទៅលើវិធីសាស្ត្រដែលកងទ័ពសម្លាប់ «ខ្មាំង» ឡើយ ។

## «ដាវកាន់តែប្រើ កាន់តែមុត»

បន្ទាប់ពីឈប់សម្រាករយៈពេលខ្លី សហព្រះរាជអាជ្ញាអន្តរជាតិបន្តដំណើរការសវនាការ ដោយមានការសួរចម្លើយប្រដេញផ្តោតទៅលើកម្មវិធីអប់រំដែលនិយាយពីការបង្រៀនគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាទៅដល់បុគ្គលិកមន្ទីរ ស-២១ ។ សហព្រះរាជអាជ្ញាព្យាយាមសួរដើម្បីចង់ដឹងពីវិធីសាស្ត្រដែលដែលបុគ្គលិកនៅមន្ទីរស-២១ ត្រូវបានលើកទឹកចិត្តឲ្យអនុវត្តគោលនយោបាយសម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បានរៀបរាប់ថាតើគាត់មានសាលាបង្រៀនពិសេសដែលសង់នៅជិតផ្ទះរបស់គាត់នៅមន្ទីរស-២១ ដែលជាកន្លែងអាចផ្ទុកក្រុមមនុស្សជាច្រើនសម្រាប់ការប្រជុំបណ្តុះបណ្តាលដោយរបៀបណា ហើយថាតើគាត់ធ្វើការបង្រៀនណែនាំតែម្នាក់ឯងឬក៏មានអ្នកផ្សេងទៀត ។ យោងទៅតាម ឌុច ការប្រជុំធ្វើឡើងមួយឆ្នាំម្តងសម្រាប់បុគ្គលិកស-២១ ប៉ុន្តែបុគ្គលិកសួរចម្លើយទទួលវគ្គបណ្តុះបណ្តាលជាក្រុមតូចៗ ជាញឹកញាប់គឺមួយ

សប្តាហ៍ម្តង នៅអំឡុង «ពេលវេលា» ។ នៅពេលដែលសួរថាគាត់បង្រៀនអ្នកយាម និងទាហានឲ្យធ្វើទារុណកម្មអ្នកទោសដោយរបៀបណា ឌុច សង្ខេបពីវិធីសាស្ត្រនោះដោយនិយាយថា «ដាវកាន់តែប្រើ កាន់តែមុត» ។ ចំពោះគាត់ នេះមានន័យថា អ្នកសួរចម្លើយដែលមានសមត្ថភាពបំផុតគឺនៅពេលដែលគេទទួលបានការណែនាំពីគោលនយោបាយសម្ងាប់របស់បក្សកុម្មុយនីស្តកម្ពុជា និងវិធីសាស្ត្រសួរចម្លើយញឹកញាប់ ហើយមានឱកាសអនុវត្តវិធីសាស្ត្រទាំងនោះជាញឹកញាប់ដែរ ។ ឌុច រំឭកដល់តុលាការថាការបណ្តុះបណ្តាលរបស់គាត់មិនមានអ្វីក្រៅពីការព្យាយាមភ្ជាប់ការណែនាំពីថ្នាក់លើទៅឲ្យកម្មាភិបាលក្រោមបង្គាប់ ។ បន្ទាប់ពីពេលសម្រាប់អាហារថ្ងៃត្រង់ សហព្រះរាជអាជ្ញាបានបញ្ចប់ការសួរសំណួរ ខណៈពេលដែលរូបភាពញញឹមរបស់ ឌុច ដែលនៅពីមុខម៉ៃក្រូហ្វូនក្នុងអំឡុងពេលកិច្ចប្រជុំវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចាំងនៅក្នុងសវនាការ ។ ទោះបីជា ឌុច បានបន្តនិយាយសម្រាលពីអំណាចនៃការធ្វើសេចក្តីសម្រេចចិត្ត ក៏រូបភាពនោះបានរំឭកដល់អង្គសវនាការអំពី ឌុច ដែលមានលក្ខណៈផ្សេងទៀតដែរ ។

ដំណើរការនីតិវិធីនៅពេលថ្ងៃដឹកនាំដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីពីររូប គឺ អេលៀន វេនណឺ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និង ស៊ីល ស្ទូតហ្ស៊ីនស្គី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ។

សំណួរជាច្រើនរបស់លោក វេនណឺ ផ្អែកទៅលើចម្លើយរបស់ បណ្ឌិត អេចឆេសាន់ ថ្មីៗនេះ ។ ឌុច ក៏ប្រើឱកាសនេះដើម្បីព្យាយាមនិយាយបន្ទាបតម្លៃរបស់សាក្សី ។ ឌុច បដិសេធនឹងការចោទប្រកាន់របស់ បណ្ឌិត អេចឆេសាន់ ដែលថាគាត់ជាអ្នកសម្រេចចិត្តប្រមូលបញ្ជីឈ្មោះប្រជាជនដែលមានជាប់ពាក់ព័ន្ធនឹងខ្មាំងតាមរយៈការសួរចម្លើយ ព្រមទាំងបដិសេធនឹងការចោទប្រកាន់ដែលថាគាត់ជាអ្នករៀបចំបញ្ជីឈ្មោះដើម្បីបញ្ជូនទៅមន្ទីរសន្តិសុខផ្សេង ។ ឌុច ព្យាយាមសម្តែងថាខ្លួនជាអ្នកកណ្តាលដែលស្តាប់តាមការបញ្ជាឲ្យប្រមូលព័ត៌មានពីអ្នកសួរចម្លើយរបស់គាត់ ហើយរាយការណ៍ទៅ សុន សេន ។

ដោយចោទជាសំណួរទៅលោកបណ្ឌិតស្របតាមការយល់ដឹងរបស់លោក ឌុច ក៏ព្យាយាមបន្ថយទម្ងន់នៃចម្លើយរបស់លោកថា វិធីសាស្ត្រធ្វើទារុណកម្មនៅមន្ទីរស-២១ មានលក្ខណៈចម្លែកតែមួយ ។ ឌុច សារភាពថាគាត់បានបង្រៀនវិធីសាស្ត្រធ្វើទារុណកម្មមួយចំនួនដូចជា ឆក់ខ្សែភ្លើង និងធ្វើឲ្យថប់ដង្ហើមដោយប្រកស្បោងប្លាស្ទិក ប៉ុន្តែគាត់បានបន្ថែមថា គាត់មិនដឹងថាតើវិធីសាស្ត្រសួរចម្លើយរបស់គាត់មានលក្ខណៈចម្លែកខុសពីគេឬក៏អត់នោះទេ ។ ឌុច អះអាងថា គាត់មិនជឿថាអ្នកសួរចម្លើយបានប្រើសត្វល្អិតមានពិសទិច ឬទាញក្រចកដៃជាវិធីសាស្ត្រធ្វើទារុណកម្ម និងសួរចម្លើយ យោងតាមប្រភពរបស់លោកបណ្ឌិត អេចឆេសាន់នោះទេ ។

សវនាការបានបញ្ចប់ដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុមពីរ អ្នកស្រី ស្ទូតហ្ស៊ីនស្គី ដែលសួរទៅ ឌុច អំពីគោលនយោបាយដែលត្រូវបានចោទប្រកាន់ថាធ្វើទៅលើអ្នកទោសមន្ទីរស-២១ ដូចជាសត្វ ។ ទោះបីជា ឌុច ផ្តល់ចម្លើយសារភាពដោយបន្ទុំទៅលើចំណុចនេះក៏ដោយ គាត់ហាក់ដូចជានិយាយសម្រាលទៅលើករណីនីមួយៗដើម្បីឲ្យតុលាការធ្វើការពិចារណា ។ គាត់បានសារភាពថា គាត់បានណែនាំទាហានឲ្យចាត់ទុកអ្នកទោសដូចជាឆ្កែ ប៉ុន្តែនិយាយថាគាត់ធ្វើបែបនោះគឺដើម្បីចៀសវាងកុំឲ្យគេវាយអ្នកទោស ។ ឌុច សារភាពថា អ្នកយាមហៅឈ្មោះអ្នកទោសដោយប្រមាថដូចជាសត្វ ប៉ុន្តែគាត់មិនបានណែនាំឲ្យគេធ្វើបែបនោះទេ ហើយវា «មិនអាចចៀសផុតឡើយ ពីព្រោះអ្នកយាមតែងតែធ្វើតាមគ្នា» ។

ឌុច ឆ្លើយនឹងសំណួរចុងក្រោយពាក់ព័ន្ធនឹងការអនុវត្តសម្រាតខោអាវអ្នកទោសមុនពេលមកដល់មន្ទីរស-២១ ដោយអះអាងម្តងទៀតថា គាត់ព្យាយាមអស់ពីសមត្ថភាពដើម្បីគ្រប់គ្រងគុកនោះ ប៉ុន្តែដំណើរការប្រចាំថ្ងៃកើតឡើងលើសពីការគ្រប់គ្រងរបស់គាត់ ។ ខណៈពេលដែលគាត់ព្រមទទួលការស្តីបន្ទោសចំពោះឧក្រិដ្ឋកម្មនៅមន្ទីរស-២១ ដោយសារភាពថាវាជាបញ្ជាថ្នាក់លើគាត់ស័ក្តិសមនឹងការធ្វើបែបនោះដោយអះអាងថាឧក្រិដ្ឋកម្មដែលគាត់បានធ្វើគឺជាលទ្ធផលដែលកើតឡើងតាមបញ្ជា ហើយឧក្រិដ្ឋកម្មជាច្រើននៅមន្ទីរស-២១ ត្រូវបានអនុវត្តដោយអ្នកនៅក្រោមបង្គាប់ដែលគាត់មិនមែនជាអ្នកគ្រប់គ្រងដោយផ្ទាល់ ។

**ឆាល ឡេកសុន**

# ៣០ឆ្នាំមុន ឌុច បានដកក្រចកជើងរបស់គាត់ ថ្ងៃនេះគាត់បានបង្ហាញក្រចកជើងរបស់គាត់ទៅកាន់ ឌុច វិញ

ក្នុងទិដ្ឋភាពខ្លះៗ ដំណើរការកាត់ទោសថ្ងៃនេះមានសភាពប្រហាក់ប្រហែលនឹងកាលពីម្សិលមិញ ដោយបានស្តាប់នូវសក្ខីកម្មរបស់បុរសចំណាស់ដែលរស់រានមានជីវិតពីគុកទួលស្លែង ដោយសារតែជំនាញដ៏មានទេពកោសល្យរបស់គាត់ ។ យ៉ាងណាមិញ សក្ខីកម្មរបស់ ជុំ ម៉ី ដែលជាជាងធ្វើម៉ាស៊ីនមានលក្ខណៈប្រសើរជាងសក្ខីកម្មរបស់ជាងគំនូរ វ៉ាន់ ណាត ដែលនិយាយដដែលៗកាលពីម្សិលមិញ ។ ចុងក្រោយបំផុត ដោយសារសក្ខីកម្មរបស់ ជុំ ម៉ី ភាពក្រេវក្រោធនិងភាពខឹងសម្បាររបស់ជនរងគ្រោះនៃមន្ទីរ ស-២១ ម្នាក់នេះ គាត់បានផ្តល់នូវព័ត៌មានដ៏មានសារសំខាន់ត្រឹមត្រូវដល់តុលាការកាត់ទោស កាំង ហ្គេកអ៊ាវ ហៅ (ឌុច) ដែលជាប្រធានគុកទួលស្លែង ។

## រឿងរ៉ាវរបស់ ជុំ ម៉ី

ខណៈពេលដែលខ្មែរក្រហមកាន់កាប់អំណាចក្នុងឆ្នាំ ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី អាយុ ៧៩ឆ្នាំ មានមុខរបរជាជាងធ្វើម៉ាស៊ីននៅភ្នំពេញ ។ ជុំ ម៉ី និងគ្រួសាររបស់គាត់ត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង ប៉ុន្តែដោយសារសោកនាដកម្ម និងព្រឹត្តិការណ៍មួយចំនួនបាននាំគាត់ត្រឡប់មកកាន់ភ្នំពេញវិញ ដើម្បីមកជួសជុលម៉ាស៊ីនដេរ និងសម្ភារៈដទៃទៀតនៅក្នុងរោងចក្ររបស់ខ្មែរក្រហមមួយកន្លែងដែលផលិតសម្លៀកបំពាក់ខ្មៅទាំងអស់របស់ទាហានខ្មែរក្រហម ។ ក្រោយពីបានរស់នៅក្នុងរោងចក្រនេះអស់រយៈពេលបីឆ្នាំ ជុំ ម៉ី ត្រូវបាន (ទាហានខ្មែរក្រហម) ហៅឲ្យចេញពីរោងចក្រដោយយកលេសថាទៅជួសជុលរថយន្តរបស់ខ្មែរក្រហមមួយគ្រឿង ។ ជុំ ម៉ី ត្រូវបានបញ្ជូនទៅកាន់ទីកន្លែងមួយដែលក្រោយមកគាត់បានដឹងថាជាមន្ទីរស-២១ ដែលជាកន្លែងមួយគាត់ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ថាជាពួក សេ.អ៊ី.អា ឬកា.ហ្វេ.បេ និងត្រូវបានគេដាក់ខ្នោះ ចងមុខ ថតរូប និង ដោះខោរបស់គាត់ចេញ ។

ជុំ ម៉ី ត្រូវបានឃុំឃាំងនៅក្នុងគុកដែលមានប្រវែងពីរម៉ែត្រដែលមួយម៉ែត្រសម្រាប់ដាក់អ្នកទោសម្នាក់ៗ ។ ក្នុងគុកនោះមានតែកេសគ្រាប់មួយសម្រាប់បន្ទោរបង់ និងប៊ីដុងប្លាស្ទិកមួយសម្រាប់នោមតែប៉ុណ្ណោះ ។ ការធ្វើចលនាដោយគ្មានការអនុញ្ញាតត្រូវគេវាយនឹងខ្សែតីចំនួនពី១០០ ទៅ ២០០ ខ្សែតី ។ ជុំ ម៉ី ទទួលបានរបបអាហារ «បបរាវ» តែមួយមុខគត់ ។ ជុំ ម៉ី ត្រូវបានសួរចម្លើយអស់រយៈពេល១២ថ្ងៃ ១២យប់ ។ ជុំ ម៉ី ធ្លាប់បានឮពាក្យថា សេ.អ៊ី.អា និង កា.ហ្វេ.បេ ពីមុនដែរ ប៉ុន្តែគាត់មិនដឹងថាតើអង្គការទាំងពីរនេះធ្វើអ្វីខ្លះនោះទេ ។ យ៉ាងណាមិញ អ្វីដែលជាការពិតសម្រាប់គាត់មិនបានធ្វើឲ្យបុគ្គលិកមន្ទីរ ស-២១ ពេញចិត្តទេ ដូច្នេះ ជុំ ម៉ី ត្រូវបានគេធ្វើទារុណកម្មដោយបច្ចេកទេសផ្សេងៗគ្នាជាច្រើន រហូតដល់គាត់យល់ព្រមសារភាពថាគាត់បានចូលរួមជាមួយនឹងពួក សេ.អ៊ី.អា និង កា.ហ្វេ.បេ ហើយបានប្រគល់នូវឈ្មោះមនុស្សដទៃទៀតមាននៅក្នុងខ្សែបណ្តាញដែលគាត់បានប្រឌិតឡើង ។

នៅក្នុងបន្ទប់ដែលពោរពេញទៅដោយឈាមស្រស់ៗ និងមានផ្ទុកនូវម៉ាស៊ីនវាយអង្គុលីលេខមួយនៅលើតុមួយ និង ឧបករណ៍ធ្វើទារុណកម្មជាច្រើន ជុំ ម៉ី ត្រូវបានវាយខ្លាំងៗនឹងរំពាត់រហូតដល់រំពាត់នោះបាក់ ។ ម្តងនោះ គាត់បានព្យាយាមយកដៃរបស់គាត់រងនឹងការវាយនេះ ប៉ុន្តែជាលទ្ធផលបានធ្វើឲ្យបាក់ម្រាមដៃរបស់គាត់ ។ ជុំ ម៉ី ត្រូវបានឆក់ខ្សែភ្លើងដែលមានកម្លាំងអគ្គិសនី ២២០ វ៉ុលត៍ដែលរត់ចេញពីរន្ធដោតភ្លើងចូលមកក្នុងត្រចៀករបស់គាត់ ។ ក្រចកជើងរបស់គាត់ត្រូវបានដកចេញដោយដង្កាប់ក្នុងអំឡុងពេលពីរថ្ងៃ ហើយបន្ទាប់ពីការទទួលទារុណកម្មនេះគាត់មិនអាចដើរបានរហូតដល់ទៅមួយខែ ។ ចៅក្រមបានឲ្យអ្នកចាប់រូបភាពពង្រីកយករូបក្រចកជើងរបស់ ជុំ ម៉ី ដែលមានសភាពខូចទ្រង់ទ្រាយនៅឡើយក្នុងរយៈពេលសាមសិបឆ្នាំកន្លងមកនេះ ។ ក្រោយមកទៀត ជុំ ម៉ី មិនបានទទួលនូវការព្យាបាលជាថ្នាំពេទ្យឡើយ ហើយត្រូវបានបញ្ជូនមកកាន់គុករបស់គាត់វិញ ដែលខណៈពេលនោះគាត់បានយំខ្សឹបៗ ពីព្រោះថាគាត់មិនមានសិទ្ធិធ្វើឲ្យមានសំឡេងរំខានអ្វីឡើយ ។

ដុំ មុី បានឆ្លើយបដិសេធលើការអះអាងរបស់ ឌុច ដែលថាជាញឹកញាប់ការសួរចម្លើយមានលក្ខណៈ «ត្រជាក់» មានន័យថា ទារុណ្ណកម្មមិនត្រូវបានប្រើប្រាស់ឡើយ ។ ដុំ មុី បាននិយាយថា ទង្វើដែលធ្វើមកលើអ្នកទោស គឺសុទ្ធតែមានលក្ខណៈ «ក្តៅ» ជានិច្ច ។

ខណៈពេលដែលត្រូវបានសួរថាតើ ឌុច មានបានវាយគាត់ដោយផ្ទាល់ដែរឬទេ ដុំ មុី បានឆ្លើយដោយខឹងសម្បាថា ប្រសិនបើគាត់បានឃើញមុខ ឌុច នៅពេលនោះ ឌុច ប្រហែលជាមិនអាចមានអាយុជីវិតរហូតមកដល់សព្វថ្ងៃនេះ គាត់ប្រហែលជានឹងសម្លាប់ ឌុច ហើយ ។ ភ្លាមនោះ លោកប្រធានចៅក្រម និល ណុន បានណែនាំ ដុំ មុី ឲ្យ «ចៀសវាងនូវអាកប្បកិរិយាបំពាន» ឬ «ការជេរប្រមាថ» ឌុច ដោយក្រើនរំឭកគាត់ថាទង្វើបែបនេះពិតជាមិន «សមរម្យ» ឡើយ ។

ក្រោយពីផ្តល់ចម្លើយសារភាពរបស់គាត់ឲ្យអ្នកយាមមន្ទីរស-២១ ដុំ មុី ត្រូវបានបង្ខំឲ្យធ្វើការជាជាងធ្វើម៉ាស៊ីនជាជាងយកទៅកម្ទេចតាមដំណើរការធម្មតារបស់មន្ទីរនេះ ។ តាំងពីពេលនោះមក ដុំ មុី បានចំណាយពេលបួនខែជួសជុលម៉ាស៊ីនដេរ ម៉ាស៊ីនវាយអក្សរលេខ ឧបករណ៍ក្នុងផ្ទះបាយ និងបំពង់ទឹកនៅក្នុងរោងជាងមួយនៅខាងលិចបរិវេណមន្ទីរស-២១ ក្បែរផ្ទះបាយ ទ្រុងជ្រូក និង ក្បែរគំនរខោអាវដែលដោះចេញពីអ្នកទោសដែលយកទៅសម្លាប់នៅជើងឯក ។ នៅកន្លែងនោះ ដុំ មុី បានឮសំឡេងសើចរបស់អ្នកយាមគុក អ្នកទោសទទួលទារុណ្ណកម្ម និងក្មេងយំ ។ ដុំ មុី បានទទូចនិយាយយ៉ាងដាច់ខាតថា ក្នុងអំឡុងពេលទស្សនកិច្ចរបស់ ឌុច មកកាន់មន្ទីរស-២១ គាត់នៅតែបានឮសំឡេងដដែលនោះ ។ នៅពេលយប់ ដុំ មុី បានជាប់ឃុំឃាំងនៅក្នុងគុករួមមួយជាមួយនឹងអ្នកទោសចំនួន៤០នាក់ផ្សេងទៀត ដែលក្នុងគុកនោះគាត់មិនអាចនិយាយ ឬ កម្រើកខ្លួនបានឡើយ ។ ខណៈពេលដែលកងទ័ពវៀតណាមបានចូលមកដល់ភ្នំពេញនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដុំ មុី (ត្រូវទាហានខ្មែរក្រហម) ភ្ជង់នឹងកាំភ្លើងបង្ខំឲ្យចាកចេញពីមន្ទីរស-២១ ជាមួយនឹងក្រុមអ្នកទោសដែលមានចំនួនលើសពី១០នាក់ ។ នៅក្បែរកន្លែងកសាងខ្លួនព្រៃស (មន្ទីរស-២៤) ដែលគ្រប់គ្រង ដោយ ឌុច ដែរនោះ ដុំ មុី មានឱកាសជួបជុំជាមួយនឹងប្រពន្ធគាត់ដែលជាប់ឃុំឃាំងនៅមន្ទីរស-២៤ ។ ក្នុងអំឡុងពេលនោះប្រពន្ធគាត់កើតបានកូនប្រុសម្នាក់ ។ ដុំ មុី ត្រូវបីកូនប្រុសអាយុពីរខែរបស់គាត់អស់ជាច្រើនម៉ោងខណៈពេលដែលគាត់ និងប្រពន្ធគាត់បន្តរត់គេចពីការបាញ់កាំភ្លើងនិងភៀសខ្លួនចេញពីភ្នំពេញ ។ ជាអកុសល ក្នុងខណៈពេលមួយនោះ ប្រពន្ធរបស់គាត់បានបីកូនប្រុសគាត់វិញ ប៉ុន្តែអ្នកទាំងពីរត្រូវបានកងឈ្លបបាញ់សម្លាប់ ។ ដោយសារតែកូនស្រីពីរនាក់ និងកូនប្រុសដទៃទៀតរបស់គាត់បានស្លាប់តាំងពីដើមរបបខ្មែរក្រហមមក ពេលនេះគាត់នៅសល់តែម្នាក់ឯងគត់ ហើយគាត់ក៏សម្រេចចិត្តភៀសខ្លួនមកកាន់ភូមិកំណើតរបស់គាត់វិញ ។

ដុំ មុី ជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលមានវត្តមានជារៀងរាល់ថ្ងៃនៅក្នុងតុលាការ បាននិយាយថា បន្ទាប់ពីដំណើរការកាត់ក្តី ជារៀងរាល់យប់គាត់នៅតែយំពីព្រោះថាគាត់មិនអាចឮពាក្យ «ខ្មែរក្រហម» ដោយមិនគិតដល់ប្រពន្ធ និង កូនៗរបស់គាត់បានឡើយ ។ ខណៈពេលដែលត្រូវបានសួរថាតើគាត់គិតយ៉ាងដូចម្តេចនៅពេលដែលគាត់ឮពាក្យ «ទួលស្លែង» ដុំ មុី បាននិយាយថា «ទឹកភ្នែករបស់ខ្ញុំនៅតែហូរចុះមករហូត ទោះបីជាខ្ញុំព្យាយាមបញ្ឈប់វាយ៉ាងណាក៏ដោយ» ។ គាត់បាននិយាយថា គាត់នឹងមិនបំភ្លេចនូវទុក្ខវេទនារបស់គាត់ទេរហូតដល់ថ្ងៃគាត់ស្លាប់ ប៉ុន្តែខ្លួនគាត់នឹងមានភាពធូរស្បើយនៅពេលដែលយុត្តិធម៌ត្រូវបានរកឃើញដោយចៅក្រម ។ ដុំ មុី បាននិយាយថា គាត់មានអារម្មណ៍សប្បាយរីករាយ និងរំភើបណាស់ក្នុងការផ្តល់សក្ខីកម្មនៅមុខតុលាការ ហើយគាត់នឹងស្វាគមន៍នូវឱកាសដើម្បីជុតភ្លើងបំភ្លឺអតីតកាលដែរ ។

ក្នុងការឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តី ដុំ មុី បានបញ្ជាក់ថា វាបានធ្វើឲ្យគាត់មានអារម្មណ៍រីករាយដែលបានស្តាប់ឮការសុំអភ័យទោសរបស់ ឌុច និងបានឃើញ ឌុច យំនៅពេលគាត់បង្ហាញពីសកម្មភាពដែលគាត់បានធ្វើនៅមន្ទីរស-២១ នៅឆ្នាំ២០០៨ ពីព្រោះថាគាត់បានរង់ចាំថ្ងៃនោះអស់រយៈពេលសាមសិបឆ្នាំមកហើយ ។ យ៉ាងណាមិញ ដុំ មុី បាននិយាយថា ទឹកភ្នែកពីរ-បីតំណក់របស់ ឌុច នេះមិនអាចលុបបំបាត់នូវទុក្ខវេទនារបស់មនុស្សរាប់លាននាក់ដែលបានស្លាប់ហើយនោះទេ ។

គាត់បានបន្ថែមថា «មានតែតុលាការមួយគត់ដែលអាចលុបបំបាត់នូវទុក្ខវេទនានេះបាន» ។

## ផ្ទុយពីម្សិលមិញ

ដូចដែលបានរៀបរាប់កាលពីម្សិលមិញ សក្ខីកម្មរបស់ វ៉ាន់ ណាត ហាក់ដូចជាមានឥទ្ធិពលនិងប្រសិទ្ធភាព ។ វ៉ាន់ ណាត មានអារម្មណ៍ស្ងប់ស្ងាត់និងនឹងនរ ដែលអាចធ្វើឲ្យគាត់ផ្តល់នូវសក្ខីកម្ម ។ សក្ខីកម្មរបស់ ជុំ ម៉ី មានភាពផ្ទុយស្រឡះពីព្រោះថាគាត់មានសកម្មភាពរស់រវើកពោរពេញដោយមនោសញ្ចេតនា និងកំហឹង ហើយពេលខ្លះមានលក្ខណៈសាហាវទៀតផង ។ ដោយពិចារណាឃើញថា ជុំ ម៉ី គឺជាបុរសមាឌតូចដ៏គួរឲ្យគោរពម្នាក់ ដែលអង្គុយយ៉ាងស្ងៀមស្ងាត់នៅជ្រុងមួយក្នុងបន្ទប់សវនាការជារៀងរាល់ថ្ងៃដោយយកចិត្តទុកដាក់ស្តាប់គ្រប់ពាក្យនោះ សក្ខីកម្មរបស់គាត់នៅពេលនេះមានឥទ្ធិពលយ៉ាងខ្លាំង ។ ផ្ទុយពី វ៉ាន់ ណាត ដែលធ្លាប់មានបទពិសោធន៍ទទួលទារុណ្ណកម្មដោយផ្ទាល់ដៃរបស់ខ្មែរក្រហម ជុំ ម៉ី បានរៀបរាប់ពីការធ្វើទារុណ្ណកម្មដែលកើតមានឡើងក្រោមបញ្ជារបស់ ឌុច ផ្ទាល់តែម្តង ហើយគាត់បាននិយាយពីរឿងរ៉ាវនេះដោយសភាពរស់រវើក ។

ផ្ទុយពីសក្ខីកម្មរបស់ វ៉ាន់ ណាត មានភាពច្បាស់លាស់នោះ សក្ខីកម្មរបស់ ជុំ ម៉ី បានជួបនូវបញ្ហាបកប្រែ និង ការយល់ច្រឡំ ។ វាពិតជាមានភាពខកខានខ្លាំងណាស់ពីព្រោះថាព័ត៌មានជាច្រើនបានបាត់បង់ ។ ជាក់ស្តែង ជុំ ម៉ី បានប្រើពាក្យគ្រៀមភាសាយ៉ាងច្រើនដែលជាហេតុផលបន្តឲ្យមានបញ្ហានេះកើតឡើង ។

ដោយគិតថា វ៉ាន់ ណាត មិនមែនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី មិនមានភាគីណាមួយបានរៀបចំឲ្យគាត់ធ្វើជាសាក្សីឡើយ ។ ខណៈពេលសំណួរនាំមុខមានលក្ខណៈស្របទៅតាមបទដ្ឋាននៃនីតិវិធី សំណួរនេះជានិច្ចជាកាលមិនបានទទួលនូវការឆ្លើយតបទៅតាមអ្វីដែលគេចង់បាននោះទេ ហើយដំណើរការនីតិវិធីកាលពីម្សិលមិញក៏មិនខុសប្លែកគ្នាដែរ ។ ទាំងព្រះរាជអាជ្ញា និង មេធាវីដើមបណ្តឹងរដ្ឋប្បវេណីហាក់បីដូចជាសួរ វ៉ាន់ ណាត នូវសំណួរជាច្រើនដែលគាត់មិនអាចឆ្លើយបាន ឬក៏មិនបានឆ្លើយដោយឥរិយាបថដែលមានប្រយោជន៍ដល់គេជាជាងចោទសួរនូវសំណួរផ្សេងទៀត ។ ដូច្នេះហើយបានជាព្រះរាជអាជ្ញា និង មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានពន្យាពេលវេលាដ៏ខ្លីរបស់ខ្លួនដើម្បីសួរសាក្សីដ៏សំខាន់នេះឡើយ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ថា វ៉ាន់ ណាត បាននិយាយប្រឆាំងនឹងខ្លួនឯងទាក់ទិននឹងហេតុការណ៍ពីរ ដោយមេធាវីរូបនោះបានធ្វើការកត់សម្គាល់ទៅលើសេចក្តីរាយការណ៍ដែលត្រូវបានចោទប្រកាន់ថាមិនដូចគ្នា ។ ខ្ញុំមានអារម្មណ៍ថាមិនយល់អ្វីទាល់តែសោះ ។ បើពិចារណាទៅលើកាលៈទេសៈកាលពីម្សិលមិញ ថ្ងៃនេះខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ជុំ ម៉ី ជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមានក្នុងតុលាការរៀងរាល់ថ្ងៃនឹងបានរៀបចំខ្លួនរួចជាស្រេចដើម្បីឆ្លើយនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ការចោទសួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានដំណើរការទៅមុខយ៉ាងល្អប្រសើរ ប៉ុន្តែ ជុំ ម៉ី នៅតែមិនអាចយល់ពីសំណួរបាន ហើយបែរជាផ្តល់នូវចម្លើយក្នុងករណីផ្សេងទៅវិញ ។

ទោះបីជាទិដ្ឋភាពជាក់លាក់នៃដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះគួរតែអាចមានភាពរលូតទៅមុខប្រសើរជាងនេះក៏ដោយ ក៏វានៅតែជាថ្ងៃដ៏មានឥទ្ធិពលបំផុតសម្រាប់តុលាការដែរ ។ ក្រោយពីបានស្តាប់នូវប្រភេទអង្គហេតុដដែលៗពីមួយថ្ងៃទៅមួយថ្ងៃក្នុងបរិយាកាសដ៏គួរឲ្យធុញទ្រាន់បែបនេះ ទាំងចៅក្រម និងអ្នកតាមដានជាប្រចាំមើលទៅហាក់បីដូចជាមានភាពសោះអង្គើយបន្តិច ។ ប៉ុន្តែថ្ងៃនេះ ក្រោយពីរយៈពេលបីខែនៅក្នុងសាលសវនាការ (ក្នុងបន្ទប់រួមជាមួយនឹងចៅក្រម ព្រះរាជអាជ្ញា និងមេធាវី) និងសាមសិបឆ្នាំដែលរងទុក្ខវេទនា ជុំ ម៉ី បានចែករំលែកនូវរឿងរ៉ាវពោរពេញដោយមនោសញ្ចេតនាទៅកាន់ពិភពលោក រួមជាមួយនិងបទពិសោធន៍ទទួលរងទារុណ្ណកម្មនៅមន្ទីរស-២១ ដែលជាបទពិសោធន៍មួយដែលទទួលការដឹងឮយ៉ាងច្បាស់ ។ ជុំ ម៉ី បានក្រោកឈរឡើងយ៉ាងមានជំនឿជឿជាក់ នៅចុងបញ្ចប់សក្ខីកម្មរបស់គាត់ហាក់បីដូចជាចង់ប្រកាសប្រាប់ថា ទោះបីជាខ្មែរក្រហមបានឆក់យកជីវិតកូនបួននាក់ និងប្រពន្ធគាត់ និងក្រចកជើងរបស់គាត់ក៏ដោយ ក៏គាត់មានថ្ងៃរបស់គាត់នៅក្នុងតុលាការ ហើយក៏គ្មាននរណាម្នាក់អាចយកថ្ងៃនេះពីគាត់បានដែរ ។ សូម្បីតែសក្ខីកម្មដែលជួបបញ្ហាសន្ទនា ក៏អាចនាំពាក្យសម្តីដ៏មានន័យនេះបានដែរ ។ **ឡូរ៉ា ម៉ាកជូណាល**

# ពិធីចែកសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ខេត្តកំពង់ឆ្នាំង ថ្ងៃទី២







# នៅវិទ្យាល័យព្រះបាទសុរាម្រឹត និងវិទ្យាល័យរលាប្អៀរ ខែមិថុនា ឆ្នាំ២០០៩









# ការប្រព្រឹត្តទៅលើអ្នកទោស

នៅថ្ងៃរំឭកវិញ្ញាណក្ខន្ធចុងសប្តាហ៍នេះ ខ្ញុំគិតថាវាមានសារសំខាន់ក្នុងការគោរពទៅដល់អ្នកដែលបម្រើប្រទេស ដោយធ្វើការចងចាំនូវបុព្វហេតុដែលគេពលីជីវិតដើម្បីការពារជាតិ ។ បុព្វហេតុមួយក្នុងចំណោមបុព្វហេតុទាំងនោះ គឺជាវិធានច្បាប់ ។

ការបណ្តែតមនុស្សនៅលើទឹកដោយចងភ្ជាប់ជាមួយក្តារត្រូវបានយកមកប្រើដើម្បីសួរចម្លើយអ្នកទោស ។ ការធ្វើទារុណកម្មនិងបង្ខំឲ្យសារភាពគឺជាវិធីស៊ើបអង្កេតយ៉ាងព្រៃផ្សៃរបស់ជនជាតិអេស្ប៉ាញ កាលពីសម័យមុន ។

វាមានសារសំខាន់ដើម្បីយល់ដឹងឲ្យច្បាស់ថា អ្វីជាការបណ្តែតមនុស្សនៅលើទឹក ផលប៉ះពាល់របស់វា និងផ្លូវច្បាប់ ។

**ការបណ្តែតមនុស្សនៅលើទឹកដោយចងភ្ជាប់នឹងក្តារ** ៖ រួមមានការធ្វើឲ្យជនរងគ្រោះមិនអាចធ្វើចលនាចង្កេះ ទាញក្បាលជនរងគ្រោះមកក្រោយ ហើយបន្ទាប់មកបាញ់ទឹកដាក់មុខជនរងគ្រោះ និងបញ្ចូលទៅក្នុងផ្លូវដង្ហើម ។ ដោយមិនអាចដកដង្ហើមនិងឈ្លក់ទឹក ជនរងគ្រោះត្រូវលង់ទឹកស្លាប់ ។

**យន្តការនៃការបណ្តែតមនុស្សនៅលើទឹកដោយចងភ្ជាប់នឹងក្តារៈ** ការបណ្តែតមនុស្សនៅលើទឹកដោយចងភ្ជាប់នឹងក្តារបង្ហាញឲ្យឃើញចម្លើយមិនពិតយ៉ាងរហ័ស ។ ទោះបីជាការធ្វើបែបនេះអាចបង្កឲ្យមានការខូចខាតខាងរូបរាងកាយក៏ដោយ ប៉ុន្តែវាមិនតែងតែបង្កឲ្យមាននោះទេ ។ ស្ថានភាពរូបរាងកាយរបស់ជនរងគ្រោះ ភាពធ្ងន់ធ្ងរ និងរយៈពេលនៃព្រឹត្តិការណ៍ ព្រមទាំងសីតុណ្ហភាពទឹកគឺមានភាពខុសប្លែកគ្នាក្នុងការធ្វើឲ្យមានការខូចទ្រង់ទ្រាយរូបរាងកាយ ។

លទ្ធផលដែលមើលឃើញបន្ទាប់ពីការបណ្តែតមនុស្សនៅលើទឹកដោយចងភ្ជាប់នឹងក្តារមានដូចជា ៖

- **ការឈឺចាប់យ៉ាងខ្លាំង** ៖ បណ្តាលមកពីការធ្វើសកម្មភាពសាច់ដុំដោយបង្ខំ ។
- **ការខូចខាតដល់សួត** ៖ កើតឡើងដោយសារការផឹកទឹក ។

នៅពេលដែលទឹកចូលទៅក្នុងសួត វាហូរទៅក្នុងផ្នែករបស់សួតតាមរយៈថង់តូចៗ នៅក្នុងសួតដោយសារសម្ពាធសសៃឈាមស្រូបទាញយកទឹកទាប និងសម្ពាធច្រោះសារធាតុអន្ទិលខ្ពស់ ។ ជាលទ្ធផល ផ្នែកដែលផ្ទុកកោសិកាឈាមត្រូវបានលាយឡំជាមួយទឹក ហើយប្រព័ន្ធរំលាយធ្វើឲ្យបែកកោសិកាឈាមក្រហម ។ លទ្ធផលនៃការកើនឡើង កម្រិតប៉ូតាស្យូមប្លាស្មា និងការធ្លាក់ចុះនៃកម្រិតសូដ្យូមដោយសារការបែកឈាមក្រហម ធ្វើឲ្យមានការប្រែប្រួលសកម្មភាពតង់ស្យុងបេះដូង ។ ចលនាចតបេះដូងកើតឡើងជាលទ្ធផលនៃការប្រែប្រួលអ៊ីយ៉ុង ។ បន្ថែមទៅលើនេះទៀត ប្រសិនបើពេលបណ្តែតទឹក គេប្រើទឹកត្រជាក់ដែលមានសីតុណ្ហភាព ៥០ អង្សាហ្វារិនហៃ បរិមាណទឹកត្រជាក់នៅក្នុងប្រព័ន្ធសសៃ



អ្នកទោសនៅមន្ទីរស-២១

ឈាមអាចធ្វើឲ្យបេះដូងឈប់ធ្វើចលនា ។

◆ **នៅពេលដែលសួតមនុស្សមិនអាចទាញយកអុកស៊ីសែនបាន** ៖ ទឹកដែលមិនមានសារធាតុអំបិលនឹងបំផ្លាញផ្នែកខាងក្នុងនៃផ្ទៃខាងលើរបស់សួត ធ្វើឲ្យគ្មានការកើនឡើងសារធាតុរាវនៅក្នុងសួត ហើយកាត់បន្ថយសមត្ថភាពផ្លាស់ប្តូរខ្យល់ ។ វាអាចបណ្តាលឲ្យមនុស្សលង់ទឹកស្លាប់ បន្ទាប់ពីរយៈពេល៧២ម៉ោង ។

◆ **ការខូចខាតខួរក្បាលដោយមិនមានអុកស៊ីសែន៖** ការមិនមានអុកស៊ីសែនដោយសារការបណ្តែតទឹកអាចបង្ហាញតាមពីររបៀបគឺការផ្តល់អុកស៊ីសែនឲ្យខួរក្បាលមិនគ្រាប់គ្រាន់ដោយសារការចុះខ្សោយមុខងារខួរក្បាលគឺបណ្តាលមកពីកម្រិតអុកស៊ីសែននៅក្នុងឈាមទាប ហើយមានការកាត់បន្ថយលំហូរអុកស៊ីសែនពីឈាមទៅកាន់ខួរក្បាល ។ ការផ្តល់ឈាមទៅឲ្យសរីរាង្គខួរក្បាលមិនគ្រប់គ្រាន់ វាបណ្តាលមកពីការកាត់បន្ថយលំហូរអុកស៊ីសែនពីឈាមទៅខួរក្បាល ។ នៅពេលកោសិកាសរសៃប្រសាទខូច វាមិនអាចដូចដើមបានទេ ។



◆ **ឆ្អឹងបាក់៖** ដោយសារតែធ្វើសកម្មភាពប្រឆាំងនឹងស្ថានភាពដែលគេរារាំង ។ ការធ្វើឲ្យមុខងារខួរក្បាលចុះខ្សោយដោយសារតែកម្រិតទាបនៃអុកស៊ីសែននៅក្នុងឈាមគឺជាផលដែលអ្នកធ្វើទារុណកម្មចង់បាន ។ ការធ្វើឲ្យមានរបួសផ្លូវកាយនិងអំពើឃោរឃៅអាចធ្វើឲ្យជនរងគ្រោះបង្ហាញពីព័ត៌មាន ឬសារភាព ។

ពាក្យសម្រាលដែលធ្វើឲ្យជនរងគ្រោះទាំងនោះ «មិនស្រួល» គឺពិតជាខុស ។ តើខ្ញុំត្រូវយកចិត្តទុកដាក់ទៅលើអ្វីដែលកើតឡើងចំពោះជនរងគ្រោះឬទេ? មិនរាល់ពេលទេ ។ យ៉ាងណាមិញ នៅពេលដែលខ្ញុំបម្រើសេវាកម្មយោធា ខ្ញុំត្រូវបានបង្រៀនពីវិធានច្បាប់សង្គ្រាម និងអ្វីត្រូវធ្វើចំពោះអ្នកទោស ។ អ្វីដែលបានកើតឡើងវាផ្ទុយពីប្រពៃណីដែលល្អនិងខ្ពស់បំផុតនៃយោធារបស់សហរដ្ឋអាមេរិក ។

## ការលាក់កំបាំងនៅកណ្តាលវាល

អ្វីដែលច្បាស់គឺ នៅពេលដែល ប៊ូស គ្រប់គ្រង គេបានប្រើច្បាប់ដែលមានស្រាប់ធ្វើទៅលើអ្នកទោសដោយធ្វើឲ្យអ្នកទោសនៅក្រៅក្រមច្បាប់សង្គ្រាម និងនៅក្រៅអ្វីដែលត្រូវធ្វើទៅលើអ្នកទោសយោងតាមរដ្ឋាភិបាលអាមេរិក ។ ការពិតដែលថា គេប្រើពេលវេលាច្រើនដើម្បីធ្វើបែបនោះ ពីព្រោះគេដឹងថាសកម្មភាពដែលគេធ្វើគឺខុសច្បាប់ ។ ខ្ញុំយល់ច្បាស់ថា ហេតុផលចម្បងសម្រាប់ការប្រើប្រាស់ «យុត្តិសាស្ត្រសួរចម្លើយបន្ថែម» គឺដើម្បី «ស្វែងរក» ពួកអាល់កៃដា គឺអ្នកដែលជាប់ពាក់ព័ន្ធនឹងសង្គ្រាមអ៊ីរ៉ាក់ ។

ទស្សនៈធ្វើឡើងដោយអនុរដ្ឋមន្ត្រី ឈិន នី អ្នកសាធារណរដ្ឋ និងអ្នកជំនាញស្តាំនិយម ដែលថាការផ្សព្វផ្សាយវិធីសាស្ត្រត្រូវបានបោះពុម្ពនៅក្នុងឯកសារដែលមិនទាន់បានបែងចែកដែលមានឈ្មោះថាសៀវភៅក្បួនយុទ្ធសាស្ត្រកងទ័ព២១-៧៦-១ អាចបង្កគ្រោះថ្នាក់ដល់សន្តិសុខជាតិគឺគ្មានន័យ ។ វត្តមាននៃវិធីសាស្ត្រនេះមានភាពល្បីល្បាញដូចដែលបានកំណត់សម្គាល់នៅក្នុងឯកសារអាល់កៃដាដែលបានប្រមូល ។ ចរិតលក្ខណៈនៃ «ការសម្ងាត់» ចំពោះការធ្វើទារុណកម្មមានគោលបំណងលាក់កំបាំងមធ្យោបាយនៃការបង្កើតព័ត៌មានដើម្បីគាំទ្រសង្គ្រាមវៀតណាមមិនមែនការពារសន្តិសុខជាតិទេ ។

## តើយើងកំពុងស្វែងរកព័ត៌មានឬចម្លើយសារភាព?

ជាមួយនឹងសេចក្តីសន្និដ្ឋាននៅក្នុងចិត្ត វាមានសារសំខាន់ក្នុងការធ្វើកំណត់សម្គាល់អំពីភាពស្រដៀងគ្នារវាងការអនុវត្តដែលប្រើដោយខ្មែរក្រហម និងអ្នកដែលធ្វើការឲ្យ សេ អ៊ី អា និងយោធាអាមេរិក ។ វាមិនមែនជាការចៃដន្យទេ ។

យោងទៅតាមឯកសារដ៏ច្រើនលើសលុប «វិធីសាស្ត្របន្ថែម» ជាច្រើនមកដល់សេ.អ៊ី.អា និងអ្នកសួរចម្លើយកងទ័ពតាមរយៈសាលា *SERE* (ដែលបង្រៀនពីរបៀបធ្វើឲ្យរួចរស់ជីវិត គេចពីការចាប់ខ្លួន តស៊ូនឹងការធ្វើទារុណកម្មនិងគេចពីការឃុំឃាំង) ដែលជាកន្លែងដែលយោធាសហរដ្ឋអាមេរិកត្រូវបានបណ្តុះបណ្តាលពីរបៀបតបតនឹងការធ្វើទារុណកម្ម ប្រសិនបើត្រូវសត្រូវចាប់ខ្លួនបាន ។ ប្រភេទនៃការរំលោភបំពានដាក់លាក់ដែលយកមកបង្រៀនឲ្យតស៊ូ គឺវិធីសាស្ត្រដែលប្រើដោយសត្រូវនៅក្នុងសង្គ្រាមត្រជាក់ ។ ហេតុអ្វីបានជាវាមានទំនាក់ទំនងជាមួយកិច្ចពិភាក្សាបច្ចុប្បន្ន? ពីព្រោះវិធីសាស្ត្រធ្វើទារុណកម្មរបស់កូរ៉េខាងជើង វៀតណាមខាងជើង សហភាពសូវៀតនិងប្រទេសនៅក្រោមបង្គាប់ ហើយជារដ្ឋដែលយោធាអាមេរិកប្រឈមមុខនឹងទារុណកម្មមិនត្រូវបានគាក់តែងដើម្បីស្វែងរកព័ត៌មានពិតទេ ។ វិធីសាស្ត្រទាំងនេះត្រូវបានគាក់តែងដើម្បីចង់បានចម្លើយសារភាព ។ នេះគឺជាអ្វីដែលខ្មែរក្រហមនិងអ្នកដទៃទៀតយកមកធ្វើតាម ។ ព័ត៌មានដែលបានមកមិនមែនជាព័ត៌មានដែលអាចជឿជាក់បានទេ ។

## បញ្ហាភាពមិនលម្អៀង

បញ្ហាទារុណកម្មក៏ជាបញ្ហានៃភាពមិនលម្អៀងដែរ ។ អ្វីដែលប៊ូស ធ្វើនៅពេលគ្រប់គ្រងអំណាចបានរំលោភទៅលើលក្ខន្តិកៈអនុសញ្ញានិងគោលនយោបាយមួយចំនួនរបស់សហរដ្ឋអាមេរិក ។ ច្បាប់និងវិធានដែលកងទ័ពប្រុស-ស្រីកំពុងតែអនុវត្តនៅក្នុងគុកសហព័ន្ធគឺជាការរំលោភបំពាន ។ នៅពេលជាមួយគ្នានេះដែរមេដឹកនាំរស់នៅក្នុងសេរីភាព (ដែលពោរពេញទៅដោយការភ័យខ្លាច) ដោយនៅពីក្រោយមានការគាំទ្រអំពីបញ្ហា «វិធីសាស្ត្រសួរចម្លើយបន្ថែម» ។ ចំពោះខ្ញុំ ផ្លូវធ្វើដំណើរទៅមុខគឺមានភាពច្បាស់លាស់ ។

ខ្ញុំនិយាយថា អ្នកកាន់របបសាធារណរដ្ឋត្រូវមានភាពក្លាហានប្រឈមមុខនឹងសាលក្រមរបស់ខ្លួន ។ ឈប់លាក់ខ្លួននៅពីក្រោយការបកស្រាយពន្យល់ដែលមានភាពមិនច្បាស់លាស់និងមិនពិតអំពីរដ្ឋធម្មនុញ្ញនិងអំណាចបង្កើតច្បាប់ដើម្បីប្រើប្រាស់ ។ ឈប់បន្ថែមទស្សនៈគាំទ្រការធ្វើទារុណកម្មទៅលើទស្សនៈរបស់អ្នកសាធារណរដ្ឋ ។ អ្នកគាំទ្រសង្គ្រាមដែលមិនមានភាពក្លាហានត្រូវក្លាហានឡើង ។ ត្រូវមានភាពក្លាហានសម្តែងការពិតជាជាងលាក់ខ្លួននៅពីក្រោយ «ការកែតម្រូវនយោបាយដែលគ្រោះថ្នាក់» ដែលទាក់ទងនឹងវិធីសាស្ត្រសួរចម្លើយបន្ថែម ។

គួរតែបន្ធូរបន្ថយ ឬលើកលែងទោសដល់អ្នកបម្រើជួរកងទ័ពដែលត្រូវបានសម្រេចថាធ្វើបាបអ្នកទោសនៅពេលសួរសម្លើយនៅគុក អាប៊ូគ្រេប និងអាហ្វហ្កានីស្ថាន ។ បន្ទាប់មក អ្នកទាំងនោះត្រូវបានណែនាំឲ្យ «ធ្វើល្អ» ដាក់អ្នកទោសដើម្បីសួរចម្លើយ ។ ខ្ញុំឃើញថាមិនមានភាពខុសគ្នារវាង «ភ្នាក់ងារអាល់កៃដាថ្នាក់ខ្ពស់» និងថ្នាក់ក្រោមទេ ហើយចំពោះអ្នកនៅក្រោមបង្គាប់គោលការណ៍គឺមានភាពដូចគ្នា ។ អ្នកបម្រើកងទ័ពដែលរំលោភបំពានទៅលើអ្នកទោសដោយចិត្តខ្លួនឯងគួរតែទទួលការកាត់ទោស ។

ប្រសិនបើការលើកលែងទោសដល់អ្នកបម្រើកងទ័ពទាំងនោះស្ថិតនៅក្រៅឆន្ទៈនយោបាយរបស់ច្បាប់និងក្រៅនីតិប្រតិបត្តិ នោះយើងអាចកាត់ទោស ឬបញ្ឈប់ (ការងារឬការផ្តល់សេវាកម្ម) ជាមន្ត្រី ឬបុគ្គលិកស៊ីវិល និងអ្នកប្រតិបត្តិដែលដឹងគ្រប់យ៉ាងពីវិធីសាស្ត្រសួរចម្លើយបន្ថែម ។

**អ៊ីម.អ ព្រៃដ**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ *http://www.voanews.com/ khmer/democratic-kampuchea.cfm* របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ក្រោយពីសក្ខីកម្មដ៏ឈឺចាប់របស់ក្មេងរស់រានមានជីវិតពីមន្ទីរស-២១ ឌុច បដិសេធថា ក្មេងនេះមិនមែនជាអ្នកទោសរបស់មន្ទីរស-២១ទេ

អង្គជំនុំជម្រះរបស់តុលាការបានទទួលបាននូវសក្ខីកម្មពីលោក នង ចាន់ផល អាយុ ៣៩ឆ្នាំ អ្នករស់រានមានជីវិតទីបួនពីគុកទួលស្លែងដើម្បីចូលមកផ្ដល់នូវសក្ខីកម្មក្នុងតុលាការកាត់ទោសជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ឌុច) ។ អង្គជំនុំជម្រះបានគ្រោងពេលវេលាសម្រាប់សាក្សីចំនួនពីរនាក់ក្នុងថ្ងៃនេះ ដោយរំពឹងទុកថាសក្ខីកម្មរបស់ នង ចាន់ផល អាចនឹងសង្ខេបឲ្យខ្លីពីព្រោះថា នង ចាន់ផល នៅក្មេងណាស់ក្នុងអំឡុងពេលដែលគាត់រស់នៅក្នុងមន្ទីរស-២១ ។ យ៉ាងណាមិញ បញ្ហាភ័ស្ដុតាងនិងការបដិសេធរបស់ឌុច ដែលមិននឹកស្មានដល់ បានធ្វើឲ្យសក្ខីកម្មរបស់ នង ចាន់ផល មានភាពស្មុគស្មាញ ជាហេតុធ្វើឲ្យគ្មានពេលវេលាគ្រប់គ្រាន់សម្រាប់ការកោះហៅសាក្សីម្នាក់ទៀត ។ ទោះបីជា ចម្លើយឆ្លើយតបភាគច្រើនរបស់ នង ចាន់ផល និយាយថា «ខ្ញុំមិនបានចាំទេពីព្រោះថាខ្ញុំនៅក្មេងពេក» ក៏ដោយ ក៏ នង ចាន់ផល បានផ្ដល់នូវសក្ខីកម្មគួរឲ្យចាប់អារម្មណ៍យ៉ាងច្រើន ។

កាលពីដើមឆ្នាំនេះ នង ចាន់ផល បានខកខានក្នុងការដាក់ពាក្យធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីតាមថ្ងៃកំណត់ ។ ខណៈពេល នង ចាន់ផល បានខំប្រឹងប្រែងបន្តទៀត មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំពន្យារថ្ងៃផុតកំណត់ដាក់ពាក្យបណ្ដឹងដើម្បីទទួលយកនូវពាក្យបណ្ដឹងរបស់ នង ចាន់ផល ផ្ទុយទៅវិញសំណើនេះត្រូវបានបដិសេធ ។ ដូច្នេះ ថ្ងៃនេះ នង ចាន់ផល គ្រាន់តែលេចមុខឡើងក្នុងនាមជាសាក្សីរបស់អង្គហេតុ ហើយនិងមិនចូលរួមក្នុងការជួសជុលសំណងខូចខាតដែលចៅក្រមអាចនឹងផ្ដល់ឲ្យនៅក្នុងសេចក្ដីសម្រេចចុងក្រោយឡើយ ។

### ភ័ស្ដុតាងដែលជំទាស់បានពន្យារពេលដល់សក្ខីកម្មរបស់សាក្សី

ក្នុងដំណើរការនីតិវិធីដំបូង ព្រះរាជអាជ្ញាបានប្រកាសនូវសំណើពីរ ។ ទីមួយ ព្រះរាជអាជ្ញាបានស្នើសុំឲ្យចៅក្រមយកចិត្តទុកដាក់ទៅលើសារណាដែលទើបតែបានដាក់កាលពីម៉ោង៩ព្រឹកនេះ ។ សារណានេះបានបន្ថែមលើសំណុំរឿងទាក់ទងជាមួយនឹងបទសម្ភាសរបស់ នង ចាន់ផល ធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាជាអង្គការក្រៅរដ្ឋាភិបាលដែលមានទីតាំងនៅភ្នំពេញ ។ ព្រះរាជអាជ្ញាបានបន្តស្នើសុំភាគីដើមបណ្ដឹងរដ្ឋប្បវេណីគួរតែត្រូវបានអនុញ្ញាតឲ្យនិយាយអំពីឯកសារនេះក្នុងដំណើរការនីតិវិធីថ្ងៃនេះ ។ ខណៈពេលដែលព្រះរាជអាជ្ញាបានទទួលបានបទសម្ភាសន៍នេះតាំងពីខែកុម្ភៈ ឆ្នាំ២០០៩ បទសម្ភាសនេះត្រូវបានបំភ្លេចក្រោយពី នង ចាន់ផល ខកខានមិនបានដាក់ពាក្យធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី ។ រាល់ឯកសារទាំងអស់ដែលបានភ្ជាប់ជាមួយ ដើម្បីទទួលស្គាល់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដោយស្វ័យប្រវត្តិ ។

សំណើទីពីរ ព្រះរាជអាជ្ញាបានស្នើសុំថា ចៅក្រមគួរតែបញ្ចាំងខ្សែវីឌីអូពីរផ្ដល់ឲ្យដោយរដ្ឋាភិបាលវៀតណាមដែលព្រះរាជអាជ្ញាបញ្ជាក់ថា វីឌីអូនេះបានថតភ្លាមៗក្រោយពី ឌុច បានភៀសខ្លួនក្នុងខែមករា ឆ្នាំ១៩៧៩ ។ ដោយសារតែមេធាវីការពារបានជំទាស់លើភាពត្រឹមត្រូវតាមច្បាប់អំពីរូបភាពរបស់ខ្សែវីឌីអូទាំងនេះ ចៅក្រមមិនទាន់បានសន្និដ្ឋានថាតើខ្សែវិឌីអូដកស្រង់នឹងត្រូវបានអនុញ្ញាតឲ្យធ្វើជាភ័ស្ដុតាងនោះទេ ។ ចៅក្រមបានបញ្ជាក់យ៉ាងច្បាស់រហូតដល់ទៅបីលើកថា ការបញ្ចាំងខ្សែវីឌីអូដកស្រង់នេះមិនទាន់សម្រេចនៅឡើយទេ ។ ព្រះរាជអាជ្ញាបានស្នើថា ខ្សែវីឌីអូដកស្រង់ទាំងនេះគួរតែត្រូវបានអនុញ្ញាតឲ្យបញ្ចាំងដើម្បីឲ្យសាក្សីដែលមានវត្តមានក្នុងខ្សែវីដេអូបាននិយាយបកស្រាយឲ្យបានត្រឹមត្រូវតាមច្បាប់យថាភាពថា ខ្សែវីឌីអូដកស្រង់ គឺពិតជាទាក់ទងជាមួយនឹង «ទិដ្ឋភាពទាំងអស់របស់សំណុំរឿងនេះ» ដែលអាចផ្ដល់ភ័ស្ដុតាងពីស្ថានភាពការសម្លាប់ និងឧបករណ៍ធ្វើទារុណកម្ម ។

ក្រោយពីការបំភ្លឺសំណួរ និងការបដិសេធជាច្រើនពីមេធាវីការពារក្ដីលើបញ្ហាសំណើទាំងពីរនេះមក ចៅក្រមបានឈប់សម្រាករយៈពេល៤៥នាទីមុននឹងធ្វើការសម្រេចបដិសេធលើសំណើរនេះ ។ ទាក់ទងជាមួយនឹងបទសម្ភាសរបស់ នង ចាន់ផល ចៅក្រមបាន

កត់សម្គាល់ថា ខណៈពេលដែលទទួលបាននូវបទសម្ភាសន៍នេះគាំង ពីខែកុម្ភៈ ព្រះរាជអាជ្ញាបានព្រងើយកន្តើយក្នុងការដាក់សំណុំរឿងនេះ រហូតមកទល់ព្រឹកនេះ ។ ជាលទ្ធផល មេធាវីការពារក្តីមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យនិងរៀបចំបទសម្ភាសនេះសារឡើងវិញទេ ។ ស្តីពីខ្សែវីឌីអូវិញ ចៅក្រមបានរក្សានូវគោលជំហររបស់ខ្លួនដដែលដោយនិយាយថា ចៅក្រមនឹងសម្រេចថានឹងត្រូវបង្ហាញខ្សែវីឌីអូដកស្រង់នេះនៅក្នុងកាលបរិច្ឆេទលើកក្រោយ ។

## រឿងរ៉ាវរបស់ នង ចាន់ផល

ឪពុករបស់ នង ចាន់ផល ជាកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាផ្នែកដាំងឈើសាងសង់ផ្លូវរទេះភ្លើង ។ នៅក្នុងអំឡុងឆ្នាំ ១៩៧៨ គ្រួសាររបស់ នង ចាន់ផល ដឹងថាឪពុករបស់ នង ចាន់ផល ត្រូវបានបញ្ជូនទៅភ្នំពេញ ។ ពីរបីខែក្រោយមក រថយន្តហ្ស៊ីបចំនួនពីរគ្រឿងបានឈប់នៅសហករណ៍កសិកម្មដែលជាកន្លែងគ្រួសាររបស់ នង ចាន់ផល កំពុងតែរស់នៅ ។ កងឈ្លបបានអះអាងថាពួកគេនឹងនាំយក នង ចាន់ផល ម្តាយ និងប្អូនប្រុសរបស់ នង ចាន់ផល ទៅភ្នំពេញដើម្បីជួបឪពុករបស់ នង ចាន់ផល ។ ក្រោយពីចំណាយពេលអស់ពីរ-បីថ្ងៃនៅស្ថានីយ៍រថភ្លើង គ្រួសាររបស់ នង ចាន់ផល រួមជាមួយនឹងស្ត្រី ពីរនាក់និងក្មេងៗបីនាក់ទៀតត្រូវបាននាំមកកាន់មន្ទីរស-២១ ។

ពេលបានមកដល់មន្ទីរស-២១ នង ចាន់ផល កាលនោះមានអាយុទើបតែប្រាំបីឆ្នាំ បានឃើញអ្នកយាមគុកវាយម្តាយគាត់ដែលកំពុងតែមានជំងឺ ។ ម្តាយ នង ចាន់ផល ត្រូវបានអ្នកយាមគុកគំរាមកំហែងនិងរុញច្រានឥតឈប់ឈរ ។ នៅពេលដែលម្តាយរបស់ នង ចាន់ផល ដួល គាត់ត្រូវបានអ្នកយាមគុកបោចសក់ បន្ទាប់មកទះធាត់ ហើយក្រោយមកនាំយកទៅថតរូប ។ នង ចាន់ផល បាននិយាយថា ប្អូនប្រុសរបស់គាត់អាយុទើបតែបួនឆ្នាំ បានអង្គុយលេងលើឥដ្ឋការ៉ូ ដោយសារគេនៅក្មេងពេក ដូច្នេះមិនដឹងថាមានរឿងអ្វីកំពុងតែកើតឡើងនោះទេ ជាពិសេសគឺមិនបានដឹងអំពីការវាយធ្វើបាបលើម្តាយឡើយ ។ ចំណែក នង ចាន់ផល វិញ បានចងចាំការវាយធ្វើបាបនោះយ៉ាងច្បាស់ ដោយគាត់បាននិយាយបន្ថែមថា «ខ្ញុំគក់ស្មុគយ៉ាងខ្លាំង» ។

គ្រួសារ នង ចាន់ផល ដែលមានគ្នាបីនាក់ រួមជាមួយនឹងស្ត្រី និងក្មេងៗដទៃទៀតដែលមកជាមួយនឹងគ្រួសារ នង ចាន់ផល ត្រូវបានយកទៅឃុំឃាំងនៅក្នុងគុកដ៏ធំមួយ ។ ក្មេងៗទាំងនោះម្នាក់មានអាយុប្រហែលបីឆ្នាំ ម្នាក់ទៀតអាយុតិចជាងបីឆ្នាំ ចំណែកម្នាក់ទៀតនៅបៅដោះម្តាយនៅឡើយ ។ ក្រោយពីបាននៅក្នុងគុកពេញមួយយប់ដោយគ្មានអាហារហូប នង ចាន់ផល ប្អូនប្រុសរបស់ នង ចាន់ផល និងក្មេងៗដទៃទៀតត្រូវបានបំបែកពីម្តាយរបស់គេ ។ នង ចាន់ផល និងក្មេងៗត្រូវបាននាំយកទៅទុកនៅក្នុង រោងជាងខាងក្រោយមន្ទីរស-២១ ដែលជាកន្លែងជាងឈើ ជាងគំនូរ និងជាងជួសជុលម៉ាស៊ីននៅក្បែរទ្រុងជ្រូក ។ ក្មេងៗទាំងអស់ត្រូវបានឃ្លាំមើលដោយស្ត្រីចំណាស់គួរឲ្យខ្លាចម្នាក់ ។ អស់រយៈពេលពីរបីសប្តាហ៍នៅក្នុងមន្ទីរស-២១ នង ចាន់ផល មិនបានហៅឲ្យទៅងូតទឹកទេ ។ ក្មេងៗនាំគ្នាដេកនៅលើក្តារនិងហូបបបររាវ លើកលែងតែទារកដែលនៅតូចពេកមិនអាចហូបបបរក៏បានស្លាប់ដោយសារតែភាពអត់ឃ្លាន ។ នង ចាន់ផល បានរំឭកថា មានស្រមោចរ៉ាវចេញចូលតាមត្រចៀក និងមាត់របស់ទារកដែលបានស្លាប់នោះ ។


TSL 6245
7

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

១- ឈ្មោះដើម មុំ.ឈឿ . ឈ្មោះក្លែង
២- អាយុ ៥០ ឆ្នាំ ភេទ ស្រី ជនជាតិ ខ្មែរ.
៣- ក្រសួងនិងធ្លាប់ធ្វើការពីដើមមក និងបច្ចុប្បន្ន
៤- កើតនៅភូមិ ... ឃុំ ... ស្រុក ... តំបន់ ៣៥.
៥- ឪពុកឈ្មោះ មុំ. ... ម្តាយឈ្មោះ ...
៦- ...
៧- ប្តី ឬ ប្រពន្ធ ឈ្មោះដើម ... ឈ្មោះក្លែង
៨- កើតនៅភូមិ ... ឃុំ ... ស្រុក ... តំបន់ ៣៥
៩- ក្រសួង-នាទី និងការងាររបស់នៅបច្ចុប្បន្ន
១០- មានកូនប្រុសចំនួន ៤ នាក់ កូនស្រី ៣ នាក់
១១- ទីកន្លែងចាប់ខ្លួន ...
១២- ចាប់ខ្លួន ថ្ងៃទី ១ ខែ ១ ឆ្នាំ ១៩៧៨ ។ ម៉ោង ... បញ្ជូនមក ... រូប
កិតភាគ
កំពស់ : ១៧៥២.
ប្រវត្តិរូបចំនួន : ០៧៧៨

ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា K08732

នង ចាន់ផល អាចមើលឃើញបង្អួចគុកដែលគាត់ និងម្ដាយគាត់ត្រូវបានឃុំខ្លួនពីរោងជាងដែល នង ចាន់ផល រស់នៅ ។ មានម្ដងនោះ នង ចាន់ផល បានឃើញម្ដាយរបស់គាត់ឈរនៅមាត់បង្អួចដោយដៃរបស់គាត់ទាំងពីរតោងចម្រឹងបង្អួច ។ ពេលនោះគឺជាពេលចុងក្រោយដែល នង ចាន់ផល បានឃើញម្ដាយរបស់គាត់ ។ នង ចាន់ផល បាននិយាយថា គាត់បានឮសំឡេងស្រែកជាញឹកញាប់ ប៉ុន្តែ នង ចាន់ផល មិនដឹងថាសម្លេងនោះចេញពីកន្លែងណាទេ ។ នង ចាន់ផល តែងតែសំឡេងមើលបង្អួចនោះជានិច្ច ។

នង ចាន់ផល បាននិយាយអធិប្បាយពីភាពចលាចលកើតឡើងកាលពីខែមករា ឆ្នាំ១៩៧៩ ជាពេលដែលគ្រាប់ផ្លោងចាប់ផ្ដើមធ្លាក់នៅមន្ទីរស-២១ ហើយមនុស្សនាំគ្នាភៀសខ្លួនចេញ ។ ស្ត្រីបោសសម្អាតអគារចំណាស់ម្នាក់បានព្យាយាមនាំ នង ចាន់ផល ចេញពីមន្ទីរស-២១ជាមួយនាង ប៉ុន្តែ នង ចាន់ផល បានបដិសេធមិនព្រមចាកចេញ ដោយគ្មានម្ដាយរបស់គាត់ ។ នង ចាន់ផល បានចូលពួននៅក្នុងគំនរដាក់ខោអាវនៅក្បែរអគារជាកន្លែងដែលគាត់គិតថាម្ដាយគាត់នៅជាប់ឃុំឃាំងដោយសង្ឃឹមរង់ចាំម្ដាយគាត់ចេញមកក្រៅ ។ ខណៈពេលនោះ នង ចាន់ផល បានសម្រេចចិត្តរត់ទៅតាមជួរអគាររកម្ដាយគាត់ ។ ផ្ទុយទៅវិញ នង ចាន់ផល បានឃើញមនុស្សជាប់ច្រវាក់នៅលើគ្រែទើបតែនឹងស្លាប់ថ្មីៗ ដោយមានសត្វរុយរោមជុំវិញ ។ ទិដ្ឋភាពបែបនេះបានធ្វើឲ្យ នង ចាន់ផល មានភាពភ័យខ្លាចយ៉ាងខ្លាំង ដូច្នេះហើយ នង ចាន់ផល ក៏សម្រេចចិត្តរត់មកកាន់រោងជាងវិញ ហើយនៅជាមួយនិងក្មេងដទៃទៀត ។ ក្មេងៗភ័យញ័រខ្លួន ខណៈពេលដែលឮគ្រាប់ធ្លាក់ក្បែរទីតាំងមន្ទីរស-២១ ។ នង ចាន់ផល បានដឹកទឹកភ្លៀងពីក្រឡបែក ហើយបានហូបបបរដួមដែលនៅសល់ ។ ប្រហែលជាមួយថ្ងៃក្រោយមកទាហានវៀតណាមពីរនាក់បានរកឃើញក្មេងៗ ហើយបានដាំបាយនិងស្ងោរទាឲ្យក្មេងៗហូបមុននឹងចាកចេញពីមន្ទីរស-២១ ។ ប្រហែលជាមួយថ្ងៃក្រោយមកទៀត ក្រុមទាហានកម្ពុជា និងវៀតណាមជាច្រើនបានមកដល់មន្ទីរស-២១ ។ ទាហានទាំងអស់នេះបានសួរក្មេងៗនូវសំណួរជាច្រើនទាក់ទងនឹងឪពុកម្ដាយរបស់ពួកគេថាតើពួកគេមកពីណា ។ ដោយកត់សម្គាល់ពីស្ថានភាពជំងឺនិងភាពអត់ឃ្លានរបស់ក្មេងៗ ទាហានទាំងអស់នោះបាននាំពួកគេទៅកាន់មន្ទីរពេទ្យនៅក្បែរនោះ ប៉ុន្តែដោយឡែក នង ចាន់ផល ត្រូវបានដាក់នៅបន្ទប់ដាច់ដោយឡែក ។ នង ចាន់ផល ភ័យខ្លាចនឹងចាកចេញពីមន្ទីរស-២១ នោះណាស់ ពីព្រោះគាត់មិនដឹងថា ម្ដាយរបស់គាត់នឹងរកគាត់ឃើញដោយវិធីណានោះទេ ។ ក្រោយពីបានរស់នៅជាមួយនឹងទាហានអស់មួយរយៈពេលក្រោយមក នង ចាន់ផល ត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងគ្រឹះស្ថានក្មេងកំព្រា ។

បន្ទាប់ពីចាកចេញពីមន្ទីរស-២១មក នង ចាន់ផល បានទៅទស្សនាទីកន្លែងនោះដែលក្រោយមកក្លាយជាសារមន្ទីរដោយសារតែគាត់នឹកម្ដាយរបស់គាត់ ។ មានម្ដងនោះ ពេលដែលគាត់បានទៅទស្សនាសារមន្ទីរ អតីតជាងជួសជុលម៉ាស៊ីននៅឯរោងជាងមន្ទីរស-២១ ដែលបានធ្វើជាអ្នកថែសួននៅសារមន្ទីរបានចំណាំមុខ នង ចាន់ផល ហើយបានប្រាប់ នង ចាន់ផល ឲ្យបំភ្លេចចោលនូវទុក្ខវេទនាក្នុងនៅមន្ទីរស-២១នោះទៅ ។

ខណៈពេលដែលត្រូវបានសួរថា តើ នង ចាន់ផល ចង់បានអ្វីពីតុលាការនេះ? នង ចាន់ផល បានឆ្លើយតបថា «ខ្ញុំចង់បានយុត្តិធម៌សម្រាប់ឪពុកម្ដាយរបស់ខ្ញុំតែប៉ុណ្ណោះ» ។ ប្រវត្តិរូបឪពុករបស់ នង ចាន់ផល ត្រូវបានរកឃើញនៅក្នុងមន្ទីរស-២១ ដោយឡែកគ្មានភស្តុតាងណាមួយឡើយ នៅក្នុងសំណុំរឿងដែលទាក់ទងនឹងម្ដាយរបស់ នង ចាន់ផល ។ ក្នុងពេលផ្ដល់សក្ខីកម្ម នង ចាន់ផល មិនសូវបានឆ្លើយតបនឹងសំណួរដែលទាក់ទងនឹងម្ដាយរបស់គាត់ប៉ុន្មានទេដោយសារតែគាត់មិនអាចទប់ទឹកភ្នែករបស់គាត់បាន ។

## ឌុច ទទួលស្គាល់ពីទុក្ខវេទនា ប៉ុន្តែបានបដិសេធលើទីកន្លែង

ចំនួនអ្នកទោសដែលត្រូវបានសម្លាប់មុនពេលដែល ឌុច បានភៀសខ្លួនចេញពីមន្ទីរស-២១ កាលពីដើមខែមករា ឆ្នាំ១៩៧៩ គឺជាអង្គហេតុវិវាទមួយ ។ ឌុច បានអះអាងថា មានតែអ្នកទោសបួននាក់ប៉ុណ្ណោះត្រូវបានសម្លាប់ក្នុងថ្ងៃនោះ ចំណែកអ្នកទោសជាច្រើននាក់ទៀតបានសម្លាប់នៅថ្ងៃបន្តបន្ទាប់រហូតដល់ថ្ងៃភៀសខ្លួន ។ មានរណ្ដៅចំនួន១៤នៅក្នុងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសម្រាប់កប់សាកសពដែលត្រូវបានអះអាងថា រកឃើញនៅទីនោះដោយកងទ័ពវៀតណាម ។ សក្ខីកម្មរបស់សាក្សីបានបញ្ជាក់បន្ថែមលើចំនួនអ្នកទោសទាំងអស់នេះ ។ បើពិចារណាលើសក្ខីកម្មរបស់ នង ចាន់ផល ទាក់ទងនឹងសាកសពដែល នង ចាន់ផល បានឃើញ

ជាប់ច្រវាក់នៅលើគ្រែក្រោយពីការកៀសខ្លួន មេធាវីម្នាក់ក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យលោកប្រធានអនុញ្ញាតឲ្យ ឌុច ធ្វើអធិប្បាយពីបញ្ហានេះ ។ លោកប្រធានបានអនុញ្ញាតឲ្យ ឌុច ធ្វើការអធិប្បាយ ហើយបានណែនាំ ឌុច មិនឲ្យចំណាយពេលលើការបកស្រាយអំពីការទទួលស្គាល់ទំនួលខុសត្រូវ ដែល ឌុច មានបំណងធ្វើឡើងក្នុងរយៈពេលយូរទេ ។ ប៉ុន្តែ ឌុច គួរតែបង្កើតការផ្តោតទៅលើព័ត៌មានទាក់ទងនឹងចំនួនសាកសពវិញប្រសើរជាង ។ ច្បាស់ណាស់ លោកប្រធានមិនបានប្រមើមើលទុកជាមុនអំពីការឆ្លើយតបរបស់ ឌុច ទេ ។

ឌុច បាននិយាយថា គាត់ទទួលស្គាល់ពីទុក្ខវេទនារបស់ នង ចាន់ផល ប៉ុន្តែ ឌុច មិនទទួលស្គាល់ថា នង ចាន់ផល ជាអ្នកទោសមន្ទីរស-២១ទេ ។ ឌុច បានពន្យល់ថា គាត់ទទួលស្គាល់ឪពុករបស់ នង ចាន់ផល ពិតជាអ្នកទោសរបស់មន្ទីរស-២១មែនដោយយោងតាមប្រវត្តិរូបដែលបានបង្ហាញក្នុងដំណើរការនីតិវិធីនេះ ។ យ៉ាងណាមិញ ឌុច នៅតែប្រកាន់ជំហរថាគ្មានក្មេងណាម្នាក់អាចរត់រួចពីមន្ទីរស-២១បានទេ ហើយក្មេងទាំងអស់ត្រូវបានសម្លាប់ចោលតាមបញ្ជារបស់ នួន ជា មុនពេលការជម្លៀសចាប់ផ្តើមឡើង ។ ដូច្នេះ នង ចាន់ផល តាមមើលទៅប្រហែលជាត្រូវបានជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខបក្សកុម្មុយនីស្តកម្ពុជានៅកន្លែងផ្សេង ។ ដោយមិនមានរូបថត និង ឯកសារទាក់ទងនឹងម្តាយរបស់ នង ចាន់ផល ឌុច ក៏បានបដិសេធមិនទទួលស្គាល់ថាម្តាយ នង ចាន់ផល បានជាប់ឃុំឃាំងនៅមន្ទីរស-២១ទេ ។ ឌុច បាននិយាយថា «តើពួកគេទទួលទុក្ខវេទនានៅកន្លែងណា? ខ្ញុំមានភាពមិនច្បាស់លាស់សោះចំពោះបញ្ហានេះ» ។ ក្រោយមក ឌុច បានឆ្លើយដោយសង្ខេបទាក់ទងនឹងចំនួនសាកសពដោយប្រកាន់ជំហរដដែលថាអ្នកទោសចំនួនតែបួននាក់ប៉ុណ្ណោះត្រូវបានសម្លាប់នៅថ្ងៃចុងក្រោយនៅមន្ទីរស-២១ ។

មនុស្សគ្រប់គ្នានៅក្នុងបន្ទប់សវនាការមានអារម្មណ៍ភ្ញាក់ផ្អើល ។ ចៅក្រម ខាតព្រ៉ាយ បានស្នើឲ្យ ឌុច ពិភាក្សាជាមួយមេធាវីរបស់ខ្លួនបើចាំបាច់ ។ ចៅក្រម ឡាវើញ បានសួរបញ្ជាក់ឡើងវិញជាច្រើនដើម្បីធានាថា គាត់បានឮ ឌុច ត្រឹមត្រូវច្បាស់លាស់ ហើយក្រោយមកឲ្យ ឌុច និយាយសាឡើងវិញម្តងទៀត ។

ទោះបីជាយោងតាមវិធានតាំងពីដំបូងរបស់ចៅក្រមក៏ដោយ ក៏ក្នុងអំឡុងពេលសួរសំណួរព្រះរាជអាជ្ញា បានព្យាយាមដាក់បង្ហាញរូបភាពដកស្រង់មួយដែលបានពីខ្សែវីឌីអូដកស្រង់របស់វៀតណាមនៅលើកញ្ចក់អេក្រង់ ដើម្បីឲ្យសាក្សីអាចបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន ។ គោលបំណងត្រូវបានបដិសេធ ។ ដោយក្តាប់បាននូវឱកាសដើម្បីលើកឡើងបញ្ហាខ្សែវីឌីអូដកស្រង់នោះម្តងទៀត ព្រះរាជអាជ្ញាបានជំទាស់ថា ប្រសិនបើ ឌុច ពិតជាបានអះអាងថា នង ចាន់ផល មិនដែលជាប់នៅក្នុងមន្ទីរស-២១ ប្រាកដមែននោះ ចៅក្រមគួរតែចាក់បង្ហាញខ្សែវីឌីអូនៅក្នុងថ្ងៃនេះ ឬយ៉ាងហោចណាស់គួរតែអញ្ជើញ នង ចាន់ផល ឲ្យមកធ្វើការអធិប្បាយម្តងទៀតតាមកាលបរិច្ឆេទក្នុងពេលអនាគត ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានស្នើសុំឲ្យចៅក្រមចាក់បង្ហាញខ្សែវីឌីអូដកស្រង់នេះដូចគ្នា ។ បន្ថែមពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ថាកាលពីថ្ងៃ៣០ ខែមីនា មេធាវីការពារបានទទួលស្គាល់ នង ចាន់ផល ជាអ្នករស់រានមានជីវិត ផ្ទុយទៅវិញ មេធាវីការពារបែរជាជំទាស់បដិសេធលើឯកសារដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់ នង ចាន់ផល នៅពេលនេះទៅវិញ ដោយជំទាស់ថា ដោយសារតែ ឌុច មិនបានប្រកែកថា ពិតជាមានក្មេងនៅមន្ទីរស-២១មែន នោះសក្ខីកម្មរបស់ នង ចាន់ផល ពិតជាគ្មានសារសំខាន់អ្វីឡើយ ។

ក្នុងដំណើរការសម្របសម្រួលដ៏គួរឲ្យភ្ញាក់ផ្អើល ចៅក្រម ខាតព្រ៉ាយ បានសម្រេចចាក់បង្ហាញរូបភាពដកស្រង់ចេញពីខ្សែវីឌីអូរបស់វៀតណាម ដោយក្នុងនោះគេឃើញមានក្មេងប្រុសពីរនាក់មិនមានស្លៀកខោអាវឈរនៅពីមុខទាហានមួយក្រុម ។ មេធាវីម្នាក់ក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានញញឹមយ៉ាងរីករាយ ។ នង ចាន់ផល បានបញ្ជាក់ថាក្មេងទាំងពីរនាក់នោះគឺជារូបគាត់ និងប្អូនប្រុសរបស់គាត់កាលពីថ្ងៃដែលពួកគាត់ចាកចេញពីមន្ទីរស-២១ ។ នង ចាន់ផល បាននិយាយនៅពេលនោះថាគាត់មិនដឹងថាពួកគាត់ត្រូវបានគេថតរូបនៅក្នុងពេលនោះទេ ។

អ្នករស់រានមានជីវិតពីមន្ទីរស-២១ម្នាក់ទៀតនឹងចូលមកឆ្លើយនឹងសំណួរនៅថ្ងៃច័ន្ទនេះ ។ សម្រាប់សុវត្ថិភាពរបស់សាក្សី ឈ្មោះរបស់សាក្សីមិនត្រូវបានប្រកាសឲ្យដឹងជាមុនឡើយ ។

**ឡូរ៉ា ម៉ាក់ដូណាល**

# ពីរទសវត្សរ៍នៃគណៈកម្មការស្វែងរកការពិតរបស់កម្ពុជា

ការផ្សះផ្សានិងការដោះស្រាយអំពើរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំ ដូចជាអំពើរំលោភសិទ្ធិមនុស្សដែលមានលក្ខណៈធ្ងន់ធ្ងរដូចជាអំពើប្រល័យពូជសាសន៍ជាដើម តម្រូវឲ្យមានវិធានការដោះស្រាយលើសពីដំណោះស្រាយតាមផ្លូវច្បាប់ ។ ជាក់ស្តែង ប្រសិនបើយើងក្រឡេកមើលដំណើរការកន្លងមករបស់តុលាការអន្តរជាតិ ជាតិ និងតុលាការចម្រុះវិញ យុត្តិធម៌តាមផ្លូវច្បាប់តែមួយមុខមិនអាចដោះស្រាយបញ្ហាជម្លោះពីអតីតកាលឲ្យបានពេញលេញទាំងស្រុងនោះទេ ។ ជាពិសេស តុលាការដែលធ្វើការកាត់ទោសតែមនុស្សមួយក្តាប់តូច ដោយទុកឲ្យជនដៃដល់រាប់រយពាន់នាក់ទៀតរួចខ្លួនហាក់ដូចជាធ្វើឲ្យជនរងគ្រោះមិនអស់ចិត្ត ហើយពួកគេត្រូវការយន្តការយុត្តិធម៌ផ្សេងពីនេះកាន់តែខ្លាំងថែមទៀត ។ ក្នុងកាលៈទេសៈនេះ អ្នកខ្លះបានស្នើសុំឲ្យបង្កើតគណៈកម្មការស្វែងរកការពិតដោយសារគេគិតដល់តួនាទីដ៏មានតម្លៃពិតប្រាកដរបស់គណៈកម្មការនេះនៅក្នុងដំណើរការផ្សះផ្សាកម្រិតជាតិ និងកម្រិតបុគ្គល ។

កាលពីប៉ុន្មានឆ្នាំមុន ទន្ទឹមនឹងពេលដែលគេរំពឹងថានឹងមានការបង្កើតតុលាការខ្មែរក្រហម អ្នកជំនាញនិងសកម្មជនជាច្រើនបានគាំទ្រយោបល់ឲ្យបង្កើតគណៈកម្មការស្វែងរកការពិតមួយនៅកម្ពុជា ។ ប៉ុន្តែអ្វីដែលអ្នកទាំងនោះមិនបានយល់ឲ្យច្បាស់នោះគឺថាកិច្ចខិតខំប្រឹងប្រែងធ្វើការស៊ើបអង្កេតនិងចងក្រងឯកសារស្តីពី



លោក ខី ខាំបូលី ចែកសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ជូនសិស្សានុសិស្ស

អំពើឃោរឃៅរបស់រដ្ឋាភិបាលចាស់ ដែលកិច្ចការនេះជារបស់គណៈកម្មការស្វែងរកការពិតនោះត្រូវបានចាប់ផ្តើមដំណើរការនៅក្នុងប្រទេសកម្ពុជាកាលពី២០ឆ្នាំកន្លងមក ។ បទពិសោធន៍របស់ប្រទេសកម្ពុជាក្នុងការបង្កើតគណៈកម្មការស្វែងរកការពិតនេះ បើទោះបីជាពេលខ្លះមានការរំខាននិងមានលក្ខណៈប្លែកៗទៅតាមពេលវេលាក៏ដោយ ក៏សហគមន៍អន្តរជាតិមិនគួរត្រូវមើលរំលងដែរ ។ លើសពីនេះទៅទៀត បទពិសោធន៍កម្ពុជានេះអាចជាគំរូមួយសម្រាប់ប្រទេសក្រោយជម្លោះបញ្ចប់ទៅក្នុងករណីដែលប្រទេសទាំងនេះមានទស្សនៈផ្នែកសាសនាមិនដូចគ្នាទៅនឹងបស្ចិមប្រទេស ។ សម្រាប់ប្រទេសទាំងនេះ ទស្សនៈអំពីការសារភាពនិងការអត់ឱនទោសមានការខុសប្លែកគ្នាយ៉ាងខ្លាំង ហើយភាពខុសប្លែកគ្នាទាំងនេះគួរតែត្រូវយកមកពិចារណានៅពេលសម្រេចលើបែបបទនិងតួនាទីរបស់គណៈកម្មការស្វែងរកការពិត ។

បើពិនិត្យមើលអំពីដំណើរដ៏វែងឆ្ងាយរបស់កម្ពុជានៅក្នុងការលាតត្រដាងនិងការកត់ត្រានូវអំពើឃោរឃៅរបស់របបខ្មែរក្រហម យើងបានរកឃើញនូវវិធានការច្បាស់លាស់និងខុសប្លែកៗគ្នាជាច្រើន ។ វិធានការទីមួយ គឺការប្រមូលព័ត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់អំពីការខូចខាតនិងការស្លាប់របស់ជនរងគ្រោះដំណាលគ្នានឹងការប្រមូលហត្ថលេខាពីមនុស្សជាងមួយលាននាក់ ។ ទាំងនេះគឺមាននៅក្នុងឯកសារញត្តិរណសិរ្សកាលពីឆ្នាំ១៩៨២ ដែលញត្តិនេះបានស្នើសុំជំនួយពីសហគមន៍អន្តរជាតិឲ្យកាត់ទោសឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ។ វិធានការដទៃទៀតនៅក្នុងទសវត្សរ៍៨០ រួមមានការស្ថាបនាបូជនីយដ្ឋានចំនួន៨៨នៅទូទាំងប្រទេសនិងការកសាងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនៅរាជធានីភ្នំពេញ ។ ច្បាប់ស្តីអំពីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលត្រូវបានអនុម័តកាលពីឆ្នាំ១៩៩៤ ក៏ដូចជាកម្មវិធីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាមានតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់ដល់ការស៊ើបអង្កេតនិងការកត់ត្រាឯកសារឧក្រិដ្ឋកម្មខ្មែរក្រហម ។ ផ្តើមចេញពីកិច្ចខិតខំប្រឹងប្រែងទាំងពីរនេះ មជ្ឈមណ្ឌលស្រាវជ្រាវមួយត្រូវបានបង្កើតឡើង ហើយគោលបំណងសំខាន់បំផុតរបស់មជ្ឈមណ្ឌលនេះគឺកត់ត្រានិងស្រាវជ្រាវអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយមានជំនួយពីសំណាក់អ្នកជំនាញអន្តរជាតិនិងការគាំទ្រពីសំណាក់ប្រជាជនសាមញ្ញដ៏ច្រើនលើសលប់កាលពី១០ឆ្នាំកន្លងមក មជ្ឈមណ្ឌលស្រាវជ្រាវនេះបានធ្វើជាផែនទីរណ្តៅសាកសពដែលនៅក្នុងផែនទីនោះមានរណ្តៅចំនួន១៩,០០០កន្លែង បោះពុម្ពផ្សាយសៀវភៅជាង២០ក្បាល និងបោះពុម្ពទស្សនាវដ្តីដែលចុះផ្សាយរៀងរាល់ខែ ព្រមទាំងបានលើកកម្ពស់តួនាទីរបស់ជនរងគ្រោះនិងអ្នករស់រានមានជីវិតក្នុងដំណើរការផ្សះផ្សាផ្លូវចិត្ត ។ កិច្ចការសំខាន់បំផុតកន្លងមកនេះគឺជាគម្រោងសហប្រតិបត្តិការជាមួយនឹងក្រសួងអប់រំ ដើម្បីការបង្រៀនពីអំពើប្រល័យពូជសាសន៍ទូទាំងប្រទេស ។

គណៈកម្មការស្វែងរកការពិតរបស់កម្ពុជា ឬហៅម្យ៉ាងទៀតថាគណៈកម្មការស្វែងរកការពិតតាមបែបកម្ពុជាបានផ្តល់នូវទស្សនៈមួយចំនួនចំពោះយន្តការយុត្តិធម៌មួយនេះ ។ ដំបូងបង្អស់ គោលបំណងរបស់គណៈកម្មការស្វែងរកការពិតមិនចាំបាច់ត្រូវតែធ្វើឡើងនៅក្នុងទម្រង់ជាគណៈកម្មការនោះទេ ។ ញត្តិ បូជនីយដ្ឋាន សារមន្ទីរ មជ្ឈមណ្ឌលស្រាវជ្រាវនិងការអប់រំពីអំពើប្រល័យពូជសាសន៍ប្រហែលអាចជាវិធានការសមស្របទៅនឹងស្ថានភាពជាក់ស្តែងជាងគណៈកម្មការនោះទៀតផង ។ ទីពីរ ទឹកប្រាក់ចំនួនរាប់លានដុល្លារនិងឆន្ទៈនយោបាយដ៏រឹងមាំមិនចាំបាច់តម្រូវឲ្យមានជាមុននោះទេ ។ ការផ្តួចផ្តើមគំនិតពីសំណាក់ប្រជាជនថ្នាក់មូលដ្ឋាននិងមនសិការខិតខំប្រឹងប្រែងអាចជួយកាត់បន្ថយការចំណាយលើផ្នែកនយោបាយនិងសេដ្ឋកិច្ច ។ ទីបី ការអប់រំទូទាំងប្រទេសស្តីពីអំពើប្រល័យពូជសាសន៍កាលពីអតីតកាលគួរតែជាធាតុដ៏សំខាន់មួយឈានទៅរកការសម្រេចបាននូវគោលបំណងសំខាន់របស់គណៈកម្មការស្វែងរកការពិត ពោលគឺការផ្សះផ្សានិងការធូរស្បើយផ្លូវចិត្ត ។ ដូចដែលយើងបានឃើញនៅក្នុងករណីអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងរយៈកាលពីរទសវត្សរ៍កន្លងមក វាតម្រូវឲ្យមានការយល់ដឹងកាន់តែទូលំទូលាយជាងនេះទៅទៀតនិងរបៀបក្នុងការបង្កើតគណៈកម្មការស្វែងរកការពិតនេះ ដែលនេះតម្រូវឲ្យពិនិត្យមើលអំពីភាពខុសគ្នារបស់ប្រទេសនីមួយៗនិងគោលដៅសំខាន់របស់គណៈកម្មការស្វែងរកការពិត ព្រមទាំងវិធីសាស្ត្រផ្សេងៗដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ។ **កែវ ជាស៊ីល**

# ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

### តើពាក្យ «ប្រល័យពូជសាសន៍» មានប្រភពចេញមកពីណា?

មុនសង្រ្គាមលោកលើកទីពីរ(១៩៣៩-១៩៤៥) ពាក្យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនទាន់មាននៅឡើយទេ ។ វាជាឧក្រិដ្ឋកម្មដែលមិនទាន់មានឈ្មោះ ។ ពាក្យប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដោយមេធាវីម្នាក់ដែលយល់ថា ការប៉ុនប៉ងកម្ទេចជនជាតិជ្វីហ្វដោយរបបណាហ្ស៊ីអាល្លឺម៉ង់ គឺជាឧក្រិដ្ឋកម្មដែលអាក្រក់ជាងការសម្លាប់ទៅទៀត ។

### អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍

នៅខែធ្នូ ឆ្នាំ១៩៤៨ មិនយូរប៉ុន្មានបន្ទាប់ពីសង្រ្គាមលោកលើកទីពីរបានបញ្ចប់ អង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ កម្ពុជានិងប្រទេសភាគច្រើនផ្សេងទៀតនៅលើពិភពលោកបានចុះហត្ថលេខាលើអនុសញ្ញានេះ ។ អនុសញ្ញាទទួលស្គាល់អំពើប្រល័យពូជសាសន៍ថាជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបំផុត ។ គ្រប់ប្រទេសដែលចុះហត្ថលេខាលើអនុសញ្ញាបានធ្វើការការពារនិងដាក់ទោសអំពើប្រល័យពូជសាសន៍ ។

### តើអ្វីជាអំពើប្រល័យពូជសាសន៍?

ជនណាម្នាក់បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅពេលដែលជននោះប្រព្រឹត្តអំពើនោះដោយចេតនាបំផ្លាញក្រុមសាសនា ពូជសាសន៍ ជាតិពន្ធុ ឬជនជាតិ ។ អំពើប្រល័យពូជសាសន៍មិនចាំបាច់ថាត្រូវតែសំដៅទៅលើការបំផ្លាញក្រុមទាំងមូលនោះទេ គ្រាន់តែជាការកំណត់ទៅលើផ្នែកណាមួយនៃក្រុមដែលការខូចខាតរបស់ក្រុមនោះអាចគំរាមកំហែងដល់ក្រុមទាំងមូល ក៏ជាអំពើប្រល័យពូជសាសន៍ដែរ ។

### តើអ្វីជាសកម្មភាពប្រល័យពូជសាសន៍

សកម្មភាពដែលត្រូវបានផ្តន្ទាទោសជាអំពើប្រល័យពូជសាសន៍ នៅពេលដែលសកម្មភាពនោះត្រូវបានប្រព្រឹត្តដោយចេតនាបំផ្លាញក្រុមមួយក្នុងចំណោមក្រុមដែលទទួលការការពារដែលទាំងនោះរួមមាន ៖

- ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម
- ការបង្កការឈឺចាប់ និងខូចខាតជាដំណំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។ ការធ្វើបាបទៅលើផ្លូវកាយនិងផ្លូវចិត្តបែបនេះរួមមានៈ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ការចាប់រំលោភ និងការប្រើអំពើហិង្សាលើផ្លូវភេទ ។
- ការបង្កឡើងនូវមហន្តរាយចំពោះស្ថានភាពរស់នៅរបស់ក្រុមទាំងមូលឬដោយផ្នែក ដូចជាកាត់បន្ថយធនធានដែលចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់ក្រុម ដូចជា ទឹកស្អាត អាហារ សម្លៀកបំពាក់ ជម្រក ឬសេវាកម្មសុខាភិបាល ។ ឧទាហរណ៍ប្រហែលជារួមបញ្ចូលការដកហូតផលស្រូវ ឬអាហារ រារាំងមិនឲ្យផ្តល់អាហារដល់អ្នកដែលត្រូវការឃុំខ្លួនប្រជាជននៅក្នុងជំរំ ឬជម្លៀសប្រជាជនចេញ ។
- ការចាត់វិធានការដោយចេតនាបង្ការមិនឲ្យមានកំណើតទារកនៅក្នុងក្រុម ដូចជាបង្ខំប្រជា ជនធ្វើការរហូតមិនអាចមានកូន បង្ខំស្ត្រីឲ្យពន្លូតកូន រំលោភស្ត្រី ដូច្នេះក្រុមនេះនឹងមានកូនជាមួយក្រុមផ្សេងទៀត និងហាមប្រាមមិនឲ្យរៀបការ ។
- ការបញ្ជូនកូនក្មេងដោយបង្ខិតបង្ខំចេញពីក្រុមមួយទៅក្រុមមួយទៀត ដែលអាចអនុវត្តដោយបង្ខំផ្ទាល់ ឬបំភ័យក្មេងៗដោយអំពើហិង្សា ឬការធ្វើបាបផ្សេងទៀត ។

### តើអំពើប្រល័យពូជសាសន៍ខុសពីការសម្លាប់ដោយរបៀបណា?

អំពើប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាងការសម្លាប់ ពីព្រោះវាតម្រូវថាជននោះត្រូវតែមានចេតនាអ្វីផ្សេងទៀតច្រើនជាងការសម្លាប់មនុស្ស ។ ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ជននោះត្រូវតែសម្លាប់នរណាម្នាក់ដោយចេតនាបំផ្លាញសមាជិកក្រុមដែលទទួលបានការការពារ ។

### ក្រុមដែលទទួលបានការការពារពីអំពើប្រល័យពូជសាសន៍

នៅពេលជនណាម្នាក់ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ នៅពេលដែលជននោះប្រព្រឹត្តអំពើនោះដោយចេតនាបំផ្លាញក្រុមមួយឬច្រើននៃក្រុមប្រជាជនដូចខាងក្រោម ៖

**ក្រុមជនជាតិ** ជាក្រុមបុគ្គលដែលអត្តសញ្ញាណរបស់គេត្រូវបានកំណត់ដោយជាតិសាសន៍របស់ប្រទេស ឬសញ្ជាតិដើមរបស់ប្រទេសនោះ ។

**ក្រុមជាតិពន្ធ** ជាក្រុមបុគ្គលដែលអត្តសញ្ញាណរបស់គេត្រូវបានកំណត់ដោយវប្បធម៌ ប្រពៃណី ភាសា និងកេរមរតកជាក់លាក់ណាមួយ ។

**ក្រុមពូជសាសន៍** ជាក្រុមដែលមានចរិតលក្ខណៈនិងរូបរាងស្រដៀងគ្នា ដូចជាពណ៌សម្បុរ ស្បែក ទម្រង់ខ្លួន និងមុខ ។

**ក្រុមសាសនា** ជាក្រុមបុគ្គលដែលអត្តសញ្ញាណត្រូវបានកំណត់ដោយការគោរពសាសនា ជំនឿ ទ្រឹស្តី ការប្រតិបត្តិ ឬការប្រារព្ធពិធីសាសនា ។

## ***អំពើប្រល័យពូជសាសន៍ និង ខ្មែរក្រហម***

អំពើឃោរឃៅភាគច្រើនដែលប្រព្រឹត្តដោយខ្មែរក្រហមមិនអាចហៅថាអំពើប្រល័យពូជសាសន៍បានទេ ពីព្រោះខ្មែរក្រហមមានចេតនាបំផ្លាញសត្រូវនយោបាយ អ្នកមិនមែនជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាទេ ។ ប៉ុន្តែអំពើខ្លះប្រហែលជាមានចេតនាបំផ្លាញក្រុមដែលទទួលការការពារ ដូចជា ព្រះសង្ឃ ឬជនជាតិចាមដោយសារតែសាសនារបស់គេ និងប្រជាជនកម្ពុជា-វៀតណាមដោយសារជាតិពន្ធរបស់ពួកគេ ។

អាស្រ័យហេតុនេះ សមាជិកខ្លះរបស់ខ្មែរក្រហមដែលប្រឈមមុខនឹងការកាត់ក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចត្រូវបានកាត់ទោសពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ការចោទប្រកាន់បែបនេះពិបាកនឹងលើកអំណះអំណាង ។

អំពើឃោរឃៅរបស់ខ្មែរក្រហមដែលប្រព្រឹត្តឡើងដោយហេតុផលនយោបាយ ឬដោយហេតុផលផ្សេងទៀតដែលមិនបានរាប់បញ្ចូលនៅក្នុងនិយមន័យអំពើប្រល័យពូជសាសន៍ទំនងជាអាចយកមកចោទប្រកាន់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

## ***ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ***

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្រដៀងនឹងអំពើប្រល័យពូជសាសន៍ដែរ ប៉ុន្តែអំពើទាំងនោះមិនចាំបាច់ជាការបំផ្លាញក្រុមដែលទទួលការការពារដោយចេតនាទេ ។ ប៉ុន្តែ គេត្រូវតែប្រព្រឹត្តសកម្មភាពដែលជាផ្នែកមួយនៃការវាយប្រហារជាប្រព័ន្ធនិងនៅគ្រប់ទីកន្លែងផ្ទាល់ប្រឆាំងនឹងប្រជាជនស៊ីវិល ដូចដែលបានកើតឡើងនៅទូទាំងប្រទេសកម្ពុជានៅអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ តាមផ្លូវច្បាប់ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនសូវជាធ្ងន់ធ្ងរជាងអំពើប្រល័យពូជសាសន៍ទេ ហើយតែងតែងាយស្រួលក្នុងការលើកយកមកអះអាង ។ **អេះរ្រេជ អូលីវី និងហៀធើ មូរេវ**



អដ្ឋិធាតុជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# ភាពភ្លឺស្វាងនៃគោលនយោបាយ ភាពខ្មៅងងឹតនៃសង្គ្រាម

*ការអនុវត្តគោលការណ៍នយោបាយបក្សកុម្មុយនីស្តកម្ពុជារបស់ ឌុចៈ «ខ្ញុំធ្វើអ្វីតាមគេបញ្ជាមកខ្ញុំ ដោយមិនអាចធ្វើលើស ឬធ្វើខុសពីបញ្ជាបានឡើយ» ។*

លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច បានចូលទៅកន្លែងសួរចម្លើយរបស់គាត់ដែលមានរាងក្រចកសេះម្តងទៀតដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅក្នុងគុកទួលស្លែង(មន្ទីរស-២១) ជាគុកដែលគាត់បានធ្វើជាប្រធានក្នុងអំឡុងរបបខ្មែរក្រហមចាប់ផ្តើមពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបញ្ចប់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ក្នុងការឆ្លើយតបនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឌុច បានរៀបរាប់ពីវិធីសាស្ត្រ «ការវាយរហ័ស ទទួលជោគជ័យរហ័ស» របស់គាត់សម្រាប់ហ្វឹកហាត់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ ដែលរៀបចំឡើងដើម្បីពង្រីកការបង្រៀនសម្រាប់រយៈពេលដ៏ខ្លីប៉ុណ្ណោះ ។ ខណៈពេលដែល ឌុច ជឿជាក់ថាវិធីសាស្ត្របំពាក់បំប៉នរបស់គាត់មានលក្ខណៈខុសប្លែក ឌុច បានអះអាងថា គោលបំណងរបស់គាត់មិនមែនខុសប្លែកដោយសារតែមិនបានបន្ថែមអ្វីឲ្យខុសពីមាគ៌ារបស់បក្សនោះទេ ។ ឌុច និយាយថា គាត់បានលះបង់មួយភាគបីនៃពេលវេលារបស់គាត់ដើម្បីហ្វឹកហាត់កម្មាភិបាល ដោយបែងចែកពេលវេលាសេសសល់របស់គាត់សម្រាប់កិច្ចការរៀបចំឯកសារចម្លើយសារភាពជូនថ្នាក់លើ និងសម្រាប់កិច្ចការគ្រប់គ្រងដំណើរការក្នុងមន្ទីរស-២១ ។ ជាមួយនឹងមោទនភាពដែលស្តែងឲ្យឃើញ ឌុច បានពន្យល់ថាគ្មាននរណាម្នាក់នៅមន្ទីរស-២១ យល់ច្បាស់ពីគោលនយោបាយនិងមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាជាងខ្លួនគាត់ទេ សូម្បីតែកម្មាភិបាលឈ្មោះ ណាត ដែលជាថ្នាក់លើរបស់គាត់ ក្នុងអំឡុងពេលនោះក៏មិនយល់ច្បាស់ដូចគាត់ដែរ ។ ឌុច បានពន្យល់ពីរបៀបដែលគាត់រៀន «ការពារជីវិត» ក្នុងការគ្រប់គ្រងឯកសារស្មូលដូចជា ឯកសារលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឯកសារទង់បដិវត្តន៍ និងទស្សនាវដ្តីយុវជនបដិវត្តន៍ជាដើម ។ ឌុច បាននិយាយដោយជឿជាក់អំពីទ្រឹស្តីបដិវត្តន៍របស់ «ប៉ុល ពត» ដោយធ្វើការរៀបរាប់អំពីវិធីសាស្ត្រលុបបំបាត់វណ្ណៈគហបតី និង វណ្ណៈមូលធននិយមដើម្បីធ្វើឲ្យវណ្ណៈកសិករ និង កម្មករ ទទួលបានជោគជ័យដ៏អស្ចារ្យ ។ បន្ទាប់ពីបានបង្កើនចំណេះដឹងរបស់ខ្លួនអំពីរបបខ្មែរក្រហមក្រោយមក ឌុច ក៏បានផ្អាកការរៀនសូត្រពីទ្រឹស្តីនេះដោយពន្យល់ថា គាត់មិនមានមធ្យោបាយដើម្បីរៀនវគ្គបណ្តុះបណ្តាលនៅមជ្ឈិមបក្សដែលបានផ្តល់ឲ្យទេ ដោយសារតែគាត់គ្រាន់តែជាកម្មាភិបាលថ្នាក់កណ្តាលម្នាក់ប៉ុណ្ណោះ ។

ខណៈពេលសួរថាតើ ឌុច គិតថាគោលនយោបាយរបស់បក្សកុម្មុយនីស្តដែល ឌុច ទទួលបន្ទុកក្នុងការអនុវត្តនយោបាយនៅក្នុងមន្ទីរស-២១ល្អឬទេ? ឌុច បានឆ្លើយយ៉ាងរីករាយថា «តើឲ្យយើងនិយាយបែបនេះដោយរបៀបណា? គោលនយោបាយនេះជាគោលនយោបាយឧក្រិដ្ឋកម្ម» ។ ឌុច បានសង្កត់ធ្ងន់ថាបក្សកុម្មុយនីស្តកម្ពុជាមានលក្ខណៈសាហាវជាងបនចោរ៤នាក់នៅប្រទេសចិនទៅទៀត ។ បន្ទាប់មក មេធាវីបានព្យាយាមឲ្យ ឌុច ធ្វើការវែកញែកថាតើ ឌុច កំពុងតែបង្ហាញអំពីទស្សនៈរបស់គាត់កាលពីទសវត្សរ៍៧០ ឬជាទស្សនៈក្នុងពេលបច្ចុប្បន្ន ។ ឌុច បានឆ្លើយថា នេះគឺជាការយល់ដឹងរបស់គាត់ក្នុងពេលបច្ចុប្បន្នដែលបាននាំឲ្យមានទស្សនៈបែបនេះ ។ ជាញឹកញាប់តែងតែគ្មានភាពច្បាស់លាស់ថាតើ ឌុច កំពុងតែពិពណ៌នាអំពីគំនិតរបស់ខ្លួនពីអតីតកាលឬបច្ចុប្បន្ន ។ បញ្ហាបកប្រែក៏បានចោទក្នុងបញ្ហានេះដែរ ។ ដូចគ្នាដែរ ពេលខ្លះយើងមិនដឹងច្បាស់ថាតើ ឌុច កំពុងតែនិយាយពីការយល់ដឹងពីហេតុការណ៍អតីតកាល ឬអនាគតនោះទេ ។ ឌុច បានបង្ហាញឯកសាររាប់រយក្នុងអំឡុងដំណើរការស៊ើបអង្កេតក្នុងករណីដែល ឌុច ត្រូវបានចៅក្រមស៊ើបអង្កេតសួរ ។ ឌុច អាចបង្ហាញឯកសារខ្លះនៃឯកសារទាំងអស់នេះ ហើយបញ្ហានេះត្រូវបានដោះស្រាយដោយភាពងាយស្រួលដោយសារតែការឆ្លើយបំភ្លឺរបស់ ឌុច ទាក់ទងនឹងឯកសារទាំងនេះអាចកើតមានឡើងតែនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែប៉ុណ្ណោះ ។

ចៅក្រមការពារក្តីបានព្យាយាមបង្ហាញភាពអាណិតអាសូរ

ទៅកាន់ ឌុច នៅថ្ងៃនេះ ។ ឌុច បានទទួលស្គាល់ថា គាត់រស់រានមានជីវិតនៅថ្ងៃនេះដោយសារតែភាពស្មោះត្រង់របស់ខ្លួនចំពោះបក្សកុម្មុយនីស្តកម្ពុជា ។ ឌុច បាននិយាយពន្យល់ថា គាត់តែងតែធ្វើតាមអ្វីដែលគាត់ត្រូវបានគេប្រាប់ឲ្យធ្វើ ហើយគាត់មិនដែលលាក់បាំងអ្វីឡើយ ។ បន្ទាប់មក មេធាវីការពារក្តីចាប់ផ្តើមអានចម្លើយដែល ឌុច បានឆ្លើយកាលពីមុនទាក់ទងនឹងវិប្បដិសារីចំពោះសកម្មភាពរបស់គាត់ ហើយមេធាវីក៏បានឲ្យ ឌុច ធ្វើសេចក្តីអធិប្បាយលើចម្លើយសារភាពនេះ ។ ពាក់កណ្តាលនៃការឆ្លើយតបដ៏វែងរបស់ ឌុច ត្រូវមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបដិសេធដោយចោទថា បញ្ហានេះគឺខុសពីប្រធានបទ ប៉ុន្តែ លោកប្រធានចៅក្រម និល ណុន អនុញ្ញាតឲ្យ ឌុច និយាយបន្ត ។ ឌុច បានពិពណ៌នាអំពីវិប្បដិសារីដ៏ធំធេងរបស់ខ្លួនចំពោះកំហុសឆ្គងដែលគាត់បានប្រព្រឹត្តដោយធ្វើការអនុវត្តតាមគោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជានៅឯមន្ទីរស-២១ ។ ឌុច បាននិយាយម្តងហើយម្តងទៀតថា គាត់នឹងមិនទម្លាក់កំហុសទាំងស្រុងទៅថ្នាក់លើរបស់គាត់ ឬ ទៅលើអ្នកនៅក្រោមបញ្ជារបស់គាត់ទេ ។ ឌុច ក៏បានទទួលស្គាល់ថា ក្នុងនាមជាសមាជិកម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា គាត់បានរិះគន់ទៅលើភាពសាហាវយោរយៅដែលបានកើតឡើងនៅទូទាំងប្រទេស ។ នៅពេលព្រឹក ឌុច បានបដិសេធលើដីកាស៊ើបអង្កេតរបស់អ្នកជំនាញការរបបខ្មែរក្រហម ក្រេក អេចឆេសាន់ ដែលនិយាយថា អ្នកទោសរាប់រយនាក់ត្រូវបានដោះលែងពីមន្ទីរស-២១ ខណៈពេលស្ថិតនៅក្រោមការមើលខុសត្រូវរបស់ ឌុច ។ ឌុច បាននិយាយទទូចថា គាត់មិនដែលដោះលែងអ្នកទោសណាម្នាក់ឡើយ ហើយក៏នឹងមិនអនុញ្ញាតឲ្យមានបញ្ជីឈ្មោះអ្នកទោសដែលប្រឌិតឡើងនោះកើតមានដើម្បីយកមកលាក់បាំងឧក្រិដ្ឋកម្មរបស់ខ្លួនដែរ ។ ឌុច បាននិយាយថា «អ្នកមិនអាចយកចង្អេរមកបាំងដំរីបានទេ» ។

## ជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងវៀតណាម ៖ អាថ៌កំបាំងដែលរក្សាទុកបានយ៉ាងល្អបំផុត

នៅពេលរសៀល ឌុច បានឆ្លើយទៅនឹងសំណួររបស់ចៅក្រម ស៊ីលវៀ ខាតវ៉្រាយ ដែលមានបំណងចង់កំណត់ថាតើពេលណា និង ដោយរបៀបណាដែល ឌុច បានដឹងពីជម្លោះរវាងកម្ពុជានិងវៀតណាម ។ ផ្ទុយពីសវនាការពេលព្រឹក ដែល ឌុច បានឆ្លើយយ៉ាងជឿជាក់ និងយ៉ាងក្រអឺតក្រទមអំពីការយល់ដឹងរបស់ខ្លួនទាក់ទងនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ឌុច បានបង្ហាញអំពីកង្វះខាតការយល់ដឹងអំពីការប៉ះទង្គិចរវាងរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងប្រទេសជិតខាង ។

ផ្អែកលើមូលដ្ឋានយល់ដឹងក្នុងពេលបច្ចុប្បន្នរបស់ខ្លួន ឌុច មិនបានបដិសេធលើជម្លោះប្រដាប់អាវុធដែលចាប់ផ្តើមក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញទាំងមូល ។ យ៉ាងណាមិញ ឌុច បានអះអាងថាមិនមានការយល់ដឹងកើតឡើងស្របពេលជាមួយនឹងជម្លោះនេះឡើយ រហូតមកដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ ខណៈពេលដែលកម្ពុជា និងវៀតណាមបានបំផ្លាញទំនាក់ទំនងការទូតរបស់ប្រទេសទាំងពីរជាសាធារណៈ ។ នៅក្នុងសេចក្តីអធិប្បាយដែលហាក់បីដូចជាមិនអាចធ្វើឲ្យចៅក្រម ខាតវ៉្រាយ ជឿទុកចិត្តបាននោះ ឌុច បានពន្យល់ថា សង្គ្រាមបានលាក់ទុកជាអាថ៌កំបាំងដោយសារតែ ឌុច បានធ្វើការទាក់ទងយ៉ាងទៀងទាត់ជាមួយនឹងសមាជិកបក្សកុម្មុយនីស្តកម្ពុជាជាន់ខ្ពស់ ។ ឌុច និយាយថា គាត់គ្មានពេលសម្រាប់ស្តាប់វិទ្យុ ប៉ុន្តែ ឌុច ប្រហែលជាអាចឮពាក្យចចាមអារ៉ាមមួយចំនួន ។

ខណៈពេលដែលចៅក្រម ខាតវ៉្រាយ អានកថាខណ្ឌខ្លះចេញពីចម្លើយ ឌុច ដែលបានបញ្ជាក់អះអាងថា មានអ្នកទោសជនជាតិវៀតណាមប្រហែល៤០០នាក់ បានជាប់ឃុំឃាំងនៅក្នុងមន្ទីរស-២១ ដែលក្នុងនោះរួមមានខ្មាំងសង្គ្រាមចំនួន១៥០នាក់ និងប្រជាជនស៊ីវិលចំនួន១០០នាក់ ។ បន្ថែមពីលើនេះ ឌុច បានបញ្ជាក់ផងដែរថា អ្នកទោសជនជាតិវៀតណាមដំបូងគេបង្អស់ត្រូវបានកត់ត្រាប្រវត្តិរូបទុក កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដកស្រង់ចេញពីបញ្ជីឈ្មោះអ្នកទោសរបស់មន្ទីរស-២១ ។

ឌុច បានដឹងថា បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ ប្រជាជនវៀតណាមខ្លះនៅកម្ពុជាត្រូវបានចាត់ទុកជាខ្មាំង ហើយត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខដូចជាមន្ទីរស-២១ជាដើម ។ ប៉ុន្តែ ឌុច បានបដិសេធលើការយល់ដឹងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីសម្លាប់ប្រជាជនវៀតណាមទាំងអស់ក្នុងប្រទេសកម្ពុជា ។

**ឡូរ៉ា ម៉ាកដូណាល**

# នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) និងបក្សកុម្មុយនីស្តថៃ: ជីវិតរបស់បុរសនេះនៅទីក្រុងបាងកកដែលបានក្លាយជា"បងធំទី២" នៅក្នុងរបបខ្មែរក្រហម

***(តចប់)***

*ទោះបីយ៉ាងណាក៏ដោយ ចាប់តាំងពីពេលដែលគាត់ក្លាយជានិស្សិតឆ្នាំទី២ នៅចុងឆ្នាំ១៩៤៨ រហូតដល់ដើមឆ្នាំ១៩៥០ រំពេចនោះគាត់មានការហួតចត់ចំពោះការសិក្សារបស់គាត់ណាស់ ។ វគ្គសិក្សាដែលតម្រូវចាំបាច់សម្រាប់ឆ្នាំទី២រួមមានពាក្យបណ្តឹង និងបំណុល ប្រកាសនីយបត្រសម្រាប់ចំណាយលើកម្ចី ពាណិជ្ជកម្ម ការជួល ការខ្ចី សិទ្ធិប្រទាន និងភ្នាក់ងារ ច្បាប់ព្រហ្មទណ្ឌទី២ និងច្បាប់រដ្ឋបាល ។ នៅខែមករា ឆ្នាំ១៩៥០ មួយឆ្នាំបីខែបន្ទាប់ពីប្រឡងជាប់វគ្គសិក្សាដែលតម្រូវជាចាំបាច់សម្រាប់ឆ្នាំទី១របស់គាត់នៅខែតុលា ឆ្នាំ១៩៤៨ រុងឡឺត បានប្រឡងទៅលើវគ្គសិក្សាដែលតម្រូវចាំបាច់សម្រាប់ឆ្នាំទី២ ហើយប្រឡងជាប់វគ្គសិក្សាចំនួន៧មុខទៀត លើកលែងតែពាណិជ្ជកម្មជួញដូរ ។ នេះអាចគូសបញ្ជាក់ថា រហូតដល់ដើមឆ្នាំ១៩៥០ រុងឡឺត នៅតែមានបំណងប្រាថ្នាបញ្ចប់ការសិក្សានៅសកលវិទ្យាល័យធម្មសាត្រ ។ វគ្គសិក្សាភាគច្រើនដែលតម្រូវឲ្យគាត់សិក្សាគឺច្បាប់និងជំនាញអំពីសង្គមមូលធននិយម ហើយទោះបីគាត់ប្រឡងជាប់យឺតយ៉ាវទៅលើវគ្គសិក្សាទាំងឡាយប្រចាំឆ្នាំទី១ក៏ដោយ ក៏នៅដើមឆ្នាំ១៩៥០ គាត់ទទួលជោគជ័យក្នុងការប្រឡងជាប់វគ្គទាំងអស់ដែរ លើកលែងតែមួយមុខប៉ុណ្ណោះ ។ នៅឆ្នាំ១៩៥០ គាត់បានប្រឡងជាប់ចូលធ្វើការនៅក្រសួងការបរទេស ហើយបន្ទាប់មកក៏លាឈប់ពីនាយកដ្ឋានជម្រះបញ្ជីទូទៅនៅក្រសួងហិរញ្ញវត្ថុ រួចហើយក៏ផ្លាស់ទៅធ្វើការនៅក្រសួងការបរទេស ។ អំឡុងឆ្នាំ១៩៥០ រុង ឡឺត មានអាយុ២៤ឆ្នាំ ។ នៅក្នុងឆ្នាំនោះ វាហាក់ដូចជាថាជម្រើសអាជីពមួយដែលគាត់សញ្ជឹងគិត គឺក្រោយបញ្ចប់ការសិក្សានៅសកលវិទ្យាល័យថៃ ហើយប្រែក្លាយជាមន្ត្រីរដ្ឋាភិបាលថៃនេះ ប្រហែលជាថ្ងៃណាមួយ គាត់នឹងក្លាយជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ។ ប៉ុន្តែឆ្នាំ១៩៥០ គឺជាឆ្នាំដែលគាត់បានចូលរួមក្នុងបក្សកុម្មុយនីស្តផងដែរ ក៏ប៉ុន្តែនេះមិនមានការប៉ះទង្គិចនឹងតំណែងរបស់គាត់ជាមន្ត្រីរដ្ឋាភិបាលជាន់ទាបឡើយ (ស៊ុមខាន ភិឆៃគុល និង ខុត្តម ចារើនរ៉ាត ក្នុងចំណោមអ្នកដទៃទៀត គឺជាសមាជិកបក្សដែលធ្វើការជាមន្ត្រីរដ្ឋាភិបាលជាន់ទាប) ។ ការចូលរួមក្នុងបក្សបង្ហាញថា រុងឡឺត មានអារម្មណ៍ប៉ះទង្គិចទៅនឹងអសមត្ថភាពក្នុងសង្គមនិងគំនិតដែលអាជីពនៅក្នុងរដ្ឋាភិបាលរួមចំណែកនៅក្នុងការធ្វើឲ្យមានអសមត្ថភាព ហើយមានតែបក្សកុម្មុយនីស្តនិងមនោគមន៍វិជ្ជារបស់កុម្មុយនីស្តទេ ទើបអាចបង្ក្រាបនូវបញ្ហាទាំងនេះបាន ។ ដោយសារតែរឿងជាច្រើនបានផ្លាស់ប្តូរការក្លាយខ្លួនជាសមាជិកបក្សបានផ្តល់ឱកាសឲ្យមានការតស៊ូផ្សេងៗ ដោយក្លាយទៅជាសកម្មជននៅក្នុងការតស៊ូដើម្បីរំដោះឥណ្ឌូចិន ជាពិសេសគឺប្រទេសកម្ពុជាដែលជារឿងមួយគាត់បានជ្រើសរើស ។ នេះជួយទៅនឹងមនុស្សពីរនាក់ទៀតដែលជាមិត្តរួមជំនាន់របស់ រុងឡឺត គឺ និខុម ចានថុរ៉ាវិថុន និង ស៊ុធី ណាតវ៉ូរ៉ាថាត ដែលបានលើកឡើងក្នុងការសិក្សាខាងដើមត្រូវបានអូសទាញឲ្យចូលចលនាឆ្វេងនិយម ហើយដូច រុងឡឺត ដែលបានចូលប្រឡូកក្នុងអង្គការយុវជនថៃ ។ ដូចជា រុងឡឺត ដែរ ពួកគេក៏បានប្រឡងជាប់ការងារ ហើយក្លាយទៅជាមន្ត្រីរដ្ឋាភិបាល ។ ប៉ុន្តែពួកគេទាំងពីរនាក់មិនបានឈានជើងចូលក្នុងបក្សកុម្មុយនីស្តថៃឡើយ ។ ពួកគេនៅតែរក្សាអាជីពក្នុងរដ្ឋាភិបាល ហើយក្រោយមកបានបន្តទៅជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ។ និខុម បានក្លាយជាប្រធាននាយកដ្ឋានពលកម្មនៃក្រសួងមហាផ្ទៃ ហើយ សុធី ក្លាយជាប្រធាននាយកដ្ឋានជំនួញអន្តរជាតិនៅក្រសួងពាណិជ្ជកម្ម ។*

*នៅដើមឆ្នាំ១៩៥០ រុងឡឺត នៅសល់តែវគ្គសិក្សាដែលតម្រូវជាចាំបាច់មួយទៀតប៉ុណ្ណោះដើម្បីប្រឡងឲ្យជាប់ ហើយគួរតែបញ្ចប់ការសិក្សាឆ្នាំទី២របស់គាត់នៅសកលវិទ្យាល័យធម្មសាត្រ ។ ប្រសិនបើគាត់ខិតខំប្រឹងប្រែងដូចដែលគាត់បានធ្វើឡើងនៅក្នុងអំឡុងឆ្នាំមុនៗ គាត់អាចនឹងប្រឡងជាប់រាល់វគ្គសិក្សាដែលតម្រូវជាចាំបាច់សម្រាប់ឆ្នាំសិក្សាទី៣ ដោយចំណាយពេល*

ត្រឹមឆ្នាំក្រោយ ឬឆ្នាំបន្ទាប់ទៀត ហើយទទួលបានចំនួនក្រេឌីតគ្រប់គ្រាន់សម្រាប់បញ្ចប់ការសិក្សានៅសកលវិទ្យាល័យ ។ ប៉ុន្តែនៅឆ្នាំ១៩៥០ នៅពេលដែលលទ្ធផលក្លាយជាលទ្ធភាពជាក់ស្តែង វុងឡឹត បានបោះបង់ចោលការសិក្សានៅសកលវិទ្យាល័យធម្មសាស្ត្រ និងតំណែងជាមន្ត្រីរដ្ឋាភិបាលនៅក្រសួងការបរទេសថៃ បើទោះជាគាត់ធ្លាប់បានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការងារ និងទើបតែចាប់ផ្តើមការងារក៏ដោយ ។

ការប្រឡងបានធ្វើឡើងនៅខែតុលា ឆ្នាំ១៩៥០ ប៉ុន្តែមានព័ត៌មានតិចតួចដែលអាចដឹងថាតើ វុងឡឹត បានចូលប្រឡងវគ្គពាណិជ្ជកម្មដែលជាវគ្គនៅសល់សម្រាប់ឆ្នាំសិក្សាទី២របស់គាត់ឬអត់ ដោយសារថាឯកសារដែលទាក់ទិននឹងការប្រឡងទាំងនោះត្រូវបានបាត់បង់ ឬមិនបានរក្សាទុកដោយបណ្ណសារដ្ឋានរបស់សកលវិទ្យាល័យ ។ បញ្ជីរាយនាមរបស់សិស្សឆ្នាំទី២និងឆ្នាំទី៣ដែលប្រឡងនៅខែមករា ឆ្នាំ១៩៥១ អាចរកបានប៉ុន្តែមិនឃើញមានឈ្មោះ វុងឡឹត ឡៅឌី នៅក្នុងបញ្ជីរាយនាមទាំងនោះឡើយ ។

## ៩) ហេតុអ្វីបានជា វុងឡឹត ចាកចេញពីប្រទេសថៃ?

វុងឡឹត ឡៅឌី បានចុះឈ្មោះចូលរៀននៅសកលវិទ្យាល័យធម្មសាស្ត្រអស់រយៈពេលជាង៤ឆ្នាំ ដោយអំឡុងពេលដែលគាត់បានបញ្ចប់វគ្គសិក្សាតម្រូវជាចាំបាច់សម្រាប់ឆ្នាំទី១ និងស្ទើរតែបញ្ចប់វគ្គទាំងអស់សម្រាប់ឆ្នាំទីពីររបស់គាត់ ។ វាអាចទៅរួចដែលថាពេលវេលាសម្រាប់និស្សិតដែលបញ្ចប់ការសិក្សានៅសកលវិទ្យាល័យធម្មសាស្ត្រនៅក្នុងពេលបញ្ចប់ការសិក្សាឆ្នាំទី៣របស់ខ្លួន ។ អាស្រ័យហេតុនេះ ប្រសិនបើ វុងឡឹត បានបន្តការសិក្សាដោយមានការកំណត់ដូចដែលគាត់បានធ្វើឡើងកាលពីឆ្នាំមុនៗ ប្រហែលជាគាត់មានលទ្ធភាពដើម្បីបញ្ចប់ការសិក្សានៅឆ្នាំបន្ទាប់ ។ ប៉ុន្តែគាត់មិនបានបញ្ចប់ការសិក្សានៅសកលវិទ្យាល័យឡើយ គាត់ក៏បានបោះបង់ការងារនៅក្រសួងការបរទេសថៃបន្ទាប់ពីធ្វើការបានត្រឹមតែ១ខែប៉ុណ្ណោះ ហើយនៅពាក់កណ្តាលឆ្នាំ១៩៥០ គាត់ក៏បាត់ខ្លួនពីទីក្រុងបាងកកតែម្តង ។ គាត់គឺជាពលរដ្ឋថៃ ។ អស់រយៈកាលជាង៨ឆ្នាំដែលគាត់បានរស់នៅទីក្រុងបាងកកមិនមានអ្វីដែលផ្លាស់ប្តូរវាងគាត់និងមិត្តភក្តិរបស់គាត់ដែលរៀនជាមួយគ្នានៅសាលាមធ្យមសិក្សានិងសកលវិទ្យាល័យដែលធំធាត់នៅក្នុងតំបន់ជនបទឡើយ ។ គាត់ទទួលបានជោគជ័យក្នុងការក្លាយខ្លួនទៅជាសមាជិកនៃក្រុមវរជនថៃ ។ យ៉ាងហោចណាស់ គាត់មានទស្សនវិស័យចំពោះអនាគតរបស់គាត់ដែលជាផ្នែកមួយរបស់សង្គមថៃ ។ ប៉ុន្តែនៅពាក់កណ្តាលឆ្នាំ១៩៥០ នៅពេលមានអាយុ២៨ឆ្នាំ វុងឡឹត ឡៅឌី (អនាគតគឺ នួន ជា) បានធ្វើដំណើរត្រឡប់មកស្រុកកំណើតរបស់ខ្លួនដើម្បីចូលរួមក្នុងការតស៊ូដើម្បីរំដោះប្រទេសកម្ពុជា ។

នៅក្នុងសេចក្តីផ្តើមនៃការសិក្សានេះ អ្នកនិពន្ធបានធ្វើអត្ថាធិប្បាយទៅលើអត្ថបទសារព័ត៌មានរបស់អ្នកកាសែតថៃឈ្មោះ នូសារ៉ា ថៃថាវ៉ាត ដែលគាត់បានរាយការណ៍នូវបទសម្ភាសន៍របស់គាត់ជាមួយ នួន ជា ហើយដែលផ្សាយនៅក្នុងលេខចេញផ្សាយរបស់កាសែតបាងកកប៉ុស្តិ៍ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៦ ។ គាត់បានធ្វើការរិះគន់ នូសារ៉ា ចំពោះការធ្វេសប្រហែសក្នុងការពិនិត្យនិងផ្ទៀងផ្ទាត់សម្តីរបស់ នួន ជា ជាមួយឯកសារដទៃទៀត ហើយចំពោះការរាយការណ៍យ៉ាងងាយនូវកំហុសឆ្គងក្នុងការចងចាំឡើងវិញនូវហេតុការណ៍តាំងពីយូរមកហើយហាក់ដូចជាហេតុការណ៍ទាំងនោះគឺជាការពិតជាក់ស្តែង ។ នូសារ៉ា ថែមទាំងធ្វើការប៉ាន់ស្មានដោយខ្លួនឯងចំពោះហេតុផលដែល នួន ជា ចាកចេញពីប្រទេសថៃដើម្បីវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដោយមិនគិតអំពីការពិតនិងសម្តីរបស់ នួន ជា ផ្ទាល់ ។ យោងតាមការពន្យល់របស់គាត់ នួន ជា បានប្រឡងជាប់ការងារនៅក្រសួងការបរទេសនៅឆ្នាំ១៩៤៧ ប៉ុន្តែតំណែងដែលគាត់ត្រូវបានផ្តល់ឲ្យនៅក្នុងក្រសួងជាតំណែងស្មៀនជាន់ទាបដូចដែលគាត់ធ្លាប់ធ្វើកាលពីនៅក្រសួងហិរញ្ញវត្ថុដែរ ។ ក្រសួងការបរទេសមិនបានផ្តល់ឲ្យគាត់នូវមុខតំណែងជាអាជីពដូចដែលគេបានផ្តល់ឲ្យជនជាតិថៃពិតប្រាកដឡើយ ។ ដោយសារមិនសប្បាយចិត្តនឹងការធ្វើការដោយមិនមានយុត្តិធម៌បែបនេះ រយៈពេល១ខែក្រោយពីធ្វើការ គាត់បានបោះបង់ចោលការងារនោះ ហើយចូលរួមក្នុងចលនាយុវជនដែលបង្កើតឡើងថ្មី ហើយក្រោយមកទៀតទើបចូលក្នុងបក្សកុម្មុយនីស្តថៃ ។ បន្ទាប់មក នូសារ៉ា បានបន្តធ្វើការប៉ាន់ស្មានថា ប្រហែលជាដោយសារភាពរើសអើងដែលគាត់ទទួលរងបែបនេះហើយ ទើបជាមូលហេតុបណ្តាលឲ្យ វុងឡឹត

សម្រេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៥០ ។

ឆ្នាំដែល នូសារ៉ា បានប្រាប់អំពីការចូលធ្វើការរបស់ វុន្នឡឹត នៅក្រសួងការបរទេស គឺមានភាពខុសគ្នា៣ឆ្នាំពីឆ្នាំជាក់ស្តែង ហើយអ្វីដែលមានភាពកាន់ប្រឡំស្រដៀងគ្នានេះ គឺមាននៅក្នុងការពន្យល់របស់ នូសារ៉ា អំពីការចាកចេញពីក្រសួងការបរទេសនិងការចាកចេញពីប្រទេសថៃ ដែលនេះមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ពីច្បាប់និយ័តកម្មស្តីពីសេវាកម្មស៊ីវិលនៅឆ្នាំ១៩៤៧ ដែលនៅជាធរមាននៅឡើយក្នុងឆ្នាំ១៩៥៩ ។ ច្បាប់នេះបានចែងថា តម្រូវការជំរុញបន្ថែមដើម្បីមានសិទ្ធិប្រឡងចូលធ្វើការនៅក្នុងជួររដ្ឋាភិបាលគឺត្រូវមានសញ្ជាតិថៃ (មាត្រា៣១) ។ ការចូលបម្រើក្នុងរដ្ឋាភិបាលធម្មតាត្រូវបែងចែកទៅជា៥ថ្នាក់ ដោយចាប់ផ្តើមពីថ្នាក់ទី៤ ស្ថិតនៅក្នុងលំដាប់ទាបជាងគេ បន្ទាប់មកឡើងទៅថ្នាក់ទី៣ ទី២ ទី១ ដែលជាថ្នាក់ពិសេសនៅត្រង់កម្រិតខ្ពស់ជាងគេ (មាត្រា៧) ។ មុខតំណែងការងារត្រូវបានបែងចែកជា៧ប្រភេទដោយចាប់ផ្តើមពីស្មៀនធម្មតា (មាមៀន) នៅក្រោមគេបង្អស់ រួចឡើងរហូតដល់ប្រធានស្មៀន ប្រធានផ្នែក ប្រធានការិយាល័យ ប្រធានអគ្គភាព នាយនាយកដ្ឋាន ហើយចុងក្រោយអនុរដ្ឋមន្ត្រីទទួលបន្ទុកផ្នែករដ្ឋបាល (មាត្រា៨) ។ ស្មៀនធម្មតាគឺជាមន្ត្រីនៅក្នុងលំដាប់ថ្នាក់ទី៤ ហើយប្រធានស្មៀននៅក្នុងលំដាប់ថ្នាក់លេខ៤ លើសពីឋានន្តរស័ក្តិ១១ឬលំដាប់ថ្នាក់លេខ៣ ប្រធានផ្នែកស្ថិតក្នុងលំដាប់លេខ៣ឬលេខ២ ហើយប្រធានការិយាល័យស្ថិតនៅក្នុងលំដាប់ថ្នាក់លេខ២ឬមន្ត្រីនៅក្នុងលំដាប់លេខ១ (មាត្រា២៥) ។ លក្ខណៈសម្បត្តិដើម្បីប្រឡងយកឋានន្តរស័ក្តិលំដាប់ថ្នាក់លេខ៤ដែលមានឋានន្តរស័ក្តិលេខ១ដល់លេខ៣ គឺត្រូវបញ្ចប់ការសិក្សានៅសាលាមធ្យមសិក្សា ។ ចំពោះលំដាប់ថ្នាក់លេខ៤ក្នុងឋានន្តរស័ក្តិលេខ៧ គឺតម្រូវឲ្យបញ្ចប់វគ្គសិក្សាថ្នាក់ត្រៀមនៅសកលវិទ្យាល័យ ។ សម្រាប់លំដាប់ថ្នាក់លេខ៣ សមត្ថភាពលក្ខណៈសម្បត្តិត្រូវបញ្ចប់ថ្នាក់សកលវិទ្យាល័យឬធ្វើការរយៈពេលលើសពី៥ឆ្នាំនៅក្នុងលំដាប់ថ្នាក់លេខ៤ក្នុងឋានន្តរស័ក្តិលេខ៦ឬខ្ពស់ជាងនេះ (មាត្រា៣៥) ។

ចំពោះការចែងខាងលើស្តីអំពីការជ្រើសរើសឲ្យធ្វើការងារជាមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ មនុស្សម្នាក់ៗត្រូវរៀននៅក្នុងសកលវិទ្យាល័យធម្មសាស្ត្រដែលមានសញ្ជាតិជាថៃ ហើយបញ្ចប់វគ្គសិក្សាថ្នាក់ត្រៀមនៅសកលវិទ្យាល័យ ។ មនុស្សម្នាក់ៗមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើការប្រឡងចូលធ្វើជាមន្ត្រីនៅក្នុងកម្រិតលំដាប់ថ្នាក់លេខ៤នៃឋានន្តរស័ក្តិលេខ៧ ។ ប្រសិនបើបេក្ខជនប្រឡងជាប់ បេក្ខជននឹងអាចត្រូវបានតែងតាំងឲ្យកាន់មុខតំណែងជាស្មៀនធម្មតា ។ ប្រសិនបើសមត្ថភាពសិក្សារបស់បេក្ខជនមិនមានការផ្លាស់ប្តូរ ហើយអ្នកនោះបំពេញការងារអស់រយៈពេលយ៉ាងតិច៥ឆ្នាំ ឬប្រសិនបើបេក្ខជនបញ្ចប់ការសិក្សាពីសកលវិទ្យាល័យធម្មសាស្ត្រ ហើយទទួលបានសញ្ញាប័ត្រ ដូច្នេះបេក្ខជនអាចធ្វើការប្រឡងចូលបម្រើការងារជាមន្ត្រីក្នុងលំដាប់ថ្នាក់លេខ៣ ។ ប្រសិនបើបេក្ខជនប្រឡងជាប់ បេក្ខជននឹងត្រូវតែងតាំងឲ្យកាន់មុខតំណែងជាប្រធានស្មៀន ដែលជាមុខតំណែងខ្ពស់ជាងស្មៀនធម្មតា ។

បើពិនិត្យមើលទៅលើច្បាប់ដូចមានចែងទាំងអស់នេះនិងនៅក្នុងឆ្នាំ១៩៥០ គឺ វុន្នឡឹត មិនទាន់បញ្ចប់ការសិក្សានៅសកលវិទ្យាល័យនៅឡើយ ហើយត្រូវធ្វើការរយៈពេល៣ឆ្នាំក្នុងមុខតំណែងជាស្មៀន (នឹងត្រូវការពេល២ឆ្នាំទៀតដើម្បីឲ្យគ្រប់រយៈពេល៥ឆ្នាំ) គាត់មិនអាចមានលក្ខណៈសម្បត្តិពេញលេញចំពោះមុខតំណែងដែលខ្ពស់ជាងស្មៀនឡើយ ទោះបីជានៅក្នុងការិយាល័យរដ្ឋាភិបាលណាមួយដែលគាត់ស្វែងរកការងារធ្វើក៏ដោយ ។ ច្បាស់ណាស់វាមានលក្ខណៈដូចគ្នាទៅនឹងប្រជាជនថៃទូទៅ ដូចជា ខត្តម ចារើនរ៉ាត និង ស៊ុមខាន កិតែគុល ។ វាមិនមែនជាការរើសអើងនៅក្នុងក្រសួងការបរទេសដោយសារតែគាត់មិនមែនជាជនជាតិថៃដែលធ្វើឲ្យ វុន្នឡឹត ទទួលមុខតំណែងជាស្មៀនធម្មតានោះទេ ។ គាត់មានសញ្ជាតិជាថៃមុនពេលគាត់មកកាន់ទីក្រុងបាងកកទៅទៀត ។ ដូច្នេះហើយ គាត់មានលទ្ធភាពក្នុងការប្រឡងនិងទទួលឲ្យបម្រើការងារជាមន្ត្រីរដ្ឋាភិបាល ។ សញ្ជាតិនៅក្នុងប្រទេសថៃគឺមានក្រុមជនជាតិផ្សេងៗគ្នា ហើយវាពិបាកណាស់ក្នុងការជឿថានៅពេលដែលទទួលមនុស្សឲ្យចូលធ្វើការដោយមានសញ្ជាតិជាថៃ ការិយាល័យរដ្ឋាភិបាលត្រូវបែងចែកតាមជនជាតិខុសៗគ្នា ដែលជាហេតុផលមួយធ្វើឲ្យមានការរើសអើងក្នុងការជ្រើសរើសឲ្យចូលបម្រើការងារ ។ ការជាប់ទាក់ទងនឹងទំនាក់ទំនងបុគ្គលគឺមាន

លក្ខណៈសំខាន់ ក៏ប៉ុន្តែបើពិនិត្យមើលលើសមត្ថភាពក្នុងសិក្សារបស់ រុងឡឹត និងចំនួនឆ្នាំដែលគាត់ធ្វើជាមន្ត្រីរដ្ឋាភិបាលក្រោមច្បាប់បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ គាត់មិនអាចមានសង្ឃឹមថានឹងបានទទួលមុខតំណែងខ្ពស់ជាងមុខតំណែងស្មៀននោះទេ ។ ជាការពិតណាស់ ប្រការនេះមានលក្ខណៈច្បាស់លាស់ចំពោះ រុងឡឹត ផ្ទាល់ក្នុងនាមជានិស្សិតដែលសិក្សាផ្នែកច្បាប់នៅក្នុងសកលវិទ្យាល័យ ។

ដូច្នេះហេតុអ្វីក៏ រុងឡឹត បានបោះបង់ចោលការងារមួយដែលនឹងអាចរស់នៅក្នុងចំណោមមនុស្សឆ្នើមនៅប្រទេសថៃ? ហេតុអ្វីបានជាគាត់ជ្រើសរើសយកការលំបាកដោយធ្វើការវិលត្រឡប់មកកាន់ទឹកដីកំណើតនៅប្រទេសកម្ពុជាវិញ? នេះមិនមែនដោយសារតែភាពមិនសប្បាយចិត្តទៅលើការរើសអើងចំពោះរូបគាត់នៅក្នុងការងាររដ្ឋាភិបាលនោះទេ ។ នោះដោយសារតែគាត់មានភាពខ្វាយខ្វល់ខាងផ្នែកសីលធម៌អំពីការធ្វើការងារ ។ នោះគឺជាភាពខ្វាយខ្វល់ដែលបង្កមកពីឧត្តមគតិកុម្មុយនីស្តដែលនាំឲ្យគាត់ចូលរួមក្នុងបក្សកុម្មុយនីស្តថៃ ។ គំនិតជាតិនិយមដ៏រឹងមាំសម្រាប់ប្រទេសកំណើតគឺជាកត្តារួមផ្សំផងដែរ ។ ហេតុដូច្នេះហើយនៅពេលដែលបណ្តាញបក្សកុម្មុយនីស្តរបស់គាត់បានផ្តល់ឱកាសឲ្យត្រឡប់និងចូលរួមក្នុងចលនាតស៊ូរំដោះប្រទេសកម្ពុជា គាត់ក៏ទទួលយកឱកាសនេះ ។

## សេចក្តីសន្និដ្ឋាន

មានការដឹងតិចតួចណាស់អំពីប្រវត្តិរូបរបស់ នួន ជា ជាពិសេសស្តីអំពីពេលវេលានៅជាយុវវ័យក្នុងការសិក្សារបស់គាត់នៅក្នុងទីក្រុងបាងកក ហើយការដឹងពត៌តិចតួចនេះច្រើនតែមិនសូវត្រូវទៀតផង ។ ការសិក្សានេះព្យាយាមស្វែងរកនូវការពិនិត្យពិច័យប្រកបដោយភាពជាក់លាក់និងលម្អិតជាងនេះទៅលើប្រវត្តិរូបរបស់បុរសម្នាក់នេះនៅក្នុងចន្លោះឆ្នាំ១៩៤៧ ជាពេលដែលគាត់បានទៅដល់ទីក្រុងបាងកកក្នុងនាមជាសិស្សសាលាមធ្យមសិក្សាអាយុ១៦ឆ្នាំ និងឆ្នាំ១៩៥០ ដែលគាត់លាឈប់ពីការរៀនសូត្រនិងការងារ ព្រមទាំងត្រឡប់មកប្រទេសកម្ពុជាក្នុងនាមជាសកម្មជនកុម្មុយនីស្តអាយុ២៤ឆ្នាំ ។ ដើម្បីសម្រេចគោលបំណងនេះ អ្នកនិពន្ធបានជួបធ្វើសម្ភាសន៍ជាមួយ នួន ជា ហើយបន្ទាប់មកធ្វើការត្រួតពិនិត្យ និងប្រៀបធៀបព័ត៌មានចេញពីបទសម្ភាសន៍នេះជាមួយបទសម្ភាសន៍ជាច្រើនរបស់អ្នកដែលធ្វើការងារយ៉ាងសកម្មជាមួយគាត់ក្នុងអំឡុងចុងទសវត្សរ៍៤០ ពោលគឺមានឈ្មោះ សាណុះ ជានិតចារើន, ស៊ុមខាន ភិនៃគុល និង ឧត្តម ចារើនវ៉ាត ដែលជាសមាជិកបក្សកុម្មុយនីស្តថៃ ។ អ្នកនិពន្ធក៏បានវាយតម្លៃចេញពីបទសម្ភាសន៍ទាំងអស់នេះជាមួយនឹងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត ជាពិសេសកំណត់ហេតុឯកសារដើមរបស់និស្សិតដែលមាននៅក្នុងសាលាម៉ាថាយុម បិនចាម៉ា បូភិត សកលវិទ្យាល័យធម្មសាត្រនិងក្រសួងទទួលបន្ទុកកិច្ចការបរទេសរបស់ថៃ ។

អង្គហេតុនានាអំពីយុវវ័យរបស់ នួន ជា ដែលបានប្រមូលពីប្រភពខាងលើ ត្រូវបានប្រើប្រាស់នៅក្នុងការសិក្សានេះ ហើយនឹងត្រូវសង្ខេបដូចខាងក្រោម ។

នួន ជា កើតនៅថ្ងៃទី៧ ខែ៧ ឆ្នាំ១៩២៦ នៅក្នុងទីក្រុងបាត់ដំបងភាគខាងលិចប្រទេសកម្ពុជា ។ នៅពេលដែលភាគខាងលិចប្រទេសកម្ពុជាមួយនេះត្រូវបានបញ្ចូលទៅក្នុងទឹកដីថៃនាឆ្នាំ១៩៤១ នួន ជា បានក្លាយជាពលរដ្ឋថៃដោយស្វ័យប្រវត្តិ ។ ឆ្នាំបន្ទាប់ គាត់បានធ្វើដំណើរទៅទីក្រុងបាងកក ជាទីដែលគាត់ស្ថិតនៅក្រោមការមើលថែរក្សាពីសំណាក់ព្រះសង្ឃពាអង្គ រស់នៅក្នុងវត្តបិនចាម៉ាបូពិត ដែលជាអ្នកមានដើមកំណើតមកពីខេត្តបាត់ដំបងដែរ ។ នៅទីនោះ គាត់រស់នៅជាមួយព្រះសង្ឃ ហើយចុះឈ្មោះចូលរៀននៅក្នុងសាលាមធ្យមសិក្សារបស់រដ្ឋាភិបាលនៅក្នុងបរិវេណវត្ត ដោយប្រើឈ្មោះថៃ រុង ឡឹត (រុងឡឹត) ឡោឌី ។ គាត់បានសិក្សានៅសាលាវត្តបិណ្ឌចាម៉ាបូពិតអស់រយៈពេល ២ឆ្នាំក្នុងឆ្នាំសិក្សា១៩៤២និង១៩៤៣ ដោយបញ្ចប់ការសិក្សាពីសាលាមធ្យមសិក្សានៅដើមឆ្នាំ១៩៤៤ ។ ភ្លាមនោះ គាត់បានបន្តចូលវគ្គត្រៀមនៅសកលវិទ្យាល័យធម្មសាត្រ ដោយចុះឈ្មោះចូលរៀនវគ្គត្រៀមថ្នាក់បញ្ចប់ជំនាន់ទី៧ ។ គាត់រៀនបានល្អដោយបញ្ចប់ការសិក្សានៅឆ្នាំ១៩៤៦ ដោយទទួលបានពិន្ទុប្រសើរ ។ គាត់ក៏បន្តចូលរៀននៅសកលវិទ្យាល័យដោយចុះឈ្មោះចូលរៀននៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៤៦ ។

វាអាចទៅរួចដែលថា នៅពេលនោះដើម្បីបញ្ចប់ការសិក្សា

នៅសកលវិទ្យាល័យធម្មសាត្រត្រូវការរយៈពេល៣ឆ្នាំ ប៉ុន្តែ វុងឡឺត បានចំណាយពេលរហូតដល់ខែតុលា ឆ្នាំ១៩៤៨ គឺ២ឆ្នាំកន្លះបន្ទាប់ពីការចុះឈ្មោះចូលរៀនដើម្បីប្រឡងឲ្យជាប់នូវវគ្គសិក្សាដែលតម្រូវជាចាំបាច់សម្រាប់ឆ្នាំទី១របស់គាត់ ។ ការឈានទៅមុខយឺតៗនេះមកពីការខ្វះខាតពេលវេលាដើម្បីសិក្សាដោយសារគាត់បានចូលរួមក្នុងអង្គការយុវជនថៃ គឺជាក្រុមដែលទទួលឥទ្ធិពលពីកុម្មុយនីស្ត ពេលគាត់បានចូលរួមនៅឆ្នាំ១៩៤៧ តាមការអញ្ជើញរបស់ រួម វង់ផាន ដែលជាអតីតនិស្សិតសកលវិទ្យាល័យធម្មសាត្រ ហើយបានក្លាយជាសមាជិកបក្សកុម្មុយនីស្តថៃ ។ បន្ថែមពីលើសកម្មភាពនេះ នួន ជា ក៏បានធ្វើការជាមន្ត្រីរដ្ឋាភិបាលធម្មតាម្នាក់នៅចុងឆ្នាំ១៩៤៧ឬដើមឆ្នាំ១៩៤៨ ដោយបម្រើការងារជាស្មៀននៅការិយាល័យគណនេយ្យក្នុងនាយកដ្ឋានជម្រះបញ្ជីទូទៅរបស់ក្រសួងហិរញ្ញវត្ថុថៃ ។ ក្នុងនាមជានិស្សិតម្នាក់ គាត់អានសារព័ត៌មានមហាជនប្រចាំអង្គការបក្សកុម្មុយនីស្តថៃដែលបោះពុម្ពផ្សាយជាសាធារណៈ ចាប់តាំងពីខែតុលា ឆ្នាំ១៩៤៥ ហើយការចូលប្រឡូករបស់គាត់នៅក្នុងអង្គការយុវជនថៃដែលទទួលឥទ្ធិពលពីកុម្មុយនីស្តចាប់តាំងពីឆ្នាំ១៩៤៥ គឺជាបទពិសោធន៍ដំបូងបង្អស់របស់គាត់នៅក្នុងសកម្មភាពនយោបាយ ។ មិត្តភក្តិជិតស្និទ្ធដែលគាត់បានស្គាល់នៅក្នុងអង្គការយុវជនថៃនិងនៅកន្លែងធ្វើការ គឺជាអ្នកដែលបានចូលជាសមាជិកបក្សកុម្មុយនីស្តថៃរួចហើយ ក៏ប៉ុន្តែស្ថិតនៅខាងក្រៅជួរបក្សរយៈពេល៤ឆ្នាំរហូតដល់ឆ្នាំ១៩៥០ ។

នៅក្នុងខែមករា ឆ្នាំ១៩៥០ រយៈពេល១ឆ្នាំ៣ខែបន្ទាប់ពីបានបញ្ចប់ឆ្នាំទី១នៅខែតុលា ឆ្នាំ១៩៤៨ វុងឡឺត បានធ្វើការប្រឡងវគ្គសិក្សាចំនួន៨សម្រាប់ឆ្នាំទី២ ហើយប្រឡងជាប់ចំនួន៧មុខវិជ្ជា និងធ្លាក់មុខវិជ្ជាពាណិជ្ជកម្ម ។ ប្រការនេះមានភាពផ្ទុយគ្នាស្រឡះពីរយៈពេល២ឆ្នាំកន្លះដែលគាត់ត្រូវបញ្ចប់ការសិក្សាឆ្នាំទី១ ។ ភាគច្រើនបំផុត ការសិក្សានៅសកលវិទ្យាល័យធម្មសាត្រត្រូវមានឯកទេសទាក់ទងទៅនឹងច្បាប់ស្តីពីសង្គមមូលធន ។ នៅក្នុងឆ្នាំ១៩៥០ គាត់បានចូលរួមនៅក្នុងបក្សកុម្មុយនីស្តថៃតាមការអញ្ជើញរបស់ ឧត្តម ចារើនវ៉ាត ជាសមាជិកបក្សដែលជានិស្សិតនៅសកលវិទ្យាល័យធម្មសាត្រដូច វុងឡឺត ព្រមទាំងបានធ្វើការនៅការិយាល័យគណនេយ្យនៅនាយកដ្ឋានជម្រះបញ្ជីទូទៅ ។ វុងឡឺត ធ្វើការនៅកន្លែងដែលមានសមាជិកបីនាក់ដឹកនាំដោយ ឧត្តម ។ ក្រោយមកនៅឆ្នាំដដែល វុងឡឺត ធ្វើការប្រឡងចូលបម្រើការងារនៅក្នុងក្រសួងការបរទេសថៃ ហើយបានជាប់ធ្វើការ ព្រមទាំងឈប់ធ្វើការនៅឯក្រសួងហិរញ្ញវត្ថុ ។ ក៏ប៉ុន្តែត្រឹមតែរយៈពេល១ខែប៉ុណ្ណោះបន្ទាប់ពីបានចាប់ផ្តើមធ្វើការងារនៅក្រសួងការបរទេស គាត់បានលាលែងពីការងារ ។ គាត់ក៏បានបោះបង់ចោលការសិក្សានៅឯសកលវិទ្យាល័យធម្មសាត្រដែរ ដោយមិនបានបញ្ចប់ឆ្នាំទី២ដែលនៅសល់តែ១វគ្គទៀតប៉ុណ្ណោះ ។ គាត់បានផ្ទេរសមាជិកភាពរបស់គាត់ពីបក្សកុម្មុយនីស្តថៃទៅជាបក្សកុម្មុយនីស្តឥណ្ឌូចិន ដើម្បីត្រឡប់ទៅប្រទេសរបស់ខ្លួនវិញនិងចូលរួមក្នុងការតស៊ូប្រឆាំងនឹងបារាំងនៅប្រទេសកម្ពុជា ។

រួមជាមួយការពិនិត្យមើលទៅលើយុវវ័យរបស់ វុងឡឺត ឡោឌី និងជីវិតរបស់គាត់នៅក្នុងទីក្រុងបាងកក ការសិក្សានេះបានព្យាយាមបំភ្លឺឲ្យកាន់តែច្បាស់អំពីបក្សកុម្មុយនីស្តថៃនិងមនុស្សទាំងឡាយដែលធ្លាប់ពាក់ព័ន្ធនៅក្នុងបក្សនិងជាមួយ វុងឡឺត ។ មនុស្សមួយចំនួនត្រូវបានវិភាគនៅក្នុងការសិក្សានេះ ហើយអ្នកទាំងអស់នោះអាចបែងចែកទៅជា២ប្រភេទ ៖ សមាជិកបក្សដែលមានដើមកំណើតជាចិន ព្រមទាំងមនុស្សដែលជាជនជាតិថៃមានការអប់រំខ្ពស់ ។ សមាជិកបក្សនៅក្នុងប្រភេទទី១ ដែលត្រូវបានលើកយកមកសិក្សាគឺមាន វីរុត អាំងៃ (ឈ្មោះជាភាសាចិន ហ្វូង ជុនយុ) វីរ៉ាត អាងខាថាវុន (ហុង សឺកុង) ឧត្តម ស៊ីសុវ៉ាន (ត្រកូល ស៊ី) សុង នុជាខន (យុ សុង) ដារី រួងសុថាំ (វូ វៃស៊ី) និត ផុន ដាផេត (វូ គិនយិញ) ។ សមាជិកបក្សក្នុងប្រភេទទីពីរគឺ ប្រាសិទ្ធិ សាបសុនថុន រួម វង់ផាន ចារើនវ៉ាង៉ាម សាណុះ ផានិតចារើន ស៊ុមខ្វាន ភិរ៉ៃគុល និង ឧត្តម ចារើនវ៉ាត ។

សមាជិកក្នុងប្រភេទទី១គឺជាកូនរបស់អាណិជនចិនកើតនៅប្រទេសថៃ ។ អ្នកទាំងអស់នេះទទួលការអប់រំថ្នាក់បឋមសិក្សាឬមធ្យមសិក្សានៅក្នុងសាលាចិនក្នុងទីក្រុងបាងកក ។ ពេលរៀននៅសាលា អ្នកទាំងអស់នេះស្ថិតនៅក្រោមឥទ្ធិពលគ្រូជនជាតិចិនដែលជាសមាជិកបក្សកុម្មុយនីស្តសៀម (ដោយសារតែបក្សនេះត្រូវបានដាក់ឈ្មោះរហូតដល់ដំណាច់ទសវត្សរ៍៣០) ។ គ្រូទាំងអស់នេះមានសកម្មភាពក្លៀវក្លានៅក្នុងបក្សកុម្មុយនីស្តចាប់តាំងពីចុង

ទសវត្សរ៍៣០ ។ សមាជិកនៅក្នុងប្រភេទទី២ មិនមានវ័យខុសប្លែកគ្នាពីប្រភេទទី១ទេ ក៏ប៉ុន្តែអ្នកទាំងអស់នេះធំដឹងក្តីនៅតាមជនបទប្រទេសថៃ ទទួលការអប់រំថ្នាក់មធ្យមសិក្សាឬឧត្តមសិក្សានៅក្នុងទីក្រុងបាងកក ។ បន្ទាប់ពីសង្គ្រាមបញ្ចប់នៅឆ្នាំ១៩៤៥ អ្នកទាំងអស់នេះទទួលឥទ្ធិពលពីដំពូកមនុស្សប្រភេទទី១ ដែលនាំចូលក្នុងបក្សកុម្មុយនីស្ត ។ អ្នកទាំងនេះបានក្លាយទៅជាមនុស្សជំនាន់ដំបូងក្នុងចំណោមជនជាតិថៃដែលមានការអប់រំខ្ពស់ចូលជាសាមជិកបក្សកុម្មុយនីស្តថៃ ។ ចលនាកុម្មុយនីស្តបានចាប់ផ្តើមប្រតិបត្តិការនៅប្រទេសថៃចាប់តាំងពីចុងទសវត្សរ៍២០ ហើយបក្សកុម្មុយនីស្តសៀមត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣០ បន្ទាប់មកត្រូវបានរៀបចំឡើងវិញជាបក្សកុម្មុយនីស្តថៃនៅឯសមាជលើកដំបូងរបស់បក្សដែលបានធ្វើឡើងនៅខែធ្នូ ឆ្នាំ១៩៤២ ។ ប៉ុន្តែសមាជិកភាពរបស់ខ្លួនត្រូវបានបំពេញទាំងស្រុងដោយជនជាតិចិន (អាចជាអ្នកតាំងទីលំនៅក្នុងប្រទេសថៃឬមកពីប្រទេសចិន) និងជនជាតិវៀតណាម (ដែលបានចាកចេញពីតណ្ឌូចិននិងតាំងទីលំនៅក្នុងប្រទេសថៃ) ។ បក្សបានចាត់ទុកថាវាមានភាពសំខាន់ដើម្បីនាំយកជនជាតិថៃដែលទទួលបានការអប់រំនិងអាចក្លាយជាមេដឹកនាំបក្ស ប៉ុន្តែភាពជាអ្នកដឹកនាំមិនបានលេចឡើងទេក្រោយពីសង្គ្រាមលោកលើកទី២ ។

រុងឡឹត ជាជនជាតិខ្មែរ ប៉ុន្តែគាត់មិនបានបំបែកចេញនូវប្រភេទជាតិពន្ធទី៣ដែលជាប់ពាក់ព័ន្ធជាមួយបក្សកុម្មុយនីស្តថៃ ។ គាត់ស្ថិតនៅក្នុងក្រុមមនុស្សប្រភេទទី២ ។ គាត់ធំធាត់ឡើងនៅក្រោមឥទ្ធិពលព្រះពុទ្ធសាសនាហីនយាន ហើយនៅពេលគាត់បានមកកាន់ទីក្រុងបាងកក គាត់បានរស់នៅក្នុងវត្តជាមួយព្រះសង្ឃខណៈពេលសិក្សានៅសាលាមធ្យមសិក្សានិងឧត្តមសិក្សា ។ នេះពិតជាដូចគ្នាទៅនឹងសិស្សថៃដទៃទៀតដែលត្រូវបានចិញ្ចឹមនៅទីជនបទ ហើយដែលមកកាន់ទីក្រុងបាងកកដើម្បីបន្តការសិក្សាបន្ថែមទៀត ។ គាត់មានឈ្មោះថៃនិងសញ្ជាតិជាថៃ ហើយបន្ទាប់ពីចូលសកលវិទ្យាល័យធម្មសាត្រ គាត់បម្រើការងារជាមន្ត្រីរដ្ឋាភិបាលធម្មតាម្នាក់នៅក្រសួងហិរញ្ញវត្ថុ ហើយបន្ទាប់មកនៅក្រសួងការបរទេស ដូចជានិស្សិតថៃដទៃទៀតដែលសិក្សានៅសកលវិទ្យាល័យធម្មសាត្រ (រួមទាំងសមាជិកបក្សកុម្មុយនីស្ត) ដែលអាចធ្វើបានប្រសិនបើពួកគេប្រឡងជាប់ធ្វើការក្នុងរដ្ឋាភិបាល ។ ក្នុងនាមជាជនជាតិថៃម្នាក់ គាត់មានភាពសកម្មនៅក្នុងអង្គការយុវជនថៃ ហើយក្រោយមកបានក្លាយជាជនកុម្មុយនីស្ត ។ អាស្រ័យដូច្នេះ ហើយវាជាការត្រឹមត្រូវក្នុងការចាត់ទុកគាត់ជាផ្នែកនៃមនុស្សជំនាន់ដំបូងបង្អស់ក្នុងចំណោមជនជាតិថៃដែលមានការអប់រំខ្ពស់ដែលបានចូលរួមក្នុងបក្សកុម្មុយនីស្តថៃ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រុងឡឹត នៅតែរក្សាភក្តីស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះទឹកដីនៃប្រទេសកម្ពុជារបស់គាត់ ។ គាត់មានភាពខុសប្លែកពីនិស្សិតរួមជំនាន់សហការីដែលធ្វើការនៅក្នុងការិយាល័យរដ្ឋាភិបាលនិងសមមិត្តក្នុងបក្សកុម្មុយនីស្តទាំងឡាយ ។ ដោយសារតែប្រការនេះហើយទើបនៅក្នុងឆ្នាំ១៩៥០ ពេលដែលគាត់មានអាយុ២៨ឆ្នាំ រុងឡឹត ឡៅឌី បានចាប់ផ្តើមធ្វើការងារខុសប្លែកពីគេ ដែលនាំឲ្យគាត់ត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ ហើយក្រោយមកបានចូលទៅក្នុងជួរខ្មែរក្រហមជាន់ខ្ពស់ ។ ការរៀបរាប់តិចតួចឬស្ទើរតែគ្មានស្តីពីការរស់នៅរបស់ នួន ជា ក្នុងប្រទេសថៃ ផ្តល់ការពន្យល់អំពីការជ្រើសរើសយកគោលនយោបាយនិយមកែប្រែសង្គមទាំងស្រុងនិងប្រកបដោយការសម្លាប់រង្គាលនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ។ ការជ្រើសរើសទាំងអស់នេះមិនមានបុសគល់ផ្សេងទេ ដូចជាបទពិសោធន៍របស់ នួន ជា ក្នុងខណៈពេលរស់នៅប្រទេសវៀតណាមឬបន្ទាប់ពីការវិលត្រឡប់មកកាន់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៥៥ ។ **អ៊ីជី ម្វ៉ាស្ស៊ីម៉ា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# សោកនាដកម្មនៅតែបន្តមាន

ជាមួយនឹងការតែងតាំងអ្នកស្រីបណ្ឌិត ហែឡេន ចារីស ជាប្រធានដឹកនាំអង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានឈានទៅដល់ចំណុចស្មុគស្មាញថ្មីមួយទៀត ដែលជាក់ទម្ងន់ដល់ដំណើរការមួយដែលធ្លាប់បានទទួលរងផលប៉ះពាល់ពីការចោទប្រកាន់ថាមានអំពើពុករលួយនិងអសមត្ថភាព ។

កាលពីមុន អ្នកស្រីបណ្ឌិត ចារីស បានធ្វើការគ្រប់គ្រងផ្នែកកិច្ចការសាធារណៈដែលជាអង្គភាពមួយមានទំនួលខុសត្រូវក្នុងការផ្តល់ព័ត៌មានប្រាប់ប្រជាជនកម្ពុជាទូទាំងប្រទេសឲ្យដឹងអំពីដំណើរការទូទៅរបស់តុលាការនិងសម្រួលដល់ការឈ្វេងយល់និងការចូលរួមរបស់ប្រជាជនកម្ពុជា ។ ជាអកុសល ដោយស្ថិតនៅក្រោមការដឹកនាំរបស់អ្នកស្រីផ្នែកកិច្ចការសាធារណៈក៏បានលះបង់នូវធនធានសំខាន់យ៉ាងច្រើនក្នុងការខិតខំប្រឹងប្រែងផ្តល់ដំបូន្មានមិនល្អ ជាហេតុធ្វើឲ្យធនធាននេះមិនបានផ្តល់ជូនប្រជាជនកម្ពុជាមួយចំនួនឲ្យបានគ្រប់គ្រាន់នោះទេ ។ ដោយឡែក ធនធានទាំងនោះរួមមានការបោះពុម្ពអាវយឺតនិងមួកដែលមានតម្លៃថ្លៃ ប្រតិទិនសម្រាប់ដាក់លើតុ និងប័ណ្ណឃោសនាផ្សេងៗ ដែលសមិទ្ធផលទាំងអស់នេះត្រូវបានទទួលរងការរិះគន់យ៉ាងខ្លាំងចំពោះព័ត៌មានដ៏ប្របូកប្របល់របស់ផ្នែកកិច្ចការសាធារណៈនេះ ។ សកម្មភាពទាំងនេះជាការខាតបង់នូវធនធានដែលមានកម្រិតរបស់តុលាការ ។ ដូចដែលបានចង្អុលបង្ហាញម្តងរួចហើយ សមិទ្ធផលទាំងនេះបានជួយឲ្យផ្នែកកិច្ចការសាធារណៈសម្រេចនូវគោលដៅរបស់ខ្លួនតិចតួចណាស់ ។

អង្គភាពជនរងគ្រោះ គឺជាការកកើតថ្មីតែមួយគត់ដែលមានក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលមានភារកិច្ចផ្តល់ព័ត៌មាន



សិស្សានុសិស្សអានសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ”

ដល់អ្នករស់រានមានជីវិតនិងសម្រួលដល់ការចូលរួមរបស់ប្រជាជនក្នុងការស្តាប់ដំណើរការរបស់តុលាការ ។ សំខាន់ជាងនេះ ការងាររបស់អង្គភាពជនរងគ្រោះនេះត្រូវបានជឿទុកចិត្តដោយមនុស្សជាច្រើនថា អង្គភាពនេះនឹងក្លាយជាមធ្យោបាយមួយដ៏ល្អបំផុតក្នុងការធានាឲ្យប្រជាជននៅក្នុងប្រទេសកម្ពុជាមានអារម្មណ៍ថា យុត្តិធម៌សម្រេចបានដោយប្រជាជនកម្ពុជានិងសម្រាប់ប្រជាជនកម្ពុជា មិនមែនសម្រេចបានដោយអន្តរជាតិដែលមិនមានជាប់ពាក់ព័ន្ធ និងសម្រាប់ច្បាប់អន្តរជាតិដ៏ល្អអស្ចារ្យនោះទេ ។ អាណត្តិដ៏ថ្មីនេះទាមទារឲ្យមានអ្នកដឹកនាំដែលមានភាពម៉ឺងម៉ាត់ស្របទៅនឹងអាណត្តិការងារ ហើយអ្នកដឹកនាំនោះគឺជាជនជាតិកម្ពុជាដែលមានបទពិសោធន៍ការងារជាមួយជនរងគ្រោះ និងសមត្ថភាពក្នុងការសម្រេចប្រើប្រាស់ធនធាននិងក្នុងការសម្រេចគោលដៅដោយសមស្រប ។ អ្នកស្រីបណ្ឌិត ចារីស មិនមានបទពិសោធន៍ដែលទាក់ទងជាមួយនឹងវិជ្ជាជីវៈខាងលើ ហើយក៏មិនបានបង្ហាញឲ្យឃើញនូវគុណសម្បត្តិសំខាន់ៗរបស់អ្នកស្រីក្នុងការបំពេញតួនាទីជាប្រធានដឹកនាំផ្នែកកិច្ចការសាធារណៈដើម្បីដឹកនាំអង្គភាពជនរងគ្រោះនេះដែរ ។

ខណៈពេលដែលបញ្ហាកើតឡើងនៅក្នុងដំណើរការចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទំហំនៃការសម្រេចជោគជ័យ ឬបរាជ័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលស្ថិតនៅក្នុងកែវភ្នែករបស់អ្នករស់រានមានជីវិតកម្ពុជាទាំងអស់ប្រហែលជាពឹងផ្អែកទាំងស្រុងលើប្រសិទ្ធភាពការងាររបនាសម្ព័ន្ធគ្រប់គ្រង និងការយកចិត្តទុកដាក់របស់អង្គភាពជនរងគ្រោះ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបន្តដំណើរការឆ្ពោះទៅមុខដោយខ្វះខាតសេចក្តីស្វាហាប់ ការស្វែងយល់និងការយកចិត្តទុកដាក់ក្នុងការផ្តល់ព័ត៌មានដល់ប្រជាជនកម្ពុជា ដែលប្រជាជនទាំងអស់នេះបានសម្លឹងមើលការងាររបស់ផ្នែកកិច្ចការសាធារណៈយូរមកហើយ នោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាអាចនឹងទទួលបរាជ័យនៅក្នុងការឈ្វេងយល់ពីសមត្ថភាពជាក់ស្តែងដ៏ពេញលេញរបស់ខ្លួន ទោះបីជាដំណើរការកាត់ក្តីនេះទទួលបានជោគជ័យក៏ដោយ ។ សំឡេងរបស់ជនរងគ្រោះកម្ពុជាត្រូវបានបិទបាំងជាយូរណាស់មកហើយ ដូច្នេះដើម្បីឲ្យជនរងគ្រោះអាចបញ្ចេញសំឡេងរបស់គេបាន មានតែធ្វើឲ្យសោនាដកម្មនេះថយចុះប៉ុណ្ណោះ ។ **ណរមែន ផេនគេឡូវីច**

# ដំណឹងសួររកគ្រួសារ

នាងខ្ញុំឈ្មោះ អ៊ឹង ម៉ីហា អាយុ៣៩ឆ្នាំ មានបងប្អូន៣នាក់ ទី១) បងប្រុស អ៊ឹង សេងសាំង «ស្លាប់» ទី២) នាងខ្ញុំ និងទី៣) ប្អូនប្រុសឈ្មោះ អ៊ឹង ម៉ីហុង សព្វថ្ងៃមានអាយុប្រហែល៣៧ឆ្នាំ ។ ឪពុកឈ្មោះ អ៊ឹង សេង ជាមន្ត្រីសង្គមកិច្ច និងម្តាយមិនចាំឈ្មោះ ។ នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំមានសមាជិក៦នាក់ត្រូវបានជម្លៀសទៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ដោយសារតែហូបចុកមិនគ្រប់គ្រាន់ ក្រោយមកឪពុកអ្នកម្តាយនិងយាយរបស់ខ្ញុំក៏បានស្លាប់នៅជំនាន់នោះទៅ ។ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ខ្ញុំនិងប្អូនប្រុសរបស់ខ្ញុំបានភៀសខ្លួនទៅរស់នៅព្រំដែនថៃ រួចក៏វិលត្រឡប់មករស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ នៅឆ្នាំ១៩៨៣ ខ្ញុំបានធ្វើដំណើរទៅក្រុងភ្នំពេញតែម្នាក់ឯង ដោយទុកប្អូនប្រុស អ៊ឹង ម៉ីហុង ដែលទើបតែមានអាយុ១០ឆ្នាំឲ្យនៅជាមួយមីងឈ្មោះ ភាព ។ ចាប់ពីពេលនោះមក ខ្ញុំបានបែកពីប្អូនប្រុស អ៊ឹង ម៉ីហុង រហូតមកដល់សព្វថ្ងៃ ។ តាមរយៈការស៊ើបសួរដំណឹងពីអ្នកភូមិដែលធ្លាប់រស់នៅជាមួយគ្នាបានប្រាប់ថា ពួកគាត់ក៏មិនដឹងថា អ៊ឹង ម៉ីហុង រស់នៅទីណាដែរ ។

ដូច្នេះ បើសិនបងប្អូនបានស្គាល់ឬបានជួបឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំតាមអាសយដ្ឋាននៅភូមិថ្មី សង្កាត់ស្ទឹងត្រែង ខណ្ឌស្ទឹងត្រែង ក្រុងស្ទឹងត្រែង ឬទូរស័ព្ទលេខ ០៩២ ៤០ ៥៨ ៧៣ ៨៨ ។

# របួសកម្ពុជាដែលមិនទាន់ព្យាបាល

*របបខ្មែរក្រហមនិងផលវិបាកនៃអំពើប្រល័យពូជសាសន៍ បានបន្សល់ទុកនូវកេរដំណែលខាងផ្លូវចិត្តដែលធ្វើឲ្យមានការខូចខាតដល់ការអភិវឌ្ឍប្រទេសកម្ពុជា ។ ទោះបីជារបបខ្មែរក្រហមបានដួលរលំអស់ជាងបីទសវត្សរ៍មកហើយក៏ដោយ ក៏ការរាំងខាតដំណើរការព្យាបាលជនរងគ្រោះដែលមានរបួសផ្លូវចិត្ត ការជឿទុកចិត្តដែលបង្កឡើងដោយរបបខ្មែរក្រហម ការពន្យារពេលបង្កើតតុលាការខ្មែរក្រហម និងការមិនជឿទុកចិត្តរបស់សាធារណជនទៅលើតុលាការកូនកាត់នៅតែធ្វើឲ្យជនរងគ្រោះមានរបួសផ្លូវចិត្តដែលរារាំងគេមិនឲ្យសះស្បើយពីជំងឺនោះដើម្បីរួមចំណែកផ្តល់វិភាគទានយ៉ាងពេញទំហឹងក្នុងការអភិវឌ្ឍកម្ពុជាដដែល ។*

## *សេចក្តីផ្តើម*

*កម្ពុជាបានផ្លាស់ប្តូរទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់ខ្លួននៅឆ្នាំ១៩៧៥-១៩៧៩ ប៉ុន្តែរបបនេះបានបន្សល់ទុកនូវរបួសដ៏ធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ជួបប្រទះអំពើដ៏ឃោរឃៅនៅក្នុងរបបនេះ ។ របួសនេះមិនទាន់បានព្យាបាលនៅឡើយទេ ហើយវាបានបន្ថយការតស៊ូរបស់កម្ពុជាដើម្បីឆ្ពោះទៅកាន់ការជាសះស្បើយ ។ របបខ្មែរក្រហមដែលស្គាល់ជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យត្រូវបានអង្គការសហប្រជាជាតិប្រកាសថាជា «របបប្រល័យពូជសាសន៍» ហើយវាត្រូវបានកំណត់ថាជា «ហូឡូខសត៍ៈ ការសម្លាប់មនុស្សរង្គាលនៅទ្វីបអឺរ៉ុបក្នុងសម័យសង្គ្រាមលោកលើកទីពីរ ដែលមានទម្រង់ដូចប្រទេសកម្ពុជា» ។ អំពើប្រល័យពូជសាសន៍មិនត្រឹមតែធ្វើឲ្យអ្នកដែលជួបប្រទះអំពើសាហាវឃោរឃៅដោយផ្ទាល់មានរបួសប៉ុណ្ណោះទេ វាថែមទាំងប៉ះពាល់ដល់កូនចៅជំនាន់ក្រោយទៀតផង ។ ម៉ាយស្លាយវិក (Mysliwiec) បានធ្វើការកំណត់សម្គាល់ថា «មិនមានរបបណាមានឥទ្ធិពលបំផ្លាញសង្គមទាំងមូលដូចជារបបខ្មែរក្រហមដែលបានបន្សល់ទុកស្នាមរបួសដ៏ធ្ងន់ធ្ងរឲ្យប្រជាជនកម្ពុជានេះទេ» ។ ជាងនេះទៅទៀត អំពើប្រល័យពូជសាសន៍ខ្មែរក្រហមនិងផលវិបាករបស់វាបានបន្សល់ទុកនូវកេរដំណែលខាងផ្លូវចិត្តដែលធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍសង្គមកម្ពុជាថែមទៀត ។*

## *ភាពឃោរឃៅនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហមនិងផលវិបាករបស់វា*

*តាមរយៈរដ្ឋប្រហារឆ្នាំ១៩៧០ ដែលទម្លាក់ព្រះបាទនរោត្តមសីហនុ ជាព្រះប្រមុខរដ្ឋ ប្រទេសកម្ពុជាត្រូវបានប្តូរឈ្មោះទៅជាសាធារណរដ្ឋខ្មែរ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សេនាប្រមុខ លន់ នល់ ដែលគាំទ្រដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ របបអាសោចនេះបានបញ្ចប់នៅពេលដែលកងទ័ពខ្មែរក្រហមដឹកនាំដោយ សាឡុត ស (ប៉ុល ពត) ចូលមកដល់ទីក្រុងភ្នំពេញ ហើយគ្រប់គ្រងប្រទេសទាំងមូលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ អ្នកនៅទីក្រុងជាច្រើនបានស្វាគមន៍ទាហានក្មេងៗទាំងនេះដោយក្តីរីករាយ និងការជឿជាក់ដោយសង្ឃឹមក្នុងចិត្តថា បដិវត្តន៍ទទួលបានជ័យជម្នះ សង្គ្រាមស៊ីវិលក៏នឹងត្រូវបានបញ្ចប់ដែរ ។ ប៉ុន្តែក្តីសង្ឃឹមនេះគ្រាន់តែកើតឡើងមួយភ្លែតប៉ុណ្ណោះ ការពិតរបបថ្មីបានធ្វើឲ្យពួកគេមានភាពភ្ញាក់ផ្អើល បន្ទាប់មកទំព័រប្រវត្តិសាស្ត្ររបស់កម្ពុជាដ៏ខ្មៅងងឹតក៏ចាប់ផ្តើមឡើង ។*

*របបខ្មែរក្រហមមានឈ្មោះជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យ ។ អ្នកនិពន្ធរឿងប្រវត្តិសាស្ត្រកម្ពុជាផ្សេងៗបានឲ្យឈ្មោះរដ្ឋាភិបាលនេះខុសៗគ្នា ។ ជាក់ស្តែង ម៉ៃឃើល វិកឃើរី (Michael Vickery) ហៅរដ្ឋាភិបាលរបបនេះថាជារដ្ឋាភិបាល «បដិវត្តន៍កសិកម្ម» ខណៈពេលដែលបញ្ញវន្តផ្សេងទៀតហៅរបបនេះថា «លទ្ធិផ្តាច់ការ» ឬ «បដិវត្តន៍ផ្តាច់ការ» ។ មិនថាមានការហៅឈ្មោះរដ្ឋាភិបាលអ្វីនោះទេ អ្វីដែលច្បាស់គឺវាជារបបប្រល័យពូជសាសន៍ដែលធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ១,៧លាននាក់ស្លាប់ (ក្នុងចំណោមប្រជាជនកម្ពុជាសរុបចំនួនតិចជាង៨លាននាក់) ដោយសារការសម្លាប់*

ដោយហេតុផលនយោបាយ ការធ្វើការហួសកម្លាំង ជំងឺ ការអត់ឃ្លាននិងការខ្វះអាហារូបត្ថម្ភដែលជាផលវិបាកនៃ «ការផ្លាស់ប្តូរសេដ្ឋកិច្ចនិងសង្គមដែលគេជឿថាគួរតែផ្លាស់ប្តូរ» ។ ការផ្លាស់ប្តូរនេះត្រូវបានអនុវត្តដោយរដ្ឋាភិបាលថ្មី ។

នៅក្នុងផែនការបង្កើតសង្គមកសិកម្មដែលល្អឥតខ្ចោះដំបូងខ្មែរក្រហមបានផ្លាស់ប្តូរកម្ពុជាទៅជាឆ្នាំសូន្យ ដោយធ្វើឲ្យរាជធានីនិងទីក្រុងភាគច្រើនគ្មានមនុស្សរស់នៅ ព្រមទាំងជម្លៀសប្រជាជនទៅជនបទ ។ ហាមឃាត់មិនឲ្យមានទ្រព្យសម្បត្តិឯកជននិងការប្រើប្រាស់រូបិយវត្ថុ ។ មិនអនុញ្ញាតឲ្យមានអង្គការអន្តរជាតិឬស្ថានទូតបរទេស ហើយបុគ្គលិកអន្តរជាតិត្រូវបានបង្ខំឲ្យចាកចេញពីប្រទេស ។ ព្រំដែនកម្ពុជាត្រូវបានបិទជិតដោយមិនមានទំនាក់ទំនងជាមួយលោកខាងក្រៅ ។ ខ្មែរក្រហមចង់ប្រែក្លាយកម្ពុជាទៅជាប្រទេសគំរូមួយក្នុងពិភពលោកដោយព្យាយាមលុបបំបាត់ «ការចម្លងរោគមកពីខាងក្រៅ» ។ ខ្មែរក្រហមហៅខ្លួនឯងថាអង្គការ ជាឈ្មោះដែល ប៉ុល ពត រៀបរាប់នៅឆ្នាំ១៩៧៧ ថាជា «ការិយាល័យនយោបាយនៃគណៈមជ្ឈិមបក្សកុម្មុយនីស្ត» ។

ខ្មែរក្រហមបាននាំយករបបថ្មីដែលពោរពេញដោយការកាប់សម្លាប់យ៉ាងសាហាវឃោរឃៅនៅក្នុងប្រទេសប្រឆាំងនឹងប្រជាជនខ្លួនឯងតាមរយៈការបង្កើត «លក្ខណៈកម្មុចជាប្រព័ន្ធទៅលើប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ សាសនា រចនាសម្ព័ន្ធរៀបចំប្រទេសនិងគ្រួសារ» ។ ប្រទេសកម្ពុជា ដែលស្ថិតនៅក្រោមរបបខ្មែរក្រហមប្រៀបដូចជាជំរំប្រមូលផ្តុំ ឬគុកឥតជញ្ជាំង ។ ខ្មែរក្រហមធ្វើការងារដោយលាក់ការណ៍ខ្ពស់បំផុត ទោះបីជាមន្ត្រីក្នុងស្រុក កម្មាភិបាលនិងយោធាក៏មិនដឹងថាអ្នកណាជាមេដឹកនាំរបស់គេដែរ ។ វា «តំណាងឲ្យអំណាចដែលមានប្រសិទ្ធភាពនិងមើលមិនឃើញដែលធ្វើឲ្យអ្នកទាំងអស់គ្នាគោរពតាម» ។

ខ្មែរក្រហមចាប់ផ្តើមអនុវត្តការសម្លាប់តាមហេតុផលនយោបាយ ដោយធ្វើការសម្លាប់អ្នកដែលមានទំនាក់ទំនង ឬ ត្រូវបានសន្និដ្ឋានថាមានទំនាក់ទំនងជាមួយរបបមុន ។ ខ្មែរក្រហមបានកំណត់គោលដៅទៅលើមន្ត្រីប៉ូលិស យោធា អ្នករដ្ឋការ គ្រូបង្រៀនសិស្សនិងបញ្ញវន្តដទៃទៀត ។ គេចោទប្រកាន់អ្នកទោសទាំងនេះថាជាសត្រូវអង្គការ ។ អ្នកពាក់វ៉ែនតា អ្នកដែលមានសម្បុរ-សនិងដៃទន់ក៏ជាគោលដៅរបស់គេដែរ ។ មានការប៉ាន់ប្រមាណថាប្រជាជនកម្ពុជាប្រហែល២សែននាក់គឺជាជនរងគ្រោះនៃការសម្លាប់ដោយហេតុផលនយោបាយ ។ មានតែមនុស្សបន្តិចបន្តួចប៉ុណ្ណោះអាចគេចផុតពីការសម្លាប់បំផុតពូជ ពីព្រោះគេបានលាក់ប្រវត្តិនិងអត្តសញ្ញាណរបស់ខ្លួន ដែលបន្ទាប់មកបណ្តាលឲ្យមានការបាត់បង់អត្តសញ្ញាណនិងការឲ្យតម្លៃខ្លួនឯង ។

ការបំផ្លាញយ៉ាងធ្ងន់ធ្ងរទៅលើវប្បធម៌កម្ពុជាគឺជាការវាយប្រហារទៅលើតម្លៃគ្រួសារតាំងពីបុរាណ ។ ជីវិតគ្រួសារស្ទើរតែត្រូវបានបំផ្លាញ ។ កូនត្រូវបានបំបែកចេញពីឪពុកម្តាយ ហើយឲ្យរស់នៅឆ្ងាយពីគ្នា ។ ដោយសារតែឈ្លបមាននៅគ្រប់ទីកន្លែងប្រជាជនព្យាយាមមិននិយាយ ទោះបីជានិយាយជាមួយក្មេងៗក៏ដោយ ។ ជាងនេះទៅទៀត ខ្មែរក្រហមព្យាយាមណែនាំក្មេងៗដោយជំរុញឲ្យធ្វើជាកងឈ្លបស៊ើបការណ៍ពីមនុស្សធំ ដូចជាឪពុកម្តាយរបស់គេ ព្រមទាំងបង្រៀនពាក្យស្លោករបស់របបខ្មែរក្រហមដូចជា «ខ្ញុំមិនបានសម្លាប់ម្តាយរបស់ខ្ញុំទេ ខ្ញុំសម្លាប់សត្រូវ» ។ ការសន្ទនារវាងប្តីប្រពន្ធបានកាត់បន្ថយសល់ត្រឹមតែការប្រើក្រសែភ្នែកឬនិយាយខ្សឹបៗ ទោះបីជាគេនៅជាមួយគ្នាក៏ដោយ ។ នេះបង្ហាញពីទីបញ្ចប់នៃតួនាទីរបស់គ្រួសារដែលជាផ្នែកមួយនៃសង្គមនិងការគាំទ្រ ។

បន្ថែមទៅលើការកាត់បន្ថយតម្លៃគ្រួសារ អង្គការបានព្យាយាមបំផ្លាញការទុកចិត្តគ្នាទៅវិញទៅមករបស់សមាជិកគ្រួសារ មិត្តភក្តិ អ្នកជិតខាង និងអ្នកដែលធ្លាប់ស្គាល់គ្នាថែមទៀត ។ មិត្តជិតស្និទ្ធ និងមិត្តចាស់ត្រូវបានជំរុញឲ្យផ្តល់ព័ត៌មានអំពីគ្នាឯងដែលនាំឲ្យមានការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួន «អ្នកដែលជាសត្រូវបដិវត្តន៍» ។ ប្រជាជនស្ថិតនៅក្រោមការឃ្លាំមើលគ្រប់ពេល ជាពិសេសនៅពេលយប់ ។ «ដោយសារអ៊ីដែលគេធ្វើហាក់ដូចជាស្ថិតនៅក្រោមការស៊ើបអង្កេត ប្រជាជនយល់ថាអង្គការមានភ្នែកម្នាស់» ។ ស្របទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើតម្លៃគ្រួសារនិងការបំផ្លាញការជឿទុកចិត្តលើគ្នាទៅវិញទៅមក អង្គការបានលុបបំបាត់ស្ថាប័នសង្គមដែលមានសារសំខាន់រួមមាន សាលារៀន មន្ទីរពេទ្យ និងវត្ត ។ ព្រះសង្ឃត្រូវបានផ្សឹកហើយបង្ខំឲ្យធ្វើការដូចជាមនុស្សធម្មតា ខណៈពេលដែលវត្តត្រូវ

បានប្រែក្លាយទៅជាគុក មន្ទីរធ្វើទារុណកម្ម ឬឃុំឃាំងដាក់អីវ៉ាន់ ។

អំពើប្រល័យពូជសាសន៍ខ្មែរក្រហមត្រូវបានបញ្ចប់នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ទោះជាយ៉ាងណាក៏ដោយ ផលលំបាកដែលបន្សល់ទុកពីរបបខ្មែរក្រហមគឺជាការបំផ្លាញទាំងស្រុង ។ ជាបឋម ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធគឺជាបញ្ហាដ៏លំបាកសម្រាប់រដ្ឋាភិបាលថ្មីពីព្រោះតែវាមានតួនាទីដ៏សំខាន់ក្នុងការស្តារសេដ្ឋកិច្ចដែលបានដួលរលំ ។ បញ្ហាលំបាកទីពីរ គឺការបាត់បង់ធនធានមនុស្សដែលមានសារសំខាន់សម្រាប់ជួយអភិវឌ្ឍប្រទេសឡើងវិញ ។ ស្ទើតែគ្រប់បញ្ញវន្ត ដូចជាអ្នករដ្ឋការ គ្រូពេទ្យ គ្រូបង្រៀន អ្នកបច្ចេកទេស សិស្សនៅរបបមុនត្រូវបានសម្លាប់នៅក្នុងរបបនោះ ។ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិបានប៉ាន់ប្រមាណថាមានតែ «អ្នកដែលមានសមត្ថភាពនិងបទពិសោធន៍គ្រប់គ្រាន់ប្រមាណ ៣០០នាក់ប៉ុណ្ណោះនៅក្នុងប្រទេស» បន្ទាប់ពីរបបនេះដុតរលត់ទៅ ។ អ្វីដែលបន្សល់ទុកបន្ទាប់ពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមគឺកុមារកំព្រា ប្រជាជនដែលមានជំងឺនិងសុខភាពទ្រុឌទ្រោម ។ មានការប៉ាន់ប្រមាណថា បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមមានកុមារកំព្រាប្រមាណ២សែននាក់ត្រូវការការឧបត្ថម្ភសង្គ្រោះជាបន្ទាន់ ។ ជាងនេះទៅទៀត សង្គ្រាមរវាងកងទ័ពខ្មែរក្រហមដែលនៅសល់និងកងទ័ពរបស់របបថ្មីគឺជាបញ្ហាលំបាកផ្សេងទៀតសម្រាប់រដ្ឋាភិបាលថ្មី ។ តាមការពិត បន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម សង្គ្រាមស៊ីវិលនៅតែបន្តរហូតដល់ចុងឆ្នាំ១៩៩៨ ។ ជាមួយនឹងការស្លាប់អ្នកដែលមានសមត្ថភាពនិងបទពិសោធន៍ និងការបំផ្លិចបំផ្លាញគ្រប់វិស័យដូចជាវិស័យអប់រំ សេដ្ឋកិច្ច និងសុខាភិបាល ប្រទេសកម្ពុជាចាំបាច់ត្រូវតែចាប់ផ្តើមពីភាពខ្ទេចខ្ទីដើម្បីកសាងសង្គមដែលបែកបាក់សាជាថ្មី ។

មិនមានការប៉ះពាល់ដល់ផ្លូវចិត្តណាឬអំពើឃោរឃៅណាដែលកើតឡើងនៅពេលថ្មីៗនេះបណ្តាលឲ្យមានការធ្លាក់ចុះសីលធម៌នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នឡើយ ។ វាគឺជាបទពិសោធន៍រួមដែលបង្កើតជាបញ្ហាឲ្យប្រជាជនប្រឈមមុខនិងបំភ្លេចចោលពីការចងចាំ ។


អ្នកភូមិស្តាប់ការពន្យល់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីដំណើរការតុលាការខ្មែរក្រហម

អាស្រ័យហេតុនេះ ផលវិបាកនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហមគឺជារបួសផ្លូវចិត្តរបស់ជាតិទាំងមូល ។ វាជាបទពិសោធន៍រួមដែលកើតឡើងដោយការរំលោភបំពានរបស់អ្នកគ្រប់គ្រងដែលធ្វើឡើងដើម្បីប្រឆាំងនឹងប្រជាជនខ្លួនឯង ។ រហូតដល់របួសផ្លូវចិត្តត្រូវជាសះស្បើយ ហើយជនរងគ្រោះដែលមានរបួសផ្លូវចិត្តបំភ្លេចរឿងអតីតកាលដ៏ជូរចត់ ការតស៊ូរបស់កម្ពុជាដើម្បីឈានទៅដល់ការជាសះស្បើយពីរបួសផ្លូវចិត្តនិងការអភិវឌ្ឍនឹងក្លាយទៅជាបញ្ហាលំបាកដ៏ធំមួយទោះបីជារបបប្រល័យពូជសាសន៍ខ្មែរក្រហមដ៏សាហាវឃោរឃៅបានដួលរលំបីទសវត្សរ៍មកហើយក្តី ។

## ការខ្វះខាតការព្យាបាល

ជាបឋម ការខ្វះខាតដំណើរការព្យាបាលជនរងគ្រោះនៃរបបខ្មែរក្រហមបានរារាំងលទ្ធភាពរបស់ប្រជាជនដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេស ។ ប្រទេសមួយអាចអភិវឌ្ឍនៅពេលដែលប្រទេសនោះមានធនធានមនុស្សដែលមានសុខភាពល្អគ្រប់គ្រាន់ ។ ទោះជាយ៉ាងនេះក្តី តើប្រទេសកម្ពុជាអាចអភិវឌ្ឍទៅតាមល្បឿនចង់បានដែរឬទេ នៅពេលដែលបញ្ញវន្តស្ទើតែទាំងអស់ត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហម ហើយអ្នកដែលនៅរស់សុទ្ធតែមានរបួសផ្លូវចិត្តមិនមានលទ្ធភាពជួយអភិវឌ្ឍន៍ប្រទេស? ចំណុចដែលសំខាន់ជាងគេគឺថា វាមានការព្យាបាលតែបន្តិចបន្តួច ឬមិនមានការព្យាបាលជនរងគ្រោះដែលមានរបួសផ្លូវចិត្តទាល់តែសោះ ។ ការខ្វះខាតការព្យាបាលជនរងគ្រោះដែលមានរបួសផ្លូវចិត្តឲ្យទាន់ពេលវេលា បណ្តាលឲ្យជនរងគ្រោះមានរបួសផ្លូវចិត្តរ៉ាំរ៉ៃ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ជនរងគ្រោះនៅតែនឹកឃើញបទពិសោធន៍ពីអតីតកាលដែលធ្វើឲ្យគេនៅតែមានរបួសផ្លូវចិត្ត ។ នេះមិនមែនត្រឹមតែមកពីបទពិសោធន៍ដែលគេជួបប្រទះបណ្តាលឲ្យមានរបួសផ្លូវចិត្តមានការវិវត្តន៍ប៉ុណ្ណោះទេ វាថែមទាំងមកពីការនឹកឃើញបទពិសោធន៍ ឬព្រឹត្តិការណ៍ស្រដៀងគ្នាផងដែរ ។

ការខ្វះខាតការព្យាបាលឲ្យទាន់ពេលវេលានិងសមស្រប និងការខ្វះខាតការគាំទ្រពីសង្គមចំពោះជនរងគ្រោះដែលមានរបួសផ្លូវចិត្តធ្វើឲ្យមានផលប៉ះពាល់បណ្តាលឲ្យមានភាពអន្តរាយ ។ ជាមួយនឹងការគាំទ្រយ៉ាងត្រឹមត្រូវ លទ្ធភាពដែលធ្វើឲ្យជនរងគ្រោះមាន «ជំងឺផ្លូវចិត្តកម្រិតធ្ងន់» អាចកាត់បន្ថយ ហើយអាចធ្វើឲ្យអ្នកជំងឺឆាប់ «ជាសះស្បើយនិងធូរស្រាល» ។ ប៉ុន្តែជាងបីទសវត្សរ៍មកហើយ មិនមានការយកចិត្តទុកដាក់ទៅលើការព្យាបាលរបួសផ្លូវចិត្តទេ ។ នៅពេលថ្មីៗនេះ មានអង្គការក្រៅរដ្ឋាភិបាលខ្លះយកចិត្តទុកដាក់ទៅលើការព្យាបាលរបួសផ្លូវចិត្តរបស់ប្រជាពលរដ្ឋ ។ ទោះជាយ៉ាងនេះក្តី អង្គការក្រៅរដ្ឋាភិបាលនេះហាក់ដូចជាយឺតពេកទៅហើយ ពីព្រោះផលប៉ះពាល់នៃរបួសផ្លូវចិត្តហាក់ដូចជារាលដាលដល់អ្នកជំនាន់ទីពីរនៃជនរងគ្រោះរបស់ខ្មែរក្រហម ហើយចំពោះជនរងគ្រោះមួយចំនួន របួសផ្លូវចិត្តរបស់គេក៏បានវិវត្តទៅជាជំងឺបាក់ស្បាតធ្ងន់ធ្ងរដែរ ។ ជាក់ស្តែង យោងទៅតាមខេនហ្វ៊ី បានឲ្យដឹងថា «ជនរងគ្រោះនៃរបបខ្មែរក្រហមស្ទើតែទាំងអស់មានជំងឺបាក់ស្បាត» ។

ពីព្រោះរបួសផ្លូវចិត្តមិនទាន់ត្រូវបានព្យាបាល ជនរងគ្រោះនៅតែនឹកឃើញបទពិសោធន៍ពីអតីតកាល ហើយការគិតអ្វីដែលមិនល្អ ការធ្លាក់ទឹកចិត្ត ការស្មុគស្មាញ ការស្ទាក់ស្ទើរមិនហ៊ានធ្វើអ្វីមួយនៅតែមានក្នុងចិត្តប្រជាជនកម្ពុជាបច្ចុប្បន្ន ទោះបីជាបទពិសោធន៍នៃរបួសផ្លូវចិត្តដែលគេបានជួបប្រទះដោយផ្ទាល់នៅក្នុងរបបខ្មែរក្រហមបានកន្លងហួសយូរណាស់មកហើយក្តី ។ ដូចដែលបានលើកឡើងនៅក្នុងសៀវភៅ វេនដី ខក និង ម៉ាកហ៊ីសឡី «ទោះបីជាប៉ុន្មានឆ្នាំឬប៉ុន្មានទសវត្សរ៍បានកន្លងផុតទៅហើយក្តី ជនរងគ្រោះនៅតែអះអាងថាបទពិសោធន៍នោះនៅតែដក់ជាប់ក្នុងចិត្តរបស់គេយ៉ាងរស់រវើកនៅពេលដែលគេនឹកទៅដល់រឿងនោះម្តងៗ» ។ ជាក់ស្តែង ការសិក្សាបន្តបន្ទាប់រយៈពេល១២ឆ្នាំ លើយុវជនខ្មែរដែលមានរបួសផ្លូវចិត្តបណ្តាលមកពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមបង្ហាញឲ្យឃើញថាបទពិសោធន៍នៃរបួសផ្លូវចិត្តជនរងគ្រោះស្ទើរតែទាំងអស់នៅតែត្រូវបានបន្លាចដោយបទពិសោធន៍នោះម្តងហើយម្តងទៀត ។ នេះបង្ហាញថា របួសផ្លូវចិត្តដែលមិនមានការព្យាបាលមានផលប៉ះពាល់រយៈពេលវែងដល់ជនរងគ្រោះ ។ បទពិសោធន៍នៃរបួសផ្លូវចិត្តពីអតីតកាលរបស់គេរារាំងគេមិនឲ្យផ្តោតអារម្មណ៍ទៅលើអ្វីដែលកើតឡើងនៅពេលបច្ចុប្បន្ន ហើយសម្លឹងទៅអនាគតដោយមានក្តីសង្ឃឹម ។ អាស្រ័យហេតុនេះ ពួកគេត្រូវបានរារាំងមិនឲ្យចូលរួមក្នុងការអភិវឌ្ឍកម្ពុជា ។

ដោយហេតុនេះទើបមានការបាត់បង់ធនធានមនុស្សច្រើនយ៉ាងនេះ ។ ដោយបន្ថែមទៅលើការបាត់បង់បញ្ញវន្តតាមរយៈការសម្លាប់បំផុតពូជរបស់ខ្មែរក្រហម អ្នកដែលនៅសល់មានជំងឺធ្ងន់ធ្ងរ ឬមានរបួសផ្លូវចិត្តធ្ងន់ធ្ងរដែលមិនអាចធ្វើការងាររបស់គេ ។ នេះជាការបាត់បង់កម្លាំងពលកម្មយ៉ាងច្រើនរបស់ប្រទេស ។ អ្វីដែលគួរឲ្យសោកស្តាយជាងនេះទៀត គឺបទពិសោធន៍នៃរបួសផ្លូវចិត្តនេះបានឆ្លងទៅដល់កូនចៅជំនាន់ក្រោយរបស់កម្ពុជាដែលជាកូនចៅរបស់ជនរងគ្រោះដែលមានរបួសផ្លូវចិត្តដោយសាររបបខ្មែរក្រហម ។

កូនចៅរបស់អ្នកដែលនៅរស់ហាក់ដូចជាបានស្រូបយកបទពិសោធន៍បែបហូឡូខសន៍ពីឪពុកម្តាយរបស់គេនៅក្នុងជីវិតដោយមិនដឹងខ្លួនឬពេលខ្លះដោយដឹងខ្លួន ។ ដើម្បីបង្រៀនកូនពីអ្វីដែលល្អបំផុត ឪពុកម្តាយដែលមានបទពិសោធន៍បែបហូឡូខសន៍បានបង្រៀនកូនពីរបៀបធ្វើឲ្យរស់ជីវិត ។ នៅក្នុងដំណើរការបង្រៀន គេបាននាំយកស្ថានភាពជីវិតដែលគេបានធ្វើដើម្បីរស់ពីសង្គ្រាមទៅឲ្យកូន ។

អាស្រ័យហេតុនេះ វាបង្ហាញយ៉ាងច្បាស់ថារបួសផ្លូវចិត្តដែលមិនទាន់បានព្យាបាលមិនត្រឹមតែបន្ថយសមត្ថភាពរបស់ប្រជាជនដែលជួបប្រទះរបួសផ្លូវចិត្តដោយផ្ទាល់នោះទេ វាថែមទាំងបន្ថយសមត្ថភាពរបស់កូនចៅជំនាន់ក្រោយផង ។ ការបាត់បង់កម្លាំងដែលមានសុខភាពល្អ ទាំងពីរនេះគឺជាឧបសគ្គពីររបស់កម្ពុជាក្នុងការធ្វើឲ្យប្រជាជនជាសះស្បើយនិងដើម្បីអភិវឌ្ឍប្រទេស ។

## ការបាត់បង់ការជឿទុកចិត្ត

ការជឿទុកចិត្តដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវទំនាក់ទំនងរបស់ប្រជាជន ។ ជាមួយនឹងកម្រិតខ្ពស់នៃការជឿទុកចិត្ត មនុស្សអាចសហការនិងធ្វើការជាមួយគ្នាបានយ៉ាងល្អ ។ ប៉ុន្តែនៅអំឡុងពេលរបបខ្មែរក្រហម ការជឿទុកចិត្តគ្នាទៅវិញទៅមករបស់ប្រជាជនត្រូវបានប៉ះពាល់តាមរយៈការអនុវត្តនយោបាយមនោគមន៍វិជ្ជារបស់របប ។ សូម្បីតែការជឿទុកចិត្តរវាងសមាជិកគ្រួសារ និងមិត្តភក្តិក៏ត្រូវបានបំផ្លាញជាប្រព័ន្ធដែរ ។ ក្នុងគោលបំណងលុបបំបាត់ទំនាក់ទំនងរបស់ប្រជាជនជាមួយរបបមុន ខ្មែរក្រហមបានបញ្ចូលមនោគមន៍វិជ្ជាទៅឲ្យក្មេងៗ ហើយជ្រើសតាំងពួកគេឲ្យធ្វើជាឈ្លបអង្គការ ។ ឈ្លបក្មេងៗនេះត្រូវបានបណ្តុះបណ្តាលឲ្យ «ចាំស្តាប់ពាក្យសម្តីរបស់មនុស្សធំ ទោះបីគេជាអ្នកណាក៏ដោយ» ។ ក្មេងៗត្រូវបានជំរុញឲ្យរាយការណ៍ដល់អង្គការ ប្រសិនបើសមាជិកគ្រួសារ ឬអ្នកជិតខាងរបស់គេបានធ្វើខុសអ្វីមួយ ។ ជាងនេះទៅទៀត ការជឿទុកចិត្តរវាងមិត្តជិតស្និទ្ធ និងអ្នកជិតខាងក៏ត្រូវបានលុបបំបាត់ដែរ ។ «សហគមន៍ ឬសមាជិកគ្រួសារត្រូវបានលើកទឹកចិត្តឲ្យស៊ើបការណ៍និងរាយការណ៍ពីគ្នាឯង ដែលបំផ្លាញដល់ការជឿទុកចិត្ត និងបង្កើតជាការភិតភ័យយ៉ាងខ្លាំង» ។ អាស្រ័យហេតុនេះ ដើម្បីរួចរស់ពីរបបខ្មែរក្រហម ប្រជាជនមិនត្រូវជឿទៅលើអ្នកណាម្នាក់ឡើយ ទោះបីជាសមាជិកគ្រួសារ ឬមិត្តសម្លាញ់ក៏ដោយ ។ នេះជាមធ្យោបាយតែមួយគត់ដើម្បីចៀសផុតពីការសម្លាប់ និងរួចរស់ពីរបបនោះ ។ សម្រាប់ជីវិតនៅពាក់កណ្តាលផ្លូវស្លាប់រស់ «ដើម្បីចៀសផុតពីការវាយប្រហាររបស់ខ្មែរក្រហម គេត្រូវមានស្មារតីខ្ពស់សង្ស័យទៅលើមនុស្សនិងអ្វីៗទាំងអស់ដែលនៅជុំវិញខ្លួន» ។

ការសង្ស័យនិងការមិនជឿទុកចិត្តនៅតែមានទោះបីជារបបខ្មែរក្រហមបានដួលរលំទៅហើយក្តី ។ ការវាយប្រហារនៅចំពោះមុខទៅលើទំនាក់ទំនងរបស់ប្រជាជន សូម្បីតែសមាជិកគ្រួសារនិងមិត្តភក្តិ បានធ្វើឲ្យទំនាក់ទំនងសង្គមមានភាពចុះខ្សោយ ។ សោកនាដកម្មនៃអំពើសាហាវរបស់ខ្មែរក្រហមបាន «ធ្វើឲ្យសង្គមបែកបាក់បណ្តាលឲ្យប្រជាជនរស់នៅក្រោមភាពសង្ស័យនិងការមិនជឿទុកចិត្តគ្នា» ទោះបីជាគេបានជួបប្រទះបទពិសោធន៍ដូចគ្នាក៏ដោយ ។ បទពិសោធន៍នៃរបួសផ្លូវចិត្តនិងវិធីសាស្ត្រដើម្បីគេចផុតពីការសម្លាប់បានធ្វើឲ្យប្រជាជនកម្ពុជាមិនជឿទៅលើអ្នកណាឡើយទោះបីជារបបនោះបានបញ្ចប់យូរណាស់មកហើយក៏ដោយ ។ កេរដំណែលនៃការធ្វើឲ្យបាត់បង់ការជឿទុកចិត្តនិងភាពភ័យខ្លាចដែលធ្វើឡើងដោយខ្មែរក្រហមនៅពេលកាន់អំណាច៣ឆ្នាំ ៨ខែ ២០ថ្ងៃ បានបំផ្លាញដល់ការជឿទុកចិត្តនៅក្នុងសង្គមកម្ពុជា ។ ជាលទ្ធផល «ភាពជិតស្និទ្ធនៅក្នុងសង្គម» មានបញ្ហាដោយសារការមិនទុកចិត្តគ្នាជាបន្តបន្ទាប់ទាំងតាមរយៈខ្សែបណ្តោយនិងខ្សែទទឹង ។

នៅពេលជាមួយគ្នានេះដែរ ការខ្វះការជឿទុកចិត្តគ្នាធ្វើឲ្យ

សមត្ថភាពធ្វើការជាមួយគ្នាជាក្រុម ឬជាបក្ខពួករបស់បុគ្គលមានភាពចុះខ្សោយ ។ ដូចដែល ហ្វូគូយ៉ាម៉ា (*Fukuyama*) បានលើកឡើងថាការជឿទុកចិត្តនៅក្នុងសង្គមគឺជាកត្តាចម្បងដែលធ្វើឲ្យសង្គមមានភាពរីកចម្រើន ។ អាស្រ័យហេតុនេះ ការខ្វះការជឿទុកចិត្តគឺជាឧបសគ្គដ៏ធំសម្រាប់កម្ពុជាក្នុងការវិវត្តទៅរកភាពជាសះស្បើយពីជំងឺផ្លូវចិត្ត ។ បច្ចុប្បន្ន កម្ពុជាបានជួបប្រទះនឹងការបាត់បង់ការជឿទុកចិត្តនៅក្នុងសង្គមមកពីការខ្វះការជឿទុកចិត្តគ្នារវាងសមាជិកគ្រួសារ រហូតដល់អ្នកជិតខាង មិត្តរួមការងារ និយោជិក អ្នកដឹកនាំ និង ស្ថាប័នសង្គម ។ អាស្រ័យហេតុនេះ កិច្ចសហប្រតិបត្តិការរវាងប្រជាជនដែលមិនមានការជឿទុកចិត្តគ្នាទៅវិញទៅមកទំនងជាមិនមានភាពរលូន បើមិនដូច្នោះទេវាហាក់ដូចជាមិនអាចទៅរួចតែម្តង ។ នេះបណ្តាលឲ្យមានសមត្ថភាពការងារទាបដែលធ្វើឲ្យការតស៊ូដើម្បីភាពជាសះស្បើយយឺត ។



សិស្សានុសិស្សអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ»

## ការពន្យារពេលបង្កើតសាលាក្តីខ្មែរក្រហម

ការពន្យារពេលបង្កើតសាលាក្តីខ្មែរក្រហមនិងចម្ងល់អំពីតុលាការកូនកាត់បានធ្វើឲ្យសាធារណជនកម្ពុជាមានអារម្មណ៍ថាយុត្តិធម៌មិនត្រូវបានផ្តល់ឲ្យ ។ នេះក៏រារាំងមិនឲ្យមានភាពជាសះស្បើយកើតឡើង និងរារាំងប្រទេសមិនឲ្យបំភ្លេចអតីតកាលហើយឆ្ពោះទៅមុខដែរ ។ របបប្រល័យពូជសាសន៍ខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប៉ុន្តែអង្គជំនុំជម្រះមិនបានចាប់ផ្តើមប្រតិបត្តិការដល់ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ឡើយ ។ វាស្ទើតែពាទសវត្សរ៍បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ទើបមានការបង្កើតតុលាការដែលមានឈ្មោះថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើវាយឺតពេកឬទេក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះរាប់សែននាក់ដែលត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម? សម្រាប់មនុស្សជាច្រើន វាយឺតពេកទៅហើយ វាបានបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានទៅដល់ដំណើរការអភិវឌ្ឍប្រទេសកម្ពុជា ។ ការស្លាប់របស់ ប៉ុល ពត នាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៩៨ ដោយមិនបានប្រឈមមុខនឹងការកាត់សេចក្តីទេ និងការស្លាប់របស់ តាម៉ុក មេបញ្ជាការភូមិភាគនិរតីរបស់កម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ «នៅក្នុងការឃុំឃាំងដោយមិនទាន់បានជំនុំជម្រះចាប់តាំពីឆ្នាំ១៩៩៩មក» បានធ្វើឲ្យមនុស្សជាច្រើនមានចម្ងល់ចំពោះយុត្តិធម៌ដែលតុលាការមិនទាន់ផ្តល់ឲ្យ ។ ជាងនេះទៅទៀត ការពិតដែលថាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងអស់កំពុងស្ថិតនៅក្នុងវ័យ៨០គឺជាការព្រួយបារម្ភយ៉ាងខ្លាំង ។ វ័យចំណាស់របស់មេដឹកនាំទាំងនោះបានធ្វើឲ្យពួកគេ «ក្លាយជាបេក្ខជនដែលតុលាការមិនអាចពឹងផ្អែកបាន» ដោយសារស្ថានភាពសុខភាពរបស់គេ ។ អាស្រ័យហេតុនេះ ជនរងគ្រោះដែលមានរបួសផ្លូវចិត្តយល់ថា ប្រហែលជាមិនមានយុត្តិធម៌ ហើយរបួសផ្លូវចិត្តរបស់គេប្រហែលជាមិនត្រូវបានព្យាបាល ដោយសារតែការស្លាប់របស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមុនពេលកាត់ទោសនិងវ័យចំណាស់របស់ជនដែលសំខាន់ៗដែលនៅរស់ ។

ជាងនេះទៅទៀត ការខ្វះការជឿទុកចិត្តទៅលើចៅក្រមកម្ពុជានិងព្រះរាជអាជ្ញាធ្វើឲ្យសាធារណជនមានចម្ងល់ចំពោះការគ្រប់គ្រង

របស់តុលាការកូនកាត់នេះ ។ ទោះបីជាមានវត្តមាន ចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិធ្វើការជាមួយសមភាគីកម្ពុជា អង្គជំនុំជម្រះត្រូវតែអនុវត្តតាមច្បាប់កម្ពុជា ប៉ុន្តែកម្ពុជាបានបាត់បង់ការជឿទុកចិត្តទៅលើច្បាប់និងប្រព័ន្ធតុលាការយូរមកហើយ ពីព្រោះវា «ជាអ្វីដែលមិនធម្មតា» ។ បើមិនមានការគ្រប់គ្រងត្រឹមត្រូវរបស់តុលាការ ការព្យាបាលមិនអាចកើតមាន ហើយគេរងំណែលរបួសផ្លូវចិត្តនៅតែមាន ។ នេះជាការរារាំងដំណើរការអភិវឌ្ឍប្រទេស ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើតុលាការគឺជាជ័យជម្នះមួយ វាប្រហែលជាអាចបំពេញតួនាទីវិជ្ជមានខ្លះ ។ នៅឆ្នាំ ២០០០ អ្នកដឹកនាំអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយបានធ្វើកំណត់សម្គាល់អំពីគោលបំណងដែលអាចទៅរួចមួយចំនួនរបស់តុលាការថា ៖

ប្រសិនបើតុលាការដឹកនាំល្អស្របតាមបទដ្ឋានអន្តរជាតិ និងគោលការណ៍កាត់ក្តីដ៏មានយុត្តិធម៌ យ៉ាងហោចណាស់វានឹងធ្វើឲ្យមានលទ្ធផលល្អបួន ។ ទីមួយ ផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបនោះ ។ ទីពីរ ព្យាបាលសង្គមកម្ពុជានិងបញ្ចប់សុបិនអាក្រក់របស់ជនរងគ្រោះកម្ពុជា ។ ទីបី ស្វែងរកការពិតឲ្យប្រជាជនកម្ពុជានិងពិភពលោកដឹងថាហេតុអ្វីបានជាប្រជាជន១,៧លាននាក់ស្លាប់ ។ ទីបញ្ចប់ ខ្ញុំសង្ឃឹមថា តុលាការនេះអាចធ្វើជាគំរូដើម្បីបង្ហាញប្រជាជនកម្ពុជាថាអ្វីជាគោលការណ៍នៃការកាត់សេចក្តីដ៏មានយុត្តិធម៌ ។

ទោះជាយ៉ាងនេះក្តី សាធារណជនមានចម្ងល់ចំពោះតួនាទីរបស់តុលាការនិងយុត្តិធម៌ដែលតុលាការបានសន្យាថានឹងផ្តល់ឲ្យ ។ យោងទៅតាមការផ្តល់ព័ត៌មានអំពីស្ថានភាពច្បាប់របស់តុលាការនិងនយោបាយ ការអនុវត្តនិងលក្ខណៈសម្បត្តិរបស់ចៅក្រម និងព្រះរាជអាជ្ញាកម្ពុជា លក្ខខណ្ឌសុខភាពរបស់ជនដៃដល់សំខាន់ៗ និងពេលវេលាសម្រាប់ដំណើរការនីតិវិធីដែលបានលើកឡើងដោយ ម៉េនហេរុល «ប្រជាជនមិនគួរមានចម្ងល់ចំពោះតុលាការទេ» ។ អាស្រ័យហេតុនេះ តុលាការកូនកាត់មិនទំនងជាផ្តល់យុត្តិធម៌ដល់ជនរងគ្រោះដែលគួរតែទទួលបានឡើយ ដែលនេះជាការរាំងស្ទះនូវដំណើរការព្យាបាលជនរងគ្រោះដែលមានរបួសផ្លូវចិត្តតែងតែនឹងឃើញពីអតីតកាល ។

**សេចក្តីសន្និដ្ឋាន**

អំពើប្រល័យពូជសាសន៍ខ្មែរក្រហមបានបន្សល់នូវការបំផ្លិចបំផ្លាញដល់វប្បធម៌កម្ពុជាពីបុរាណ ។ ការខ្វះខាតដំណើរការព្យាបាលជនរងគ្រោះដែលមានរបួសផ្លូវចិត្ត ការធ្វើឲ្យមានការមិនជឿទុកចិត្តគ្នា ភាពភ័យខ្លាច និងការបង្ខំ ធ្វើឲ្យបាត់បង់តម្លៃស្នូលរបស់ប្រពៃណី ហើយការពន្យារពេលបង្កើតសាលាក្តីខ្មែរក្រហមដើម្បីនាំយកជនដៃដល់សំខាន់ៗទៅរកយុត្តិធម៌បានរារាំងដល់កម្ពុជានិងប្រជាជនដែលមានរបួសផ្លូវចិត្តមិនឲ្យដើរចេញពីអតីតកាលដែលគេធ្លាប់ជួបប្រទះដើម្បីរៀបចំខ្លួនសម្រាប់អនាគត ។ ជាក់ស្តែង របបប្រល័យពូជសាសន៍ខ្មែរក្រហមធ្វើឲ្យបាត់បង់ការជឿទុកចិត្តគ្នារវាងបុគ្គល ក្រុមនិងស្ថាប័នសង្គមដែលរារាំងដល់ការអភិវឌ្ឍប្រទេស ។ ដូចដែលបានលើកឡើងដោយ ខូឡេតា និង ខូឡិន «នៅសម័យក្រោយសង្គ្រាម ប្រសិនបើការមិនជឿទុកចិត្ត មិនត្រូវបានទទួលស្គាល់និងដោះស្រាយ ការអភិវឌ្ឍសាជាថ្មីនឹងមិនអាចកើតមានទេ» ។ ការខ្វះខាតការជឿទុកចិត្តធ្វើឲ្យភាពជិតស្និទ្ធនៅក្នុងសង្គមមានភាពទន់ខ្សោយ ហើយសមត្ថភាពចូលរួមសហការនិងធ្វើការជាមួយគ្នាដោយមានប្រសិទ្ធភាពរបស់បុគ្គលក៏ចុះខ្សោយដែរ ។ យន្តការព្យាបាលដែលត្រូវគិតទៅដល់តម្លៃវប្បធម៌របស់ប្រជាជនកម្ពុជាត្រូវការជាចាំបាច់ដើម្បីព្យាបាលរបួសផ្លូវចិត្តរបស់ជនរងគ្រោះនៅទូទាំងប្រទេសដែលមិនទាន់ព្យាបាល ។ ដូចដែលបានអះអាងដោយ រីឆាត ម៉ូលីកា សម្រាប់ការជាសះស្បើយដ៏មានប្រសិទ្ធភាពនិងពេញលេញរបស់សង្គម យើងមិនត្រូវទុកជនរងគ្រោះដែលមានរបួសផ្លូវចិត្តចោលទេ ។ របបប្រល័យពូជសាសន៍ខ្មែរក្រហមបានដួលរលំជាងបីទសវត្សរ៍មកហើយ ប៉ុន្តែរបួសដែលកើតឡើងដោយសាររបបនេះនៅមិនទាន់ត្រូវបានព្យាបាលនៅឡើយ ។ ខណៈពេលដែលសាលាក្តីខ្មែរក្រហមកំពុងដំណើរការ ភ្នាក់ងារអង្គការសហប្រជាជាតិនិងអង្គការក្រៅរដ្ឋាភិបាលចាំបាច់ត្រូវតែធ្វើការយ៉ាងជិតស្និទ្ធជាបន្ទាន់ជាមួយកម្ពុជាដើម្បីព្យាបាលជនរងគ្រោះខ្មែរក្រហមដែលនៅតែមានរបួសផ្លូវចិត្ត ដូច្នេះជនរងគ្រោះទាំងនេះនឹងជាសះស្បើយបានឆាប់រហ័ស ហើយចាប់ផ្តើមរស់នៅក្នុងជីវិតដ៏មានសន្តិភាពម្តងទៀត ។

**សែន ទិចិត្រ**

# ពិភពលោកនៅសែនឆ្ងាយ

## ដង្ហើមចុងក្រោយនៃរបបសាធារណរដ្ឋខ្មែរ

បន្ទាប់ពីបាតុកម្មរបស់សាស្ត្រាចារ្យនិងគ្រូបង្រៀនត្រូវបានបង្ក្រាបដោយកម្លាំងយោធាដែលបញ្ជាផ្ទាល់ដោយលោក លន់ ណុន ប្អូនប្រុសបង្កើតរបស់ប្រធានាធិបតី លន់ នល់ សាលារៀននៅទូទាំងរដ្ឋធានីបានត្រូវបិទទ្វារ ។ ចំណែកតំបន់យុទ្ធសាស្ត្រសំខាន់ៗដូចជា អ្នកលឿង ព្រែកក្ដាម ត្រូវកងទ័ពខ្មែរក្រហមចូលវាយលុកដើម្បីកាន់កាប់ទីក្រុងភ្នំពេញ ។ ពេលនោះ ទិសខាងជើងនិងខាងលិចនៅព្រលានយន្តហោះពោធិចិនតុងមានការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា ដែលធ្វើឲ្យយន្តហោះផ្អាកជើងហោះហើររបស់ខ្លួន ។ នៅថ្ងៃត្រង់ ព័ត៌មានតាមវិទ្យុបានផ្សាយពីលោកប្រធានាធិបតី លន់ នល់ សុំលាបងប្អូនជនរួមជាតិទៅព្យាបាលជំងឺនៅក្រៅប្រទេសមួយរយៈពេលខ្លី ហើយបានប្រគល់ភារកិច្ចឲ្យឧត្ដមសេនីយ៍ សាក់ ស៊ុតសាខន ធ្វើការជំនួសវិញ ។ សូរគ្រាប់កាំភ្លើងប្រយុទ្ធចេះតែរំកិលចូលមកជិតខ្សែក្រវាត់ក្រុង គ្រាប់ផ្លោងធ្លាក់ជាបន្តបន្ទាប់នៅផ្សារពោចិនតុងនិងតំបន់ទួលគោក ដែលធ្វើឲ្យប្រជាជននៅទីនោះដឹកជញ្ជូនអីវ៉ាន់និងកូនចៅដើម្បីគេចខ្លួន ។

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃចូលឆ្នាំប្រពៃណីជាតិខ្មែរក៏មិនមានការរៀបចំពិធីសែនដើម្បីទទួលទេវតាឆ្នាំថ្មីនៅតាមផ្ទះដែរ ព្រោះម្នាក់ៗត្រូវសម្ងំនៅក្នុងផ្ទះរង់ចាំកងទ័ពខ្មែរក្រហមចូលមករំដោះដើម្បីឲ្យប្រទេសរួចផុតពីរបបលន់ នល់ ។ ពេលនោះ ខ្ញុំបានស្ដាប់ឮការប្រកាសតាមវិទ្យុថា កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តន៍កម្ពុជាបានទទួលជ័យជម្នះទាំងស្រុងនៅទីក្រុងភ្នំពេញ ។

ខ្ញុំនិងក្មេងៗជាច្រើនទៀតចេញមកក្រៅទទួលស្វាគមន៍កងទ័ពខ្មែរក្រហមដែលស្ពាយកាំភ្លើងអាកា៤៧ ពាក់មួកកន្ទបរុំកក្រមាខោត្រីអ៊ីដូចពួកទាហានដើរតាមផ្លូវកម្ពុជាក្រោម ។ បន្តិចក្រោយមក កងទ័ពខ្មែរក្រហមក៏ជញ្ជូនខោអាវនិងសម្ភារៈសឹកទាំងអស់មកបោះទីតាំងនៅក្នុងដីឡូត៍មួយទុកជាប៉ុស្ដិ៍យាមរបស់សង្កាត់ ដើម្បីសម្ដែងថាគ្មានទាហានប្រយុទ្ធតទៅទៀតទេ ។ នៅមុខផ្ទះនីមួយៗមានបង់ទង់ឬក្រណាត់សព្រោងព្រាតដែលមានន័យថាចុះចាញ់ទាំងស្រុង ។ ចំណែកកងទ័ពខ្មែរក្រហមចាប់ដៃគ្នាគ្រប់មុខសញ្ញានៅពេលដែលបានជួបគ្នាដើម្បីបញ្ជាក់ពីការជោគជ័យ ហើយថ្ងៃត្រង់រថយន្តជាច្រើនគ្រឿងបានដឹកកងទ័ពខ្មែរក្រហមចូលមកក្រុងបន្ថែមទៀត ។ ពេលដែលមនុស្សដើរកកកុញតាមផ្លូវឆ្ពោះទៅពោធិចិនតុង កងទ័ពខ្មែរក្រហមបានឈរយាមតាមផ្លូវកែងនិងធ្វើសញ្ញាឲ្យប្រជាជនដើរទៅតាមទិសកំណត់របស់ខ្លួន ព្រោះខ្លាចអាមេរិកមកទម្លាក់គ្រាប់បែកលើប្រជាជននិងប្រាប់ថាអង្គការឲ្យចេញតែបីថ្ងៃប៉ុណ្ណោះ ។

## ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

ថ្ងៃ១៨ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្ញុំក្រោកនៅម៉ោង៥ព្រឹក មារបស់ខ្ញុំបានលួចខ្សឹបប្រាប់ថា ត្រូវសម្ងំនៅស្ងៀមកុំឲ្យគេដឹងថាមានមនុស្សរស់នៅ ។ ប៉ុន្តែ ខ្ញុំរៀបចំអីវ៉ាន់ចងដាក់នៅលើកង់រួចជាស្រេច ដូចជាស្បោង២ថង់ ចាន ឆ្នាំង និងអង្ករជាដើម ។ លុះដល់ម៉ោង៩ព្រឹក ទើបខ្ញុំចេញមកមើលសភាពការណ៍ខាងក្រៅផ្ទះ ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រោះឃើញផ្ទះអ្នកជិតខាងបិទទ្វារស្ងាត់អស់និងឃើញតែហ្វូងមនុស្សបន្តធ្វើដំណើរ ។

បន្តិចក្រោយមក កងទ័ពខ្មែរក្រហមម្នាក់ជិះកង់តម្រង់មកផ្ទះខ្ញុំ រួចដកកាំភ្លើងខ្លីរ៉េវ៉ុលវែពីរដើមចេញមក ដោយដៃស្ដាំលើកកាំភ្លើងឡើងលើ ដៃឆ្វេងបង្អិលតម្រង់មករកខ្ញុំនិងបញ្ជាឲ្យចាកចេញទាំងអស់គ្នា ។ ខ្ញុំនិងមារបស់ខ្ញុំដែលប្រពន្ធគាត់ទើបតែសម្រាលកូនបាន៣ខែ និងកូនតូចអាយុ៥ឆ្នាំបាននាំគ្នាចាកចេញពីផ្ទះក្រោមក្រសែភ្នែកសម្លឹងតាមដានពីក្រោយរបស់កងទ័ពខ្មែរក្រហម ។ ទៅដល់ផ្លូវធំខាងលិច ស្រាប់តែឃើញទាហានពីរនាក់ឈរយាមកណ្ដាលផ្លូវបានលើកកាំភ្លើងភ្ជង់ទ័ពខ្មែរក្រហមម្នាក់ទៀតដែលជិះកង់ចូលក្នុងក្រុង រួចសម្ងុតថានៅអង្គភាពណា? ពាក្យសម្ងាត់អ្វីខ្លះ? ក្រោយពីទាហាននោះឆ្លើយត្រឹមត្រូវហើយទើបអនុញ្ញាតឲ្យទៅ ។ ពេលខ្ញុំបណ្ដើរកង់មានអីវ៉ាន់យ៉ាងច្រើនដើរទៅដល់កាច់ជ្រុងផ្លូវពោធិចិនតុង ស្រាប់តែឃើញកងទ័ពខ្មែរ

ក្រហមដាក់របាំងមិនឲ្យទៅមុខទៀត និងបញ្ជាឲ្យធ្វើដំណើរតាមផ្លូវអង់តែនទូលគោកវិញ ។ នៅកាច់ជ្រុងសាលាតិចណូ ខ្ញុំឃើញខ្មោចយុវជនម្នាក់ដេកស្លាប់ទំនងជាគេបាញ់សម្លាប់ពីព្រឹកមិញនេះ និងមានក្មេង២-៣នាក់ស្លាប់ស្អុយរលួយតាមផ្លូវដោយសារគ្រាប់ផ្លោង ។ នៅថ្ងៃត្រង់ ខ្ញុំបានធ្វើដំណើរទៅដល់ផ្សារព្រែកព្នៅ ប៉ុន្តែខ្ញុំមិនឃើញមារបស់ខ្ញុំទេ ដូច្នេះក៏បានបណ្តើរកង់ទៅផ្ញើកងទ័ពនារីខ្មែរក្រហមដើម្បីរង់ចាំគាត់វិញ ។ នៅទីនោះ ខ្ញុំបានឃើញទាហានម្នាក់ស្លៀកឯកសណ្ឋានយ៉ាងស្អាតជិះម៉ូតូសេអិលត្រូវកងទ័ពនារីខ្មែរក្រហមឃាត់ខ្លួនដើម្បីសុំឆែកកាត ឆែកអាវុធ និងសួរពីឋានៈ ។ ក្រោយពីទាហាននោះប្រាប់ថាពាក់ស័ក្តិពីរ ពួកគេក៏បញ្ជាឲ្យទៅជួបអង្គការដើម្បីណែនាំខ្លួនមួយភ្លែត រួចចង្អុលទៅទីតាំងបន្ទាយទាហានមួយដែលនៅចម្ងាយប្រមាណ៣០០ម៉ែត្រ ។ ប៉ុន្តែដើរទៅបានតែប្រហែល៣០ម៉ែត្រ ស្រាប់តែឮស្នូរកាំភ្លើងផ្ទុះដាំងពីក្រោយ ធ្វើឲ្យទាហាននោះដួលផ្កាប់មុខ ។ បន្ទាប់មក កងទ័ពខ្មែរក្រហមបានបាញ់រះមួយបង់បន្ថែមទៀត ដែលធ្វើឲ្យអ្នកជម្លៀសភ័យរន្ធត់ញាប់ញ័រឱនក្រាបទៅដីគ្រប់ៗគ្នា ។ មួយសន្ទុះក្រោយមក ក៏ឃើញកងទ័ពខ្មែរក្រហមធ្វើដូចរបៀបមុនដដែល ដោយឲ្យទៅជួបអង្គការមួយភ្លែតសិន ហើយបាញ់សម្លាប់នៅក្បែរផ្លូវនោះតែម្តង ។ ក្រោយហេតុការណ៍នោះ ខ្ញុំបានឃើញមារបស់ខ្ញុំជិះកង់ឌុបប្រពន្ធនិងកូនរបស់គាត់មក ។ គ្រាន់តែឃើញខ្ញុំភ្លាម គាត់ស្តីបន្ទោសខ្ញុំយ៉ាងខ្លាំងថាខ្ញុំរត់ចោលគាត់ ។ ដើរបាន៥០០ម៉ែត្រ យើងទាំងអស់គ្នាក៏នាំគ្នាចូលទៅសម្រាកហូបបាយនៅមាត់ទន្លេ ដែលនៅទីនេះឃើញមានសាកសពមនុស្សហើមស្លាប់ជាច្រើន ។

## ខ្មែរក្រហមបាញ់បង្ហើរក្បាល

ព្រឹកឡើង ហ្វូងមនុស្សបានខំបន្តដំណើរទៅមុខឲ្យបានលឿន ដើម្បីចេញផុតពីកន្លែងដែលមានក្លិនស្អុយនេះ ។ ប៉ុន្តែទោះជាដើរទៅបានឆ្ងាយក៏ដោយ ក៏នៅតែមានធុំក្លិនស្អុយនេះដដែល ។ នៅម៉ោងប្រហែល១១ថ្ងៃត្រង់ យើងបានមកដល់តំបន់មួយមានវាលធំល្ហ និងមានដើមត្រសេកជាច្រើន ។ ពេលកំពុងតែបណ្តើរកង់លើផ្លូវដ៏ចង្អៀតមួយ ទ័ពខ្មែរក្រហមម្នាក់រាងចំណាស់បន្តិចមាឌល្អិត មានពាក់មួកកន្ទឹប ស្លៀកពាក់ខោអាវពណ៌ខ្មៅកាន់កាំភ្លើងការ៉ាប៊ីនស្ទុះមកពាំងផ្លូវពីមុខ រួចភ្ជង់កាំភ្លើងតម្រង់ដើមទ្រូងខ្ញុំដោយស្រែកថាឈប់សិន ។ មិនតែប៉ុណ្ណោះ ទ័ពខ្មែរក្រហមនោះក៏បាញ់កាំភ្លើងមួយគ្រាប់បង្ហើរលើក្បាលរបស់ខ្ញុំ ហើយសម្លុតថាឯងជាកុម្មង់ដូ និងចង្អុលទៅកន្សែងទាហានដែលខ្ញុំចងលេងជាប់នឹងកកង់ ។ ខ្ញុំឆ្លើយប្រាប់ថា កន្សែងនោះខ្ញុំរើសនៅតាមផ្លូវ ខ្ញុំជាកូនសិស្ស ខ្ញុំមិនមែនកុម្មង់ដូទេ ។ ដើម្បីឲ្យខ្មែរក្រហមកាន់តែជឿពាក្យសម្តីរបស់ខ្ញុំ ខ្ញុំក៏បើកកាតាបឲ្យមើលទៀត ។ បន្ទាប់មក កងទ័ពខ្មែរក្រហមបានបញ្ជាឲ្យអ្នកដែលមានរថយន្តផ្អាកការធ្វើដំណើរទាំងអស់ ។ ចេញផុតពីទីនោះប្រហែលជា៣០០ម៉ែត្រ ទៅដល់ព្រែកមួយមានស្ពានឈើពុកបាក់ទ្រុឌទ្រោមមិនអាចដើរបាន យើងទាំងអស់គ្នាក៏ដើរចុះឆ្លងតាមព្រែកដោយយឺតៗ ។

## ការសម្លាប់រង្គាល

នៅព្រឹកថ្ងៃទី២០ ខែមេសា ខ្ញុំក៏បានបន្តដំណើរទៅមុខទៀត ។ ពេលនោះ ខ្ញុំបានជួបមិត្តរួមថ្នាក់ម្នាក់ដែលប្រាប់ខ្ញុំថា «មិនត្រូវរស់នៅស្រុកខ្មែរទេ គួរតែទៅប្រទេសថៃជាប្រទេសសេរី ព្រោះប្រទេសយើងធ្លាក់ទៅក្នុងកណ្តាប់ដៃពួកកុម្មុយនីស្តហើយ» ។ ប៉ុន្តែ ខ្ញុំបានប្រាប់ទៅវិញថា «ខ្ញុំនឹកប្អូនៗខ្ញុំខ្លាំងណាស់ ខ្ញុំទៅស្រុកកំណើតវិញ» ។ តាមផ្លូវពេលដែលខ្ញុំបានទៅដល់វត្តអារាមមួយស្ថិតនៅខាងកើតផ្លូវ ខ្ញុំស្រាប់តែឃើញប្រុសៗរាប់រយនាក់ឈរជាជួរស្លៀកពាក់ខោអាវខ្មៅមានបង់ក្រមាកំពុងកត់ឈ្មោះម្នាក់ម្តងៗ និងនៅខាងលិចផ្លូវមានកងនារីខ្មែរក្រហមកំពុងចែកអង្ករនិងចេកហាល ។ ឃើញដូច្នេះ ខ្ញុំបានចូលទៅសុំអង្ករបានពាកំប៉ុង ។ ក្រោយមក ខ្មែរក្រហមបានឃោសនាថា អង្គការត្រូវការជ្រើសរើសទាហាននិងអ្នកមានចំណេះដឹងខ្ពស់ដើម្បីកសាងប្រទេសជាតិឡើងវិញ រួចបញ្ជាឲ្យប្រុសៗឈរតម្រង់ជួររង់ចាំនៅទីនេះសិន ព្រោះត្រូវការយកបញ្ជីទៅឲ្យថ្នាក់លើនៅក្នុងវត្ត ។ ពេលនោះ មារបស់ខ្ញុំសំណាងល្អណាស់ ព្រោះនៅតាមផ្លូវប្រជាជនម្នាក់ដែលគាត់បានទៅជួយពេលជិះកង់ឌុបអីវ៉ាន់របូតប្រវាក់បានខ្សឹបប្រាប់គាត់ថាកុំឲ្យចូលទៅចុះឈ្មោះឲ្យសោះ ។ ក្រោយពីដឹងថាសភាពការណ៍មិនល្អ គាត់ក៏ជិះកង់បន្តទៅមុខទៀត ។ ចំណែកអ្នកផ្សេងវិញ គាត់ឃើញពូម្នាក់ជាមន្ត្រីរាជការបានចូលទៅជួបមេខ្មែរក្រហម ហើយប្រាប់ថា គាត់ជាខ្សែរយៈផ្ទៃក្នុងធ្វើការសម្ងាត់ឲ្យអង្គការ

ព្រមទាំងរៀបរាប់ឈ្មោះមេធំៗដែលគាត់ស្គាល់ដើម្បីសុំឲ្យបញ្ជូន
គាត់ទៅជួបថ្នាក់លើក្នុងទីក្រុងវិញ ។ បន្តិចក្រោយមក ទាហានទាំង
នោះក៏នាំគាត់ចូលក្នុងវត្តបាត់ ។ ធ្វើដំណើរបានប្រហែលមួយ
ម៉ោង ខ្ញុំលែងឃើញមានមនុស្សដើរមកតាមក្រោយពួកខ្ញុំទៀត
ហើយ ។ ខ្ញុំគិតថា ទាហានខ្មែរក្រហមបាញ់សម្លាប់អ្នកចុះឈ្មោះ
ធ្វើទាហាននៅពេលព្រឹកទាំងអស់ ព្រោះមានឮសំឡេងផ្ទុះអាវុធ
ជាច្រើនគ្រាប់ទៀតផង ។

នៅម៉ោងបីរសៀល ខ្ញុំក៏បានទៅដល់ផ្លូវមួយដែលមាន
ដើមឈើដុះអមសងខាងផ្លូវ ។ នៅទីនោះ ខ្ញុំក្អួតយ៉ាងខ្លាំងដោយ
សារតែហូបទឹកឆៅ ។ ក្រោយពីមារបស់ខ្ញុំយកថ្នាំមកដាំឲ្យហូប
ទើបធ្វើឲ្យជំងឺរបស់ខ្ញុំជាសះស្បើយ ។

## អំបិលក្លាយជាប្រាក់

ព្រឹកថ្ងៃទី២១ មេសា យើងក៏ធ្វើដំណើរដល់កំពង់ចម្លង
ព្រែកក្ដាមដែលមានមនុស្សយ៉ាងច្រើននៅមាត់ប្រាំងទន្លេដើម្បី
រង់ចាំឆ្លងស្រឡាង និងមួយចំនួនទៀតធ្វើដំណើរឆ្ពោះទៅខាងជើង
តាមផ្លូវជាតិលេខ៥ ។ ពេលឆ្លងទន្លេព្រែកក្ដាមរួច ខ្ញុំនិងមារបស់
ខ្ញុំក៏បានមកដល់ភូមិមួយ រួចសម្រាកនៅទីនោះតែម្ដង ។ ព្រឹកឡើង
យើងក៏ដើរមកដល់ដីរំដោះដែលនៅតំបន់នោះមានកងឈ្លបក្មេង
ជំទង់ប្រុសស្រីនៅឈរយាមផ្លូវ ដើម្បីឆែករកអីវ៉ាន់ ។ ពេលដែល
រើទៅឃើញមានដូចជា ទឹកអប់ សាប៊ូ ថ្នាំពេទ្យ ពិល ប៊ិចេង ឬអ្វី
ផ្សេងទៀតដែលគេចង់បាន ឈ្លបនោះក៏ប្រាប់ថា សម្ភារៈចក្រពត្តិ
ត្រូវស្ទើដកហូតទុក ។ ដោយសារតែធ្វើដំណើរអស់រយៈពេល
ជាច្រើនថ្ងៃ យើងក៏អស់អាហារហូប ។ ប៉ុន្តែយើងសំណាងល្អ
ណាស់ ដោយពេលមកដល់ចុងភូមិ ស្រាប់តែមានស្ត្រីម្នាក់សុំដូរ
អំបិលរបស់ខ្ញុំជាមួយនឹងត្រីរបស់គាត់ប្រហែល១០ ។ ក្រោយពី
នាំគ្នាសម្រាកហូបបាយជាមួយនឹងត្រីទាំងនោះរួចមក យើងក៏ឆ្លង
ទន្លេមេគង្គតាមរយៈទូកមួយមកដល់ទឹកដីភូមិកំណើតរបស់ខ្ញុំ ។
ពេលនោះ ខ្ញុំត្រេកអរជាខ្លាំង ដោយសង្ឃឹមថានឹងបានទៅដល់ផ្ទះ
ដើម្បីជួបជុំឪពុកម្ដាយនិងប្អូនៗជាទីស្រឡាញ់ ព្រោះខ្ញុំបានចាក
ចេញពីផ្ទះអស់រយៈពេលជាងបួនឆ្នាំមកហើយ ។

## ជ័យជម្នះខ្មែរក្រហម

ភូមិរបស់ខ្ញុំត្រូវបានរំដោះតាំងពីឆ្នាំ១៩៧០ ដែលវាជា
មូលដ្ឋានដ៏រឹងមាំសម្រាប់កងទ័ពខ្មែរក្រហម ។ ភូមិនេះមានសភាព
ស្ងប់ស្ងាត់ខុសពីភូមិដែលខ្ញុំរស់នៅ ព្រោះគ្មានសំឡេងសើច ឃើញ
តែប្រជាជននាំគ្នាធ្វើការរៀងៗខ្លួន ដូចជាពុះអុស និងរែកទឹក
ជាដើម ។ ចំណែកនៅតាមផ្ទះនីមួយៗ ឃើញតែពាក្យស្លោក
សរសេរថា «ជយោ! បដិវត្តន៍កម្ពុជាដ៏រុងរឿង» «ជយោ!
ប្រជាជនកម្ពុជាដ៏មហិមា» «ជយោ! កងកម្លាំងប្រដាប់អាវុធ
បដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហាន ដៃម្ខាងវាយខ្មាំង ដៃម្ខាងបង្ក
បង្កើនផល និង ជយោ! អង្គការបដិវត្តន៍កម្ពុជាដ៏ត្រឹមត្រូវ និង
ភ្លឺស្វាង ជឿអង្គការរស់ មិនជឿអង្គការស្លាប់» ។ ព្រលប់បន្តិច ខ្ញុំ
បានទៅដល់ភូមិរបស់ជីតាខ្ញុំ រួចចូលសួរសុខទុក្ខនិងជម្រាបគាត់
ឲ្យបានដឹងថា ខ្ញុំត្រឡប់មកវិញហើយ ។ ពេលមកដល់មុខសាលា
បឋមសិក្សាបដិវត្តន៍ដែលខ្ញុំធ្លាប់រៀន កងឈ្លបយាមផ្លូវបាន
ចេញមកឃាត់ខ្លួនខ្ញុំ ហើយឲ្យចូលក្នុងថ្នាក់រៀនដើម្បីឆែកឆេរ
រកអីវ៉ាន់ ។ ពេលនោះ ខ្ញុំត្រូវបានឃាត់ខ្លួនទុកដើម្បីរង់ចាំជួប
ប្រធានភូមិ ព្រោះពួកគេរកឃើញក្រដាសពីរសន្លឹកជាប់គ្នាដែលខ្ញុំ
សរសេរជាពាក្យស្លោកសម្រាប់មើលខ្លួនឯង ។ ក្រោយមក ខ្ញុំត្រូវ
បានដោះលែងឲ្យត្រឡប់មកផ្ទះវិញ ដោយសារតែមីងថ្លៃបានទៅ
អង្វរប្រធានភូមិថា «វានៅក្មេងគ្មានដឹងអីទេ ឲ្យវាទៅផ្ទះសិនទៅ
ក្រែងពូបានស្គាល់ឪពុកម្ដាយវាហើយ ចាំបាច់ខ្លាចវារត់ទៅណា
ទៀត» ។

## មកដល់ផ្ទះជួបជុំបងប្អូន

ខ្ញុំត្រេកអរជាខ្លាំង ក្រោយពីប្រធានភូមិអនុញ្ញាតឲ្យខ្ញុំ
ត្រឡប់មកផ្ទះវិញ ។ ចូលដល់ក្នុងផ្ទះ ខ្ញុំបានឃើញមុខឪពុកខ្ញុំនៅ
ដដែល ប៉ុន្តែមុខប្អូនៗរបស់ខ្ញុំធំប្លែកមើលស្ទើរមិនស្គាល់ ។ ដើរចូល
ទៅជ្រៅដល់ក្នុងផ្ទះ ខ្ញុំក៏ឃើញម្ដាយរបស់ខ្ញុំដែលទើបនឹងសម្រាល
បានកូនស្រីម្នាក់អង្គុយលើគ្រែខំញញឹមមករកខ្ញុំ ។ បន្ទាប់មកយើង
ទាំងអស់គ្នានាំគ្នាសើចសប្បាយនិងហូបបាយជុំគ្នា ។ ចំណែក មា
របស់ខ្ញុំក៏បានទៅសម្រាកនៅផ្ទះយាយនៅទល់មុខផ្ទះរបស់ខ្ញុំដែរ ។

នៅថ្ងៃបន្ទាប់ ខ្ញុំបានអង្គុយជជែកលេងជាមួយឪពុកម្ដាយ
របស់ខ្ញុំនិងដើរទៅខាងក្រោយផ្ទះដើម្បីមើលអណ្ដូងទឹកនិងដើមចេក
ដែលខ្ញុំខំដាំពីមុនមក ។ ដើរទៅមើលនៅខាងមុខផ្ទះវិញ ខ្ញុំឃើញ
ផ្ទះអ្នកជិតខាងមួយចំនួនត្រូវបានរុះរើ និងមួយចំនួនទៀតបិទទ្វារ ។

ភូមិរបស់ខ្ញុំប្រជាជនរស់នៅមិនដល់ពាក់កណ្ដាលទេ ដោយម្នាក់ៗនាំគ្នាធ្វើការជាក្រុមសាមគ្គីប្រវាស់ដៃបង្កបង្កើនផល ដូចជារានព្រៃ និងធ្វើស្រែចម្ការបន្តិចបន្តួចនៅឯចុងភូមិ ។ ប៉ុន្តែរយៈពេលពីរ-បីថ្ងៃក្រោយមក ចំនួនប្រជាជនក៏បានកើនឡើងដោយសារតែប្រជាជនដែលជម្លៀសពីក្រុងភ្នំពេញបានមកដល់ផ្ទះកំណើតស្ទើរគ្រប់ៗគ្នា ។

## អង្គការហៅមាទៅរៀនសូត្រ

នៅរាល់ព្រឹកតែងមានក្រុមយុវជនមួយក្រុម ដែលភាគច្រើនជានារីមានកាន់កាំបិតដើរកាត់មុខផ្ទះរបស់ខ្ញុំសំដៅទៅធ្វើស្រែចម្ការនៅខាងចុងភូមិ ។ ពេលប្រទះឃើញខ្ញុំ ស្រាប់តែនារីម្នាក់បានដើរមកប្រាប់ខ្ញុំថា ប្រធានយុវជនឲ្យខ្ញុំទៅធ្វើពលកម្មចាប់ពីថ្ងៃស្អែកនេះ បើមិនទៅនឹងចុះអវត្តមាន ។ ស្អែកឡើង ខ្ញុំលីចបនិងកាំបិតដើរទៅជាមួយប្រជាជនជាច្រើននាក់ ប៉ុន្តែគ្មានអ្នកណានិយាយស្ដីជាមួយខ្ញុំទេ ។ ទៅដល់កន្លែងធ្វើការ អង្គការចាត់តាំងឲ្យខ្ញុំកាស់រានដីព្រៃនាមដែលនៅដាច់ឆ្ងាយពីគេ មានទំហំប្រហែល ១០ម៉ែត្រ បណ្ដោយ៥០ម៉ែត្រ ដើម្បីធ្វើជាថ្នាលដំណាំ ។ ខ្ញុំព្យាយាមធ្វើការនេះយ៉ាងអត់ធ្មត់និងយកចិត្តទុកដាក់ជាទីបំផុត ដើម្បីកុំឲ្យអង្គការចាប់កំហុសបាន រហូតដល់ចប់ភារកិច្ចទើបបានត្រឡប់មកផ្ទះវិញ ។ ធ្វើការបានបីថ្ងៃ ប្រធានភូមិក៏ដើរប្រាប់នៅតាមផ្ទះថាឲ្យមេគ្រួសារប្រុសៗដែលជាប្រជាជនថ្មីទើបជម្លៀសមកពីភ្នំពេញរៀបចំអីវ៉ាន់ ព្រោះអង្គការហៅទៅរៀនសូត្រ ។ ពេលនោះ មារបស់ខ្ញុំក៏មានឈ្មោះទៅដែរ សរុបទាំងអស់ជាង ១០នាក់ ក្នុងនោះមានគ្រូបង្រៀន២នាក់ ដោយបញ្ជូនឲ្យទៅស្នាក់នៅក្នុងបន្ទប់សាលារៀន មិនអនុញ្ញាតឲ្យចេញមកក្រៅ និងហាមមិនឲ្យប្រជាជនដើរទៅជិតទីនោះឡើយ ។ មួយសប្ដាហ៍ក្រោយមកយើងមិនដែលបានទទួលដំណឹងពីគាត់ទាល់តែសោះ ដែលធ្វើឲ្យយើងក៏ដូចជាសមាជិកគ្រួសារដទៃទៀតព្រួយបារម្ភពីសុវត្ថិភាពរបស់អ្នកទាំងនោះយ៉ាងខ្លាំង ។ ដោយសារគាត់មិនដែលបានទទួលដំណឹងពីប្ដីសោះ គាត់ក៏នាំកូនទាំង២នាក់ទៅរស់នៅជាមួយម្ដាយនៅវាលស្រែដែលអង្គការចាត់តាំងវិញ ។ ប៉ុន្តែគាត់ក៏បានផ្ដាំផងដែរថា បើប្ដីរបស់គាត់ត្រឡប់មកវិញ ឲ្យទៅរកគាត់នៅភូមិដែលគាត់ស្នាក់នៅផង ។

បន្ទាប់មក អង្គការចាត់តាំងខ្ញុំឲ្យរុះរើផ្ទះនៅក្នុងភូមិដើម្បីផ្លាស់ទៅរស់នៅភូមិផ្សេង លើកលែងតែផ្ទះ៩ខ្នងដែលអង្គការចាត់ទុកជាវណ្ណៈអនុធន ។ រយៈពេលមួយសប្ដាហ៍ក្រោយមកផ្ទះទាំងអស់ត្រូវបានរុះរើគ្មានសល់ ។ ដូច្នេះ យើងក៏បានពិភាក្សាគ្នាធ្វើលិខិតផ្លាស់ទីលំនៅនិងជ្រើសរើសថ្ងៃល្អដើម្បីចាកចេញពីភូមិ ។ ពេលដែលខ្ញុំជិះកង់ឆ្លងកាត់ពីភូមិមួយទៅភូមិមួយទៀត ខ្ញុំឃើញភូមិមានសភាពស្ងាត់ជ្រងំ ព្រោះប្រជាជននាំគ្នាធ្វើការដើម្បីទទួលបានអាហារហូបរៀងៗខ្លួន ។ ចំណែកថ្នាក់រៀនមាន៣-៤ថ្នាក់ មានយុវនារីក្មេងៗជាអ្នកបង្រៀន តែភាគច្រើនគ្មានសិស្សរៀនទេ ព្រោះរវល់ធ្វើស្រែចម្ការ និងខ្លះទៀតបានចូលជាកងឈ្លបដើម្បីការពារភូមិ ។ ក្រោយពីប្រធានភូមិអនុញ្ញាតឲ្យខ្ញុំផ្លាស់ទីលំនៅ យើងក៏ចាប់ផ្ដើមរុះរើផ្ទះនិងដឹកជញ្ជូនអីវ៉ាន់ ។ មុនពេលចាកចេញ ខ្ញុំនិងប្អូនប្រុសរបស់ខ្ញុំបានទៅរកត្រីខាងលិចភូមិចម្ងាយប្រហែល២-៣គីឡូម៉ែត្រសម្រាប់ទុកហូបពេលធ្វើដំណើរ ។

ទៅដល់ស្រែ ក្រុមរបស់ខ្ញុំបានសង់រោងមួយសម្រាប់ស្នាក់នៅបណ្ដោះអាសន្ន រួចធ្វើថ្នាលសំណាបមួយនៅឆ្ងាយដាច់ពីចុងភូមិ ដោយដាក់វេនគ្នាយាមកុំឲ្យសត្វចូលបំផ្លាញ ។ រស់នៅក្រោមរបបនេះ ខ្ញុំត្រូវស្លៀកពាក់ខោអាវចាស់ៗ បេះដក់បារីឲ្យដូចជាកូនអ្នកស្រែ ពេលកងឈ្លបសួរថាចេះកត់ត្រាអក្សរឬគិតលេខ ខ្ញុំត្រូវប្រាប់ថាសរសេរមិនល្អ មិនត្រូវពាក្យ ហើយយឺតណាស់ការគិតលេខក៏ច្រើនច្រឡំ ។ បន្ទាប់ពីធ្វើស្រែរួច ប្រធានភូមិបានជ្រើសរើសខ្ញុំនិងអ្នកភូមិប្រមាណ៤០នាក់ទៀតឲ្យទៅកាប់ខសជូនអង្គការដែលក្នុងនោះមានបងប្អូនជនជាតិចាមជាង១០នាក់ ។ រយៈពេលជាងមួយខែកន្លះដែលធ្វើការនេះ ក្រុមរបស់យើងតែងតែទៅទៅងូតទឹកនៅក្នុងទន្លេ ។ ប៉ុន្តែមានថ្ងៃមួយ ស្រាប់តែមានកសិករម្នាក់បានមកលួចខ្សឹបប្រាប់ខ្ញុំថា កុំឲ្យទៅត្រើយម្ខាងទៀតឲ្យសោះ ព្រោះបីថ្ងៃមុននេះ ពេលគាត់យកគោទៅឃ្វាលក្បែរមន្ទីរសន្តិសុខ ស្រាប់តែឃើញខ្មោចស្លាប់គរលើគ្នាជាច្រើនក្នុងរណ្ដៅក្បែរអាងទំនប់ទឹក ។ ក្រោយពីខ្មែរក្រហមដឹង ពួកគេបានហាមដាច់ខាតមិនឲ្យទៅទៅទីនោះទៀត ។ ឮដូច្នេះ ខ្ញុំក៏ឈប់ទៅងូតទឹកនៅត្រើយម្ខាងនោះទៀត ។

នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៥ អង្គការបានកោះហៅ

ប្រជាជនទាំងអស់ឲ្យចូលរួមប្រជុំធំមួយដែលលើកឡើងអំពីអង្គការបដិវត្តន៍យើងមានមាគ៌ាដឹកនាំភ្លឺស្វាង និងឈ្លាសវៃ ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនសម្រេចលើជោគវាសនាខ្លួនដោយខ្លួនឯង ។ នៅចុងបញ្ចប់ក៏ឲ្យតំណាងប្រជាជនម្នាក់ឡើងចាប់អារម្មណ៍ ។

## ការដ្ឋានលើកទំនប់និងជីកប្រឡាយ

នៅព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៥ ខ្ញុំបានចេញដំណើរឆ្ពោះទៅការដ្ឋានជាមួយក្រុមរបស់ខ្ញុំមានគ្នាប្រហែល១០នាក់ ។ ដោយសារនេះជាលើកដំបូង ខ្ញុំបានរៀបចំអីវ៉ាន់ជាច្រើនដូចជាអង្ករ១០គីឡូក្រាម ចាន ឆ្នាំង ខោ អាវ ភួយ មុង កន្ទេល ពីដុងទឹក ចប និងបង្គីជាដើម ។ តាមផ្លូវ ខ្ញុំសង្កេតឃើញថា ប្រជាជនចេញដំណើរបន្តគ្នាជាហូរហែមានលក្ខណៈដូចជាក្បួន ចំណែកក្នុងភូមិមានសភាពស្ងប់ស្ងាត់ នៅសល់តែកងឈ្លបដែលនៅប្រចាំការតាមមូលដ្ឋានប៉ុណ្ណោះ ។ តាមរយៈការគ្រប់គ្រងពីថ្នាក់លើរហូតដល់ក្រោម មេក្រុមដែលគ្រប់គ្រងមនុស្សពី១០ទៅ១៥នាក់ បានដឹងតាំងពីប្រវត្តិរូប សតិអារម្មណ៍ អាកប្បកិរិយា និងទឹកមុខរបស់ប្រជាជនគ្រប់រូប ប្រសិនបើមិនពេញចិត្តនឹងនរណាម្នាក់ គេគំរាមថានឹងយកទៅរៀនសូត្រ ។ លើសពីនេះទៅទៀត គ្រួសារឬបងប្អូនរបស់អ្នកទាំងនោះក៏មានប្រវត្តិរូបអាក្រក់បន្តគ្នាថែមទៀតដែរ ។ ដូច្នេះ គ្មានប្រជាជនណាម្នាក់ហ៊ានតវ៉ាឬប្រឆាំងនឹងផែនការរបស់អង្គការបានឡើយ ។ អង្គការប្រើមនោគមន៍វិជ្ជាកុម្មុយនីស្តលើកតម្កើងវណ្ណៈកសិករ ដើម្បីឲ្យក្លាយទៅជាឧបករណ៍ផ្តាច់ការ ហ៊ានពលីជីវិតជូនអង្គការ ។ ប្រសិនបើអង្គការចាត់ទុកនរណាថាជាខ្មាំងគឺគ្មានការយោគយល់ឡើយ សូម្បីញាតិសន្តានខ្លួនឯង ។

ធ្វើដំណើរបានចម្ងាយប្រហែល៣០គីឡូម៉ែត្រ ខ្ញុំក៏បានមកដល់ភូមិស្វាយទាប ដែលឆ្លងពីភូមិនេះឃើញមានវាលស្រែធំល្វឹងល្វើយលាតសន្ធឹងរហូតទៅដល់ផ្លូវជាតិកំពង់ចាម ព្រៃវែង ។ ក្រោយពីសម្រាកបានបន្តិច ខ្ញុំក៏នាំគ្នាបន្តដំណើរឆ្ពោះទៅការដ្ឋានរហូតដល់ម៉ោង៨យប់ទើបទៅដល់គោលដៅ ។ ពេលនោះ ប្រធានក្រុមបានចេញមកទទួលយើងទាំងអស់គ្នា ហើយឲ្យយើងទៅហូបបាយនៅឯរោងបាយដែលមានសល់សម្លនៅបាតខ្ទះ ។ បន្ទាប់មកអង្គការតម្រូវឲ្យយើងយកអង្ករនិងស្បៀងអាហារទាំងអស់ទៅដាក់ក្នុងរោងបាយ រួចនាំគ្នាទៅសម្រាកក្នុងរោងរួមគ្នាមួយដែលសង់ផ្ទាល់ដីប្រក់ដំបូលស្លឹកភក់ ។

ព្រឹកឡើងម៉ោង៤ភ្លឺ ចូលដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៧៦ សំឡេងកញ្ចែរបស់មេកងផ្លុំឡើងលាន់ទ្រហឹង មេក្រុមវាយជ៉ោតនិងគុងដើម្បីដាស់ប្រជាជនទាំងអស់គ្នាឲ្យក្រោកទៅធ្វើការ ។ ទោះជាខ្ញុំមានជំងឺមិនអាចទៅធ្វើការកើតយ៉ាងណាក៏ដោយ ក៏ខ្ញុំព្យាយាមលីចបដើរក្រោមទឹកសន្សើមនិងខ្យល់ធ្លាក់នាខែកត្តិកដែរ ។ ដើរចម្ងាយប្រហែល២០០ម៉ែត្រ ទើបយើងទៅដល់គោលដៅ ប្រធានក្រុមបានហៅឈ្មោះឲ្យចុះវត្តមាន រួចបញ្ជាឲ្យក្រុមនីមួយៗដែលមានគ្នា១៥នាក់ជីកប្រឡាយមានរាងជាការេ ប្រវែង៣ម៉ែត្រ និងជម្រៅ១,៥ម៉ែត្រ ឲ្យហើយក្នុងរយៈពេល១៥ថ្ងៃ ក្រោមការគ្រប់គ្រងរបស់មេក្រុមមានរាងចំណាស់ម្នាក់ និងធ្វើការមិនសូវហ្មត់ចត់ទេ ។ ខ្ញុំកាប់ដីបណ្តើរ លួចសម្លឹងមើលទៅហ្វូងមនុស្សជាច្រើនស្លៀកពាក់ខោអាវខ្មៅពាក់មួកស្លឹកត្នោតនាំគ្នាឱនងើបៗលើកចបកាប់ដីចុះឡើងក្នុងជួរប្រឡាយមួយយ៉ាងវែងបណ្តើរ ។ ចំណែកស្រីៗឈរជាជួរបណ្តាក់គ្នាហុចបង្គី ដែលមានអាចម៍ដីពេញៗបន្តគ្នាទៅចាក់ពូនជាទំនប់ ។ យើងទាំងអស់គ្នាមើលទៅដូចជាសកម្មខ្លាំងណាស់ ប៉ុន្តែក្នុងចិត្តសុទ្ធតែខំធ្វើដោយបង្ខំ និងភ័យខ្លាចបំផុត ។

បន្ទាប់ពីសម្រាកបានបន្តិច យើងបន្តកាប់ដីរហូតដល់ម៉ោង១១ថ្ងៃត្រង់ ទើបមេកងផ្លុំកញ្ចែឲ្យសម្រាក ។ ទៅដល់រោងស្នាក់នៅ រោងបាយក៏គោះជួងឲ្យប្រជាជនទាំងអស់ទៅយកបាយនិងសម្លមកហូប ។ សម្លម្ជូរត្រីប្រឡាក់ជាមួយផ្លែចេក ដើមចេក ឬព្រលិតពិតជាពិបាកហូបណាស់ព្រោះវាមានក្លិនឆ្អាប ។ ប៉ុន្តែយើងទាំងអស់គ្នាត្រូវតែទ្រាំ ព្រោះគ្មានជម្រើស សូម្បីតែបងប្អូនចាមក៏នាំហូបសម្លសាច់ជ្រូកទាំងអស់គ្នាដែរ ។ អង្គការតែងតែលើកឡើងថា ប្រជាជនកម្ពុជាមានសិទ្ធិជឿសាសនា ប៉ុន្តែកុំឲ្យតែសាសនានោះប្រតិកិរិយា ។ បន្ទាប់ពីហូបបាយរួច យើងនាំគ្នាទៅសម្រាកក្រោមរោងរួមមួយដ៏វែង ។ លុះដល់ម៉ោង១រសៀលអង្គការក៏ផ្លុំកញ្ចែឲ្យទៅធ្វើការបន្តទៀត ។ យើងកាប់ដីរហូតដល់ម៉ោង៣រសៀលទើបសម្រាក១០នាទី រួចបន្តធ្វើរហូតដល់ម៉ោង៥ល្ងាច ទើបផ្លុំកញ្ចែឲ្យត្រឡប់ទៅរោងវិញ ។ មកដល់ភ្លាម ម្នាក់ៗទាញចាននិងស្លាបព្រាតម្រង់រោងបាយ រួចនាំគ្នាយកបាយមួយ

ឆ្នាំង សម្រាប់មួយឆ្នាំងសម្រាប់មនុស្ស១០ក្នុងមួយក្រុម ។ ហូបបាយល្ងាចរួច យើងអាចអង្គុយនិយាយគ្នាលេង រួចនាំគ្នាទៅងូតទឹកក្នុងប្រឡាយចាស់មួយ ។

## សម្រុកធ្វើការនិងប្រជុំជីវភាព

នៅការដ្ឋាន មេកងតែងតែផ្លុំកញ្ចែតាំងពីម៉ោង៤ព្រឹក ដើម្បីដាស់ប្រជាជនឲ្យក្រោករៀបចំខ្លួនទៅធ្វើការ ។ យើងនាំគ្នាលីចបដើរទៅការដ្ឋានកាប់ដីរហូតដល់ម៉ោង៦ភ្លឺ ទើបឮសំឡេងផ្សាយបន្តផ្ទាល់ពីវិទ្យុភ្នំពេញអំពីចម្រៀងជាតិនិងព័ត៌មានដែលនិយាយលើកសរសើរពីអង្គការមហាភ្លឺស្វាង មហាឈ្លាសវៃ មហាលោតផ្លោះ មហាអស្ចារ្យ ជ័យជម្នះ១៧មេសា និងសកម្មភាពលើកទំនប់ជីកប្រឡាយយ៉ាងសស្រាក់សស្រាំរបស់ប្រជាជន ។ ប្រជាជនគ្រប់គ្នារួមទាំងខ្ញុំផងដែរខិតខំធ្វើការទៅតាមការកំណត់របស់អង្គការ បើមិនអីចឹងទេនឹងត្រូវមានទោសភ្លាម ។ ក្រៅពីការងារនេះ យើងទាំងអស់គ្នាត្រូវចូលរួមប្រជុំជីវភាពនៅរៀងរាល់ពីរថ្ងៃម្តងនៅវេលាយប់ ដោយកិច្ចប្រជុំនោះប្រធានក្រុមតែងតែលើកសរសើរពីអង្គការ រួចលើកពីគុណសម្បត្តិនិងគុណវិបត្តិមិនឲ្យនរណាម្នាក់ទម្រន់ការងារធ្វើពុតជាឈឺឡើយ ។ លើសពីនេះទៅទៀត អង្គការតែងតែលើកពីការច្បាំងឈ្នះអាមេរិកដោយមិនបាច់រៀនពីសាលានិងកង់ប្រវត្តិសាស្ត្រកំពុងវិលទៅមុខអ្នកណាចង់ប្រឆាំងរាំងខ្ទប់អ្នកនោះពិតជាត្រូវកង់ប្រវត្តិសាស្ត្រកិនកម្ទេចជាមិនខាន ហើយចុងបញ្ចប់ អនុប្រធានក្រុម និងយុវនារីមូលដ្ឋានម្នាក់ពីរនាក់ឡើងប្តេជ្ញាចិត្តសម្រេចផែនការដែលអង្គការដាក់ចុះ ។

អស់រយៈពេល១៦ថ្ងៃក្រោមការបង្ខិតបង្ខំ យើងទាំងអស់គ្នាក៏សម្រេចផែនការដែលអង្គការដាក់ឲ្យ តែក្រុមរបស់ខ្ញុំនៅក្រោយគេបង្អស់ព្រោះសម្បុរស្រីៗច្រើន ។ ក្រោយពីសម្រេចជោគជ័យ មេកងបានអនុញ្ញាតឲ្យយើងឈប់សម្រាករយៈពេល១០ថ្ងៃ ដើម្បីធ្វើដំណើរត្រឡប់មកផ្ទះវិញ ។ មុនពេលចាកចេញអង្គការបានចែកបាយម្នាក់១កញ្ចប់ ដើម្បីហូបមុនធ្វើដំណើរត្រឡប់ទៅផ្ទះ ។ ខ្ញុំនិងប្រជាជនផ្សេងទៀតនាំគ្នាចេញដំណើរត្រឡប់ទៅផ្ទះយ៉ាងរួសរាន់ ។

## លើកប្រព័ន្ធភ្លឺស្រែក្រឡាឈើត្រង់

នៅថ្ងៃបន្ទាប់ ខ្ញុំបានធ្វើដំណើរទៅសួរសុខទុក្ខម្តាយ និងប្អូនៗជាមួយឪពុករបស់ខ្ញុំទៅភូមិចាស់ ។ ទៅដល់ផ្ទះ ខ្ញុំត្រេកអរណាស់ ប៉ុន្តែនៅក្នុងភូមិមានសភាពស្ងប់ស្ងាត់ណាស់ ពីព្រោះនៅសល់តែផ្ទះរបស់យើងមួយគត់ ។ ថ្ងៃបន្ទាប់ ខ្ញុំក៏ឃើញអង្គការជម្លៀសប្រជាជន១៧មេសា ដែលរស់នៅក្នុងភូមិឃុំនានាឲ្យទៅរស់នៅឯខេត្តបាត់ដំបងវិញ ដែលក្នុងនោះក៏មានមីងខ្ញុំពីរនាក់ព្រមទាំងប្តី និងកូនៗ ហើយនិងសាច់ញាតិខាងជីតាបីគ្រួសារទៀត ។ ខ្ញុំបានជូនដំណើរមីងរបស់ខ្ញុំរហូតដល់ចុងភូមិ ទើបខ្ញុំត្រឡប់មកផ្ទះវិញ ដោយគិតក្នុងចិត្តថាពួកគាត់ពិតជាទៅបានសុខសប្បាយ ។ ថ្ងៃបន្ទាប់មកទៀត ឆ្លៀតពេលទំនេរខ្ញុំក៏បានរុះរើផ្ទះបានមួយចំណែកដឹកជញ្ជូនតាមទូកយកទៅភូមិនៅឯស្រែវិញដើម្បីបញ្ជាក់ឲ្យអង្គការដឹងថាគ្រួសារខ្ញុំនៅឯស្រែមែន ។

ព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៦ ខ្ញុំបានចេញដំណើរទាំងឈឺ ដោយសារខ្ញុំបានភ្នាល់ដក់បារីជាមួយពូម្នាក់កាលពីម្សិលមិញ ។ ដូច្នេះ ខ្ញុំស្ពាយតែខោអាវ ភួយ មុង ចាន ស្លាបព្រាប៉ុណ្ណោះ ចំណែកចបកាប់ បង្គី អង្ករ អង្គការបានដឹកជញ្ជូនតាមរទេះត្រៀមទុកនៅឯការដ្ឋានរួចហើយ ។ លើកនេះការដ្ឋានរបស់ខ្ញុំត្រូវបានផ្លាស់ទីតាំងថ្មីនៅជិតផ្លូវជាតិក្បែរភូមិមួយដែលមានអណ្តូងទឹកដីថ្លាសម្រាប់ដឹកនិងងូត ។ ពេលទៅដល់ ប្រធានក្រុមបានបញ្ជាឲ្យយើងទាំងអស់គ្នាយកចបកាប់ម្នាក់មួយនៅឯឃ្លាំង ដែលចបនេះមានទំហំធំជាងមុន ផលិតមកពីប្រទេសចិន ដើម្បីកាប់ដីឲ្យបានច្រើនជាងមុន ។ នៅខែកុម្ភៈ មេកងបានបញ្ជាឲ្យយើងទៅលើកប្រព័ន្ធភ្លឺស្រែនិងភ្លឺក្លោះ ដែលមានទទឹងមួយម៉ែត្រ កម្ពស់កន្លះម៉ែត្រ និងមានប្រវែង១០០ម៉ែត្រចម្ងាយពីភ្លឺស្រែមួយទៅភ្លឺស្រែមួយ ។ ក្រោយធ្វើការរួច ក្នុងមួយសប្តាហ៍យើងធ្វើការប្រជុំជីវភាពម្តង ដើម្បីបំពាក់ជំហរគោលនយោបាយឲ្យគោរពវិន័យអង្គការ ។ នៅរយៈពេលនោះ មីទ្ទិងបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រក៏បានប្រព្រឹត្តឡើង ដោយកងចល័តទូទាំងស្រុកបានធ្វើដំណើរពីគ្រប់កន្លែងទាំងអស់ដើម្បីចូលរួមប្រជុំ ។ មនុស្សច្រើនរាប់ពាន់នាក់ចាំស្តាប់ការថ្លែងសុន្ទរកថា និងចំណាប់អារម្មណ៍បន្តគ្នាពេញមួយព្រឹក រួចប្រកាសឈ្មោះដែលមាននៅក្នុងបញ្ជីបេក្ខជនតំណាងរាស្ត្រ ។ ក្រោយពីប្រកាសលទ្ធផលរួច យើងក៏ត្រឡប់មកផ្ទះរៀងខ្លួនៗ ។ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់

ប្រជាជនទាំងអស់គ្នា ប្រព័ន្ធភ្លើស្រែក៏បានលេចចេញជារូបរាង ។

ព្រឹកថ្ងៃមួយ ខ្ញុំក៏សុំប្រធានក្រុមត្រឡប់ទៅផ្ទះមុន ដោយសារតែខ្ញុំឈឺក្តៅខ្លួនអស់រយៈពេលជាច្រើនថ្ងៃមកហើយ ។ ប៉ុន្តែទោះបីជាខ្ញុំឈឺបែបនេះក៏ដោយ ក៏ខ្ញុំមិនត្រូវបានគេផ្តល់ថ្នាំសម្រាប់ព្យាបាលដែរ គឺមានតែយកលុយសេនមកកោសខ្យល់ប៉ុណ្ណោះ ។ ដូច្នេះជំងឺរបស់ខ្ញុំមានលក្ខណៈកាន់តែធ្ងន់ធ្ងរទៅ រហូតដល់អង្គការបានយករទេះសេះដឹកខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យឃុំ ដែលមានចម្ងាយប្រហែល៧គីឡូម៉ែត្រ ។ ពេលទៅដល់ពេទ្យ អង្គការបានសួរពីប្រវត្តិរូបនិងជំងឺរបស់ខ្ញុំ រួចឲ្យថ្នាំចិនខ្ញុំលេបដើម្បីឲ្យបានត្រជាក់ខ្លួន ។ ប៉ុន្តែ ខ្ញុំនៅឈឺក្បាលនិងអស់កម្លាំងដដែល ។ បីថ្ងៃក្រោយមក ស្រាប់តែមានរទេះសេះមកដឹកខ្ញុំត្រឡប់ទៅព្យាបាលនៅមន្ទីរពេទ្យថ្មីមួយទៀតស្ថិតនៅក្នុងវត្តមួយដែលជាពេទ្យកងចល័តថ្នាក់តំបន់សម្បូរទៅដោយថ្នាំអាចម៍ទន្សាយនិងថ្នាំចាក់ផលិតដាក់ក្នុងដបទឹកក្រូច ដែលស្ថិតនៅជិតការដ្ឋានថ្មីប្រហែលជាង១០គីឡូម៉ែត្រ ។ នៅទីនេះ គ្រូពេទ្យនៅតែឲ្យខ្ញុំលេបថ្នាំ៣ថ្ងៃបន្តទៀត ។ រយៈពេលប្រហែល១០ថ្ងៃក្រោយមក បុណ្យរំពុកខួបជ័យជម្នះកងទ័ពបដិវត្តន៍ក៏បានប្រារព្ធឡើង ដោយមានធ្វើម្ហូបឆ្ងាញ់ៗនិងកាប់ជ្រូកឲ្យប្រជាជនបានហូបទៀតផង ។ ក្រោយពីពិធីបុណ្យបានបញ្ចប់ អង្គការបានមកប្រាប់ខ្ញុំថា បីថ្ងៃទៀតខ្ញុំត្រូវតែចេញពីពេទ្យមកធ្វើការដូចជាប្រជាជនធម្មតា ។ ខ្ញុំព្រួយចិត្តយ៉ាងខ្លាំងព្រោះខ្លាចធ្វើការមិនកើតនាំឲ្យអង្គការចោទប្រកាន់ ។ នៅពេលនោះ គួរឲ្យភ្ញាក់ផ្អើលជាខ្លាំង ដោយឃើញមានវត្តមានរបស់ឪពុកខ្ញុំមកសួរសុខទុក្ខខ្ញុំ និងប្រាប់ខ្ញុំថាគាត់មកនេះគឺដើម្បីយកខ្ញុំទៅរស់នៅជាមួយជីតារបស់ខ្ញុំវិញ ពីព្រោះគ្រួសារទាំងមូលត្រូវបានអនុញ្ញាតឲ្យប្តូរទីលំនៅជាថ្នូរសម្រាប់យកទៅធ្វើរោងបាយរួម ។ បន្ទាប់មក ខ្ញុំបានយកលិខិតប្តូរទីលំនៅដែលមានឈ្មោះខ្ញុំទៅជួបប្រធានកងនៅឯការដ្ឋាន ។

## មន្ទីរពេទ្យបដិវត្តន៍

សម្រាកនៅផ្ទះរយៈមួយសប្តាហ៍ ខ្ញុំកាន់តែព្រួយបារម្ភដោយសារនៅសង្គមបដិវត្តន៍មនុស្សម្នាក់ៗធ្វើការសម្រាប់តែខ្លួនឯងម្នាក់ប៉ុណ្ណោះ គ្មានថ្ងៃឈប់សម្រាក ប៉ុន្តែទទួលបានរបបអាហារត្រឹមតែបបរប៉ុណ្ណោះ ហើយប្រសិនបើនរណាម្នាក់អវត្តមាន អង្គការនឹងវាយតម្លៃថាជាមនុស្សអសកម្មមិនស្មោះត្រង់ចំពោះបដិវត្តន៍ មិនយូរប៉ុន្មានអង្គការចោទថាជាខ្មាំងទៀត ។ ក្រោយមក ដោយសារតែជីតាខ្ញុំស្គាល់ប្រធានមន្ទីរពេទ្យយោធា គាត់ក៏សុំអនុញ្ញាតឲ្យខ្ញុំចូលសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យឃុំដែលអ្នកភូមិខ្លះមិនសូវមានការចាប់អារម្មណ៍ទេ ព្រោះច្រកចូលពុំមានដាក់ផ្លាកសញ្ញាសម្គាល់ជាមន្ទីរពេទ្យ ។ នៅចំកណ្តាលទីធ្លាមន្ទីរពេទ្យ មានការិយាល័យធំមួយសង់ពីឈើប្រក់ក្បឿងនិងបន្ទប់មានទំហំប៉ុនៗគ្នាប្រក់ស្លឹកត្នោតសង់តម្រៀបគ្នាជាជួរ និងបន្ទប់មួយទៀតដែលមានក្រណាត់កៅស៊ូខាងក្នុងជាបន្ទប់វះកាត់ ចំណែកនៅផ្នែកខាងក្រោយមានឃ្លាំងដាក់សម្ភារៈ និងរោងបាយរួម ។ គ្រូពេទ្យនិងបុគ្គលិកមានវ័យក្មេងអាយុប្រមាណ១៨ទៅ២០ឆ្នាំពាក់អាវពេទ្យមានភាពរហ័សរហួន ពេលពិនិត្យព្យាបាលមានឱសថបុរាណនិងសម័យយ៉ាងសម្បូរ ប្រើសេរ៉ូមកំប្លោកដែលសល់ពីរបប លន់ នល់ ។ អ្នកជំងឺភាគច្រើនជាយោធា មានបន្ទប់ពីរសម្រាប់ប្រជាជនចូលសម្រាក ប៉ុន្តែបើប្រជាជនសាមញ្ញកម្របានស្គាល់មន្ទីរពេទ្យនេះណាស់ ព្រោះជាកន្លែងលាក់ការណ៍របស់បដិវត្តន៍ ។ នៅទីនោះ ពេទ្យបានព្យាបាលខ្ញុំដោយចាក់និងលេបថ្នាំជាច្រើនប្រភេទ ។ ប៉ុន្តែរយៈពេល២សប្តាហ៍ក្រោយមក ខ្លួនរបស់ខ្ញុំនៅតែស្គមនិងឈឺក្បាលមួយចំហៀងមិនបាត់សោះ រហូតដល់អង្គការសម្រេចបញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យតំបន់២២ស្ថិតនៅក្នុងវត្តមហាលាភ តាមរទេះសេះនិងកាណូតទៀត ។ មន្ទីរពេទ្យនេះបែងចែកបន្ទប់រវាងបុរសផ្សេង និងស្ត្រីផ្សេងដែលមានអ្នកជំងឺយ៉ាងច្រើនមកសម្រាកព្យាបាល ក្រោមការត្រួតពិនិត្យរបស់គ្រូពេទ្យប្រចាំការ ។ ចំណែកថ្នាំដែលប្រើប្រាស់សម្រាប់ចាក់មានដូចជា ថ្នាំអាចម៍ទន្សាយនិង ថ្នាំចាក់ដែលផលិតដាក់ក្នុងដបទឹកក្រូចមានពណ៌ក្រហម លឿង ស សម្រាប់ចាក់សាច់ដុំ ។ នៅទីនេះក៏ដូចកន្លែងធ្វើការដែរ អង្គការដាក់មនុស្សសម្រាប់តាមដានសកម្មភាពរបស់អ្នកជំងឺ ដើម្បីការពារកុំឲ្យអ្នកជំងឺខ្លះឈឺទម្រន់សម្រាកយូរថៃនាំឲ្យខាតបាយនិងកម្លាំងពលកម្ម ព្រោះមន្ទីរពេទ្យនេះសម្បូរថ្នាំនិងអាហារហូបច្រើនណាស់ ។

ដោយសារសម្រាកនៅពេទ្យនេះអស់១ខែកន្លះនៅតែនៅមិនជាសះស្បើយ អង្គការក៏បញ្ជូនខ្ញុំនិងអ្នកជំងឺចំនួន១០នាក់ទៀត

ទៅព្យាបាលនៅមន្ទីរពេទ្យភូមិភាគបូព៌ា (មន្ទីរពេទ្យព-២) ដែលស្ថិតនៅក្នុងទីរួមស្រុកអូររាំងឪ តាមរយៈរថយន្តយោធាធុនមធ្យមផលិតនៅប្រទេសចិន ។ អ្នកដែលអាចចូលទៅសម្រាកនៅមន្ទីរពេទ្យនេះបាន លុះត្រាតែមានលិខិតអនុញ្ញាត ។ មន្ទីរពេទ្យនេះមានទំហំធំទូលាយនៅលើដីជាច្រើនហិកតា មានភ្លើងអគ្គិសនីបំភ្លឺតាមផ្លូវ បន្ទប់នីមួយៗមានទំហំប៉ុនគ្នា មានដំបូលនិងជញ្ជាំងធ្វើពីស្លឹកខាមម៉ា មានគ្រែដេកទល់ជើងគ្នា បែងចែកជាច្រើនផ្នែក និងនៅខាងមុខបន្ទប់មានកៅអីឈើវែងមួយសម្រាប់អង្គុយលេង ថែមទាំងមានដីសម្រាប់ដាំបន្លែទៀតផង ។ ចំណែកបន្ទប់អ្នកជំងឺធ្ងន់ធ្ងរមានគ្រូពេទ្យចំណាស់បន្តិចនៅចាំត្រួតពិនិត្យ ក្រៅពីនេះសុទ្ធតែគ្រូពេទ្យវ័យក្មេងអាយុប្រមាណជា២០ឆ្នាំ ។ មន្ទីរពេទ្យនេះមានលក្ខណៈពិសេសពីមន្ទីរពេទ្យផ្សេងទៀត ព្រោះសម្បូរទៅដោយឱសថបុរាណនិងថ្នាំចាក់ ។ ប៉ុន្តែការហូបចុកវិញមិនបានគ្រប់គ្រាន់ទេ ហើយថែមទាំងគ្មានអនាម័យទៀតផង ។

***(នៅមានត)***

**ហេង ខុន**

---

# ដំណឹងស្វែងរកបងប្រុស មិល សុណ្ណ ហៅ ណុប

នាងខ្ញុំឈ្មោះ មិល ចាន់ថា អាយុ៥៥ឆ្នាំ សព្វថ្ងៃរស់នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ នាងខ្ញុំសូមសួររកបងប្រុសឈ្មោះ មិល សុវណ្ណ ហៅ ណុប ជាអតីតសិស្សមកពីសហភាពសូវៀត ។ សុវណ្ណ គឺជាកូនទី៤នៅក្នុងគ្រួសារដែលមានបងប្អូន៦នាក់ ។ សុវណ្ណ បានទៅរៀននៅវិទ្យាល័យនៅភ្នំពេញ ហើយជាសិស្សឆ្លាត ជាពិសេសខាងមុខវិជ្ជាគណិតវិទ្យា ។ នៅក្នុងឆ្នាំ១៩៦៧ សុវណ្ណ បានចាប់ផ្តើមរៀនថ្នាក់បរិញ្ញាបត្រ ហើយមួយឆ្នាំក្រោយមក ក៏ទទួលបានអាហារូបករណ៍ទៅសិក្សានៅសហភាពសូវៀត ។ នៅអំឡុងពេលដែលសុវណ្ណ សិក្សាឆ្នាំទី១ គាត់បានសរសេរសំបុត្រមកលេងផ្ទះម្តង ក្រោយមកទៀតខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ទៀតទេ ។

ដូច្នេះ បើបងប្អូនណាបានដឹងដំណឹងពីឈ្មោះខាងលើនេះ សូមមេត្តាជួយផ្តល់ព័ត៌មានមកនាងខ្ញុំតាមអាសយដ្ឋានដូចបានរៀបរាប់ខាងលើ ឬតាមមជ្ឈមណ្ឌលឯកសារកម្ពុជា ។

# ដំណឹងស្វែងរកឪពុកម្តាយនិងប្អូនប្រុស

នាងខ្ញុំឈ្មោះ ស៊ិន ស៊ីណែត ហៅស្រ៊ិន រស់នៅភូមិរស្មីរំដោះ ឃុំសូយោង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ម្តាយរបស់ខ្ញុំឈ្មោះ ស៊ិន សុផុន ឪពុកឈ្មោះ នី និង ប្អូនប្រុសឈ្មោះ លីន ។ នៅពេលដែលកងទ័ពខ្មែរក្រហមបានចូលមកកាន់កាប់ភូមិនេះ ខ្ញុំបានចាកចេញពីផ្ទះទៅរស់ជាមួយជីតារបស់ខ្ញុំឈ្មោះ ភាច គឹម ហៅ ស៊ិន និងយាយឈ្មោះ ណុប សេង នៅខេត្តកំពង់សោម ។ ក្រោយពីកងទ័ពខ្មែរក្រហមបានចូលមករំដោះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៩ ខ្ញុំក៏បានបែកគាត់រហូត ។

ដូច្នេះ បើបងប្អូនណាបានដឹងដំណឹងពីឈ្មោះខាងលើនេះ សូមមេត្តាជួយផ្តល់ព័ត៌មានមកនាងខ្ញុំតាមអាសយដ្ឋានដូចបានរៀបរាប់ខាងលើ ឬតាមរយៈទូរស័ព្ទលេខ ០៩២ ៩៩ ៥៦ ៥៩ ។

# សេចក្តីប្រកាសរកបងប្រុសឈ្មោះ មាស ពន្លក

នាងខ្ញុំឈ្មោះ ស្វាយ វ៉ាន់ថង រស់នៅស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ស្វាយ សារិន (ស្លាប់) ធ្វើពេទ្យ ម្តាយឈ្មោះ ឌី យ៉ាត (ស្លាប់) ស្រុកកំណើតនៅក្នុងភូមិកំពង់សំណាញ់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សូមសួររកបងប្រុសឈ្មោះ មាស ពន្លក ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៥ ។ មុនពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ពន្លក ធ្វើជាទាហានលន់ នល់ ឈរជើងនៅក្នុងខេត្តពោធិ៍សាត់ ។ ប្រសិនបើបងបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនបានស្គាល់ឈ្មោះខាងលើនេះ សូមទាក់ទងមកខ្ញុំតាមរយៈទូរស័ព្ទលេខ ០៩២ ៦៩៩ ០៣៨ ។



លោក ឆាំង យុ ដឹកនាំសាស្ត្រាចារ្យ និងគ្រូបង្គោលថ្នាក់ជាតិចូលជួបសម្តែងការគួរសមជាមួយ ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា



ការថតរូបអនុស្សាវរីយ៍រវាងគ្រូបង្គោលថ្នាក់ជាតិ និង ឯកឧត្តម អ៊ឹម សិទ្ធី (កម្មវិធីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ)

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 114, June 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.